**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Économiques

Royal University of law and Economic

# សារណាបញ្ចប់ការសិក្សា

# គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ

ស្រាវជ្រាវថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


រៀបរៀងដោយ

និស្សិតឈ្មោះ **ថុល រស្មី**

**ល័ក្ខ មករា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **រុន ពណ្ណារិទ្ធ**


ឆ្នាំចូលរៀន ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរនាក់ឈ្មោះ **ថុល រស្មី** និងឈ្មោះ **លក័ខ្ម មករា** ជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី ២២ ឆ្នាំសិក្សា ២០១៨-២០២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ**

**លោកឪពុក អ្នកម្តាយ** ជាទីគោរពរបស់កូនដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាផ្តល់ការអប់រំគ្រប់បែបយ៉ាង ព្រមទាំងផ្គត់ផ្គង់ឱ្យកូនបានសិក្សាចាប់ពីបឋមសិក្សារហូតមកដល់ថ្នាក់ឧត្តមសិក្សានេះ។ នៅក្នុងភារៈជាអ្នកចិញ្ចឹមបីបាច់ថែរក្សាកូន លោកទាំងពីរបានលះបង់គ្រប់បែបយ៉ាងទាំងកម្លាំងកាយចិត្ត មិនខ្លាចនឿយហត់ដើម្បីរកប្រាក់ចិញ្ចឹមបីបាច់ថែរក្សា ព្រមទាំងអប់រំទូន្មានឱ្យកូនខិតខំប្រឹងប្រែងសិក្សាដើម្បីក្លាយខ្លួនជាកូនល្អ សិស្សល្អ និងពលរដ្ឋល្អនៅក្នុងសង្គម។ កូនមានថ្ងៃនេះក៏ដោយសារពាក្យទូន្មានរបស់លោកទាំងពីរ ហើយកូននឹងមិនអាចបំភ្លេចបានឡើយចំពោះគុណុបការៈ ដែលពុំអាចកាត់ថ្លៃបាននេះ។

**ឯកឧត្តមបណ្ឌិត លុយ ចន្ណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច រួមទាំងគណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យ ដែលបានដឹកនាំ សម្របសម្រួល ចាត់ចែងការសិក្សា និងបានបង្ហាត់បង្រៀន ណែនាំដល់យើងខ្ញុំ ជានិស្សិតជំនាន់ថ្មី ឱ្យទទួលបាននូវចំណេះជំនាញ បទពិសោធន៍ក្នុងជីវិត ដើម្បីជាទុន ក្នុងការចូលរួមចំណែកអភិវឌ្ឍជាតិមាតុភូមិ។

លោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** ព្រឹទ្ធបុរស នៃមហាវិទ្យាល័យនីតិសាស្ត្រ និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំសារណាមួយនេះអស់ពីកម្លាំងកាយចិត្ត ដោយលោកគ្រូ អ្នកគ្រូបង្ហាត់បង្រៀន ផ្តល់ដំបូន្មាន បទពិសោធន៍ថ្មីៗ ហើយថែមទាំងណែនាំឱ្យសិស្សបានធ្វើការងារ ដែលមានតម្លៃនេះ ទទួលបានជោគជ័យចេញជាផ្លែផ្កាផងដែរ។

ជាទីបញ្ចប់ យើងខ្ញុំសូមគោរពអរគុណយ៉ាងក្រៃលែងជូនចំពោះរាជរដ្ឋាភិបាលកម្ពុជា មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងកងកម្លាំងយោធា ដែលបានលះបង់កម្លាំងកាយចិត្តក្នុង ការរក្សាការពារសន្តិភាព ហើយរួមគ្នាអភិវឌ្ឍប្រទេសដ៏ផូរផង់របស់យើង។

យើងខ្ញុំសូមប្រគេនពរ និងជូនពរដល់អ្នកមានគុណទាំងអស់ សូមប្រសិទ្ធពរជ័យសិរីមង្គល វិបុលសុខគ្រប់ប្រការចូលកើតមានដល់លោក លោកស្រីទាំងអស់ឱ្យជួបប្រទះនូវ ពុទ្ធពរទាំងឡាយបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បាតុភូតអសកម្មក្នុងសង្គមនីមួយៗតែងតែកើតមានឡើងនៅលើសកលលោកនេះ តាំងពីសម័យអតីតកាលមកម្លេះ។ ដើម្បីជាការឆ្លើយតបទៅនឹងបាតុភូតអវិជ្ជមាន ជាបទល្មើស ដែលកើតចេញពីអំពើរបស់មនុស្សនៅក្នុងសង្គម ដោយគ្រប់សម័យកាលរមែងបង្កើតយន្តការទប់ស្កាត់ បង្ក្រាប និងផ្តន្ទាទោសឱ្យបានសមស្របទៅតាមបរិបទនៃសង្គមនីមួយៗ។ ព្រមជាមួយគ្នានៃការវិវដ្តនៃសង្គម ជនល្មើសក៏បានធ្វើការអភិវឌ្ឍខ្លួន ដើម្បីរួចផុតពីការផ្តន្ទាទោស ឬស្វែងរកយុត្តិសាស្ត្រ សកម្មភាពថ្មីៗ ក្នុងការប្រព្រឹត្តបទល្មើស។ ទន្ទឹមជាមួយគ្នានេះ មិនថាជនល្មើសសាមញ្ញ ក៏នៅមានបុគ្គលមួយចំនួនទៀតដូចជា ថ្នាក់ដឹកនាំប្រទេស រួមទាំងបុគ្គលដែលទទួលខុសត្រូវមុខងារសំខាន់ៗ និងជាមុខងារគ្រឹះ ដោយបុគ្គលនោះស្ថិតនៅក្នុងអំណាចឆន្ទានុសិទ្ធិ ដែលខ្លួនមានក្នុងការយកទៅប្រើប្រាស់ជា ឧបករណ៍ដើម្បីជាផលប្រយោជន៍ផ្ទាល់ខ្លួន ឬក្រុមបក្សពួករបស់ខ្លួន ដើម្បីប្រើប្រាស់ជាឧបករណ៍ក្នុងការធ្វើទុកបុកម្នេញភាគីម្ខាងទៀត។ បើយើងក្រឡេកមើល មកព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសនីតិរដ្ឋ ដែលមានច្បាប់ព្រហ្មទណ្ឌ សម្រាប់ធ្វើការអនុវត្ត ដោយមានការកែប្រែ និងវិសោធនកម្ម ជាបន្តបន្ទាប់រហូតមកដល់បច្ចុប្បន្ន។ ការអនុវត្តច្បាប់ព្រហ្មទណ្ឌ គឺត្រូវមានកម្រិតនៅក្នុងដែនរបស់វា ដូច្នេះយើងត្រូវឈ្វេងយល់អំពីដែនអនុវត្តនៃច្បាប់ព្រហ្មទណ្ឌថា មានអានុភាពអនុវត្តទៅតាមទំហំណា កម្រិតណា បែបណាដោយពិចារណាទៅលើពេលវេលា ទីកន្លែង នៃការប្រព្រឹត្តបទល្មើសនោះ។

ក្នុងទស្សនវិស័យនេះ ជាការសម្រេចចិត្តរបស់យើងខ្ញុំបានជ្រើសរើសយកប្រធានបទ ភាពមិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ មកធ្វើការស្រាវជ្រាវ សរសេរ ឬចងក្រង ជាអត្ថបទសារណា ដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតសាស្ត្រនាពេលនេះ។ ជាក់ស្តែង នៅក្នុងព្រះរាជាណាចក្រកម្ពុជា បរិបទក្នុងការដឹកនាំ ក៏ដូចជាស្ថានភាពនយោបាយជាកត្តាចម្បង ដែលមានការចាប់អារម្មណ៍ និងយកចិត្តទុកដាក់ពីសាធារណៈជន ទាំងជនរួមជាតិ និងអន្តរជាតិ។ ការទាញចំណាប់អារម្មណ៍របស់សាធារណៈជន យ៉ាងទូលំទូលាយបែបនេះ គឺដោយសារប្រសិទ្ធភាពនៃច្បាប់ និងភាពមិនចុះសម្រុងគ្នា ក្នុងការអនុវត្តមួយចំនួន ដែលត្រូវកំណត់ដែនអនុវត្តនៃច្បាប់ឱ្យស្របទៅតាមគោលការណ៍គ្រឹះ។

ជាចុងបញ្ចប់ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ សាស្ត្រាចារ្យ ក៏ដូចជាមិត្តនិស្សិតទាំងអស់ ដែលបានអានអត្ថបទសារណានេះ ក្នុងបំណងពង្រីកចំណេះដឹង ចង់យល់ឱ្យកាន់តែច្បាស់អំពី ភាពមិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌនេះ។ យើងខ្ញុំសូមអភ័យទោសរាល់កំហុសខុសឆ្គង នៅចន្លោះខ្វះខាត ចំពោះអក្ខរាវិរុទ្ធ និងពាក្យពេចន៍ ឬប្រយោគណាមិនសមរម្យ ដោយអចេតនាណាមួ នៅក្នុងកម្រងសារណានេះ យើងខ្ញុំរង់ចាំការរិះគន់ក្នុងន័យស្ថាបនា និងកែលំអ ដោយសេចក្តីជ្រះថ្លា ដើម្បីធ្វើឱ្យស្នាដៃនេះកាន់តែមានភាពល្អប្រសើរឡើង ក្នុងន័យពង្រឹងសមត្ថភាព ធនធានមនុស្ស និងមានការអភិវឌ្ឍ ឆ្ពោះទៅរកចំណេះដឹង។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

## ជំពូកទី១

## ច្បាប់ព្រហ្មទណ្ឌ និងការអនុវត្តច្បាប់ព្រហ្មទណ្ឌ

**ផ្នែកទី១ ៖ ច្បាប់ព្រហ្មទណ្ឌ** ........ ៣

១.១. អត្ថន័យនៃច្បាប់ព្រហ្មទណ្ឌ ........ ៣

១.១.១. ច្បាប់ព្រហ្មទណ្ឌក្នុងន័យទូលាយ និងច្បាប់ព្រហ្មទណ្ឌក្នុងន័យចង្អៀត ........ ៤

ក. ច្បាប់ព្រហ្មទណ្ឌក្នុងន័យទូលាយ ........ ៥

ខ. ច្បាប់ព្រហ្មទណ្ឌក្នុងន័យចង្អៀត ........ ៥

១.២. ប្រភពនៃច្បាប់ព្រហ្មទណ្ឌ ........ ៥

១.២.១. ប្រភពអន្តរជាតិ ........ ៥

១.២.២. ប្រភពជាតិ ........ ៦

ក. ច្បាប់ក្នុងន័យចង្អៀត ........ ៦

ខ. បទបញ្ជា ........ ៧

គ. រដ្ឋធម្មនុញ្ញ ........ ៨

១.៣. ប្រភេទនៃច្បាប់ព្រហ្មទណ្ឌ និងបទប្បញ្ញត្តិព្រហ្មទណ្ឌ ........ ១០

១.៣.១. បទប្បញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌខ្មែរថ្មីចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ........ ១១

១.៣.២. ច្បាប់ និងបទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែកផ្សេងទៀត ដែលកំពុងនៅជាធរមាន ........ ១១

១.៣.៣. ច្បាប់ព្រហ្មទណ្ឌដែលមានចរិតពិសេស ........ ១២

**ផ្នែកទី២ ៖ ការអនុវត្តច្បាប់ព្រហ្មទណ្ឌ** ........ ១៣

២.១. ការអនុវត្តច្បាប់ព្រហ្មទណ្ឌ ឬក្រមព្រហ្មទណ្ឌខ្មែរថ្មីឆ្នាំ២០០៩ ........ ១៣

២.២. ការបាត់បង់អានុភាពនៃច្បាប់និងបទប្បញ្ញត្តិព្រហ្មទណ្ឌពីមុន ........ ១៤

## ជំពូកទី២

## គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ

**ផ្នែកទី១ ៖ អត្ថន័យនៃគោលការណ៍មិនប្រតិសកម្ម** ........ ១៧

១.១. សញ្ញាណនៃគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ...... ១៨
១.២. ការអនុវត្តគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ...... ១៩
១.២.១. គោលការណ៍មិនប្រតិសកម្មចំពោះបទល្មើស...... ១៩
ក. បទល្មើសភ្លាមៗ ...... ២០
ខ. បទល្មើសបន្តជាហូរហែ...... ២០
គ. បទល្មើសអូសបន្លាយ...... ២១
ឃ. បទល្មើសកើតចេញពីអំពើប្រព្រឹត្តជាទម្លាប់...... ២១
១.២.២. គោលការណ៍មិនប្រតិសកម្មចំពោះទោស ...... ២២
**ផ្នែកទី២ ៖ ភាពមិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌធ្ងន់ជាង** ...... ២៣
២.១. ផលវិបាកនៃគោលការណ៍នីត្យានុកូល ...... ២៦
២.២. អត្ថន័យគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌធ្ងន់ជាង...... ២៨

## ជំពូកទី៣

## អញ្ញត្រកម្មទៅនឹងគោលការណ៍

## (ភាពមិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ)

**ផ្នែកទី១ ៖ ច្បាប់ដែលលុបចោលបទល្មើស** ...... ៣០
១.១. ការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលលុបចោលបទល្មើស...... ៣០
១.២. ការលើកលែងទោស ...... ៣១
១.២.១. ការលើកលែងទោស ឬបន្ធូរបន្ថយទោសក្រោមវិធានច្បាប់អន្តរជាតិ ...... ៣២
១.២.២. ការលើកលែងទោស ឬបន្ធូរបន្ថយទោសក្រោមវិធានច្បាប់ជាតិ...... ៣៣
**ផ្នែកទី២ ៖ ច្បាប់ព្រហ្មទណ្ឌថ្មីដែលស្រាលជាង** ...... ៣៣
២.១. អានុភាពការអនុវត្តច្បាប់ព្រហ្មទណ្ឌថ្មីស្រាលជាង...... ៣៥
២.២. ការអនុវត្តច្បាប់ព្រហ្មទណ្ឌថ្មីស្រាលជាងដែលបញ្ញត្តិអំពីទោស ...... ៣៧
**ផ្នែកទី៣ ៖ អញ្ញត្រកម្មទៅនឹងគោលការណ៍អប្រតិសកម្មនៃច្បាប់ថ្មី** ...... ៣៨
៣.១. ច្បាប់ថ្មីអាចអនុវត្តលើការបង្កើតស្ថានភាពគតិយុត្ត...... ៣៨
៣.២. ច្បាប់ថ្មីអាចអនុវត្តលើអានុភាពក្នុងអតីតកាលរបស់ស្ថានភាពគតិយុត្ត...... ៣៨
៣.៣. ច្បាប់ថ្មីអាចអនុវត្តលើការបញ្ចប់ស្ថានភាពគតិយុត្ត...... ៣៩

៣.៤. អញ្ញត្រកម្មទៅនឹងច្បាប់នីតិវិធី ........ ៣៩

៣.៥. អញ្ញត្រកម្មទៅនឹងគោលការណ៍នៃការអនុវត្តភ្លាមៗនៃច្បាប់ថ្មី ........ ៣៩

**សេចក្តីសន្និដ្ឋាន** ........ ៤១

**អនុសាសន៍** ........ ៤៤

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

យោងតាម គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលមានចែងនៅត្រង់មាត្រា ២៤ នៃក្រមព្រហ្មទណ្ឌ បុគ្គលម្នាក់ៗ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ។ ដើម្បីឱ្យបុគ្គលម្នាក់ៗ ទទួលខុសត្រូវអំពើដែលខ្លួនបានប្រព្រឹត្ត លុះត្រាអំពើនោះជាបទល្មើសព្រហ្មទណ្ឌ ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ត្រង់មាត្រា ៣ នៃក្រមដដែល។

បទល្មើសព្រហ្មទណ្ឌមានធាតុផ្សំបីយ៉ាងគឺ ធាតុផ្សំនីត្យានុកូល ធាតុផ្សំសត្យានុម័ត ឬធាតុផ្សំសម្ភារៈ និងធាតុផ្សំអត្តនោម័ត ធាតុផ្សំសំខាន់សម្រាប់អនុវត្តច្បាប់ព្រហ្មទណ្ឌនាពេលបច្ចុប្បន្ន ឬនាពេលអនាគត គឺធាតុផ្សំនីត្យានុកូល ដែលយើងខ្ញុំនឹងបកស្រាយឱ្យកាន់តែស៊ីជម្រៅ អំពីធាតុមួយនេះ ថាតើគេអនុវត្ត ដោយរបៀបណាខ្លះ?

ធាតុផ្សំនីត្យានុកូលគឺជាធាតុផ្សំដែលទាក់ទងនឹងច្បាប់។ ច្បាប់គឺជាកត្តាចាំបាច់បំផុតនៅក្នុងរឿងក្តីព្រហ្មទណ្ឌ។ នេះជាមូលដ្ឋាននៃគោលការណ៍នីត្យានុកូលភាពដែលត្រូវបានបង្កើតឡើង ក្នុងបំណងការពារសិទ្ធិ សេរីភាពរបស់បុគ្គលក្នុងការប្រព្រឹត្តអំពើផ្សេងៗ។ មាត្រា ៣ នៃក្រមព្រហ្មទណ្ឌបានចែង និងទទួលស្គាល់យ៉ាងច្បាស់នូវគោលការណ៍នីត្យានុកូលភាព មាត្រានេះចែងថា មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែង **ក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន មានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន**។ ជាដំបូងបំផុតដាច់ខាតត្រូវតែមានច្បាប់ចែងដើម្បីកំណត់បានថា អំពើណាមួយគឺជា បទល្មើស នេះគឺជាគោលការណ៍នីត្យានុកូលភាព។ គោលការណ៍នីត្យានុកូលភាពបង្កើតឱ្យមានផលវិបាកជា គោលការណ៍ចំនួនពីរផ្សេងទៀត ដែលចាំបាច់ត្រូវតែយល់ដឹងពោលគឺ គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ដែលពាក់ព័ន្ធនឹងការអនុវត្តច្បាប់ព្រហ្មទណ្ឌជាទូទៅ និងការបកស្រាយច្បាប់ព្រហ្មទណ្ឌយ៉ាងតឹងរ៉ឹង។ បន្ទាប់មកនេះយើងខ្ញុំនឹងបកស្រាយខ្លះៗអំពីការអនុវត្តច្បាប់ព្រហ្មទណ្ឌជាទូទៅ ៖

ការអនុវត្តច្បាប់ព្រហ្មទណ្ឌត្រូវគោរពគោលការណ៍ ២ គឺ **គោលការណ៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង** និង**គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌដែលធ្ងន់ជាង**។ **គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ** គឺជាគោលការណ៍គ្រឹះនៃនីតិព្រហ្មទណ្ឌ។ យើងខ្ញុំនឹងបង្ហាញថា តើអត្ថន័យគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌមានខ្លឹមសារយ៉ាងដូចម្តេច ហើយមានសារៈសំខាន់យ៉ាងដូចម្តេច?

ប្រសិនបើច្បាប់ពីរមានកម្មវត្ថុដូចគ្នាទាំងស្រុង ឬដូចគ្នាខ្លះៗ ហើយបានចូលជាធរមាននៅក្នុងកាលបរិច្ឆេទខុសៗគ្នា ដូច្នេះនឹងអាចចោទជាបញ្ហានៃការអនុវត្តច្បាប់ទាំងពីរនេះចំពោះស្ថានភាពគតិយុត្តមួយដែលបាន កើតឡើង។ តាមគោលការណ៍នីត្យានុកូលភាព អំពើមួយមិនត្រូវបានចាត់ទុកជាបទល្មើសឡើយប្រសិនបើគ្មាន ច្បាប់ចែង ដែលនេះស្តែងឱ្យឃើញថា ច្បាប់ព្រហ្មទណ្ឌមិនមានលក្ខណៈប្រតិសកម្មឡើយ។ គោលការណ៍

មិន ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ មានអត្ថន័យថា ច្បាប់ដែលចូលជាធរមាននៅថ្ងៃណាមួយជាកំណត់ គឺជាទូទៅ ពុំមានអានុភាពគ្រប់គ្រងស្ថានភាពទាំងឡាយណា ដែលបានកើតឡើងមុនពេលច្បាប់ចូលជាធរមានឡើយ។ គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌមានគោលបំណងការពារសិទ្ធិសេរីភាពប្រជាពលរដ្ឋក្នុងការធ្វើសកម្មភាពផ្សេងៗ ដែលច្បាប់នៅខណៈនោះពុំបានចាត់ទុកថាជាបទល្មើសទេ។ ទោះបីជាថ្ងៃក្រោយមកទៀតស្រាប់តែមានច្បាប់កំណត់ថា អំពើដដែលជាបទល្មើសក៏ដោយ ក៏ចារីដែលបានប្រព្រឹត្តអំពើល្មើសពុំចាំបាច់ភ័យខ្លាចឡើង ពីព្រោះថាច្បាប់ដែលទើបតែបានចូលជាធរមានត្រូវមានអានុភាពអនុវត្តតែទៅលើសកម្មភាព ដែលកើត ឡើងចាប់ពីថ្ងៃដែលច្បាប់ចូលជាធរមានតែប៉ុណ្ណោះ។

គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ មានចែងនៅក្នុងបញ្ញត្តិមាត្រា ១០ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌថា បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសធ្ងន់ជាងនឹងត្រូវអនុវត្តតែទៅលើអំពើ ដែលបានប្រព្រឹត្តក្រោយការចូលជាធរមាននៃបទប្បញ្ញត្តិនោះប៉ុណ្ណោះ។

ដើម្បីយល់ឱ្យបានច្បាស់ពីគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌចាំបាច់ត្រូវសិក្សាពីការអនុវត្តគោលការណ៍នេះ ដូចខាងក្រោម៖

ជំពូកទី១. ច្បាប់ព្រហ្មទណ្ឌ និងការអនុវត្តច្បាប់ព្រហ្មទណ្ឌ

ផ្នែកទី១. ច្បាប់ព្រហ្មទណ្ឌ

ផ្នែកទី២. ការអនុវត្តច្បាប់ព្រហ្មទណ្ឌ

ជំពូកទី២. គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ

ផ្នែកទី១. អត្ថន័យនៃគោលការណ៍មិនប្រតិសកម្ម

ផ្នែកទី២. ភាពមិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌធ្ងន់ជាង

ជំពូកទី៣. អញ្ញត្រកម្មទៅនឹងគោលការណ៍ (ភាពមិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ)

ផ្នែកទី១. ច្បាប់ដែលលុបចោលបទល្មើស

ផ្នែកទី២. ច្បាប់ថ្មីដែលស្រាលជាង

ផ្នែកទី៣. អញ្ញត្រកម្មទៅនឹងគោលការណ៍អប្រតិសកម្មនៃច្បាប់ថ្មី

# ជំពូកទី១

# ច្បាប់ព្រហ្មទណ្ឌ និងការអនុវត្តច្បាប់ព្រហ្មទណ្ឌ

# ជំពូកទី១

# ច្បាប់ព្រហ្មទណ្ឌ និងការអនុវត្តច្បាប់ព្រហ្មទណ្ឌ

មុននឹងសិក្សាពីគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ជាដំបូងយើងត្រូវឈ្វេងយល់អំពីអត្ថន័យរបស់ច្បាប់ព្រហ្មទណ្ឌ និងការអនុវត្តរបស់ច្បាប់ព្រហ្មទណ្ឌជាមុនសិន ទើបយើងអាចឈ្វេងយល់កាន់តែច្បាស់ថាអ្វីទៅគឺជាគោលការណ៍មិនប្រតិសកម្ម បន្ទាប់មកទៀតយើងខ្ញុំនឹង បង្ហាញអំពីអញ្ញត្រកម្មទៅនឹងគោលការណ៍នេះ ហេតុនេះហើយគោលបំណង និងអត្ថន័យនៃគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ យើងខ្ញុំនឹងបកស្រាយនៅខាងក្រោម។

## ផ្នែកទី១ ៖ ច្បាប់ព្រហ្មទណ្ឌ

នៅក្នុងផ្នែកនេះ យើងខ្ញុំនឹងបកស្រាយពី **១.១. អត្ថន័យនៃច្បាប់ព្រហ្មទណ្ឌ ១.២. ប្រភពនៃច្បាប់ព្រហ្មទណ្ឌ និង ១.៣. ប្រភេទនៃច្បាប់ព្រហ្មទណ្ឌ**។

### ១.១. អត្ថន័យនៃច្បាប់ព្រហ្មទណ្ឌ

ច្បាប់ព្រហ្មទណ្ឌ គឺជាកម្រងនៃក្រម ដែលរៀបចំធ្វើឡើង និងយកទៅអនុវត្តដោយរដ្ឋ ដើម្បីបម្រើក្នុងគោលបំណងរៀបចំរបៀបរៀបរយសង្គម និងការពារប្រជាជន ព្រមទាំងទ្រព្យសម្បត្តិរបស់ពួកគេ ក៏ដូចជាការពាររដ្ឋ ឬក៏ទ្រព្យសម្បត្តិរបស់រដ្ឋនោះផងដែរ។ រឿងក្ដីព្រហ្មទណ្ឌមួយ ឬគេអាចហៅបានម៉្យាងទៀតថា "បណ្ដឹងអាជ្ញា" គឺជាពាក្យបណ្ដឹងស្របច្បាប់មួយ ដែលរដ្ឋរៀបចំធ្វើឡើងដើម្បីធ្វើការចោទលើបុគ្គលណាម្នាក់ថាបុគ្គលនោះបានប្រព្រឹត្តបទល្មើស ដែលផ្ទុយទៅ នឹងច្បាប់ជាធរមាន។ ក្រមទូទៅនៃច្បាប់ព្រហ្មទណ្ឌចែងអំពី ៖

- រាល់បទល្មើស និងទោសទាំងអស់ (ហៅថា "ក្រមព្រហ្មទណ្ឌ")
- នីតិវិធីព្រហ្មទណ្ឌ ដើម្បីយកទៅដោះស្រាយលើបទល្មើសទាំងនោះ ដោយរួមទាំងភារកិច្ចទាំងឡាយរបស់អ្នករាជការ និងដំណើរការព្រហ្មទណ្ឌដទៃៗទៀត។

ច្បាប់ព្រហ្មទណ្ឌចែងអំពីទង្វើទាំងឡាយណា ដែលអាចបង្កើត ដែលអាចកកើតបានទៅជាបទល្មើសព្រហ្មទណ្ឌ ដោយរួមទាំងធាតុផ្សំនៃបទល្មើស[១]ទាំងនោះ និងសណ្ឋានការពារទាំងឡាយ[២] ដែលជនជាប់ចោទមាន ដើម្បីការពារខ្លួនក្នុងការចោទទាំងនោះ។ បទល្មើស គឺជាប្រភេទនៃទង្វើ ឬអំពើទាំងឡាយណា ដែលបានហាមឃាត់ដោយសារតែអំពើ ឬទង្វើទាំងនោះត្រូវបានចាត់ទុកថាមានផលប៉ះពាល់ដល់ឯកត្តបុគ្គលទៅលើរដ្ឋ ឬ

[១] បទល្មើសទាំងឡាយកើតឡើងដោយធាតុផ្សំរបស់វា។ ដើម្បីអាចឱ្យជនជាប់ចោទម្នាក់មានទោសពីបទល្មើសព្រហ្មទណ្ឌណាមួយ នៅក្នុងប្រទេសកម្ពុជាបាន លុះត្រាអយ្យការមានភស្តុតាងគ្រប់គ្រាន់បង្ហាញ ឱ្យលែងនៅសល់ចំណុចអ្វីដែលនៅសង្ស័យ (វិមតិសង្ស័យ)។

[២] សណ្ឋានការពារ គឺជាសេចក្ដីតវ៉ាស្របច្បាប់មួយ ដែលធ្វើឡើងដោយជនជាប់ចោទ ក្នុងគោលបំណងដើម្បីបង្ហាញថាខ្លួនមិនបានប្រព្រឹត្តបទល្មើស ដែលត្រូវបានចោទប្រកាន់នោះឡើយ ឬនៅក្នុងរឿងមួយចំនួនជនជាប់ចោទអាចមានទោស ពីបទល្មើសណាមួយ ដែលមានស្ថានទោសស្រាលជាងអ្វី ដែលចោទប្រកាន់មកលើខ្លួន។

ក៏ទៅលើប្រទេសទាំងមូលតែម្តង។ បញ្ញត្តិទូទៅនៃច្បាប់ព្រហ្មទណ្ឌគឺថា គ្មានអ្វីដែលអាចចាត់ថាជាបទល្មើសបាននោះទេកាលបើអ្វីនោះមិនទាន់ចែងដោយច្បាប់ថាជាបទល្មើសនោះ ហើយក៏គ្មាននរណាម្នាក់នឹងត្រូវចោទប្រកាន់ដោយសារតែការប្រព្រឹត្តអំពើអ្វីមួយបានដែរ កាលបើមិនធ្វើឡើងដោយច្បាប់ដែលមានចែងនោះ។ រាល់ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌជានិច្ចជាកាលតែងតែត្រូវដាក់ទណ្ឌកម្មដោយរដ្ឋ។ ទណ្ឌកម្មនៃបទល្មើសព្រហ្មទណ្ឌមួយគឺអាស្រ័យ ទៅលើសភាពលក្ខណៈគ្រោះថ្នាក់របស់បទល្មើសនោះ ដោយអាចមានចាប់ពីការផាកពិន័យ រហូតដល់ការផ្តន្ទាទោសឱ្យជាប់ពន្ធនាគារជាច្រើនឆ្នាំ។

មួយវិញទៀតច្បាប់ព្រហ្មទណ្ឌ គឺជាផ្នែកមួយនៃច្បាប់សាធារណៈ។ ច្បាប់ព្រហ្មទណ្ឌស្វែងរកការបង្ការមិនឱ្យកើតមាននូវការគ្រោះថ្នាក់ដល់សង្គម ដោយការប្រកាសថាតើអំពើអ្វីខ្លះដែលចាត់ថាជាបទល្មើសព្រហ្មទណ្ឌបញ្ជាក់ពីទណ្ឌកម្មដែលនឹងទទួល កាលបើប្រព្រឹត្តនូវអំពើល្មើសនោះ និងកំណត់ពីនីតិវិធីដែលបទល្មើសព្រហ្មទណ្ឌនោះត្រូវធ្វើការស៊ើបអង្កេត ចោទប្រកាន់ វិនិច្ឆ័យ និងដាក់ទណ្ឌកម្ម។

ជារួមមកប្រសិនបើយើងគិតទៅតាមចង្កោមនៃច្បាប់ ដែលគេបែងចែកទៅតាមទ្រឹស្តីជាច្បាប់សាធារណៈ ឬច្បាប់ឯកជននោះ ច្បាប់ព្រហ្មទណ្ឌជាច្បាប់មួយដែលស្ថិតនៅក្នុងចង្កោមនៃច្បាប់សាធារណៈ ហើយជាអត្ថបទច្បាប់មួយដែលប្រមូលផ្តុំនូវរាល់បទប្បញ្ញត្តិដែលទាក់ទង ជាពិសេសដល់ការកំណត់បទល្មើស ការចង្អុលបង្ហាញអំពីបុគ្គលដែលអាចប្រកាសថាជាអ្នកទទួលខុសត្រូវចំពោះបទល្មើស ការកំណត់ពីទោស ក៏ដូចជាបែបបទនៃការអនុវត្តទោសនោះដែរ។ គោលការណ៍នេះ យើងបានកំណត់យ៉ាងច្បាស់នៅក្នុងមាត្រា ១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩ របស់ព្រះរាជាណាចក្រកម្ពុជាយើង។ ច្បាប់ព្រហ្មទណ្ឌនេះ គឺបានបញ្ញត្តិដើម្បីបង្កើតនូវបញ្ជីនៃបទល្មើសមានន័យថាជាបញ្ជីនៃអំពើដែលសង្គមបានហាមឃាត់ និងបានបញ្ញត្តិដើម្បីបង្កើតនូវបញ្ជីនៃទោស ព្រមទាំងគោលការណ៍មួយចំនួនទាក់ទងដល់ការកំណត់អំពីទោស ក៏ដូចជាការអនុវត្តទោសផងដែរ។ ជាបន្តទៅទៀតនេះ យើងខ្ញុំនឹងបកស្រាយអំពីច្បាប់ព្រហ្មទណ្ឌ ឱ្យកាន់តែស៊ីជម្រៅទៀតនោះគឺ **១.១.១. ច្បាប់ព្រហ្មទណ្ឌក្នុងន័យទូលាយ និងច្បាប់ព្រហ្មទណ្ឌក្នុងន័យចង្អៀត**។

### ១.១.១. ច្បាប់ព្រហ្មទណ្ឌក្នុងន័យទូលាយ និងច្បាប់ព្រហ្មទណ្ឌក្នុងន័យចង្អៀត

តើច្បាប់ព្រហ្មទណ្ឌនេះមានអ្វីខ្លះទៅ?

ក្នុងការបកស្រាយច្បាប់ព្រហ្មទណ្ឌ យើងអាចកំណត់អត្ថន័យរបស់ច្បាប់នេះជាពីរគឺ ច្បាប់ព្រហ្មទណ្ឌក្នុងន័យទូលាយ និងច្បាប់ព្រហ្មទណ្ឌក្នុងន័យចង្អៀត។ ជាបន្តទៅទៀតយើងខ្ញុំនឹងបកស្រាយឱ្យកាន់តែច្បាស់ អំពីនិយមន័យ **ក. ច្បាប់ព្រហ្មទណ្ឌក្នុងន័យទូលាយ និង ខ. ច្បាប់ព្រហ្មទណ្ឌក្នុងន័យចង្អៀត**។

**ក. ច្បាប់ព្រហ្មទណ្ឌក្នុងន័យទូលាយ**

បើយើងប្រើច្បាប់ព្រហ្មទណ្ឌក្នុងន័យទូលាយ មានន័យថា គឺជាបណ្តុំនៃបទប្បញ្ញត្តិព្រហ្មទណ្ឌ ដែលមានប្រភពចេញមកពីអង្គការនីតិប្រតិបត្តិ និងចេញមកពីអង្គការនីតិប្បញ្ញត្តិ។

**ខ. ច្បាប់ព្រហ្មទណ្ឌក្នុងន័យចង្អៀត**

ឯនៅក្នុងន័យចង្អៀតវិញ ច្បាប់ព្រហ្មទណ្ឌ គឺជាបណ្តុំនៃបទប្បញ្ញត្តិព្រហ្មទណ្ឌដែលអនុម័តដោយអង្គការនីតិប្បញ្ញត្តិសុទ្ធសាធ។

### ១.២. ប្រភពនៃច្បាប់ព្រហ្មទណ្ឌ

គោលការណ៍ជាមូលដ្ឋានរបស់ច្បាប់ព្រហ្មទណ្ឌគឺ គ្មានអ្វីដែលជាបទល្មើសទេ លុះត្រាតែមានចែងនៅក្នុងច្បាប់ ហើយគ្មានជនណាម្នាក់ត្រូវទទួលការចោទប្រកាន់លើសកម្មភាពរបស់ខ្លួនបានឡើយ លើកលែងតែ ទង្វើនោះត្រូវបានចាត់ទុកដោយច្បាប់ថាជាអំពើល្មើស។ ដូច្នេះហើយទើបច្បាប់ព្រហ្មទណ្ឌត្រូវរៀបចំ សរសេរជាលាយលក្ខណ៍អក្សរឱ្យបានត្រឹមត្រូវ។ នេះក៏ដោយសារហេតុថាបុគ្គលគ្រប់ៗរូបត្រូវយល់ដឹង អំពីច្បាប់នេះ ពីព្រោះថា គេត្រូវគោរពប្រតិបត្តិតាមច្បាប់នេះ។ ច្បាប់ព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជាយើង មានប្រភពពីរសំខាន់ៗចូលរួម នោះគឺ **១.២.១. ប្រភពអន្តរជាតិ និង ១.២.២. ប្រភពជាតិ** ។

#### ១.២.១. ប្រភពអន្តរជាតិ

ប្រភពអន្តរជាតិ គឺជាសន្ធិសញ្ញាអន្តរជាតិ។ សន្ធិសញ្ញាអន្តរជាតិ គឺជាកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សររវាងរដ្ឋ និងរដ្ឋ ឬរវាងរដ្ឋ និងអង្គការអន្តរជាតិ។ ជាក់ស្តែង សន្ធិសញ្ញាអន្តរជាតិអាចធ្វើឡើងជាទ្វេភាគី ឬពហុភាគី ឬមានលក្ខណៈជាសកលតែម្តង។ អនុលោមតាមមាត្រា ៩០ ថ្មី (ពីរ) កថាខណ្ឌទី២ នៃរដ្ឋធម្មនុញ្ញ រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ តាមមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល។ ចំណែកឯព្រឹទ្ធសភាវិញ មានសមត្ថកិច្ចក្នុងការត្រួតពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបានអនុម័តយល់ព្រមរួចហើយ[៣]។ ហេតុនេះ សភាដែលជាអង្គការនីតិប្បញ្ញត្តិមានសមត្ថកិច្ចសម្រេចអនុម័តផ្តល់សច្ចាប័ន (ការយល់ព្រម) លើសន្ធិសញ្ញាទាំងឡាយ ដើម្បីឱ្យសន្ធិសញ្ញាទាំងនោះអាចមានអានុភាពអនុវត្តក្នុងព្រះរាជាណាចក្រកម្ពុជា។

យ៉ាងណាមិញព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសហត្ថលេខីនៃសន្ធិសញ្ញាអន្តរជាតិជាច្រើន។ ជាក់ស្តែងពាក់ព័ន្ធទៅនឹងវិស័យព្រហ្មទណ្ឌ គេសង្កេតឃើញមានសន្ធិសញ្ញាមួយចំនួនដូចជា អនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៤៨, អនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងការទូតចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៦១, អនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងកុងស៊ុលចុះថ្ងៃទី

[៣] មាត្រា ១១៣ នៃរដ្ឋធម្មនុញ្ញ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

១៨ ខែមេសា ឆ្នាំ១៩៦៣, កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦, លក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨, អនុសញ្ញាស្តីពីសិទ្ធិកុមារ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩, សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ដែលត្រូវបានផ្តល់សច្ចាប័ន និងប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ ជស/រកម/០៧៩៩/០៨ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៩, សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ដែលត្រូវបានផ្តល់សច្ចាប័ន និងប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០០/០៤ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០០, សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដែលត្រូវបានផ្តល់សច្ចាប័ន និងប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៣០៥/០០៦ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៥, សន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌដែលត្រូវបានផ្តល់សច្ចាប័ន និងប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០១១០/០១ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១០, កិច្ចព្រមព្រៀងស្តីពីបត្យាប័នរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ដែលបានផ្តល់សច្ចាប័ន និងប្រកាសឱ្យប្រើតាមព្រះរាជាក្រមលេខ នស/រកម/០១១១/០០១ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១១, សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលត្រូវបានផ្តល់សច្ចាប័ន និងប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០២០ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤, កិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលកម្ពុជា និងប្រធានាធិបតិយ្យអាមេរិកស្តីពីការមិនប្រគល់ខ្លួនជូនតុលាការឧក្រិដ្ឋកម្មអន្តជាតិ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥។

**១.២.២. ប្រភពជាតិ**

យើងអាចដឹងបានថាប្រភពជាតិ គឺបានមកពីប្រភពបី ដាច់ដោយឡែកផ្សេងពីគ្នាទៀតនោះគឺ ៖ **ក. ច្បាប់ក្នុងន័យចង្អៀត ខ. បទបញ្ញា និង គ. រដ្ឋធម្មនុញ្ញ** ។

**ក. ច្បាប់ក្នុងន័យចង្អៀត**

ច្បាប់ក្នុងន័យចង្អៀត គឺជាច្បាប់ដែលមានប្រភពកើតចេញមកពីអង្គការនីតិប្បញ្ញត្តិ។ អនុលោមតាមបទប្បញ្ញត្តិរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា អង្គការនីតិប្បញ្ញត្តិ រួមមាន រដ្ឋសភា និងព្រឹទ្ធសភា។ ជាការពិតទៅ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ ត្រូវបានប្រកាសឱ្យប្រើដោយព្រះមហាក្សត្រ។ បន្ទាប់មកទៀត ច្បាប់នេះត្រូវចូលជាធរមាននៅរាជធានីភ្នំពេញ ក្នុងរយៈពេល ១០ថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឱ្យប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេល ២០ថ្ងៃគត់ ក្រោយថ្ងៃប្រកាសឱ្យប្រើ។ ប៉ុន្តែប្រសិនបើច្បាប់បានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេស ក្រោយថ្ងៃប្រកាសឱ្យប្រើ[៤]។

[៤] មាត្រា ៩៣ ថ្មី នៃរដ្ឋធម្មនុញ្ញ។

រហូតមកដល់បច្ចុប្បន្ន មានច្បាប់ជាច្រើនត្រូវបានអនុម័ត និងប្រកាសឱ្យប្រើ។ នៅក្នុងវិស័យព្រហ្មទណ្ឌ ច្បាប់ទាំងនោះរួមមានដូចជា ច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ប្រកាសឱ្យប្រើនៅថ្ងៃទី០៧ ខែមករា ឆ្នាំ ២០០២ (ប៉ុន្តែត្រូវបាននិរាករណ៍ដោយក្រមព្រហ្មទណ្ឌ) ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី៨ ខែ មីនា ឆ្នាំ១៩៩៣ (ប៉ុន្តែត្រូវបាននិរាករណ៍ដោយក្រមនីតិវិធីព្រហ្មទណ្ឌ) ច្បាប់ស្តីពីការបង្រ្កាបល្បែងស៊ីសង ប្រកាសឱ្យប្រើនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៩៦, ច្បាប់ស្តីពីការរំលូតកូន ប្រកាសឱ្យប្រើនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ ១៩៩៧, ច្បាប់ភូមិបាល ប្រកាសឱ្យប្រើនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១, ច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ ប្រកាសឱ្យប្រើនៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៥, ច្បាប់ស្តីពីឯកពន្ធភាព ប្រកាសឱ្យប្រើនៅ ថ្ងៃទី ២១ ខែតុលា ឆ្នាំ២០០៦, ច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ប្រកាសឱ្យប្រើ នៅថ្ងៃ ទី២៤ ខែមិថុនា ឆ្នាំ២០០៧, ច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម ប្រកាសឱ្យប្រើនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, ច្បាប់ស្តីពីការបង្រ្កាប ការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រកាសឱ្យប្រើនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ប្រកាសឱ្យប្រើនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០, ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រកាសឱ្យប្រើនៅថ្ងៃទី ០២ ខែមករា ឆ្នាំ២០១២, ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ប្រកាសឱ្យប្រើនៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៥ និងច្បាប់ ស្តីពីយុត្តិធម៌អនីតិជន ប្រកាសឱ្យប្រើនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦។

### ខ. បទបញ្ជា

បទដ្ឋានគតិយុត្តនានា ដែលមានប្រភពកើតចេញមកពីអង្គការនីតិប្រតិបត្តិក៏ជាប្រភពនៃនីតិព្រហ្មទណ្ឌ ដែរ។ ដូច្នេះហើយទើបមាត្រា ១ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌបានបញ្ជាក់យ៉ាងច្បាស់លាស់ដោយបានចែង ថា នៅក្នុងករណីចាំបាច់ បទដ្ឋានគតិយុត្តដែលចេញដោយអង្គការនីតិប្រតិបត្តិ អាចចែងពីបទលហុដែលត្រូវ ផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ។ ជាក់ស្តែង អនុក្រឹត្យលេខ ៤៤ អនក្រ.បក ស្តីពីការពិន័យអន្តរការណ៍ ចំពោះអំពើល្មើសនឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ គឺជាលិខិតបទដ្ឋានគតិយុត្ត កើតចេញពីអង្គការនីតិប្រតិបត្តិ ដែលកំណត់ពីអំពើដែលត្រូវទទួលរងពិន័យអន្តរការណ៍។ នៅក្នុងករណីដែល ជនល្មើសមិនបានបង់ប្រាក់ពិន័យអន្តរការណ៍ ក្នុងរយៈពេល ៩០ថ្ងៃ គិតពីថ្ងៃដែលបានទទួលបង្កាន់ដៃពិន័យ អន្តរការណ៍ មន្ត្រីមានសមត្ថកិច្ចត្រូវរៀបចំសំណុំរឿងបញ្ជូនទៅអយ្យការអមសាលាដំបូងតាមនីតិវិធីច្បាប់[៩]។

---

[៩] មាត្រា ១៤ កថាខណ្ឌទី២ នៃអនុក្រឹត្យលេខ ៤៤ អនក្រ.បក ស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើស នឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវ គោក ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧។

### គ. រដ្ឋធម្មនុញ្ញ

រដ្ឋធម្មនុញ្ញ គឺជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា[៦]។ រដ្ឋធម្មនុញ្ញបានចែងអំពីគោលការណ៍ទូទៅ ចំណែកច្បាប់ព្រហ្មទណ្ឌរបស់កម្ពុជា ភាគច្រើនអាចឃើញមាននៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាល និងច្បាប់អតីតរដ្ឋកម្ពុជា។ ច្បាប់ទាំងពីរនេះត្រូវបានអនុម័តឱ្យយកមកប្រើមុនពេល រដ្ឋធម្មនុញ្ញបានចូលជាធរមាន តែច្បាប់ទាំងពីរគ្មានច្បាប់ណាមួយដែលអាចឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់កម្ពុជា ក្នុងវិស័យច្បាប់ព្រហ្មទណ្ឌបានឡើយ។ ក្រមព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌថ្មី ត្រូវបានព្រាងរួចហើយ ប៉ុន្តែហាក់ដូចជាប្រើរយៈពេលមួយយូរអង្វែងណាស់មុនពេលរដ្ឋសភាជាតិឈានទៅអនុម័ត។ រដ្ឋធម្មនុញ្ញ (មាត្រា ៣២ មាត្រា ៣៨ មាត្រា ៤០ មាត្រា ៤៤ និងមាត្រា ៤៦) ច្បាប់ព្រហ្មទណ្ឌរួមមាន (ក្រមព្រហ្មទណ្ឌ និងច្បាប់ព្រហ្មទណ្ឌដោយឡែកដ៏ទៃទៀត ដែលខ្លះមានចរិតពិសេសផងដែរ) និងបទដ្ឋានក្រោមច្បាប់ (នៅខ្សត់ខ្សោយនៅឡើយ)។ បើយោងទៅតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ "ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួនជនណាម្នាក់នឹងអាចធ្វើទៅកើតលុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់" ("គោលការណ៍សច្ចធារណ៍ នៃនិរទោស"[៧] ការហាមឃាត់មិនឱ្យប្រើប្រាស់អំពើហិង្សាដើម្បីទទួលបានចម្លើយនៃពិរុទ្ធភាព[៨] ការការពារភាពមិនអាចរំលោភបាននៃលំនៅដ្ឋាន អាថ៌កំបាំងនៃការឆ្លើយឆ្លងតាមលិខិត តាមសារទូរលេខ ទូរពុម្ព និងតាមទូរស័ព្ទ[៩]។ ក្នុងមាត្រា ៣១ បានទទួលស្គាល់អនុសញ្ញាអន្តរជាតិទាក់ទងទៅនឹងសិទ្ធិមនុស្ស ដែលក្នុងនោះមានកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយត្រង់មាត្រា ១៥ (គោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងទោស) បានចែងថា "គ្មានជនណាម្នាក់ត្រូវជាប់ទោសពីបទល្មើសព្រហ្មទណ្ឌឡើយ ចំពោះអំពើ ឬការធ្វេសប្រហែសណាមួយដែលពុំមែនជាបទល្មើសព្រហ្មទណ្ឌ ដែលមាននៅក្រោមច្បាប់ជាតិ ឬក៏ច្បាប់អន្តរជាតិ ខណៈពេលដែលអំពើនោះត្រូវបានប្រព្រឹត្ត។ ហើយក៏មិនត្រូវមានការដាក់ទោសណាមួយឱ្យធ្ងន់ធ្ងរជាងទោសដែលផ្តន្ទា នៅពេលដែលបទល្មើសព្រហ្មទណ្ឌនោះត្រូវបានប្រព្រឹត្តឡើយ។ ប្រសិនបើក្រោយពីការប្រព្រឹត្តបទល្មើសរួចហើយ ច្បាប់បានបញ្ញត្តិឱ្យមានការដាក់ទោសស្រាលជាងមុន ជនល្មើសត្រូវទទួលផលប្រយោជន៍នោះ"។ លើសពីនេះទៀត រដ្ឋធម្មនុញ្ញបានដាក់កំហិតឱ្យសភានីតិប្បញ្ញត្តិទទួលបន្ទុកបង្កើតនូវបទល្មើស កំណត់នូវទោស និងការអនុវត្តទោស (ដោយគោរព និងសម្រេចឱ្យបាននូវគោលការណ៍នីត្យានុកូលភាព គ្មានបទល្មើស គ្មានទោស ប្រសិនបើគ្មានច្បាប់ចែងទេ ដែលបច្ចុប្បន្ននេះសភាជាតិបានចែងបញ្ចូលក្នុងក្រមព្រហ្មទណ្ឌត្រង់មាត្រា ៣)។ ម្យ៉ាងទៀត គឺគោរពនូវគោលការណ៍នៃ ការអនុវត្តច្បាប់

[៦] មាត្រា ១៥០ ថ្មី នៃរដ្ឋធម្មនុញ្ញ។

[៧] មាត្រា ៣៨ កថាខណ្ឌទី ៧ នៃរដ្ឋធម្មនុញ្ញ។

[៨] មាត្រា ៣៨ កថាខណ្ឌទី៥ នៃរដ្ឋធម្មនុញ្ញ។

[៩] មាត្រា ៤០ កថាខណ្ឌទី៣ នៃរដ្ឋធម្មនុញ្ញ។

ព្រហ្មទណ្ឌក្នុងពេលវេលា តាក់តែងច្បាប់ព្រហ្មទណ្ឌឱ្យបានល្អិតល្អន់ និងពេញលេញ ដើម្បីជៀសវាងការប្រព្រឹត្ត តាមទំនើងចិត្តរបស់ចៅក្រម។ ដោយឈរលើស្មារតីនេះ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាត្រូវបាន តាក់តែង គិតចាប់ពីពេលដែលចូលជាធរមាន និងមានអានុភាពអនុវត្ត ក្រមព្រហ្មទណ្ឌបានក្លាយជាប្រភពដ៏ សំខាន់នៃការបង្កើត និងបង្ក្រាបបទល្មើសព្រហ្មទណ្ឌ។ ក្រមព្រហ្មទណ្ឌថ្មីអាចចាត់ទុកជាក្រមដ៏ទាន់សម័យមួយ ដោយសារតែក្រមនេះទទួលស្គាល់នូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ការកំណត់អំពីប្រភេទនៃ ទោស ដែលធ្វើឱ្យចៅក្រមអាចបត់បែនទៅតាមកាលៈទេសៈ ស្របតាមស្មារតីនៃឧត្តមគតិរបស់ច្បាប់ គឺមិនត្រូវ ពុករលួយឡើយ។

ក្រមព្រហ្មទណ្ឌថ្មី (ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩) នេះរួមមាន ០៦ (ប្រាំមួយ) គន្ថី ដូចខាងក្រោម ៖

- គន្ថីទី១ ៖ បទប្បញ្ញត្តិទូទៅ
- គន្ថីទី២ ៖ បទល្មើសប្រឆាំងនឹងបុគ្គល
- គន្ថីទី៣ ៖ បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ
- គន្ថីទី៤ ៖ បទល្មើសប្រឆាំងនឹងជាតិ
- គន្ថីទី៥ ៖ អន្តរប្បញ្ញត្តិ និង
- គន្ថីទី៦ ៖ អវសានប្បញ្ញត្តិ

ក្រមព្រហ្មទណ្ឌទាំងអស់រួមមាន ៦៧២ មាត្រា ដែលនេះជាការចងក្រងអត្ថបទដែលមានចរិតបង្ក្រាបឱ្យជុំ មួយជុំ ក្នុងគោលដៅងាយស្រួលក្នុងការអនុវត្ត ការសិក្សាស្រាវជ្រាវ និងការស្វែងយល់នូវប្រព័ន្ធបង្ក្រាបរបស់ព្រះ រាជាណាចក្រកម្ពុជា។ លើសពីនេះទៅទៀត គេអាចរកឃើញក្នុងក្រមនេះនូវអ្វីដែលធ្លាប់មាន និងមិនធ្លាប់មានពី មុននៅក្នុងប្រវត្តិច្បាប់ខ្មែរគឺ ៖

- កំណត់នូវការបែងចែកអំណាចរវាងអង្គការនីតិប្បញ្ញត្តិ និងអង្គការនីតិប្រតិបត្តិ ក្នុងការចែងនូវច្បាប់ ព្រហ្មទណ្ឌ ពិសេសត្រង់មាត្រា ១ កថាខណ្ឌទី២ ជាដើម
- ចែងអំពីនិយមន័យនៃបទល្មើស និងចំណាត់ថ្នាក់នៃបទល្មើសព្រហ្មទណ្ឌ ដូចជាបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុជាដើម (មាត្រា ២)
- បញ្ញត្តិនូវគោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌ រួមមានដូចជាគោលការណ៍នីត្យានុកូលភាពនៃបទ ល្មើស និងទោស (មាត្រា៣) គោលការណ៍នៃការបកស្រាយច្បាប់ព្រហ្មទណ្ឌ (មាត្រា៥) គោលការណ៍ ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ (មាត្រា២៤) គោលការណ៍ឯកត្តកម្មនៃទោស (មាត្រា៩៦)

- កំណត់បញ្ជាក់ពីការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងពេលវេលា និងក្នុងលំហ គឺ (មាត្រា ៩ ដល់ មាត្រា ២៣) ដែលក្នុងនេះបានបង្កប់នូវអានុភាពប្រតិសកម្ម នៃច្បាប់ព្រហ្មទណ្ឌ និងអានុភាពមិនប្រតិសកម្ម នៃច្បាប់ព្រហ្មទណ្ឌ
- មានការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល (នីតិជន អនីតិជន) និងមានការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលផងដែរ
- ចែងនូវមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ឬមួយការសម្រាលនូវការទទួលខុសត្រូវព្រហ្មទណ្ឌ (មាត្រា ៣១ ទៅដល់មាត្រា ៣៧)
- បញ្ញត្តិពីប្រភេទនៃទោសរួមមានមូលទោស ទោសបន្ថែម ទោសជំនួស
- ស្ថានទម្ងន់ទោស និងស្ថានសម្រាលទោសជាអាទិ៍
- របបនៃការអនុវត្តទោស ដូចជា (ការព្យួរទោស របបពាក់កណ្តាលសេរីភាពការបែងចែកទោសជាប្រភាគ ករណីបទល្មើសត្រួតគ្នារួមមាន ការស្រូបទោស ការត្រួតទោស និងការបូកទោស) ដែលអនុញ្ញាតឱ្យចៅក្រមអាចបត់បែននិងអាចសម្របតាមស្ថានភាពជាក់ស្តែងនីមួយៗ ដោយគោរពនូវគោលការណ៍មនុស្សធម៌ជាចាំបាច់ មិនត្រូវប្រព្រឹត្តអំពើពុករលួយឡើយ។

### ១.៣. ប្រភេទនៃច្បាប់ព្រហ្មទណ្ឌ និងបទប្បញ្ញត្តិព្រហ្មទណ្ឌ

ជាធម្មតាគេបែងចែកច្បាប់ជាពីរប្រភេទ គឺច្បាប់សាធារណៈ និងច្បាប់ឯកជន។ ច្បាប់សាធារណៈ គឺជាវិធានសម្រាប់រៀបចំគ្រប់គ្រងរដ្ឋ និងសមូហភាពសាធារណៈផ្សេងៗទៀត ព្រមទាំងគ្រប់គ្រងទំនាក់ទំនងរវាងរាជការ និងរាស្ត្រ។ ដូច្នេះក្បួនដែលសិក្សាអំពីច្បាប់សាធារណៈគឺ នីតិសាធារណៈ[១០]។ ឬមួយក៏ នីតិសាធារណៈ គ្រប់គ្រង រៀបចំរដ្ឋ និងការទំនាក់ទំនងរវាងរដ្ឋ និងរាស្ត្រ[១១]។ ចំណែកឯច្បាប់ឯកជន គឺជាវិធានសម្រាប់រៀបចំគ្រប់គ្រង ទំនាក់ទំនងរវាងបុគ្គលឯកជន និងបុគ្គលឯកជន ទោះបីជារូបវន្តបុគ្គលក្តី ឬនីតិបុគ្គលក្តី។ ដូច្នេះក្បួនដែលសិក្សាអំពីច្បាប់ឯកជន[១២]។ តើនីតិព្រហ្មទណ្ឌស្ថិតនៅក្នុងផ្នែកណា? នៅពេលមានបទល្មើសកើតឡើងឃើញមានការអន្តរាគមន៍ពីរដ្ឋ ដែលជាហេតុនាំឱ្យគេថានីតិព្រហ្មទណ្ឌស្ថិតនៅក្នុងសាខានីតិសាធារណៈ។ តែក្នុងរឿងព្រហ្មទណ្ឌ ក៏យើងឃើញថាមានទំនាក់ទំនងមួយទៀតរវាងជនល្មើស និងជនរងគ្រោះ ដែលជនរងគ្រោះ

[១០] សៀវភៅរបស់ ឯកឧត្តម បណ្ឌិត សាយ បូរី ស្តីពី "សេចក្តីផ្តើមចូលសិក្សានីតិរដ្ឋបាលទូទៅខ្មែរ" បង្រៀននៅសាកលវិទ្យាល័យបាត់ដំបង នាថ្ងៃទី១៦ និង ១៧ មិថុនា ឆ្នាំ២០១២។

[១១] សៀវភៅរបស់ ឯកឧត្តម បណ្ឌិត សាយ បូរី ស្តីពី "នីតិរដ្ឋបាលទូទៅ" បោះពុម្ពលើកទី ២ ឆ្នាំ២០០២ (ទំព័រទី៩)។

[១២] សៀវភៅរបស់ ឯកឧត្តម បណ្ឌិត សាយ បូរី ស្តីពី "សេចក្តីផ្តើមចូលសិក្សានីតិរដ្ឋបាលទូទៅខ្មែរ" បង្រៀននៅសាកលវិទ្យាល័យបាត់ដំបង នាថ្ងៃទី១៦ និង ១៧ មិថុនា ឆ្នាំ២០១២។

ក៏មានប៉ះពាល់ទៅដល់ផលប្រយោជន៍របស់ពួកគាត់ ទើបបណ្ដាលឱ្យមានការផ្ដន្ទាទោសជនល្មើស និងទាមទារឱ្យជនល្មើស ជួសជុលការខូចខាតដែលកើតចេញពីបទល្មើសដល់ជនរងគ្រោះ។ គេសង្កេតឃើញថា នីតិព្រហ្មទណ្ឌគឺជានីតិចម្រុះ។

តើអ្វីទៅជាបទប្បញ្ញត្តិ? យោងតាមនិយមន័យដែលក្រុមប្រឹក្សាធម្មនុញ្ញបានឱ្យនៅក្នុងសេចក្ដីសម្រេច លេខ ០៣៩/០០១/២០០១ កបធ.ច ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០១ នោះបទប្បញ្ញត្តិ គឺជាវិធានគតិយុត្តដែលមានចែងនៅក្នុងមាត្រានៃច្បាប់ ឬបទបញ្ជា។ ឯបទបញ្ជា គឺជាវិធាន ឬអត្ថបទគតិយុត្តដែលមានវិសាលភាពទូទៅ និងមិនចំពោះមុខបុគ្គលណាមួយឡើយ ហើយដែលធ្វើឡើយដោយអាជ្ញាធររដ្ឋបាលមានសមត្ថកិច្ច[១៣]។

បើតាមស្មារតី នៃក្រមព្រហ្មទណ្ឌរបស់យើង ជាពិសេសគឺមាត្រា ៦៦៨ បានបញ្ជាក់អំពីពាក្យថាច្បាប់ព្រហ្មទណ្ឌដែលយើងប្រើនៅក្នុងក្រមព្រហ្មទណ្ឌ នេះគឺបានក្ដោបនូវបទប្បញ្ញត្តិព្រហ្មទណ្ឌចំនួន ៣ (បី) ប្រភេទ គឺ **១.៣.១. បទប្បញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌខ្មែរថ្មីចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ១.៣.២. ច្បាប់ និងបទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែកផ្សេងទៀត ដែលកំពុងនៅជាធរមាន និង ១.៣.៣. ច្បាប់ព្រហ្មទណ្ឌដែលមានចរិតពិសេស**

### ១.៣.១. បទប្បញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌខ្មែរថ្មីចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

នៅក្នុងប្រភេទទីមួយនេះ គឺបទប្បញ្ញត្តិព្រហ្មទណ្ឌ ដែលកំណត់ដោយក្រមព្រហ្មទណ្ឌថ្មីនេះតែម្ដង ដែលមានភាគច្រើនជាងគេ នេះបើយោងតាមមាត្រា ៦៦៨ កថាខណ្ឌទី២ បានចែងថា "នៅក្នុងករណីដែលមានទំនាស់រវាងច្បាប់ និងបទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែក និង **បទប្បញ្ញត្តិនៃក្រមនេះ** ត្រូវអនុវត្តដោយអនុលោមតាមវិធានដែលមានចែងក្នុងគន្ថីទី១ (បទប្បញ្ញត្តិទូទៅ) នៃក្រមនេះ។ "ដូច្នេះហើយទើបយើងឃើញថាក្រមព្រហ្មទណ្ឌនេះគឺជាច្បាប់សារធាតុដ៏សំខាន់នៅក្នុងវិស័យព្រហ្មទណ្ឌចាប់តាំងពីសភាបានអនុម័តតាំងពីឆ្នាំ ២០០៩ មកម្ល៉េះ។

### ១.៣.២. ច្បាប់ និងបទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែកផ្សេងទៀត ដែលកំពុងនៅជាធរមាន

នៅក្នុងប្រភេទទីពីរនេះ គឺយោងតាមកថាខណ្ឌទី ១ នៃមាត្រា ៦៦៨ ខាងលើដែលបានចែងថា "ចំពោះបទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសដោយ**ច្បាប់ និងបទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែកផ្សេងទៀត** ដែលកំពុងនៅជាធរមាន ត្រូវអនុវត្តដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិព្រហ្មទណ្ឌទាំងនោះ"។ ដូច្នេះបទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែកដែលមានកំណត់នៅក្នុងច្បាប់មួយចំនួនផ្សេងទៀតអាចមានដូចជាច្បាប់ស្ដីពីការអប់រំ ច្បាប់ស្ដីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ច្បាប់ស្ដីពីផលផលជាដើម។ល។

[១៣] សៀវភៅរបស់ ឯកឧត្តម បណ្ឌិត សាយ បូរី ស្ដីពី "សេចក្ដីផ្ដើមចូលសិក្សានីតិរដ្ឋបាលទូទៅខ្មែរ" នៅសាកលវិទ្យាល័យបាត់ដំបង នាថ្ងៃទី១៦ និងទី១៧ ខែមិថុនា ឆ្នាំ២០១២។

### ១.៣.៣. ច្បាប់ព្រហ្មទណ្ឌដែលមានចរិតពិសេស

នៅក្នុងប្រភេទទីបីនេះ គឺបទប្បញ្ញត្តិព្រហ្មទណ្ឌដែលមានចរិតពិសេសមានដូចជាច្បាប់ស្តីពីព្រៃឈើ (មាត្រា ៧៦) ច្បាប់ស្តីពីការប្រឆាំងនឹងអំពើភេរវកម្ម ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ ជាអាទិ៍។ ម្យ៉ាងទៀតប្រសិនបើយើងពិនិត្យទៅលើកថាខណ្ឌទី៣ នៃមាត្រា ៦៦៨ ដដែលបានចែងកំណត់យ៉ាងច្បាស់ថា "បទប្បញ្ញត្តិនៃកថាខណ្ឌទី២ ខាងលើ មិនត្រូវយកមកអនុវត្តចំពោះ **ច្បាប់ព្រហ្មទណ្ឌដែលមានចរិតពិសេស**"។ នៅក្នុងករណីដែលមានទំនាស់រវាង "ច្បាប់ព្រហ្មទណ្ឌដែលមានចរិតពិសេស" និងបទប្បញ្ញត្តិនៃក្រមខាងលើនេះ គឺមិនត្រូវអនុវត្តតាមវិធានដែលមានចែងក្នុងគន្លឹទី១ នៃក្រមនេះទេ ផ្ទុយទៅវិញគឺត្រូវអនុវត្តទៅតាមវិធាន នៃច្បាប់ព្រហ្មទណ្ឌដែលមានចរិតពិសេសនោះវិញ។ ម៉្យាងទៀតច្បាប់ព្រហ្មទណ្ឌប្រភេទនេះក៏អាចទាក់ទងនឹងអាជ្ញាយុកាលផងដែរ ពិសេសបើយើងពិនិត្យឱ្យបានស៊ីជម្រៅទៅលើក្រមថ្មីយើងនេះត្រង់មាត្រា ១៤៣ វាកខណ្ឌទី២ គឺពិតជាពាក់ព័ន្ធទៅនឹងច្បាប់ពិសេស ដែលនិយាយពីភាពមិនអាចផុតរលត់ពីអាជ្ញាយុកាលប្រាកដមែន។

<u>**ឧទាហរណ៍**</u> ៖ មាត្រា ៩ នៃច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ បានកំណត់មិនឱ្យផុតរលត់ពីអាជ្ញាយុកាលនោះឡើយពីព្រោះថាវាជាប្រភេទនៃច្បាប់ពិសេស។

សរុបមកដើម្បីដឹងថាជាច្បាប់ព្រហ្មទណ្ឌ ដែលមានចរិតពិសេសនោះ គឺលុះត្រាតែបទប្បញ្ញត្តិនៃច្បាប់នោះចែងយ៉ាងជាក់លាក់ថាឱ្យអនុវត្តតាមច្បាប់នោះជាដាច់ខាតតែម្តង ដោយមិនឱ្យអនុវត្តតាមច្បាប់ទូទៅនោះទេបានន័យថាចែងជាពិសេសដោយបទប្បញ្ញត្តិទៅនឹងគោលការណ៍នៃច្បាប់ទូទៅតែម្តង។

បើសន្និដ្ឋានអំពីក្រមព្រហ្មទណ្ឌនេះ គឺជាច្បាប់មូលដ្ឋាន ឬជាច្បាប់គ្រឹះ និងរួមផ្សំជាមួយក្រមនីតិវិធីព្រហ្មទណ្ឌ ដែលត្រូវបានប្រកាសឱ្យប្រើកាលពីឆ្នាំ២០០៧ កន្លងទៅនេះ គឺបង្កើតបានជាឧបករណ៍គតិយុត្តជាមូលដ្ឋានសម្រាប់ដំណើរការរឿងក្តីព្រហ្មទណ្ឌ ក៏ដូចជាសម្រាប់តុលាការព្រហ្មទណ្ឌនៅក្នុងនីតិវិធីនៃដំណើរការក្នុងការផ្តល់យុត្តិធម៌ព្រហ្មទណ្ឌ ជូនឱ្យបានដល់ប្រជាពលរដ្ឋកម្ពុជា។ យោងតាមន័យនេះ ច្បាប់ព្រហ្មទណ្ឌមានសារៈសំខាន់ខ្លាំងណាស់សម្រាប់កំណត់អំពីអត្ថិភាព នៃបទល្មើសពីព្រោះថានៅក្នុងសង្គមប្រជាធិបតេយ្យក៏ដូចជាសង្គមនីតិរដ្ឋ គេត្រូវកំណត់ជាមុនតាមផ្លូវច្បាប់នូវអំពើមួយចំនួនដែលច្បាប់បានចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌ និងត្រូវមានការផ្តន្ទាទោស។ ដើម្បីឱ្យប្រជាពលរដ្ឋបានដឹងថាមុននូវអំពើដែលច្បាប់បានហាមឃាត់ក៏ដូចជាគោលការណ៍អភិបាលកិច្ចល្អផងដែរ។

## ផ្នែកទី២ ៖ ការអនុវត្តច្បាប់ព្រហ្មទណ្ឌ

នៅក្នុងផ្នែកនេះ យើងខ្ញុំនឹងបកស្រាយពីការអនុវត្តច្បាប់ព្រហ្មទណ្ឌ តាមរយៈចំណុចទាំងនេះ **២.១. ការអនុវត្តច្បាប់ព្រហ្មទណ្ឌ ឬក្រមព្រហ្មទណ្ឌខ្មែរឆ្នាំ២០០៩ និង ២.២. ការបាត់បង់អានុភាពនៃច្បាប់ និងបទប្បញ្ញត្តិព្រហ្មទណ្ឌពីមុន។**

### ២.១. ការអនុវត្តច្បាប់ព្រហ្មទណ្ឌ ឬក្រមព្រហ្មទណ្ឌខ្មែរថ្មីឆ្នាំ២០០៩

អនុលោមតាមអានុភាពនៃបទប្បញ្ញត្តិមាត្រា ៩៣ ថ្មី នៃរដ្ឋធម្មនុញ្ញខ្មែរឆ្នាំ ១៩៩៣ និងយោងតាមអានុភាព នៃ បទប្បញ្ញត្តិមាត្រា ៦៧២ (ការអនុវត្តក្រមនេះ) នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ព្រមទាំងផ្អែកទៅតាមមាត្រា ៥៧ (ការអនុវត្តច្បាប់) នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយឆ្នាំ ២០១០ ក៏ដូចជា មាត្រាមួយ កថាខណ្ឌចុងក្រោយគេ និងមាត្រាពីរ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយឆ្នាំ២០១១ បានធ្វើឱ្យក្រមព្រហ្មទណ្ឌថ្មី នៃព្រះរាជាណាចក្រកម្ពុជាយើងត្រូវបានអនុវត្តតាម ៤ ដំណាក់កាល ៖

❖ <u>ដំណាក់កាលទី១</u>

- រាជធានីភ្នំពេញ = ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩
- ទូទាំងប្រទេស = ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩

(អនុវត្តសម្រាប់គន្ថីទី១ គឺ មាត្រា ១ ដល់ មាត្រា ១៨២ នេះគឺយោងតាមមាត្រា ៦៧២ នៃក្រមព្រហ្មទណ្ឌ)

❖ <u>ដំណាក់កាលទី២</u>

- រាជធានីភ្នំពេញ = ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១០
- ទូទាំងប្រទេស = ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១០

(អនុវត្តសម្រាប់គន្ថីទី២ ទី៣ ទី៤.... "មាត្រា ៦៧២ នៃក្រមព្រហ្មទណ្ឌ" តែត្រូវដកចេញនូវ បទល្មើសពុករលួយ ចេញសិននេះ គឺផ្អែកតាម មាត្រា ៥៧ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ)

❖ <u>ដំណាក់កាលទី៣</u>

- រាជធានីភ្នំពេញ = ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១១
- ទូទាំងប្រទេស = ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១

(យោងតាម "មាត្រា ៥៧ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ" ត្រូវពន្យារ ១២ ខែទៀត ដូច្នេះអាចយល់ច្រឡំថា ដល់ថ្ងៃខែឆ្នាំនៃ ដំណាក់កាលទី៣ គឺត្រូវអនុវត្តក្រមថ្មីនេះទាំងស្រុង)

❖ <u>ដំណាក់កាលទី៤</u>

- រាជធានីភ្នំពេញ = ថ្ងៃទី២ ខែសីហា ឆ្នាំ២០១១
- ទូទាំងប្រទេស = ថ្ងៃទី២ ខែសីហា ឆ្នាំ២០១១

សរុបមកក្រមព្រហ្មទណ្ឌថ្មីឆ្នាំ ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា គឺត្រូវអនុវត្តពេញលេញទាំងស្រុង ទាំងនៅរាជធានីភ្នំពេញ និងនៅទូទាំងប្រទេសគឺ **ថ្ងៃទី២ ខែសីហា ឆ្នាំ២០១១** ពីព្រោះកម្ពុជាមានច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយចុះថ្ងៃទី១ ខែសីហា ឆ្នាំ២០១១ ថ្មីមួយដែលមានចែងចំនួនពីរមាត្រា។ បើផ្អែកតាមមាត្រាមួយ កថាខណ្ឌចុងក្រោយ គឺបានលុបចោលនៅមាត្រា ៥៧ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយបាត់ទៅហើយ បានន័យថាឈប់ពន្យាររយៈពេល ១២ ខែ រហូតដល់ថ្ងៃខែឆ្នាំក្នុងដំណាក់កាលទី ៣ នោះទៀតហើយ។ ម៉្យាងដោយសារតែច្បាប់នេះ នៅក្នុងមាត្រាពីរបានប្រកាសថាជាការប្រញាប់[១៩] នោះទើបយើងត្រូវលើកយកមាត្រា ៩៣ ថ្មី នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មកប្រើ។ អនុលោមតាមអានុភាពនៃមាត្រា ៩៣ ថ្មីនេះ ទើបបានជាលទ្ធផលចុងក្រោយធ្វើឱ្យយើងទាំងអស់គ្នាឃើញថា ក្រមព្រហ្មទណ្ឌថ្មី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានអនុវត្តពេញលេញទាំងស្រុងដូចក្នុងករណីទី ៤ រួមទាំងបទល្មើសពុករលួយនិង ទោសផងដែរ។

## ២.២. ការបាត់បង់អានុភាពនៃច្បាប់និងបទប្បញ្ញត្តិព្រហ្មទណ្ឌពីមុន

យោងតាមមាត្រា ៦៧១ នៃក្រមព្រហ្មទណ្ឌ យើងឃើញច្បាស់ថាមានចែងនៅពាក្យ "និរាករណ៍និងអានុភាពនៃបទប្បញ្ញត្តិព្រហ្មទណ្ឌពីមុន" ពិតមែនក៏ប៉ុន្តែ មិនមែនមានន័យថាជាការនិរាករណ៍នូវច្បាប់ព្រហ្មទណ្ឌចាស់ៗពីមុននោះទេ គឺគ្រាន់តែត្រូវបាត់បង់អានុភាពចាប់ពីថ្ងៃដែលក្រមព្រហ្មទណ្ឌថ្មីត្រូវបានអនុវត្តតែប៉ុណ្ណោះ ចំណែកឯឈ្មោះថាជាច្បាប់នៅតែ ជាច្បាប់ដដែល។

ក្រមព្រហ្មទណ្ឌចាប់ពី មាត្រា ១ ដល់ មាត្រា ៦៧២ មិនមានបទប្បញ្ញត្តិណាមួយដែលចែងអំពីនិរាករណ៍នៃច្បាប់ព្រហ្មទណ្ឌពីមុននោះទេ មានន័យថាគ្មានបទប្បញ្ញត្តិណាមួយ ដែលចែងអំពីការធ្វើនិរាករណ៍នូវរាល់បទប្បញ្ញត្តិព្រហ្មទណ្ឌមុនឆ្នាំ ១៩៩២ និងច្បាប់ព្រហ្មទណ្ឌអន្តរកាល ក៏ដូចជាច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋឡើយ ដែលចំណុចនេះ យើងត្រូវតែបញ្ជាក់ជាមួយគ្នាឱ្យបានច្បាស់លាស់ ។

ប៉ុន្តែសូមបញ្ជាក់ជូនថា រាល់បទប្បញ្ញត្តិព្រហ្មទណ្ឌមុនឆ្នាំ ១៩៩២ និងច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល ក៏ដូចជាច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ គឺត្រូវបាត់បង់អានុភាពរបស់វានៅពេលដែលក្រមព្រហ្មទណ្ឌត្រូវបានយកទៅអនុវត្ត។ បើយើងគិតមើលអំពីស្ថានភាពទាំងនេះថា មូលហេតុអ្វីបានជាកើតមានរឿងដូច្នេះ? គឺការកំណត់នៅក្នុងក្រមព្រហ្មទណ្ឌជាពិសេសក្នុងបទប្បញ្ញត្តិនៃមាត្រា ៦៧១ បានចែងអស់ហើយអំពីបញ្ហានេះដោយបានបញ្ជាក់ថា បទប្បញ្ញត្តិមុនៗទាំងអស់នឹងត្រូវបាត់បង់អានុភាពត្រឹមកម្រិតណាដែលផ្ទុយជាមួយក្រមព្រហ្មទណ្ឌ មានន័យថានៅពេលដែលក្រមព្រហ្មទណ្ឌខ្មែរថ្មីនេះមានអានុភាព គឺរាល់ច្បាប់ផ្សេងៗ ពីមុនៗទៀតអត់មានអានុភាពទេ។ អញ្ចឹងហើយបានជាត្រូវបញ្ជាក់គ្នាលើបញ្ហានេះឱ្យបានច្បាស់លាស់ថាក្រុម

[១៩] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៣៦/០០២/២០០០ កបធ.ច ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០០

ការងារគាត់តែងសេចក្ដីព្រាងច្បាប់ស្ដីពីក្រមព្រហ្មទណ្ឌនេះមិនបានចែងអំពី **ការនិរាករណ៍នូវច្បាប់ព្រហ្មទណ្ឌពីមុននោះទេ** ប៉ុន្តែពួកគាត់គ្រាន់តែចែងឱ្យច្បាប់ពីមុនៗបាត់បង់នូវអានុភាពអនុវត្តតែប៉ុណ្ណោះ។ តែផ្ទុយទៅវិញ ប្រសិនបើជាមិនបានចែងឱ្យច្បាប់មុនៗបាត់បង់អានុភាពទេនោះ មកដល់ថ្ងៃនេះ គឺរាល់បទប្បញ្ញត្តិព្រហ្មទណ្ឌមុនឆ្នាំ ១៩៩២ និងច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាលក៏ដូចជា ច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋនៅតែមានអានុភាពដដែល។ ហើយបើច្បាប់ទាំងនេះនៅមានអានុភាពដដែល ដូច្នេះនៅពេលដែលមានអង្គហេតុមួយកើតឡើងនៅថ្ងៃនេះ ពេលនោះអង្គហេតុហ្នឹង នឹងត្រូវគ្រប់គ្រងដោយច្បាប់នោះផង ហើយត្រូវគ្រប់គ្រងដោយក្រមព្រហ្មទណ្ឌផងដែរ។ ហេតុនេះនៅពេលមានច្បាប់ចំនួនពីរ ដែលត្រូវយកទៅអនុវត្តចំពោះអង្គហេតុតែមួយ បើយោងតាមគោលការណ៍ ដែលមានចែងនៅក្នុងក្រមគឺត្រូវយកនូវច្បាប់ដែលស្រាលជាងមកអនុវត្តរហូត។ ករណីនេះបើក្រមព្រហ្មទណ្ឌមានចែងនូវ ទោសធ្ងន់ជាង គឺមិនអាចយកក្រមព្រហ្មទណ្ឌថ្មីទៅអនុវត្តបានជារៀងរហូត ។

ដូច្នេះមានសំណួរចោទថា តើបង្កើតក្រមព្រហ្មទណ្ឌថ្មីនេះមកបានប្រយោជន៍អ្វី បើយកទៅប្រើមិនកើតផងនោះ?

ហេតុដូច្នេះ ដើម្បីជៀសវាងកុំឱ្យមានស្ថានភាពបែបនេះកើតឡើងទៀតទើប មាត្រា ៦៧១ នៃក្រមព្រហ្មទណ្ឌបានលុបបំបាត់ចោលនូវអានុភាពនៃច្បាប់ព្រហ្មទណ្ឌចាស់ៗ ត្រឹមទំហំដែលផ្ទុយជាមួយក្រមថ្មីនេះចាប់ពីពេលដែលក្រមថ្មីនេះត្រូវបានអនុវត្តនៅទូទាំងប្រទេស។ យើងមិនអាចចែងនូវការនិរាករណ៍បានទេ ពីព្រោះបើសិនជាយើងពិនិត្យនៅក្នុងទិដ្ឋភាពច្បាប់ឱ្យបានគ្រប់ជ្រុងជ្រោយ ស្ដីពីការធ្វើនិរាករណ៍អំពីច្បាប់ព្រហ្មទណ្ឌមួយនឹងមានផល ឬបច្ច័យផ្នែកច្បាប់នោះធ្ងន់ធ្ងរខ្លាំងណាស់ ឬក៏បច្ច័យគតិយុត្តនោះ គឺធ្ងន់ធ្ងរតែម្ដង ៖

**ចំណុចទី១ ៖** បទល្មើសចាស់ៗនេះ ដែលយើងត្រូវយកច្បាប់ចាស់ទៅប្រើជាមួយវា ប្រសិនបើច្បាប់ចាស់នោះស្រាលជាង ហើយយកមកចាត់ការក្រោយច្បាប់ថ្មីកំពុងតែអនុវត្ត ក៏ប៉ុន្តែដោយសារតែបទល្មើសកើតមានពីមុនហើយច្បាប់ចាស់នោះផ្ដន្ទាទោសស្រាលជាង ដូច្នេះត្រូវផ្ដន្ទាទោសដោយបន្តអនុវត្តច្បាប់ចាស់។ ផ្ទុយទៅវិញនៅពេលដែលយើងនិរាករណ៍ច្បាប់ចាស់នោះបាត់ទៅហើយ គឺគ្មានចៅក្រមណាហ៊ានយកច្បាប់ចាស់ដែលនិរាករណ៍មកធ្វើជាមូលដ្ឋានសម្រាប់ សំអាងក្នុងការសម្រេចសេចក្ដីដើម្បីផ្ដន្ទាទោសបាននោះទេ។

**ចំណុចទី២ ៖** បើយើងពិនិត្យមើលឱ្យបានគ្រប់ជ្រុងជ្រោយ គ្រប់ច្បាប់ទាំងអស់ជាពិសេសនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌត្រង់បទប្បញ្ញត្តិនៃមាត្រា ៧ បានចែងអំពី ការរលត់នៃបណ្ដឹងអាជ្ញា ដែលក្នុងមូលហេតុទាំង ៥ ចំណុចនៃការរលត់នៃបណ្ដឹងអាជ្ញាគឺចំណុចទី ៤ (បួន) យើងឃើញថាក៏មានចែងនូវ "និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ" ផងដែរ។ ប្រសិនបើបណ្ដឹងអាជ្ញាត្រូវបានរលត់ពិតមែន មានន័យថាការចោទប្រកាន់លែងអាចធ្វើទៅទៀតបានហើយ និងប្រសិនបើតុលាការកំពុងតែចាត់ការ លើសំណុំរឿង

មួយដែលបណ្ដឹងអាជ្ញាបានរលត់ទៅហើយនោះ ដូច្នេះចំណាត់ការរបស់តុលាការក៏ត្រូវតែបញ្ឈប់ផងដែរ និងបច្ច័យអាក្រក់ដ៏ធំមួយទៀតគឺទាក់ទងនឹងបញ្ហានៅពេលដែល យើងបានលុបចោលបទល្មើស មានន័យថា ការផ្ដន្ទាទោស ចំពោះបទល្មើសនោះពីមុនមកត្រូវបញ្ចប់ រីឯទណ្ឌិតកំពុងតែអនុវត្តទោសនៅក្នុងពន្ធនាគារទាំងនោះក៏ត្រូវដោះលែងវិញផងដែរ។ ដូចនេះបច្ច័យគតិយុត្តរបស់វាពិតជាអាក្រក់ខ្លាំងណាស់ ព្រោះថាវានឹងធ្វើឱ្យសង្គមបាត់សណ្ដាប់ធ្នាប់សាធារណៈ។ អាស្រ័យហេតុនេះហើយ បានជាគេមិនចែងឱ្យធ្វើការនិរាករណ៍នូវច្បាប់ព្រហ្មទណ្ឌចាស់នោះ[១៥]។

ចំពោះកថាខណ្ឌទី ៣ បានចែងថា "ប៉ុន្តែបទប្បញ្ញត្តិព្រហ្មទណ្ឌពីមុនដែលកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើត្រូវបន្តមានអានុភាពអនុវត្តក្រោយការអនុវត្តនៃក្រមនេះ ចំពោះបទល្មើសដែលត្រូវបានប្រព្រឹត្ត មុនពេលក្រមនេះត្រូវបានអនុវត្ត លើកលែងតែបទប្បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៦៦៨ (ការអនុវត្តបទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែក) នៃក្រមនេះ"។ កថាខណ្ឌនេះគឺបានបង្កប់នូវ **គោលការណ៍នៃការបន្តរស់របស់ច្បាប់ព្រហ្មទណ្ឌចាស់នៅក្នុងអានុភាពនៃច្បាប់ព្រហ្មទណ្ឌថ្មី** និងពាក់ព័ន្ធគ្នាទៅនឹងមាត្រា ១០ កថាខណ្ឌទី ២ នៃក្រមនេះ ដែលយើងត្រូវកត់សម្គាល់នូវមាត្រាក្រោយថា "បទប្បញ្ញត្តិថ្មី ដែលចែងអំពីទោសធ្ងន់ជាង នឹងត្រូវអនុវត្តតែទៅលើអំពើដែលបានប្រព្រឹត្តក្រោយការចូលជាធរមាននៃបទប្បញ្ញត្តិនោះ" ហេតុនេះប្រសិនបើបទល្មើសមួយប្រព្រឹត្តមុនពេលក្រមនេះត្រូវបានអនុវត្ត បានន័យថាក្រមថ្មីនេះមិនទាន់យកទៅប្រើនោះទេ គឺត្រូវបន្តយកច្បាប់ចាស់ៗនោះមកប្រើដដែល ឬឱ្យច្បាប់ចាស់នោះនៅរស់សិន។ ម្យ៉ាងទៀតនៅពេលដែលកំពុងដំណើរការនីតិវិធីរបស់តុលាការក៏ស្រាប់តែដល់ថ្ងៃក្រមថ្មីនេះមានអានុភាពអនុវត្តផងដែរ ដូច្នេះបើច្បាប់ចាស់មានទោសស្រាលជាង គឺចៅក្រមត្រូវយកច្បាប់ចាស់មកអនុវត្តដដែល។ ចំណែកឯក្រមថ្មីដែលមានទោសធ្ងន់ជាង គឺត្រូវអនុវត្តតែចំពោះបទល្មើសប្រព្រឹត្តនៅក្រោយពេលក្រមថ្មីនេះមានអានុភាពអនុវត្តតែប៉ុណ្ណោះ នេះបើអនុលោមតាមអានុភាពនៃមាត្រា ១០ កថាខណ្ឌទី ២ នៃក្រមព្រហ្មទណ្ឌ។ ផ្ទុយទៅវិញបើច្បាប់ថ្មីមានទោសស្រាលជាងវិញ គឺត្រូវអនុវត្តភ្លាមតែម្ដងដោយមិនប្រើ ច្បាប់ចាស់ធ្ងន់ជាងនោះទៀតទេ នេះគឺដើម្បីគោរពគោលការណ៍មនុស្សធម៌។

[១៥] ប្រសាសន៍របស់ ឯកឧត្តម កើត រិទ្ធ អនុប្រធានក្រុមការងារចូលរួមតាក់តែង និងការពារសេចក្ដីព្រាងក្រមព្រហ្មទណ្ឌ នាកាលបង្រៀនដល់អ្នករៀបរៀង នៅសាលាមធ្យមសិក្សាគរុកោសល្យ មត្តេយ្យមជ្ឈិម ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១។

# ជំពូកទី២
# គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ

# ជំពូកទី២
# គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ

មុននឹងឈានទៅរកការបកស្រាយអំពីគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ជាដំបូងយើងគប្បីត្រូវដឹងអំពីគោលការនៃការអនុវត្តច្បាប់ជាមុនសិន។ ការអនុវត្តច្បាប់ព្រហ្មទណ្ឌត្រូវគោរពគោលការណ៍ ២ គឺគោលការណ៍ប្រតិសកម្ម និងគោលការណ៍មិនប្រតិសកម្ម។ គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ គឺជាគោលការណ៍គ្រឹះនៃនីតិព្រហ្មទណ្ឌ ជាបន្តយើងខ្ញុំនឹងបង្ហាញលម្អិតអំពីគោលការណ៍នេះ **ផ្នែកទី១ អត្ថន័យនៃគោលការណ៍មិនប្រតិសកម្ម និង ផ្នែកទី២ គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌដែលធ្ងន់ជាង។**

## ផ្នែកទី១ ៖ អត្ថន័យនៃគោលការណ៍មិនប្រតិសកម្ម

គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌមានអត្ថន័យថា ច្បាប់ដែលចូលជាធរមាននៅថ្ងៃណាមួយជាកំណត់ គឺជាទូទៅពុំមានអានុភាពគ្រប់គ្រងស្ថានភាពទាំងឡាយណា ដែលបានកើតឡើងមុនពេលច្បាប់ចូលជាធរមានឡើយ។ គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌមានគោលបំណងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ក្នុងការធ្វើសកម្មភាពផ្សេងៗ ដែលច្បាប់នៅខណៈពេលនោះពុំបានចាត់ទុកថាជាបទល្មើសទេ។ ទោះបីជាថ្ងៃក្រោយមកទៀត ស្រាប់តែមានច្បាប់កំណត់ថា អំពើដដែលជាបទល្មើសក៏ដោយ ក៏ចារីដែលបានប្រព្រឹត្តអំពើល្មើសពុំចាំបាច់ភ័យខ្លាចឡើយ ពីព្រោះថាច្បាប់ដែលទើបតែបានចូលជាធរមានត្រូវមានអានុភាពអនុវត្តតែទៅលើសកម្មភាពដែលកើតឡើង ចាប់ពីថ្ងៃដែលច្បាប់ចូលជាធរមានតែប៉ុណ្ណោះ។

បើតាមទ្រឹស្តីផ្សេងទៀតបានចែងថា គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ជាវិធានគតិយុត្តដែលកំណត់ថាច្បាប់ព្រហ្មទណ្ឌមានលក្ខណៈធ្ងន់ធ្ងរជាង មិនត្រូវយកទៅអនុវត្តលើអំពើណាមួយ ដែលបានកើតមុនពេលច្បាប់នេះចូលជាធរមាននោះទេ។ គោលការណ៍មិនប្រតិសកម្មជាគោលការណ៍ច្បាប់ព្រហ្មទណ្ឌ ពុំអាចចោទប្រកាន់ចំពោះអំពើទាំងឡាយណា ដែលកើតមានឡើងនៅមុនពេលដែលច្បាប់ព្រហ្មទណ្ឌចូលជាធរមានដើម្បីកំណត់ប្រភេទគតិយុត្ត ជាបទល្មើសព្រហ្មទណ្ឌបានឡើយ។

គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ មានចែងនៅក្នុងបញ្ញត្តិមាត្រា ១០ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌថា "បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសធ្ងន់ជាងនឹងត្រូវអនុវត្តតែទៅលើអំពើដែលបានប្រព្រឹត្ត ក្រោយការចូលជាធរមាននៃបទប្បញ្ញត្តិនោះ"។

ដើម្បីឈ្វេងយល់ឱ្យកាន់តែស៊ីជម្រៅអំពីគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ យើងចាំបាច់ត្រូវសិក្សាពីការអនុវត្តគោលការណ៍នេះ ទៅលើច្បាប់ព្រហ្មទណ្ឌគ្រឹះ ឬច្បាប់សារធាតុ និងច្បាប់ព្រហ្មទណ្ឌទម្រង់ ឬច្បាប់នីតិវិធីព្រហ្មទណ្ឌ ៖

- ច្បាប់ព្រហ្មទណ្ឌគ្រឹះ ឬច្បាប់សារធាតុ គឺជាច្បាប់ដែលកំណត់អំពីបទល្មើស និងអំពីទោសដែលត្រូវអនុវត្តលើបទល្មើស ព្រមទាំងលក្ខខណ្ឌនៃការទទួលខុសត្រូវរបស់ចារី។ ច្បាប់ព្រហ្មទណ្ឌគ្រឹះ ឬច្បាប់សារធាតុ សំដៅលើច្បាប់ព្រហ្មទណ្ឌជាតិ និងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដែលមានអានុភាពអនុវត្តនៅក្នុងប្រទេសកម្ពុជា។
- ច្បាប់ព្រហ្មទណ្ឌទម្រង់ ឬច្បាប់នីតិវិធី គឺជាច្បាប់ ដែលពាក់ព័ន្ធទៅនឹងការរៀបចំប្រព័ន្ធតុលាការ សមត្ថកិច្ចតុលាការ ការស៊ើបអង្កេត ការស៊ើបសួរ ការជំនុំជម្រះ ផ្លូវនៃបណ្តឹង ឬផ្លូវតវ៉ា ការអនុវត្តទោស អាជ្ញាយុកាលនៃបណ្តឹងអាជ្ញា និងអាជ្ញាយុកាលនៃទោស។ល។ បើផ្អែកតាមគោលការណ៍ទូទៅ ក៏ដូចជាបទប្បញ្ញត្តិនៃមាត្រា ៦១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនេះដែរ ច្បាប់ទម្រង់ ឬច្បាប់នីតិវិធីត្រូវអនុវត្តភ្លាមៗពេលគឺគេត្រូវអនុវត្តច្បាប់ទម្រង់ ឬច្បាប់នីតិវិធីភ្លាមចាប់ពីពេលដែលច្បាប់នេះចូលជាធរមាន រួមបញ្ចូលទាំងបទល្មើសដែលបានប្រព្រឹត្តមុនពេលច្បាប់នេះចូលជាធរមានក៏ដោយ ហើយទោះបីជាច្បាប់ថ្មីអាចមានលក្ខណៈធ្ងន់ធ្ងរជាងច្បាប់មុនក៏ដោយ។ ទោះជាយ៉ាងណាក្តី ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ[១៦] បានចែងយ៉ាងច្បាស់ថាការអនុវត្តភ្លាមៗនៃច្បាប់ទម្រង់ ឬច្បាប់នីតិវិធីពុំធ្វើឱ្យប៉ះពាល់ដល់សុពលភាព នៃកិច្ចនីតិវិធីទាំងឡាយដែលត្រូវបានបំពេញរួចរាល់ និងស្របទៅតាមបទប្បញ្ញត្តិនៃច្បាប់ចាស់នោះឡើយ។ ដើម្បីដឹងគោលការណ៍ខាងលើនេះឱ្យកាន់តែច្បាស់ យើងត្រូវដឹងអំពី ៖ **១.១. សញ្ញាណនៃគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ និង ១.២. ការអនុវត្តគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ។**

### ១.១. សញ្ញាណនៃគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ

សញ្ញាណនៃគោលការណ៍នេះចេញមកពីបារាំង ដែលកើតមានតាំងតែពីឆ្នាំ១៧៨៩ នៅក្នុងសេចក្តីថ្លែងការណ៍ស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិមនុស្ស នៅក្នុងលិទ្ធិប្រជាធិបតេយ្យ ដើម្បីធានានូវសិទ្ធិសេរីភាព និងសុវត្ថិភាពគតិយុត្តិរបស់ពលរដ្ឋ បន្ថែមពីនេះទៅទៀតនោះ វាគឺជាគោលការណ៍មួយដែលសម្រាប់ការពារ ការសងសឹកគ្នារវាង គណបក្សនយោបាយ និងគណបក្សនយោបាយ ដែលការពារមិនឱ្យអ្នកដែលឡើងកាន់អំណាចក្រោយសងសឹកទៅលើអ្នកកាន់អំណាចមុនដែលបាត់បង់អំណាច។

[១៦] មាត្រា ១១ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ចែងថា ការអនុវត្តភ្លាមៗនៃបទប្បញ្ញត្តិថ្មីគ្មានអានុភាពទៅលើសុពលភាព នៃកិច្ចនីតិវិធីដែលបានបំពេញស្របតាមបទប្បញ្ញត្តិច្បាប់ចាស់ឡើយ។ ដូចគ្នាដែរ មាត្រា ៦១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិថា ក្រមនេះត្រូវអនុវត្តភ្លាមចំពោះគ្រប់កិច្ចនីតិវិធីក្រោយក្រមនេះចូលជាធរមាន។ ការអនុវត្តភ្លាមនូវបទប្បញ្ញត្តិនៃក្រមនេះពុំមានអានុភាពលើសុពលភាពនៃកិច្ចនីតិវិធីទាំងឡាយដែលត្រូវបំពេញរួចរាល់ហើយ ដោយអនុលោមតាមច្បាប់ចាស់ឡើយ។

### ១.២. ការអនុវត្តគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ

គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ គឺជាគោលការណ៍វិបាកកម្ម ដែលដើរទន្ទឹមគ្នាជាមួយនឹងគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងទោស។ គោលការណ៍នេះមានន័យថាច្បាប់ព្រហ្មទណ្ឌគឺមានអានុភាពអនុវត្តសម្រាប់តែឆ្ពោះទៅអនាគតប៉ុណ្ណោះ គឺមិនមានអានុភាពអនុវត្តទៅលើអំពើទាំងឡាយណាដែលបានប្រព្រឹត្តនាអតីតកាលនោះទេ។ ហេតុដូច្នេះបានន័យថា យើងមិនអាចយកច្បាប់ព្រហ្មទណ្ឌនេះទៅអនុវត្តចំពោះអំពើដែលបានកើតឡើង រួមទាំងទោសដែលបានប្រកាស ឬអនុវត្តមុនច្បាប់នេះចូលជាធរមាននោះទេ[១៧] ហើយគោលការណ៍នេះគឺជាផ្នែកទាំងស្រុងទៅលើគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងទោស[១៨]។ ដោយសារថាគោលការណ៍នេះគឺជាគោលការណ៍គ្រឹះ ហើយក៏ជាគោលការណ៍ចម្បង ម្លេះហើយរាល់អត្ថបទច្បាប់ព្រហ្មទណ្ឌដែលចែងមកក្នុងការកំណត់ពីបទល្មើស និងទោស គឺដាច់ខាតត្រូវតែស្របតាមជានិច្ច។ ក្នុងការអនុវត្តនូវគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌនេះ គឺប្រៀបដូចទៅនឹងនិយមន័យនៃច្បាប់ព្រហ្មទណ្ឌផងដែរ ដោយសារថាគោលការណ៍នេះក៏កំណត់ពីបទល្មើស និងទោសផងដែរ ហើយគោលការណ៍នេះរួមមាន ៖ **១.២.១. គោលការណ៍មិនប្រតិសកម្មចំពោះបទល្មើស និង ១.២.២. គោលការណ៍មិនប្រតិសកម្មចំពោះទោស។**

#### ១.២.១. គោលការណ៍មិនប្រតិសកម្មចំពោះបទល្មើស

អ្វីទៅជាភាពមិនប្រតិសកម្មទៅលើបទល្មើស? ជាការពិតណាស់ច្បាប់មួយ អាចយកទៅអនុវត្តបានលុះត្រាតែអត្ថបទច្បាប់នោះចូលជាធរមាន ១០ (ដប់)ថ្ងៃ នៅរាជធានីភ្នំពេញ និងខេត្តកណ្តាល ក្រោយថ្ងៃប្រកាសឱ្យប្រើ ចំពោះនៅតាមបណ្តាលខេត្តត្រូវចូលជាធរមាន ២០ (ម្ភៃ)ថ្ងៃ បន្ទាប់ពីប្រកាសឱ្យប្រើនូវច្បាប់នោះ។ ប៉ុន្តែបើកាលណាអត្ថបទច្បាប់នោះត្រូវបានប្រកាសឱ្យប្រើជាការប្រញាប់ គឺត្រូវតែចូលជាធរមានភ្លាមៗ ក្រោយថ្ងៃប្រកាសឱ្យប្រើ[១៩]។ បើតាមន័យនេះយើងអាចកំណត់បានថា អំពើណាមួយដែលបង្កើតបានជាបទល្មើសអាចយកមកអនុវត្តទៅជនល្មើសបាន លុះត្រាតែអំពើទាំងនោះត្រូវបានប្រព្រឹត្តក្រោយការប្រកាសឱ្យប្រើនៃច្បាប់នេះតែប៉ុណ្ណោះ។ ដូច្នេះយើងមិនអាចយកមកអនុវត្តទៅលើអំពើណាដែលបានបង្កជាចលាចលដល់សង្គមមុនការប្រកាសឱ្យប្រើនូវច្បាប់នេះបាននោះឡើយ។

តើអ្វីទៅជាអំពើដែលកើតមុនច្បាប់ថ្មីចូលជាធរមាន? ពិតណាស់អំពើនីមួយៗ តែងតែកើតមានឡើងជារៀងរាល់ថ្ងៃ ហើយជួនកាលអំពើទាំងនោះកើតមានឡើងនៅមុនអត្ថបទច្បាប់ថ្មីចូលជាធរមាន ខ្លះទៀតកើតឡើង

---

[១៧] ប្រសាសន៍របស់ ឯកឧត្តម ផូវ សំភី អនុប្រធានក្រុមការងារចូលរួមតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌សាហការជាមួយក្រសួងព័ត៌មាន តាមរយៈទូរទស្សន៍ជាតិកម្ពុជាឆ្នាំ២០១០។

[១៨] មាត្រា ៣ នៃក្រមព្រហ្មទណ្ឌចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា។

[១៩] មាត្រា ៩៣ ថ្មីនៃរដ្ឋធម្មនុញ្ញ របស់ព្រះរាជាណាចក្រកម្ពុជា។

នៅថ្ងៃចូលជាធរមាន និងខ្លះទៀតកើតឡើងក្រោយថ្ងៃចូលជាធរមាននៃច្បាប់ថ្មីៗ ដែលកំណត់ពីបទល្មើសណាមួយ។ ហេតុនេះអំពើដែលកើតមុនការចូលជាធរមាននៃច្បាប់រួមមាន ៖ **ក. បទល្មើសភ្លាមៗ ខ. បទល្មើសបន្តជាហូរហែ គ. បទល្មើសអូសបន្លាយ និង ឃ. បទល្មើសប្រព្រឹត្តជាទម្លាប់។**

**ក. បទល្មើសភ្លាមៗ**

បទល្មើសភ្លាមៗ គឺជាបទល្មើសដែលកើតឡើងតែមួយភ្លែតបានន័យថា បទល្មើសដែលកើតមានឡើងក្នុងពេលតែមួយជាមួយនឹងអំពើប្រព្រឹត្ត។ យើងអាចនិយាយបានម៉្យាងទៀតថា ការសម្រេចនូវបទល្មើសភ្លាមៗបានកើតឡើងហើយក៏បញ្ចប់ទៅវិញភ្លាមៗដែរ។

<u>ឧទាហរណ៍</u> ៖

- **បទឃាតកម្ម** ជាបទល្មើសភ្លាមៗ ព្រោះថានៅពេលណាដែលជនល្មើសបានប្រើនូវគ្រប់មធ្យោបាយទុច្ចរិតដោយចេតនាទោះជាមានអាវុធក្តី ឬដោយគ្មានអាវុធក្តីដើម្បីផ្តាច់នូវជីវិតរបស់ជនរងគ្រោះ[២០]។
- **បទលួច** រាល់អំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬវត្ថុផ្សេងទៀតរបស់អ្នកដទៃតាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធខ្លួន[២១]។

**ខ. បទល្មើសបន្តជាហូរហែ**

បទល្មើសបន្តជាហូរហែ ជាបទល្មើសដែលផ្ទុយពីបទល្មើសភ្លាមៗត្រង់ថា បទល្មើសនេះមានអំពើជាសម្ភារៈប្រព្រឹត្តឡើងបន្តគ្នាជាហូរហែ និងស៊ីសង្វាក់គ្នាក្នុងពេលវេលា។ នេះបានសេចក្តីថា បទល្មើសបន្តជាហូរហែ ជាបទល្មើសត្រូវបានប្រព្រឹត្តឡើងជាបន្តបន្ទាប់គ្នា ក្នុងរយៈពេលមួយដែលបង្ហាញឱ្យឃើញនូវចេតនាទុច្ចរិតដែលស្ថិតនៅជាដរាប ឬទាមទាររយៈពេលជាក់លាក់ណាមួយដើម្បីសម្រេចបទល្មើស។

<u>ឧទាហរណ៍</u> ៖

- **បទទទួលផលចោរកម្ម** គេចាត់ថាជាបទល្មើសបន្តជាហូរហែដោយសារអំពើនេះបានកើតឡើងជាបន្តបន្ទាប់ជាប់គ្នាជារហូត ឥតដាច់ពីមួយទៅមួយដែលទទួលបានតាមរយៈអំពើទុច្ចរិតនៃអំពើលួច[២២]។
- **បទស្តាប់ ឬថតសំដីឯកជន** ជាបទល្មើសបន្តជាហូរហែ ដោយសារថាការថតពាក្យសំដីរបស់អ្នកដទៃនេះ ធ្វើឡើងដោយទាមទារពេលវេលាទោះខ្លី ឬច្រើនក៏ដោយដើម្បីសម្រេចបទល្មើស[២៣]។

[២០] មាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ របស់ព្រះរាជាណាចក្រកម្ពុជា។

[២១] មាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា។

[២២] មាត្រា ៣៩៩ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា។

[២៣] មាត្រា ៣០១ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា។

### គ. បទល្មើសអូសបន្លាយ

បទល្មើសអូសបន្លាយ ជាបទល្មើសដែលបង្កគ្រោះថ្នាក់ដល់សង្គមស្តែងឡើងជាប់ជាហូរហែគ្មានអាក់ខានក្នុងរយៈពេលណាមួយឡើយ។ និយាយម្យ៉ាងទៀត បទល្មើសអូសបន្លាយ សំដៅដល់បទល្មើសដែលបង្កើតឡើងដោយបណ្តាលអំពើជាច្រើនប្រហាក់ប្រហែលគ្នាជាច្រើននេះ គេចាត់ទុកជាបទល្មើតែមួយ។

ឧទាហរណ៍ ៖

- **បទផិត** ចាត់ថាជាបទល្មើសអូសបន្លាយ ដោយសារថា អំពើផិតក្បត់នេះត្រូវបានធ្វើឡើងម្តងហើយម្តងទៀតជាមួយនឹងបុរស ឬស្ត្រីក្រៅពីស្វាមី ឬភរិយារបស់ខ្លួន[២៤]។
- **បទកាន់កាប់ ឬដឹកជញ្ជូនអាវុធ ដោយគ្មានការអនុញ្ញាត** ដោយសារថាជននោះបានកាន់កាប់នូវអាវុធតាមខ្លួនដោយគ្មានការអនុញ្ញាត ពីសំណាក់អាជ្ញាធរមានសមត្ថកិច្ចនៅក្រៅពី រង្វង់លំនៅឋានរបស់ខ្លួន[២៥]។

### ឃ. បទល្មើសកើតចេញពីអំពើប្រព្រឹត្តជាទម្លាប់

បទល្មើសប្រភេទនេះ កើតឡើងដោយសារអំពើជាទម្លាប់ម្តងហើយម្តងទៀត ឬតាមមធ្យោបាយផ្សេងៗ រូបភាពផ្សេង ទោះស្ថិតក្នុងស្ថានភាពផ្សេងគ្នាក៏ដោយ រួមទាំងពេលវេលាផ្សេងៗគ្នាយ៉ាងណាក៏ដោយ បើកាលណាអំពើនេះកើតឡើងចាប់ពី ២ (ពីរ) ដងឡើងទៅ នោះបទល្មើសនេះជាបទល្មើសកើតចេញពីអំពើប្រព្រឹត្តជាទម្លាប់ហើយ។ ទោះបីជាមានបទល្មើសច្រើនក៏ដោយ ប្រសិនបើកាលណាអំពើនោះត្រូវបានប្រព្រឹត្តផ្សេងៗ ឬដាច់ដោយឡែកពីគ្នា នោះច្បាប់ពុំបានចាត់ទុកថាបទល្មើសនេះប្រព្រឹត្តជាទម្លាប់នោះទេ។

ឧទាហរណ៍ ៖

- **បទរុកគួនខាងផ្លូវភេទ** ចាត់ថាជាបទល្មើសប្រព្រឹត្តជាទម្លាប់ដោយសារថា អំពើដែលបុគ្គលម្នាក់បានរំលោភអំណាច នៃមុខងាររបស់ខ្លួន ហើយបានធ្វើការគាបសង្កត់ម្តងហើយម្តងទៀតទៅលើអ្នកដ៏ទៃក្នុងគោលបំណងការអនុគ្រោះផ្លូវភេទ[២៦]។
- **បទគំរាមកំហែង** បទល្មើសនេះធ្វើឡើងក្នុងការគម្រាមកំហែងថានឹងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមប្រឆាំងនឹងបុគ្គល កាលបើការគម្រាមកំហែងនេះធ្វើឡើងម្តងហើយម្តងទៀត ឬសម្តែងចេញតាមលិខិត រូបភាព ឬវត្ថុអ្វីមួយ[២៧]។

---

[២៤] មាត្រា ៧ និងមាត្រា ១០ នៃច្បាប់ស្តីពីឯកពន្ធភាព

[២៥] មាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា។

[២៦] មាត្រា ២៥០ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា។

[២៧] មាត្រា ២៣១ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា។

### ១.២.២. គោលការណ៍មិនប្រតិសកម្មចំពោះទោស

អ្វីទៅជាភាពមិនប្រតិសកម្មនៃទោស? ជាក់ស្តែងណាស់ទោសមួយអាចយកទៅអនុវត្តចំពោះជនល្មើសបាន លុះត្រាតែទោសនោះមានចែងនៅក្នុងបទប្បញ្ញត្តិច្បាប់ព្រហ្មទណ្ឌជាធរមាន នៅពេលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន[២៨]។ នេះបានន័យថា ទោះបីជាមានច្បាប់ចែងយ៉ាងជាក់លាក់ពីបទល្មើសណាមួយក៏ដោយ ក៏ទោសដែលចែងក្នុងច្បាប់នេះមិនអាចយកទៅប្រកាសបានដែរ ដោយសារថា ពុំមានកើតឡើងនូវបទល្មើសពីសំណាក់ប្រធាននៃបទល្មើស ឬនិយាយឱ្យខ្លីថា ច្បាប់ចែងតែអវត្តមាននៃអំពើល្មើសនោះ តុលាការនៅតែមិនអាចប្រកាសទោសនេះបានដដែល។ ហើយបើផ្អែកតាមទ្រឹស្តីនៃគោលការណ៍មិនប្រតិសកម្មនៃបទល្មើស យើងអាចកំណត់ពីគោលការណ៍មិនប្រតិសកម្មនៃទោសបានថា បទល្មើសថ្មីមួយត្រូវបានប្រព្រឹត្តហើយអាចយកមកផ្តន្ទាទោសក្រោមអានុភាពនៃច្បាប់ថ្មីបាន លុះត្រាតែបទល្មើសនោះត្រូវបានប្រព្រឹត្តក្រោយការចូលជាធរមាននៃអត្ថបទច្បាប់ថ្មីតែប៉ុណ្ណោះ។

ម្យ៉ាងវិញទៀត ចំពោះទោសណាមួយដែលច្បាប់ចាស់ និងច្បាប់ថ្មីបានចែងមកដូចគ្នា គ្រាន់តែខុសអប្បបរមា និងអតិបរមា ដែលច្បាប់ចាស់ធ្ងន់ជាងច្បាប់ថ្មី។ ក្រោយពីការប្រព្រឹត្ត និងត្រូវបានតុលាការសម្រេចផ្តន្ទាទោសទៅលើអំពើទាំងនោះ ហើយទោសដែលប្រកាសនេះគឺធ្ងន់ធ្ងរ ហើយក៏បានចូលជាស្ថាពរដោយសារតែពុំមានការប្តឹងបន្តពីសំណាក់ទណ្ឌិត ព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញា ឬក៏បុគ្គលដែលពាក់ព័ន្ធផ្សេងទៀត[២៩]។ លុះក្រោយពីបានសម្រេចផ្តន្ទាទោសរួចមក ក្រមព្រហ្មទណ្ឌថ្មីក៏បានចូលជាធរមានហើយក៏បានចែងពីទោសដែលបានប្រកាសទៅលើទណ្ឌិតនោះ ស្រាលជាងច្បាប់ចាស់។ តែទោះបីជាយ៉ាងនេះក៏ដោយ ក៏ក្រមព្រហ្មទណ្ឌថ្មីដែលបានចូលជាធរមានក្រោយនេះបានចែងពីករណីនេះផងដែរថា "ការផ្តន្ទាទោសដែលចូលជាស្ថាពរហើយ គឺត្រូវតែអនុវត្ត ទោះបីជាទោសដែលប្រកាសនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ"[៣០]។ នេះបានសេចក្តីថាបើទោះបីជាច្បាប់ថ្មីបានចែងពីទោសដែលប្រកាសនេះស្រាលជាងក៏ដោយ ក៏ទោសនោះនៅតែអនុវត្តក្រោមអានុភាពនៃច្បាប់ចាស់ដដែល ទោះបីជាធ្ងន់ធ្ងរជាងច្បាប់ថ្មីយ៉ាងណាក៏ដោយ។ មួយវិញទៀតចំពោះទោសដែលច្បាប់ថ្មីបានចែងមកធ្ងន់ធ្ងរជាងច្បាប់ចាស់ ឬច្បាប់ចាស់ចែងស្រាលជាងច្បាប់ថ្មី តែទោសនេះបានប្រកាសហើយក៏បានចូលជាស្ថាពរមុនការចូលជាធរមាននៃច្បាប់ថ្មី នោះទោសដែលស្រាលនេះ គឺមានអានុភាពអនុវត្តដដែលបើទោះបីជាបទល្មើសនោះធ្ងន់ធ្ងរ និងមានការផ្តន្ទាទោសស្រាលក្រោមអានុភាពនៃច្បាប់ចាស់យ៉ាងណាក៏ដោយ ក៏នៅតែអនុវត្តបានដដែល។

---

[២៨] មាត្រា ៣ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា។

[២៩] ការចូលជាស្ថាពរនេះ គឺជាការចូលជាស្ថាពរដែលត្រូវគិតតាំងពី ការប្តឹងជំទាស់ ការប្តឹងឧទ្ធរណ៍ បណ្តឹងសារទុក្ខជាដើម។

[៣០] មាត្រា ១០ វាក្យខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា។

## ផ្នែកទី២ ៖ ភាពមិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌធ្ងន់ជាង

គោលការណ៍នេះមានបញ្ញត្តិនៅក្នុងមាត្រា ១០ កថាខណ្ឌទី ២ នៃក្រមព្រហ្មទណ្ឌ និងនៅក្នុងមាត្រា ១១ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលបានចែងថា ៖ គ្មានជនណាម្នាក់ត្រូវជាប់ទោសពីបទល្មើសព្រហ្មទណ្ឌឡើយ ចំពោះអំពើ ឬការធ្វេសប្រហែសណាមួយដែលពុំមែនជាបទល្មើសព្រហ្មទណ្ឌដែលមាននៅក្រោមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ នៅខណៈពេលដែលអំពើនោះបានប្រព្រឹត្ត។

តើអ្វីទៅជាអំពើដែលកើតឡើងមុនច្បាប់ចូលជាធរមាន?

+ **ចំពោះបទល្មើសភ្លាមៗ** គឺជាបទល្មើសកើតឡើងនៅថ្ងៃដែលប្រព្រឹត្តបទល្មើសតែម្តង។ ហេតុដូច្នេះប្រាកដជាមានភាពងាយស្រួលក្នុងការកំណត់ថា តើបទល្មើសបានកើតឡើងមុន ឬក្រោយច្បាប់ថ្មីចូលជាធរមាន។

<u>**ឧទាហរណ៍**</u> **៖**

- អំពើលួច កើតឡើងនៅថ្ងៃដែលជនល្មើសបានដកហូតយកទ្រព្យសម្បត្តិរបស់អ្នកដទៃ។
- បទឃាតកម្ម កើតឡើងនៅពេលដែលជនរងគ្រោះបានស្លាប់បាត់បង់ជីវិត។
- បទហិង្សាដោយចេតនា កើតឡើងនៅពេលដែលជនរងគ្រោះទទួលរងនៅការប៉ះពាល់ដល់បូរណភាពរូបរាងកាយរបស់ខ្លួន ដោយសារតែអំពើហិង្សារបស់ចារី ។
- បទទ្វេពន្ធភាព កើតឡើងនៅពេលដែលជនល្មើសបានចុះបញ្ជីអាពាហ៍ពិពាហ៍ថ្មី មុនការរំលាយអាពាហ៍ពិពាហ៍ចាស់។

ហេតុដូច្នេះ ប្រសិនបើមានច្បាប់ថ្មីចូលជាធរមាន នៅក្រោយពេលដូចបានកំណត់ខាងលើនេះគឺបានសេចក្តីថា បទល្មើសបានកើតឡើងមុនពេលច្បាប់ថ្មីចូលជាធរមានហើយ។

+ **ចំពោះបទល្មើសបន្តជាហូរហែ និងបទល្មើសអូសបន្លាយ** ធន្ទៈនៃការប្រព្រឹត្តបទល្មើសនៅតែបន្ត ដរាបណាបទល្មើសពុំទាន់បានបញ្ចប់។ ដូច្នេះនៅពេលដែលអំពើបានចាប់ផ្តើមប្រព្រឹត្តមុនពេលច្បាប់ថ្មីចូលជាធរមាន ក៏ប៉ុន្តែនៅតែបន្តហូតដល់ពេលច្បាប់ថ្មីចូលជាធរមាន ហើយនៅពេលនោះ គេត្រូវតែយកច្បាប់ថ្មីមកអនុវត្ត។

<u>**ឧទាហរណ៍**</u> **៖**

ជនល្មើសបានទទួលទិញរថយន្តពីចោរម្នាក់ នៅមុនពេលដែលច្បាប់ថ្មីចូលជាធរមាន ហើយបន្តរក្សាទុករថយន្តនេះរហូតដល់ពេលច្បាប់ថ្មីចូលជាធរមាន។ ក្នុងករណីនេះជនល្មើសបានប្រព្រឹត្តបទទទួលផលចោរកម្ម នៅមុនពេលច្បាប់ថ្មីចូលជាធរមានផង និងក្រោយពេលច្បាប់ថ្មីចូលជាធរមានផង។

ហេតុដូច្នេះ ត្រូវយកច្បាប់ថ្មីមកអនុវត្ត មិនមែនយកច្បាប់ចាស់ទេ ពីព្រោះថាជនល្មើសបានប្រព្រឹត្តបទល្មើសចប់សព្វគ្រប់ក្រោមអំណាចនៃច្បាប់ថ្មី។

+ **ចំពោះបទល្មើសកើតចេញពីអំពើប្រព្រឹត្តជាទម្លាប់** បទល្មើសកើតឡើងលុះត្រាតែអំពើកើតឡើងជាទម្លាប់ពោលគឺយ៉ាងហោចណាស់ក៏ត្រូវបានប្រព្រឹត្តចំនួនពីរដងដែរ ទើបគួរចាត់ទុកថាជាទម្លាប់។ ហេតុដូច្នេះ ប្រសិនបើអំពើចុងក្រោយដែលបង្កើតបានជាទម្លាប់បានកើតឡើងក្រោមអំណាចនៃច្បាប់ថ្មី ត្រូវយកច្បាប់ថ្មីមកអនុវត្ត។

<u>ឧទាហរណ៍</u> ៖

នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១១ បុរស ក បានធ្វើការគំរាមកំហែងថានឹងសម្លាប់ឈ្មោះ ខ តាមរយៈ ទូរស័ព្ទ។ នៅពេលនោះច្បាប់ដែលផ្តន្ទាទោសការគំរាមកំហែងកំណត់ទោសដាក់ពន្ធនាគារពី ១ខែ ទៅ ១ ឆ្នាំ សម្រាប់ជនប្រព្រឹត្តបទល្មើសនេះ។ នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០១១ បុរស ក បានគំរាមកំហែងថានឹងសម្លាប់ឈ្មោះ ខ ម្តងទៀត។ ឧបមាថា នៅខែមីនា ឆ្នាំ២០១១ មានច្បាប់ថ្មីដែលកំណត់ទោសដាក់ពន្ធនាគារការគំរាមកំហែងថាសម្លាប់ ពី ១ឆ្នាំ ទៅ ២ឆ្នាំ។ ក្នុងករណីនេះ ត្រូវយកច្បាប់ថ្មីមកអនុវត្តចំពោះអំពើរបស់បុរស ក មិនមែនយកច្បាប់ចាស់ទេ ដោយសារមូលហេតុថា អំពើគំរាមកំហែងលើកទីពីរដែលបង្កើតបានជាបទល្មើសកើតឡើងក្រោយពេលច្បាប់ថ្មីចូលជាធរមានទៅហើយ។

+ **ច្បាប់ព្រហ្មទណ្ឌថ្មីដែលធ្ងន់ជាង** គឺច្បាប់ថ្មីដែលបានដាក់ទោសលើអំពើដែលច្បាប់ចាស់មិនបានចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌ។

<u>ឧទាហរណ៍</u> ៖

ក្រមព្រហ្មទណ្ឌមានបទប្បញ្ញត្តិដែលធ្ងន់ជាង ដោយបានបង្កើតបទល្មើសថ្មីៗមួយចំនួន ដែលពុំមានចែង នៅក្នុងច្បាប់ព្រហ្មទណ្ឌមុនដូចជា ៖ បទធ្វើឱ្យខូចខាតដោយខ្វះការប្រុងប្រយ័ត្ន ឬការមិនគោរពបទបញ្ជា (មាត្រា ៤១៩) បទល្មើសក្នុងវិស័យព័ត៌មានវិទ្យា (មាត្រា ៤២៧ ដល់មាត្រា ៤៣២) បទសម្លុតកុំឱ្យដាក់ពាក្យបណ្តឹង (មាត្រា ៥២៧) បទបំពានលើកាតព្វកិច្ចការងារសហគមន៍ (មាត្រា ៥៨៣)។

+ **ច្បាប់ថ្មីដាក់ទោសធ្ងន់ជាងច្បាប់ចាស់លើអំពើដដែល** (ក្នុងករណីនេះ គេត្រូវពិនិត្យមើលអតិបរមានៃទោស ដែលច្បាប់បានចែង)។

<u>ឧទាហរណ៍</u> ៖

- មាត្រា ៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលផ្តន្ទាទោសលើ អំពើមនុស្សឃាតដោយចេតនា ដោយដាក់ពន្ធនាគារពី ៨ឆ្នាំ ដល់ ១៥ឆ្នាំ ក៏ប៉ុន្តែមាត្រា ៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋដែលជា

ច្បាប់ថ្មី បែរជាកំណត់ទោសសម្រាប់អំពើមនុស្សឃាតដោយចេតនា ជាទោសដាក់ពន្ធនាគារតម្រូវឱ្យធ្វើការពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ ហើយប្រសិនបើការសម្លាប់មនុស្សដោយចេតនា ដោយអំពើឃោឃៅក្នុងកាលៈទេសៈ និងក្នុងទីកន្លែងតែមួយបណ្តាលឱ្យជនណាម្នាក់ ឬច្រើននាក់ស្លាប់ ត្រូវជាប់ទោសដាក់ពន្ធនាគារពី ១៥ឆ្នាំ ទៅ ២០ឆ្នាំ ឬអស់មួយជីវិត។

- មាត្រា ៥១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលកំណត់ទោសដាក់ពន្ធនាគារសម្រាប់បទល្មើសទទួលផលចោរកម្ម ពី១ឆ្នាំ ទៅ ៥ឆ្នាំ។ ចំណែកឯក្រមព្រហ្មទណ្ឌវិញតម្រូវឱ្យផ្តន្ទាទោសជនដែលប្រព្រឹត្តបទទទួលផលចោរកម្ម ដាក់ពន្ធនាគារ ពី ២ឆ្នាំ ទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានរៀល ទៅ ១០លានរៀល។ ក្នុងករណីនេះ ក្រមព្រហ្មទណ្ឌកំណត់អប្បបរមា នៃទោសដាក់ពន្ធនាគាររហូតដល់ទៅ ២ឆ្នាំ ហើយបន្ថែមនូវទោសពិន័យជាប្រាក់ទៀតផង។

សរុបមកវិញ បើតាមគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌធ្ងន់ជាងច្បាប់ថ្មីអាចអនុវត្តបានតែចំពោះអំពើដែលបានប្រព្រឹត្តចាប់ពីថ្ងៃដែលច្បាប់ថ្មីចូលជាធរមានតែប៉ុណ្ណោះ។ ចំណែកឯអំពើដែលបានប្រព្រឹត្តមុនពេលនេះ រួមទាំងអំពើដែលពុំទាន់បានជំនុំជម្រះជាស្ថាពរនៅឡើយ ច្បាប់ថ្មីគ្មានអានុភាពអនុវត្តទេ។ និយាយម៉្យាងទៀតថា មិនត្រូវឱ្យមានការដាក់ទោសធ្ងន់ជាងទោសដែលបានកំណត់នៅខណៈពេលដែលបទល្មើសព្រហ្មទណ្ឌបានប្រព្រឹត្តនោះឡើយ។

បញ្ហាមួយអាចចោទឡើងនៅពេលដែលបុគ្គលធ្លាប់ត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយ ក្រោមអំណាចនៃច្បាប់ព្រហ្មទណ្ឌចាស់របស់ព្រះរាជាណាចក្រកម្ពុជា ដែលពុំបានចែងពីស្ថានទម្ងន់ទោស ក្នុងករណីមិនរាងចាល បន្ទាប់មកបានប្រព្រឹត្តបទល្មើសម្តងទៀត ក្រោយពេលដែលក្រមព្រហ្មទណ្ឌចូលជាធរមានដែលមានចែងពីស្ថានទម្ងន់ទោសក្នុងករណីមិនរាងចាល។ ក្នុងករណីបែបនេះជនល្មើសបានប្រព្រឹត្តបទល្មើសទីពីរ ក្រោយពេលក្រមព្រហ្មទណ្ឌចូលជាធរមានពោលគឺ ជនល្មើសគួរតែបានដឹងហើយថាខ្លួនអាចនឹងត្រូវផ្តន្ទាទោសធ្ងន់ធ្ងរជាងធម្មតានៅពេលដែលប្រព្រឹត្តបទល្មើសលើកក្រោយនេះ។ ហេតុដូច្នេះគប្បីអនុញ្ញាតឱ្យយកការផ្តន្ទាទោសមុនពេលក្រមព្រហ្មទណ្ឌចូលជាធរមាន មកធ្វើជាមូលដ្ឋាននៃការកំណត់ថាជាករណីមិនរាងចាល សម្រាប់បទល្មើសដែលប្រព្រឹត្តនៅពេលក្រោយនេះ។

**ឧទាហរណ៍ ៖**

ឈ្មោះ ក ត្រូវបានតុលាការសម្រេចផ្តន្ទាទោសពីបទចោរកម្ម តាមបទប្បញ្ញត្តិនៃមាត្រា ៤៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលដោយដាក់ពន្ធនាគារចំនួន ១ឆ្នាំ។ សាលក្រមផ្តន្ទាទោសបានចូលជាស្ថាពរនៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៩ (មុនពេលក្រមព្រហ្មទណ្ឌចូលជាធរមាន)។ នៅថ្ងៃទី៣០ ខែមករា ឆ្នាំ ២០១១ ឈ្មោះ ក បានលួចយកទ្រព្យសម្បត្តិរបស់អ្នកដ៏ទៃម្តងទៀត ហើយត្រូវឃាត់ខ្លួនបាន។ យោង

តាមមាត្រា ៨៨ នៃក្រមព្រហ្មទណ្ឌ ឈ្មោះ ក បានប្រព្រឹត្ត បទល្មើសក្នុងស្ថានភាពមិនរាងចាល ហេតុដូច្នេះអតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទមជ្ឈិមថ្មី ត្រូវទ្វេឡើង បានសេចក្តីថា ទោសដែលត្រូវអនុវត្តចំពោះអំពើលួចដែលប្រព្រឹត្តដោយឈ្មោះ ក នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១១ ត្រូវទ្វេឡើង (ទោសដាក់ពន្ធនាគារពី ៦ខែ ទៅ ៦ឆ្នាំ)។ ក្នុងករណីនេះ យោងតាមការបកស្រាយខាងលើអាចយកបទប្បញ្ញត្តិនៃមាត្រា ៨៨ នៃក្រមព្រហ្មទណ្ឌមកអនុវត្តលើអំពើលួចដែលប្រព្រឹត្តដោយឈ្មោះ ក នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១១ បាន។

## ២.១. ផលវិបាកនៃគោលការណ៍នីត្យានុកូល

ច្បាប់គឺជាកត្តាចាំបាច់បំផុតនៅក្នុងរឿងក្តីព្រហ្មទណ្ឌ នេះគឺជាមូលដ្ឋាននៃគោលការណ៍នីត្យានុកូលភាពដែលត្រូវបានបង្កើតឡើង ដើម្បីការពារសិទ្ធិសេរីភាពរបស់បុគ្គលក្នុងការប្រព្រឹត្តអំពើផ្សេងៗ។ មាត្រា ៣ នៃក្រមព្រហ្មទណ្ឌបានទទួលស្គាល់យ៉ាងច្បាស់នូវគោលការណ៍នីត្យានុកូលភាព។ មាត្រានេះចែងថា មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន។ មានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន។

មាត្រានេះកំណត់គោលការណ៍មូលដ្ឋាន ចំពោះគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងទោសដែលអះអាងថាជនណាម្នាក់នឹងអាចចោទប្រកាន់នៅចំពោះមុខតុលាការព្រហ្មទណ្ឌបាន ចំពោះតែអំពើទាំងឡាយណាដែលត្រូវបានកំណត់ទុកដោយច្បាប់ថាជាបទល្មើស ហើយក្នុងករណីដែលច្បាប់នេះត្រូវបានប្រកាសឱ្យប្រើមុនពេលដែលអំពើទាំងនោះត្រូវបានប្រព្រឹត្តប៉ុណ្ណោះ។ ដូចគ្នាដែរមានតែទោសដែលមានចែងដោយច្បាប់នៅថ្ងៃដែលប្រព្រឹត្តអំពើប៉ុណ្ណោះ ដែលអាចប្រកាសបាន។

គោលការណ៍នីត្យានុកូលភាពនេះ ទាមទារជាចាំបាច់ថា នៅក្នុងករណីគ្មានច្បាប់កំណត់បទល្មើស និងចែងអំពីទោសណាមួយនៅក្នុងពេលដែលអំពើនោះត្រូវបានប្រព្រឹត្តទេ នោះពុំអាចមានការចោទប្រកាន់ពីបទព្រហ្មទណ្ឌបានឡើយ។

ក្រៅពីនេះទៅទៀតគោលការណ៍នីត្យានុកូលភាព ក៏ត្រូវបានទទួលស្គាល់ដោយលិខិតុបករណ៍អន្តរជាតិដែលមានតម្លៃជារដ្ឋធម្មនុញ្ញតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ផងដែរ។ មាត្រា ១៥ កថាខណ្ឌទី១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយលើកឡើងថា គ្មានជនណាម្នាក់ត្រូវជាប់ទោសពីបទល្មើសព្រហ្មទណ្ឌឡើយ ចំពោះអំពើ ឬការធ្វេសប្រហែសណាមួយដែលពុំមែនជាបទល្មើសព្រហ្មទណ្ឌមាននៅក្រោមច្បាប់ជាតិ ឬច្បាប់អន្តរជាតិនៅខណៈពេលដែលអំពើនោះបានប្រព្រឹត្ត។

ដូច្នេះរាល់ការចោទប្រកាន់ និងការដាក់ទោសទាំងអស់ត្រូវតែ ផ្អែកទៅលើច្បាប់ (គ្មានច្បាប់ចែង គ្មានបទល្មើស គ្មានទោសឡើយ)។

ផលវិបាកនៃគោលការណ៍នីត្យានុកូលនេះ គឺត្រង់ភាពមិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ជាគោលការណ៍ ច្បាប់ព្រហ្មទណ្ឌពុំអាចចោទប្រកាន់ចំពោះអំពើទាំងឡាយណា ដែលកើតមានឡើងនៅមុនពេលដែលច្បាប់ព្រហ្មទណ្ឌចូលជាធរមានដើម្បីកំណត់ប្រភេទគតិយុត្ត នៃអំពើនោះជាបទល្មើសព្រហ្មទណ្ឌបានឡើយ។ ដូចគ្នានេះដែរ ប្រសិនបើច្បាប់ព្រហ្មទណ្ឌមានចែង ប៉ុន្តែទោសដែលត្រូវបានចែងមុនពេលប្រព្រឹត្តអំពើទាំងនោះត្រូវបានកែប្រែ នៅថ្ងៃដែលអំពើទាំងនោះត្រូវបានវិនិច្ឆ័យជាគោលការណ៍មានតែទោសចាស់ទេដែលអាចយកទៅអនុវត្តបាន។

❖ **ការបកស្រាយជាក់លាក់ត្រឹមត្រូវនៃនីតិព្រហ្មទណ្ឌ**

គោលបំណងនៃគោលការណ៍នេះ គឺដើម្បីឱ្យចៅក្រមអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវហើយការផ្តន្ទាទោសត្រូវតែចំបទល្មើសដែលមានចែងក្នុងច្បាប់ ជៀសវាងការបកស្រាយទាំងឡាយណា ដែលមិនសមហេតុមិនសមផល ជាហេតុនាំឱ្យខុសឆន្ទៈរបស់នីតិនិពន្ធ។ ឆន្ទៈនេះគឺនីតិនិពន្ធសម្តែងឡើងក្រោមរូបភាពនៃការកំណត់បទល្មើស និងកំណត់អំពីទោស។ ផ្តើមចេញពីគោលការណ៍នៃការបកស្រាយជាក់លាក់ ឬត្រឹមត្រូវនៃនីតិព្រហ្មទណ្ឌបានជាគេកត់សម្គាល់ឃើញថាផ្នែកនីតិព្រហ្មទណ្ឌ ចៅក្រមពុំអាចចេញយុត្តិសាស្ត្របានទេ ពីព្រោះនៅពេលដែលច្បាប់មិនបានចែងពុំមែនជាបទល្មើសឡើយ ដូចនេះចៅក្រមត្រូវដោះលែងជនប្រព្រឹត្តនោះឱ្យមានសេរីភាពឡើងវិញ។

ជាទូទៅការបកស្រាយច្បាប់មួយ គេតែងតែធ្វើដោយរបៀប បី យ៉ាងគឺ ៖

- **ការបកស្រាយតាមពាក្យពេចន៍** គឺជាការបកស្រាយច្បាប់មួយប្រភេទ ដោយផ្អែកលើពាក្យពេចន៍ដែលច្បាប់បានចែង យ៉ាងច្បាស់លាស់នៅក្នុងច្បាប់។

<u>ឧទាហរណ៍</u> ៖

ច្បាប់បានបញ្ញត្តិថា ការធ្វើចរាចរណ៍បញ្ច្រាសទិសលើទ្រូងថ្នល់ និងត្រូវផាកពិន័យជាប្រាក់។ ប្រសិនបើគេធ្វើចរាចរណ៍បញ្ច្រាសទិសលើផ្លូវថ្នល់វិញនោះ នគរបាលចរាចរណ៍មិនអាចផាកពិន័យគេបានឡើយ ពីព្រោះច្បាប់ហាមតែលើទ្រូងថ្នល់ប៉ុណ្ណោះ មិនបានហាមលើចញ្ចើមថ្នល់ទេ។

- **ការបកស្រាយតាមស្មារតី នៃអង្គប្រជុំរបស់រដ្ឋសភា** គឺជាការបកស្រាយមួយបែបដែលពឹងផ្អែកលើការពិភាក្សាដេញដោលរបស់វាគ្មិន នៅពេលបញ្ចេញមតិក្នុងការអនុម័ត សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នានា។

<u>ឧទាហរណ៍</u> ៖

ដូចករណីមាត្រា ៧៩ កថាខណ្ឌទី ២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ បានចែងអំពីវិសមិតភាពរវាងសមាជិករដ្ឋសភាជាមួយ សមាជិករាជរដ្ឋាភិបាល នៅពេល

ដែល ជាសមាជិករដ្ឋសភាផង និងជាសមាជិករដ្ឋាភិបាលផងនោះ សមាជិករដ្ឋសភារូបនោះមានឋានៈជាសមាជិករដ្ឋសភាធម្មតាមិនត្រូវមានតំណែងអ្វីទាំងអស់ក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ និងក្នុងគណៈកម្មការនានារបស់រដ្ឋសភាឡើយ ចំណុចនេះហើយដែលវាគ្មិនរបស់រដ្ឋសភាកំណត់ថា ជាវិសមិតភាពតាមខ្លឹមសារ។

- **ការបកស្រាយតាមគោលការណ៍ប្រហាក់ប្រហែល** ភាគច្រើនគេអនុវត្តនៅប្រទេសប្រកាន់របបសង្គមនិយម ហេតុនេះហើយបានជាគេឃើញច្បាប់នានារបស់ប្រទេសសង្គមនិយម ច្រើនតែសរសេរខ្លីៗ មិនសូវច្បាស់លាស់ ដោយគេសំអាងថា នៅពេលមានការបន្ទិលសង្ស័យគេលើកយកគោលការណ៍នេះមកបកស្រាយ។

<u>**ឧទាហរណ៍**</u> ៖

នៅឆ្នាំ ១៩៨៨ ដែលប្រទេសកម្ពុជាយើងប្រកាន់យករបបសង្គមនិយម គេផ្តន្ទាទោសចំពោះអ្នកបញ្ចាំង វីដេអូអាសអាភាសលួចលាក់ ថ្វីត្បិតតែច្បាប់មិនបានចែងដោយគេសំអាងលើគោលការណ៍ប្រហាក់ប្រហែលថា ធ្វើឱ្យខូចសណ្តាប់ធ្នាប់ និងធ្វើឱ្យខូចប្រពៃណីល្អរបស់ជាតិ។

### ២.២. អត្ថន័យគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌធ្ងន់ជាង

គោលការណ៍អប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌធ្ងន់ជាងនេះ គឺជាគោលការណ៍គ្រឹះនៃនីតិព្រហ្មទណ្ឌ ហើយគោលការណ៍ច្បាប់ព្រហ្មទណ្ឌមានអានុភាពអនុវត្តសម្រាប់តែទៅអនាគតតែប៉ុណ្ណោះ គឺមិនមានអនុភាពអនុវត្តទៅលើអតីតកាលនោះទេ។ ហេតុដូច្នេះបានន័យថាយើងមិនអាចយកច្បាប់ព្រហ្មទណ្ឌមួយទៅអនុវត្តចំពោះអំពើដែលកើត ឬប្រព្រឹត្តមុនច្បាប់ចូលជាធរមានទេ។ ជាងនេះទៅទៀត គោលការណ៍នេះជាវិបាកកម្ម ពីព្រោះវាដើរទន្ទឹមគ្នាជាមួយនឹងគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងគោលការណ៍នីត្យានុកូលភាពនៃទោសដូចដែលបង្ហាញនៅក្នុងផលវិបាកនេះគោលការណ៍នីត្យានុកូលខាងលើរួចមកហើយ។ បានន័យថាមានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោស។ ដែលនេះជាគោលការណ៍សំខាន់មួយ ហើយគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌនេះ គឺជាគោលការណ៍គ្រឹះនៃសិទ្ធិមនុស្ស និងសង្គមប្រជាធិបតេយ្យ ដែលមានគោលដៅជាពិសេសធានានៅសិទ្ធិសេរីភាព ក៏ដូចជាសុវត្ថិភាពគតិយុត្តនៃពលរដ្ឋ។

ចំពោះមួយផ្នែកទៀតដែលគេវិភាគរហូតទៅដល់ថា គឺជាការជៀសវាងនូវការសងសឹកជាលក្ខណៈនយោបាយទៀតផង។ ម្យ៉ាងទៀតគឺមានសៀវភៅមួយ ដែលបោះពុម្ពដោយរដ្ឋាភិបាលសហរដ្ឋអាមេរិកបាននិយាយអំពីប្រជាធិបតេយ្យ។ គេថាគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌជាគោលការណ៍គ្រឹះនៃសិទ្ធិមនុស្ស នៃប្រព័ន្ធច្បាប់របស់ប្រទេសប្រជាធិបតេយ្យ គឺថាជារឿងជៀសវាងនូវការសងសឹកនយោបាយដើម្បីកុំឱ្យ

គណបក្សនយោបាយថ្មី ដែលឡើងកាន់អំណាចមានគោលដៅចង់សងសឹកអំពីសមាជិករដ្ឋាភិបាលមុន ឬក្រុមនេះ ក្រុមនោះ ឬរដ្ឋាភិបាលមុនថាជាបទល្មើស ហើយត្រូវផ្តន្ទាទោសដោយអានុភាពប្រតិសកម្ម។ ដូចនេះយើងឃើញថានេះគឺជាសកម្មភាពមួយគ្រោះថ្នាក់ខ្លាំងណាស់ចំពោះសង្គមប្រជាធិបតេយ្យ។ ហេតុដូច្នេះហើយ ជាគោលការណ៍គ្រឹះ គឺគេមិនអនុញ្ញាតឱ្យមានការអនុវត្តដោយប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ដែលធ្ងន់ធ្ងរជាងទៅលើអំពើណាដែលកើតឡើងមុនការចូលជាធរមាននៃច្បាប់នេះទេ។

# ជំពូកទី៣
# អញ្ញត្រកម្មទៅនឹងគោលការណ៍
# ( ភាពមិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ )

# ជំពូកទី៣
# អញ្ញត្រកម្មទៅនឹងគោលការណ៍
# (ភាពមិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ)

អញ្ញត្រកម្មទៅនឹងគោលការណ៍នេះ អាចធ្វើទៅបានប្រសិនបើអ្នកនីតិប្បញ្ញត្តិបានចែងយ៉ាងច្បាស់ទុកជាមុនថា ច្បាប់ដែលនឹងចូលជាធរមានត្រូវតែមានអានុភាពប្រតិសកម្ម បានន័យថាត្រូវគ្រប់គ្រងទំនាក់ទំនងដែលកើតមានឡើងនៅមុនពេលច្បាប់ថ្មីចូលជាធរមាន។ ចំពោះអញ្ញត្រកម្មទៅនឹងគោលការណ៍នេះ គឺមានចំណុច ៣ សំខាន់ៗ ៖ **ផ្នែកទី១ ច្បាប់ដែលលុបចោលបទល្មើស ផ្នែកទី២ ច្បាប់ព្រហ្មទណ្ឌថ្មីដែលស្រាលជាង និង ផ្នែកទី៣ អញ្ញត្រកម្មនឹងគោលការណ៍អប្រតិសកម្មនៃច្បាប់ថ្មី។**

## ផ្នែកទី១ ៖ ច្បាប់ដែលលុបចោលបទល្មើស

ច្បាប់ដែលលុបចោលបទល្មើសគឺបានន័យថាច្បាប់ថ្មីដែលទើបចូលជាធរមាន បានលុបចោលបទល្មើសណាមួយ ដែលមានក្នុងច្បាប់ចាស់ "អំពើដែលបានប្រព្រឹត្តមុនបទប្បញ្ញត្តិនេះចូលជាធរមាន មិនអាចត្រូវបានចោទប្រកាន់ទៀតឡើយ ការចោទប្រកាន់ដែលកំពុងប្រព្រឹត្តនោះត្រូវបញ្ឈប់។ ចំពោះច្បាប់ដែលលុបចោលបទល្មើសគឺមានការអនុវត្តដូចតទៅ ៖ **១.១. ការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលលុបចោលបទល្មើស និង ១.២. ការលើកលែងទោស។**

### ១.១. ការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលលុបចោលបទល្មើស

នៅក្នុងច្បាប់ដែលលុបចោលបទល្មើសនេះ ដែលមានចែងនៅក្នុងមាត្រា ៩ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា បានចែងយ៉ាងច្បាស់ថា "បទប្បញ្ញត្តិថ្មីដែលលុបចោលបទល្មើសណាមួយនោះត្រូវអនុវត្តភ្លាម" បានន័យថាអំពើប្រព្រឹត្តនៅមុនពេលបទប្បញ្ញត្តិនេះចូលជាធរមាន មិនអាចត្រូវចោទប្រកាន់ទេ ហើយការចោទប្រកាន់ដែលកំពុងប្រព្រឹត្តត្រូវបានបញ្ចប់ទាក់ទងទៅនឹងការចោទប្រកាន់។ ប្រសិនបើបានប្រព្រឹត្តរួចហើយ តែមិនទាន់ធ្វើការចោទប្រកាន់ទេនោះ ច្បាប់ព្រហ្មទណ្ឌដែលលុបបទល្មើសនេះហើយដែលគេចាត់ទុកថាជាច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង ដូច្នេះត្រូវមានអានុភាពប្រតិសកម្ម គឺមិនអាចធ្វើការចោទប្រកាន់ទេ។ ហើយបើកំពុងចោទប្រកាន់ត្រូវឈប់ធ្វើការចោទប្រកាន់ ឬក៏ការចោទប្រកាន់នោះត្រូវបញ្ចប់។

តែបើសិនជាបានផ្តន្ទាទោសរួចហើយ គឺមិនអាចយកទោសនោះមកអនុវត្តបានទៀតទេ ឬមួយក៏បើកំពុងតែអនុវត្តត្រូវបញ្ឈប់ការអនុវត្ត មានន័យថាគេយកច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង មកអនុវត្តដោយប្រតិសកម្ម ដើម្បីជាផលផ្តល់ដល់ជនល្មើស ឬផ្តល់ផលអនុគ្រោះដល់ជនល្មើស ក្នុងគោលដៅគោរពនូវគោលការណ៍មនុស្សធម៌។

<u>ឧទាហរណ៍</u> ៖

បុគ្គល ក បានប្រព្រឹត្តនៅអំពើមួយដែលច្បាប់នៅសម័យនោះថាជាបទល្មើស។ តែដល់សម័យនេះ ដោយសារតែនយោបាយព្រហ្មទណ្ឌ សភាខ្មែរបានអនុម័តនៅច្បាប់មួយថាអំពើនេះលែងជាបទល្មើសទៀតហើយ។ ដូច្នេះបើបុគ្គល ក ត្រូវបានគេផ្តន្ទាទោសរួចហើយ ប៉ុន្តែអនុវត្តទោសមិនទាន់ចប់ គឺគេត្រូវបញ្ឈប់ការអនុវត្តទោសចំពោះគាត់តទៅទៀត។ មានបទល្មើសជាច្រើនដែលយើងអាចចោទសួរថា ៖

**តើមានបទល្មើសណាខ្លះដែលរដ្ឋសភាតែងតែធ្វើច្បាប់លុបបំបាត់បទល្មើស?**

បទល្មើសដែលរដ្ឋសភាតែងតែធ្វើច្បាប់លុបបំបាត់បទល្មើស មានដូចជាបទល្មើសលេងល្បែងស៊ីសង ឬបទល្មើសក្បត់បដិវត្តជាដើម ដែលវាអាស្រ័យទៅលើនយោបាយនៃសង្គម និងអាស្រ័យទៅលើកាលៈទេសៈនៃសង្គម។ ពេលខ្លះច្បាប់កំណត់ថាលេងល្បែងស៊ីសងជាបទល្មើស ហើយអ្នកដែលប្រព្រឹត្តបទល្មើសល្បែងស៊ីសងត្រូវផ្តន្ទាទោស ឬមួយកំពុងចោទប្រកាន់។ តែក្រោយមកសង្គមយើងមានភាពរឹងមាំ មានភាពរីកចម្រើន មានការគ្រប់គ្រងបានល្អ សភាក៏កំណត់ថាការលេងល្បែងស៊ីសងមិនមែនជាបទល្មើសទៀតទេ ដូច្នេះត្រូវតែលុបអំពើ ឬក៏បទល្មើសនេះចោល។ ហេតុនេះអ្នកដែលកំពុងទទួលទោស ឬកំពុងត្រូវចោទប្រកាន់ពីច្បាប់មុនគឺបានទទួលផលអនុគ្រោះពីច្បាប់ថ្មី។

### ១.២. ការលើកលែងទោស

ជាដំបូងមានពាក្យចំនួនបីដែលត្រូវបំភ្លឺ ៖ **ការលើកលែងទោស ការអនុគ្រោះទោស** និង **ការបន្ធូរបន្ថយ ទោស**។ ការបន្ធូរបន្ថយទោសជាការកាត់បន្ថយទោសឱ្យសល់រយៈពេលកាន់តែខ្លី និងឆាប់បញ្ចប់ទោស ដែល ត្រូវអនុវត្ត។ ការលើកលែងទោសមានពីរប្រភេទគឺ ៖ ការលើកលែងទោសជាទូទៅ និងការលើកលែងទោស ធម្មតា។

- ការលើកលែងទោសជាទូទៅ សំដៅលើការលើកលែងទោសដល់ជនប្រព្រឹត្តឧក្រិដ្ឋជាក្រុម តាមរយៈច្បាប់អនុម័តដោយសភា។ ច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រោមច្បាប់[៣១] ដោយប្រយោលស្ថិតចូលក្នុងការលើកលែទោសជាទូទៅនេះ។
- ការលើកលែងទោសធម្មតា ផ្តល់ជូនដោយព្រះមហាក្សត្រ (ករណីកម្ពុជា)។ នេះខុសពីការបន្ធូរបន្ថយទោសពីព្រោះ ការលើកលែងទោស និងបញ្ចប់ការអនុវត្តទោសដែលនៅសល់ ហើយទណ្ឌិតនឹងមានសេរីភាពវិញ។ ជាទូទៅទណ្ឌិតត្រូវបំពេញលក្ខខណ្ឌមួយចំនួនដូចជា ៖ ការកែប្រែអត្តចរិតឱ្យល្អ ហើយ

[៣១] ច្បាប់ស្តីពី ការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ ឆ្នាំ១៩៩៤។

ទទួលទោសក្នុងពន្ធនាគារបានរយៈពេលកំណត់ណាមួយ មុននឹងទទួលបានការលើកលែងទោស។ ការលើកលែងទោសធម្មតា អាចត្រូវបានហៅ ថាជាការអនុគ្រោះទោស។

ជាទូទៅ ការលើកលែងទោសមិនមានភ្ជាប់នូវលក្ខខណ្ឌ ឬជាប់កាតព្វកិច្ចអ្វីទេ។ ការលើកលែងទោសធម្មតាខុសពីការត្រួតពិនិត្យតាមផ្លូវតុលាការ (ដោយចៅក្រមស៊ើបអង្កេត) ក្នុងអំឡុងមុនពេលសវនាការ ដាក់ឱ្យជនត្រូវចោទនៅក្រោមមន្ទីរឃុំឃាំងជាមួយលក្ខខណ្ឌ នៃការគោរពកាតព្វកិច្ចមួយចំនួន[៣២]។ លើកលែងករណី ទោសជាទូទៅ ការលើកលែងទោសធម្មតា មិនបានបញ្ចប់នូវសំណងរដ្ឋប្បវេណីដល់ជនរងគ្រោះឡើយ[៣៣]។ ការលើកលែងទោសគឺយើងអាចកំណត់តាមវិធានច្បាប់ពីរគឺ ៖ **១.២.១. ការលើកលែងទោស ឬបន្ធូរបន្ថយទោសក្រោមវិធានច្បាប់អន្តរជាតិ និង ១.២.២. ការលើកលែងទោស ឬបន្ធូរបន្ថយទោសក្រោមវិធានច្បាប់ជាតិ។**

### ១.២.១. ការលើកលែងទោស ឬបន្ធូរបន្ថយទោសក្រោមវិធានច្បាប់អន្តរជាតិ

មាត្រា ៦ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានចែងអំពីសិទ្ធិរស់រានមានជីវិត ហើយក្នុងនោះបានចែងករណីលើកលែងចំពោះការអនុវត្តទោសប្រហារជីវិត។ បន្ថែមពីលើនេះ មាត្រានេះបានចែងតម្រូវឱ្យមានការបន្ធូរបន្ថយទោស ពីទោសប្រហារជីវិតមកជាទោសដាក់ពន្ធនាគារអស់មួយជីវិតវិញ។ មាត្រា ១៤ នៃកតិកាសញ្ញាដដែល បានចែងនូវការលើកលែង ឬបន្ធូរបន្ថយទោសក្នុងករណីមានការប្រព្រឹត្តអយុត្តិធម៌[៣៤] ជារួមមាត្រាទាំងពីរ បានចែងឱ្យមានសិទ្ធិក្នុងការបន្ធូរបន្ថយទោស ឬលើកលែងទោស។ ទោះបីជាគេអាចនិយាយថា មាត្រានេះ អនុវត្តចំពោះតែករណីបុគ្គលទទួលទោសប្រហារជីវិត ហើយមិនអនុវត្តសម្រាប់ករណីដ៏ទៃទៀតដូចជា ករណីបុគ្គលទទួលទោសដាក់ពន្ធនាគារមានរយៈពេលកំណត់ ឬការបន្ធូរបន្ថយទោស និងការលើកលែងទោស ដោយផ្អែកលើមូលដ្ឋានផ្សេងៗទៀត ដូចជាការកែចរិតមារយាទបានល្អ វាជាការមិនត្រឹមត្រូវទេ ពីព្រោះការដាក់ពន្ធនាគារសុទ្ធ គឺជាការកម្រិតសិទ្ធិមួយដែលត្រូវធ្វើឡើងក្នុងករណីចាំបាច់ ហើយការប្រាស្រ័យសិទ្ធិគឺជាវិធានទូទៅ។ គោលបំណងរបស់កតិកាសញ្ញា គឺដើម្បីការពារ និងធានាសិទ្ធិបុគ្គល។ ដូចនេះការលើកនូវភាពខ្វះខាតមិនបានចែង ឬចែងមិនគ្រប់ជ្រុងជ្រោយដើម្បីបដិសេធសិទ្ធិបុគ្គលអាចនឹងផ្ទុយនឹងគោលបំណងនេះ។ ការបកស្រាយរបៀបនេះ ក៏អាចនឹងនាំឱ្យមានការប្រព្រឹត្តមិនស្មើគ្នារវាងប្រភេទនៃទណ្ឌិត ហើយបើសិនគ្មានហេតុផលសមស្របនោះ នឹងឱ្យរំលោភគោលការណ៍រើសអើង ដែលមានចែងក្នុងកតិកាសញ្ញានេះផងដែរ[៣៥] បន្ថែមពី

---

[៣២] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៧, មាត្រា ២២៣។
[៣៣] ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩, មាត្រា ៧។
[៣៤] កម្ពុជាបានចូលជាភាគីនៃកតិកាសញ្ញាស្តីពី សិទ្ធិពលរដ្ឋ និងនយោបាយ ក្នុងឆ្នាំ១៩៩២។
[៣៥] កតិកាសញ្ញា, លេខយោងទី១០, មាត្រា ២។

លើនេះទៅទៀត ការប្រព្រឹត្តខុសគ្នាអាចនឹងមិនស្របទៅនឹងគោលការណ៍ស្មារនីតិសម្បទា នៃប្រព័ន្ធដាក់ទណ្ឌកម្ម។

**១.២.២. ការលើកលែងទោស ឬបន្ធូរបន្ថយទោសក្រោមវិធានច្បាប់ជាតិ**

មានបទប្បញ្ញត្តិនៃច្បាប់ជាច្រើនរបស់ព្រះរាជាណាចក្រកម្ពុជា ចែងអំពីការលើកលែងទោស ឬបន្ធូរបន្ថយទោស ដោយផ្ទាល់ ឬប្រយោល ដូចជាច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ និងច្បាប់ស្តីពីពន្ធនាគារឆ្នាំ២០១១ ជាដើម។ ច្បាប់បានចែងនូវការលើកលែងទោសជាទូទៅ[៣៦] និងលើកលែងទោសធម្មតាដោយព្រះមហាក្សត្រ។ មាត្រា ៧៧ នៃច្បាប់ពន្ធនាគារផ្តល់បុព្វសិទ្ធិដល់រាជរដ្ឋាភិបាល ក្នុងការស្នើសុំនៅពេលណាក៏បាននូវការលើកលែងទោសដល់ទណ្ឌិត[៣៧]។ បន្ថែមពីលើនេះលិខិតបទដ្ឋានគតិយុត្ត ក៏អនុញ្ញាតឱ្យមានការបន្ធូរបន្ថយទោសផងដែរ[៣៨]។ មានភាពមិនច្បាស់លាស់ថា ពាក្យ**ទណ្ឌិត** សំដៅលើបុគ្គលមានទោសតាមសាលក្រមស្ថាពរឬយ៉ាងណា? ក្នុងករណីដែលពាក្យនេះសំដៅលើតែបុគ្គល ដែលត្រូវបានប្រកាសថាមានទោស តាមរយៈសាលក្រមមិនទាន់ស្ថាពរ វាមានន័យថារាជរដ្ឋាភិបាលអាចស្នើលើកលែងទោសដល់អ្នកដែលមិនទាន់មានទោសស្ថាពរតាមសាលក្រមស្ថាពរ ហាក់មិនស៊ីសង្វាក់គ្នាជាមួយនឹងខ្លឹមសារមាត្រាដ៏ទៃទៀត ដែលអនុញ្ញាតឱ្យលើកលែងទោស ឬបន្ថយទោសក្នុងករណីអនុវត្តទោសក្នុងពន្ធនាគារអស់រយៈពេលកំណត់ណាមួយ តាមរយៈសាលក្រមស្ថាពរ។

បទប្បញ្ញត្តិពាក់ព័ន្ធ មិនបានប្រើពាក្យ **អនុគ្រោះទោស** ដូចមាត្រា ៤០ថ្មី និង មាត្រា ១១ ដែលបានដកស្រង់ក្នុងទំព័រមុនទេ។ វាអាចដូចគ្នានឹងន័យការលើកលែងទោសធម្មតា ដោយព្រះមហាក្សត្រមួយឆ្នាំ បីដង ក្នុងពិធីបុណ្យជាតិសំខាន់ៗ[៣៩]។ ទោះបីជាយ៉ាងនេះក្តីបន្ថែមពីលើខ្លឹមសារនៃមាត្រា ៧៧ នៃច្បាប់ស្តីពី ពន្ធនាគារ ការអនុវត្តកន្លងមក ព្រះមហាក្សត្រក៏អាចលើកលែងទោសដល់ទណ្ឌិតដែលមិនទាន់បានអនុវត្តទោសកំណត់ក្នុងសាលក្រមកំបាំងមុខផងដែរ។

## ផ្នែកទី២ ៖ ច្បាប់ព្រហ្មទណ្ឌថ្មីដែលស្រាលជាង

ប្រភេទច្បាប់ព្រហ្មទណ្ឌថ្មីដែលកំណត់ទោសស្រាលជាង បានន័យថាបទប្បញ្ញត្តិព្រហ្មទណ្ឌដែលចែងអំពីទោសស្រាលជាងនោះ ក៏ត្រូវបានអនុវត្តភ្លាមផងដែរ គឺក្នុងគោលដៅដើម្បីផ្តល់នូវផលអនុគ្រោះដល់ជនល្មើស

[៣៦] ច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣, មាត្រា ៩០(ថ្មី)។
[៣៧] ច្បាប់ស្តីពី ពន្ធនាគារកម្ពុជា ឆ្នាំ២០១១។
[៣៨] សូមមើលឧបសម្ព័ន្ធ ស្តីពី ច្បាប់ និងបទប្បញ្ញត្តិ។
[៣៩] ក្រឹត្យច្បាប់លេខ ២៨ ឆ្នាំ១៩៨៨ របស់ក្រុមប្រឹក្សានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

និងធ្វើឱ្យជនល្មើសចេះកសាងខ្លួនឱ្យក្លាយទៅជាពលរដ្ឋល្អឡើងវិញ ដើម្បីទុកជាគុណប្រយោជន៍សម្រាប់សង្គមជាតិទាំងមូលតទៅថ្ងៃអនាគត។

**ឧទាហរណ៍ ៖**

ប្រសិនបើអំពីនោះកើតឡើងដូចជាបទលួច កើតឡើងនៅក្នុងច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាលឆ្នាំ ១៩៩២-១៩៩៣ មកបានកំណត់ផ្តន្ទាទោសដាក់ពន្ធនាគារចំនួនពី ១ឆ្នាំ ទៅ ៥ឆ្នាំ ហើយកំពុងតែធ្វើការចោទប្រកាន់រហូតមកដល់ព្រហ្មទណ្ឌថ្មីនេះចូលជាធរមាន ឥឡូវកំណត់ត្រឹមតែ ៦ខែ ទៅ ៣ឆ្នាំ។ ដូច្នេះនៅពេលដែលប្រកាសទោស ចៅក្រមយកទោសដែលកំណត់នៅក្នុងក្រមព្រហ្មទណ្ឌនេះគឺចន្លោះពី ៦ខែ ទៅ ៣ឆ្នាំ មកអនុវត្តទៅលើបទលួចដែលប្រព្រឹត្តមុនកាលក្រមព្រហ្មទណ្ឌចូលជាធរមាននេះក៏ព្រោះថាដោយសារក្រមព្រហ្មទណ្ឌថ្មីនេះស្រាលជាង។

ការអនុវត្តភ្លាមនេះបទប្បញ្ញត្តិថ្មី គ្មានអានុភាពទៅលើសុពលភាពនៃកិច្ចនីតិវិធីដែលបានបំពេញស្របទៅតាមបទប្បញ្ញត្តិចាស់នោះឡើយ[៤០] បានន័យថាចំណាត់ការ ឬកិច្ចផ្សេងៗ ដែលត្រូវបានអនុវត្តស្របតាមច្បាប់ ស្ដីពីនីតិវិធី ហើយដែលបានបំពេញស្របតាមវិធានគតិយុត្តដែលមានចែងនៅក្នុងមាត្រានៃច្បាប់ចាស់រួច និងមានតម្លៃស្របច្បាប់ព្រមទាំងមានអានុភាពអនុវត្តបាន គឺបទប្បញ្ញត្តិថ្មីដែលត្រូវអនុវត្តភ្លាមនោះ មិនមានអានុភាពទៅលើបទប្បញ្ញត្តិ ឬវិធានគតិយុត្តដែលមានចែងក្នុងមាត្រានៃច្បាប់ចាស់ៗឡើយ។

**ឧទាហរណ៍ ៖**

ក្នុងបទល្មើសមួយ បើយោងតាមច្បាប់ចាស់គឺផ្តន្ទាទោសធ្ងន់ ចំណែកឯនីតិវិធីនៃការជំនុំជម្រះ គឺបានមកដល់តុលាការកំពូលទៅហើយ ស្រាប់តែមានច្បាប់ថ្មីមួយត្រូវបានប្រកាសឱ្យប្រើ និងមានអានុភាពអនុវត្តនាកំឡុងពេលជំនុំជម្រះក្តីដល់តុលាការកំពូលនេះ។ ម្យ៉ាងទៀតច្បាប់ថ្មីគឺមានចែងនូវបទល្មើសដូចច្បាប់ចាស់ដែរ ប៉ុន្តែមានទោសស្រាលជាង ដូច្នេះត្រូវយកច្បាប់ថ្មីមកប្រើ។ អញ្ចឹងនីតិវិធីដែលបានអនុវត្តមកដល់តុលាការកំពូលរួចហើយទៅតាមច្បាប់ចាស់ គឺត្រូវបន្តអនុវត្តទៅមុខទៀតតែមិនមែនមានន័យថាពេលមានច្បាប់ថ្មីស្រាលជាងបើអនុវត្តច្បាប់ថ្មីត្រូវទៅអនុវត្តនីតិវិធី ពីសាលាដំបូងឡើងមកវិញនោះទេ។ អាស្រ័យហេតុនេះ ទើបគេចែងឱ្យមានមាត្រា ១១ នេះឡើងដើម្បីកុំឱ្យវាក្រឡាប់ចាក់ ឬដើម្បីរក្សាសណ្តាប់ធ្នាប់ និងរបៀបរៀបរយគតិយុត្តឱ្យនៅគង់វង្សបានល្អដដែល ទើបងាយស្រួលអនុវត្ត។

[៤០] មាត្រា ១១ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ចែងពីសុពលភាពនៃកិច្ចនីតិវិធី។

- កិច្ចនីតិវិធី គឺជាចំណាត់ការ ឬកិច្ចផ្សេងៗ ដែលត្រូវបានអនុវត្តស្របតាមច្បាប់ស្តីពីនីតិវិធី[៦១]។
- សុពលភាព គឺជាភាពដែលមានតម្លៃស្របច្បាប់ និងមានអានុភាពអនុវត្ត[៦២]។

ច្បាប់ព្រហ្មទណ្ឌថ្មីដែលស្រាលជាងនេះ គឺមានអានុភាពពីរ ដែលយើងត្រូវបកស្រាយនោះមានដូចជា ៖ **២.១. អានុភាពការអនុវត្តច្បាប់ព្រហ្មទណ្ឌថ្មីស្រាលជាង និង ២.២. ការអនុវត្តច្បាប់ព្រហ្មទណ្ឌថ្មីស្រាលជាងដែលបញ្ញត្តិអំពីទោស។**

## ២.១. អានុភាពការអនុវត្តច្បាប់ព្រហ្មទណ្ឌថ្មីស្រាលជាង

មាត្រា ១០ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌចែងថា ៖ បទប្បញ្ញត្តិថ្មីដែលស្រាលជាងត្រូវអនុវត្តភ្លាម។ ប៉ុន្តែការផ្តន្ទាទោសដែលជាស្ថាពរហើយនោះ ត្រូវអនុវត្តទោះបីទោស ដែលប្រកាសនោះធ្ងន់ធ្ងរជាងយ៉ាងណាក៏ដោយ។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយត្រង់មាត្រា ១៥ កថាខណ្ឌទី១ បានចែងជាបន្ថែមទៀតថា ៖ ប្រសិនបើក្រោយពីការប្រព្រឹត្តបទល្មើសហើយច្បាប់បានបញ្ញត្តិឱ្យមានការដាក់ស្រាលជាងមុន ជនល្មើសត្រូវតែបានទទួលប្រយោជន៍នោះ។

ច្បាប់ថ្មីស្រាលជាងមានអានុភាពអនុវត្ត ចំពោះអំពើទាំងឡាយណាដែលបានកើតឡើងមុនពេលដែលច្បាប់ថ្មីចូលជាធរមាន ហើយពុំទាន់ត្រូវបានវិនិច្ឆ័យជាស្ថាពរនៅឡើយ។ ប្រសិនបើមានសាលក្រម ឬសាលដីកាស្ថាពរ ហើយគេពុំអាចសើរើកែប្រែបានឡើយ លើកលែងតែទណ្ឌិតត្រូវបានដាក់ទោសដោយហេតុផលថាបានប្រព្រឹត្តអំពើណាមួយដែលច្បាប់ថ្មីពុំបានចាត់ទុកថាជាបទល្មើស។ ករណីនេះត្រូវបានបញ្ញត្តិដោះស្រាយដោយមាត្រា ៩ នៃក្រមព្រហ្មទណ្ឌ ដែលបានចែងថា ៖ បទប្បញ្ញត្តិថ្មីដែលលុបចោលបទល្មើសណាមួយនោះត្រូវលុបការអនុវត្តភ្លាម។ អំពើដែលប្រព្រឹត្តមុនបទប្បញ្ញត្តិនេះចូលជាធរមាន មិនអាចត្រូវចោទប្រកាន់ទៀតឡើយ។ ការចោទប្រកាន់ដែលកំពុងប្រព្រឹត្តទៅនោះត្រូវបញ្ចប់។ ប្រសិនបើការផ្តន្ទាទោសជាស្ថាពរត្រូវបានប្រកាសរួចមកហើយ ទោសដែលចេញអំពីការផ្តន្ទាទោសនេះមិនត្រូវអនុវត្តទេ ឬត្រូវតែឈប់ការអនុវត្តនោះភ្លាម។

ការចាត់ទុកថាច្បាប់ថ្មីណាមួយស្រាលជាង ត្រូវតែផ្អែកលើលក្ខណៈវិនិច្ឆ័យដូចបានរៀបរាប់ខាងលើពីករណីច្បាប់ថ្មីធ្ងន់ជាង។ បញ្ហាមួយអាចនឹងចោទឡើងនៅពេលដែលច្បាប់ថ្មីមានបទប្បញ្ញត្តិខ្លះធ្ងន់ជាង ហើយខ្លះទៀតស្រាលជាង ក៏ប៉ុន្តែបទប្បញ្ញត្តិទាំងនោះអាចកាត់ផ្តាច់ចេញពីគ្នាបាន។ ក្នុងករណីបែបនេះ គេត្រូវតែអនុវត្តគោលការណ៍ខាងលើទៅតាមបទប្បញ្ញត្តិនីមួយៗ។

**<u>ឧទាហរណ៍</u> ៖**

[៦១] សទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ របស់ទីស្តីការគណៈរដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១១ លេខរៀងទី២៥។
[៦២] សទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ របស់ទីស្តីការគណៈរដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១១ លេខរៀងទី២៥។

- ទន្ទឹមនឹងការអនុញ្ញាតឱ្យមានការបែងចែកទោសជាប្រភាគ (មាត្រា១៣២ និងមាត្រាបន្តបន្ទាប់ ៖ ក្នុងករណីនេះ ក្រមព្រហ្មទណ្ឌជាច្បាប់ដែលមានលក្ខណៈស្រាលជាង ពីព្រោះថាទោសដែលប្រកាសអាចអនុវត្តជាប្រភាគបាន ហេតុដូច្នេះត្រង់ចំណុចនេះក្រមព្រហ្មទណ្ឌត្រូវបានអានុភាពប្រតិសកម្ម)។ ក្រមព្រហ្មទណ្ឌក៏បាន កំណត់ពីស្ថានទម្ងន់ទោសជាទូទៅ ក្នុងករណីមិនរាងចាលដែលច្បាប់ចាស់ពុំបានចែងទេ (មាត្រា៨៣ និងមាត្រាបន្តបន្ទាប់)។ ហេតុដូច្នេះ ប្រសិនបើមានអំពើណាមួយបានកើតឡើងមុនពេលក្រមព្រហ្មទណ្ឌចូលជាធរមាន តុលាការអាចប្រកាសការបែងចែកទោសជាប្រភាគចំពោះជនល្មើសបាន បើទោះបីជាអំពើប្រព្រឹត្តបានកើតឡើងនៅមុនពេលក្រមព្រហ្មទណ្ឌចូលជាធរមានក៏ដោយ ពីព្រោះថាក្រមព្រហ្មទណ្ឌមានបទប្បញ្ញត្តិស្រាលជាង ក៏ប៉ុន្តែតុលាការមិនអាចយក បទប្បញ្ញត្តិស្តីពីស្ថានទម្ងន់ទោសទាក់ទងនឹងការមិនរាងចាល ដើម្បីបន្ថែមទម្ងន់ទោសទៅលើជនល្មើសបានឡើយ ព្រោះថាក្រមព្រហ្មទណ្ឌមានបទប្បញ្ញត្តិធ្ងន់ជាង។
- មាត្រា ៥២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលផ្តន្ទាទោសការប្រព្រឹត្តបទល្មើសធ្វើឱ្យខូចខាតដោយចេតនាដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ ៣ឆ្នាំ។ ចំណែកឯក្រមព្រហ្មទណ្ឌវិញផ្តន្ទាទោសចំពោះការប្រព្រឹត្តបទល្មើសធ្វើឱ្យខូចខាតដោយចេតនាដាក់ពន្ធនាគារពី ៦ខែ ទៅ ២ឆ្នាំ និងពិន័យជាប្រាក់ពី ១លានរៀល ទៅ ៤លានរៀល។ ក្នុងករណី ដែលមានស្ថានទម្ងន់ទោសដូចមានចែងនៅមាត្រា ៤១១ នៃក្រមព្រហ្មទណ្ឌ ដូចជាការធ្វើឱ្យខូចខាតដោយចេតនា ប្រព្រឹត្តនៅទីកន្លែងណាមួយ ឬលំនៅឋានជាដើម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ ទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានរៀល ទៅ ១០លានរៀល។ ហេតុដូចនេះ ប្រសិនបើជនល្មើសបានប្រព្រឹត្តបទធ្វើឱ្យខូចខាតដោយចេតនា នៅមុនពេលក្រមព្រហ្មទណ្ឌត្រូវបានអនុវត្ត តែអំពើនោះមិនមានស្ថានទម្ងន់ទោសណាមួយនៃមាត្រា ៤១១ នៃក្រមព្រហ្មទណ្ឌនេះទេ គឺត្រូវយកមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌមកអនុវត្តវិញ ពីព្រោះថាបទប្បញ្ញត្តិនេះស្រាលជាងច្បាប់ព្រហ្មទណ្ឌអន្តរកាល។ ផ្ទុយទៅវិញប្រសិនបើជនល្មើសបានប្រព្រឹត្តបទធ្វើឱ្យខូចខាតដោយចេតនានៅមុនពេលក្រមព្រហ្មទណ្ឌត្រូវបានអនុវត្ត ដោយមានស្ថានទម្ងន់ទោសដូចមានចែងនៅមាត្រា ៤១១ នៃក្រមព្រហ្មទណ្ឌ តុលាការមិនអាចយកមាត្រា ៤១១ នៃក្រមនេះទៅអនុវត្តបានទេ ពីព្រោះថាបទប្បញ្ញត្តិនេះមានលក្ខណៈធ្ងន់ធ្ងរជាងច្បាប់ព្រហ្មទណ្ឌអន្តរកាល។

យ៉ាងណាមិញ ប្រសិនបើច្បាប់មួយមានលក្ខណៈធ្ងន់ជាងផង និងស្រាលជាងផងដោយគេពុំអាចបែងចែកឱ្យដាច់ក្នុងបទប្បញ្ញត្តិនោះ ពោលគឺជាបទប្បញ្ញត្តិដែលមានលក្ខណៈអវិភាគ តុលាការត្រូវកំណត់ថា តើក្នុងលក្ខណៈជាទូទៅបទប្បញ្ញត្តិនោះធ្ងន់ជាង ឬក៏ស្រាលជាង។

**<u>ឧទាហរណ៍</u> ៖**

- បទប្បញ្ញត្តិច្បាប់ថ្មីបានកែប្រែបទល្មើសមួយពីបទឧក្រិដ្ឋមកជាបទមជ្ឈិមវិញ ក៏ប៉ុន្តែច្បាប់ថ្មីបានហាមឃាត់ដាច់ខាតនូវរាល់ការអនុគ្រោះទោសខុសប្លែកពីច្បាប់ចាស់ដែលចាត់ទុកបទល្មើសដដែលនោះជាបទឧក្រិដ្ឋ ក៏ប៉ុន្តែអនុញ្ញាតឱ្យអនុគ្រោះទោសបានក្នុងករណីមួយចំនួន។ ក្នុងសម្មតិកម្មខាងលើ ក្នុងលក្ខណៈជាទូទៅគេអាចចាត់ទុកថា ច្បាប់ថ្មីមានលក្ខណៈស្រាលជាងច្បាប់ចាស់។
- មាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ ផ្តន្ទាទោសចំពោះការប្រព្រឹត្តបទធ្វើឱ្យខូចខាតដោយចេតនា ដាក់ពន្ធនាគារពី ៦ខែ ទៅ ២ឆ្នាំ ដែលជាទោសស្រាលជាងទោសដែលមានបញ្ញត្តិនៅក្នុងមាត្រា ៥២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ក៏ប៉ុន្តែទន្ទឹមនឹងទោសដាក់ពន្ធនាគារ ក្រមព្រហ្មទណ្ឌបានបន្ថែមទោសពិន័យជាប្រាក់ជាបន្ថែមទៀត ពី ១លានរៀល ទៅ ៤លានរៀល។ ក្នុងករណីនេះ គេអាចចាត់ទុកថា មាត្រា៤១០ នៃក្រមព្រហ្មទណ្ឌមានលក្ខណៈស្រាលជាងច្បាប់ព្រហ្មទណ្ឌអន្តរកាល ទោះបីជាក្រមព្រហ្មទណ្ឌបន្ថែមទោសពិន័យជាប្រាក់ក៏ដោយ ព្រោះថាថ្វីត្បិតតែការពិន័យជាប្រាក់មានចំនួនច្រើនយ៉ាងណាក៏ដោយ ក៏នៅតែមានលក្ខណៈស្រាលជាងការដាក់ពន្ធនាគារ ដែលនាំឱ្យមានការដកហូតសិទ្ធិសេរីភាពរបស់បុគ្គលដែរ។

## ២.២. ការអនុវត្តច្បាប់ព្រហ្មទណ្ឌថ្មីស្រាលជាងដែលបញ្ញត្តិអំពីទោស

អ្វីទៅជាទោសព្រហ្មទណ្ឌស្រាលជាង? ពិតណាស់បើសិនជាយើងសួរនូវសំណួរបែបនេះ ច្បាស់ណាស់ថាអ្នកច្បាប់ ក៏ដូចជាអ្នកសិក្សាច្បាប់គ្រប់រូប គឺប្រាកដជានឹកឃើញភ្លាមដល់ ការអនុវត្តច្បាប់ព្រហាហ្មទណ្ឌនៅក្នុងពេលវេលា ដែលមានបញ្ញត្តិនៃជំពូកទី២ គន្ថីទី១ ស្តីពីបទប្បញ្ញត្តិទូទៅនៃក្រមព្រហ្មទណ្ឌ។ ហើយអ្វីដែលពិសេសនោះគេប្រាកដជាយល់ភ្លាមដល់ ភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌតែម្តង។ ដោយភាពប្រតិសកម្មនេះបានបញ្ញត្តិផងដែរថា បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសស្រាលជាងត្រូវអនុវត្តភាម។ បទប្បញ្ញត្តិនៃមាត្រានេះ គឺមានគោលបំណងដើម្បីអនុវត្តត្រលប់មកកាន់អតីតកាលវិញ ចំពោះបទល្មើសដែលបានប្រព្រឹត្តនៅក្រោមអានុភាពនៃច្បាប់ចាស់តែកិច្ចនីតិវិធីទាំងប៉ុន្មានពុំទាន់បានបញ្ចប់នៅឡើយទេ ឬអាចនិយាយម្យ៉ាងទៀតថា កិច្ចស៊ើបអង្កេតធ្វើដោយនគរបាលយុត្តិធម៌ កិច្ចចោទប្រកាន់ធ្វើដោយអង្គការអយ្យការ កិច្ចស៊ើបសួរធ្វើដោយចៅក្រមស៊ើបសួរ និងកិច្ចជំនុំជម្រះធ្វើឡើងដោយយុត្តាធិការជំនុំជម្រះ បានបំពេញចប់សព្វគ្រប់អស់ហើយតាំងពីតុលាការជាន់ទាប រហូតដល់តុលាការជាន់ខ្ពស់ គ្រាន់តែសេចក្តីសម្រេចដើម្បីបញ្ជាក់ពីភាពមានពិរុទ្ធរបស់ជនជាប់ចោទពុំទាន់បានចូលជាស្ថាពរប៉ុណ្ណោះ ដោយសារតែនៅមានការជំទាស់ផ្សេងៗ ដែលមិនអាចឱ្យតុលាការបញ្ជាក់ជាស្ថាពរបានឡើយពីទង្វើររបស់ជនជាប់ចោទ ក៏ព្រោះតែមានបណ្តឹងទាស់ បណ្តឹងឧទ្ធរណ៍ នឹងបណ្តឹងសារទុក្ខ ជាអាទិ៍ពីសំណាក់បុគ្គលនោះ។

ក្រោយពីកិច្ចទាំងនោះពុំទាន់បានចប់សព្វគ្រប់ផង ស្រាប់តែលេចនៅវត្តមានអត្ថបទច្បាប់ថ្មី ហើយក៏ចែងពីបទល្មើសនោះដូចគ្នា គ្រាន់តែច្បាប់ថ្មីនេះមានចែងនូវទោសដែលត្រូវអនុវត្តទៅលើបទល្មើសចាស់នោះស្រាលជាងមុនប៉ុណ្ណោះ។ យោងតាមបញ្ហានេះ គឺគេត្រូវយកក្រមព្រហ្មទណ្ឌថ្មីយើងនេះមកអនុវត្តដោយសារថា បទល្មើសដែលប្រព្រឹត្តក្រោមអានុភាពនៃច្បាប់ចាស់តែពុំទាន់បានចូលជាស្ថាពរនៅឡើយ នោះតុលាការត្រូវយកនូវច្បាប់ថ្មីដែលស្រាលជាងមកអនុវត្ត។ នេះបើយោងតាមការបកស្រាយនៃមាត្រាច្បាប់ខាងលើដែលមានចែង។ ហើយការដែលច្បាប់មានអានុភាពអនុវត្តត្រឡប់ទៅកាន់អតីតកាលនេះគេហៅថា គោលការណ៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌស្រាលជាង ព្រោះថាយើងយកច្បាប់ថ្មីដែលស្រាលជាងមកអនុវត្តចំពោះបទល្មើសដែលចែងធ្ងន់ធ្ងរជាងនេះក្រោមការប្រព្រឹត្តដែលស្ថិតក្រោមអានុភាពនៃច្បាប់ចាស់។

## ផ្នែកទី៣ ៖ អញ្ញត្រកម្មទៅនឹងគោលការណ៍អប្រតិសកម្មនៃច្បាប់ថ្មី

គេឃើញមានអញ្ញត្រកម្មប្រាំយ៉ាងទៅនឹងគោលការណ៍អប្រតិសកម្មនៃច្បាប់ថ្មី ពោលគឺ ៖ **៣.១. ច្បាប់ថ្មីអាចអនុវត្តលើការបង្កើតស្ថានភាពគតិយុត្ត ៣.២. ច្បាប់ថ្មីអាចអនុវត្តលើអានុភាពក្នុងអតីតកាលរបស់ស្ថានភាពគតិយុត្ត (ឬលើការបញ្ចប់ស្ថានភាពគតិយុត្តិណាមួយ ដែលមានមុនពេលច្បាប់ថ្មីចូលជាធរមាន) ៣.៣. ច្បាប់ថ្មីអាចអនុវត្តលើស្ថានភាពបញ្ចប់គតិយុត្ត ៣.៤. អញ្ញត្រកម្មទៅនឹងច្បាប់នីតិវិធី និង ៣.៥. អញ្ញត្រកម្មទៅនឹងគោលការណ៍នៃការអនុវត្តភ្លាមៗនៃច្បាប់ថ្មី។**

### ៣.១. ច្បាប់ថ្មីអាចអនុវត្តលើការបង្កើតស្ថានភាពគតិយុត្ត

ច្បាប់ថ្មីអាចបញ្ញត្តិដោយខ្លួនឯងថា នឹងមានឧបនិស្ស័យអនុវត្តលើស្ថានភាពគតិយុត្ត ដែលកើតមាននៅអតីតកាល។ **ឧទាហរណ៍ ៖** ច្បាប់ស្តីពីអន្តោប្រវេសន៍ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៤ មាត្រា ៣ ចែងថា ច្បាប់នេះត្រូវអនុវត្តចំពោះជនបរទេសគ្រប់រូប ទោះជាជននោះបានចូលមកតាំងលំនៅមុនពេលដែលច្បាប់នេះចូលជាធរមានហើយក៏ដោយ។

### ៣.២. ច្បាប់ថ្មីអាចអនុវត្តលើអានុភាពក្នុងអតីតកាលរបស់ស្ថានភាពគតិយុត្ត

ច្បាប់ដែលត្រូវបានអនុម័តក្នុងគោលបំណងបកស្រាយច្បាប់ចាស់ ឬបទប្បញ្ញត្តិណាមួយពីមុនអាចអនុវត្តដោយប្រតិសកម្មបានចាប់ពីថ្ងៃដែលច្បាប់ចាស់មិនច្បាស់លាស់ ដែលជាកម្មវត្ថុនៃការបកស្រាយបានចូលជាធរមាន។ អញ្ញត្រកម្មទីពីរនេះសមស្របតាមតក្កវិជ្ជា ព្រោះថាច្បាប់ដែលមានបំណងបកស្រាយច្បាប់ចាស់ត្រូវបានបង្កើតឡើងគ្រាន់តែដើម្បីបញ្ជាក់ឱ្យច្បាស់នូវអត្ថន័យរបស់ច្បាប់ ដែលមានរួចទៅហើយប៉ុណ្ណោះ។ ថ្វីត្បិតតែមានច្បាប់ពីរផ្សេងគ្នាតែគេនៅចាត់ទុកថាមានច្បាប់មួយប៉ុណ្ណោះ។ ច្បាប់ដែលមានបំណងបកស្រាយច្បាប់ចាប់អនុវត្តតាំងពីថ្ងៃ ដែលច្បាប់ដែលត្រូវបានច្បាប់ថ្មីបកស្រាយចូលជាធរមាន ព្រោះគេសន្មតថាច្បាប់ដែលត្រូវបាន

បកស្រាយដោយច្បាប់ថ្មី មានអត្ថន័យដូចគ្នានឹងអ្វីដែលមានចែងក្នុងច្បាប់ថ្មី ដែលបកស្រាយច្បាប់ចាស់ចាប់តាំងពីពេលច្បាប់ចាស់ចូលជាធរមានមកម្លេះ។

### ៣.៣. ច្បាប់ថ្មីអាចអនុវត្តលើការបញ្ចប់ស្ថានភាពគតិយុត្ត

គេសង្កេតឃើញថា នៅក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ព្រហ្មទណ្ឌស្រាលជាងអាចអនុវត្តលើបទល្មើសទាំងឡាយណា ដែលបានប្រព្រឹត្តមុនពេលច្បាប់ថ្មីចូលជាធរមាន។ នេះជាអញ្ញត្រកម្មដែលមានចែងនៅក្នុងមាត្រា ១១ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ព្រមទាំងមាត្រា ៥ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី ដែលចែងថា បទប្បញ្ញត្តិថ្មីដែលលុបចោលបទល្មើសអាចអនុវត្តភ្លាមៗ ហើយអំពើដែលមានប្រព្រឹត្តមុនពេលច្បាប់នេះ ចូលជាធរមានមិនអាចចោទប្រកាន់ទៀតបានទេ។

### ៣.៤. អញ្ញត្រកម្មទៅនឹងច្បាប់នីតិវិធី

អញ្ញត្រកម្មទីបួននេះពាក់ព័ន្ធទៅនឹងច្បាប់នីតិវិធី ព្រោះថាច្បាប់នីតិវិធីត្រូវអនុវត្តភ្លាមៗបន្ទាប់ពីបានចូលជាធរមាន ទោះជានីតិវិធីជំនុំជម្រះបានចាប់ផ្តើមរួចហើយតាមអំណាចច្បាប់ចាស់ក៏ដោយ។ **ឧទាហរណ៍ ៖** មាត្រា ២៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ កំណត់ថា គ្រប់សំណុំរឿងទាំងអស់ ដែលតុលាការកំពូលបដិសេធ ហើយតុលាការកំពូលបានបញ្ជូនទៅតុលាការខេត្តក្រុង ឬតុលាការយោធាដើម្បីជំនុំជម្រះសារឡើងវិញ ប៉ុន្តែតុលាការទាំងនោះពុំទាន់បានជំនុំជម្រះនៅឡើយ ត្រូវបញ្ជូនទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជម្រះ។ តាមបទប្បញ្ញត្តិខាងលើសាលាឧទ្ធរណ៍ ដែលទើបបង្កើតមានសមត្ថកិច្ចជំនុំជម្រះលើគ្រប់សំណុំរឿងទាំងអស់ ទាំងសំណុំរឿងថ្មី និងសំណុំរឿងដែលកំពុងតែដំណើរការនៅចំពោះមុខសាលាជម្រះក្តី ទោះជារឿងក្តីនោះត្រូវបានសម្រេចរួចម្តងហើយមុនពេលដែលច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពនៃសាលាជម្រះក្តីនៃរដ្ឋកម្ពុជាចូលជាធរមានក៏ដោយ។

### ៣.៥. អញ្ញត្រកម្មទៅនឹងគោលការណ៍នៃការអនុវត្តភ្លាមៗនៃច្បាប់ថ្មី

អញ្ញត្រកម្មចុងក្រោយនេះ ជាអញ្ញត្រកម្មច្បាប់ថ្មីមិនអាចអនុវត្តភ្លាមៗលើកិច្ចនីតិវិធីដែលកំពុងបន្តអនុវត្តទេ បានសេចក្តីថា កិច្ចនីតិវិធីដែលបានអនុវត្តតាមអំណាចច្បាប់ចាស់នៅបន្តគ្រប់គ្រងដោយច្បាប់ចាស់ដដែល។ នេះជាការបន្តអនុវត្តច្បាប់ចាស់ ការអនុញ្ញាតឱ្យមានអញ្ញត្រកម្មខាងលើជាការត្រឹមត្រូវ ព្រោះថាកិច្ចនីតិវិធីត្រូវបានអនុវត្ត គេត្រូវគោរពនូវអ្វីដែលច្បាប់ចាស់បានកំណត់ទុកនៅពេលមុន ហើយម្យ៉ាងវិញទៀតសេចក្តីសម្រេចទាំងឡាយ ដែលបានធ្វើឡើងដោយផ្អែកលើច្បាប់ចាស់ នៅជាធរមានដដែល។ ដូច្នេះកិច្ចនីតិវិធីទាំងឡាយមានអានុភាពអនុវត្តជាបន្តបន្ទាប់ រហូតដល់ក្រោយពេលដែលច្បាប់ថ្មីចូលជាធរមានក៏ដោយ។ **ឧទាហរណ៍៖** កាលពីមុនច្បាប់ព្រហ្មទណ្ឌចែងថា ការលួចទ្រព្យសម្បត្តិរបស់សហព័ទ្ធគឺ ជាបទល្មើស ក៏ប៉ុន្តែនៅពេលក្រោយស្រាប់តែ

ច្បាប់ព្រហ្មទណ្ឌថ្មី បានចូលជាធរមានហើយបានលុបចោលអំពើលួចទ្រព្យសម្បត្តិរបស់សហព័ទ្ធមិនមែនជាបទល្មើស ដូច្នេះប្រសិនបើនីតិវិធីកំពុងចោទប្រកាន់ ឬកំពុងដំណើរការដោយផ្អែកតាមគោលការណ៍ប្រតិសកម្មកំណត់ថា មិនត្រូវធ្វើការចោទប្រកាន់ឡើយ ហើយការចោទប្រកាន់ត្រូវបានបញ្ចប់។

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

ការអនុវត្តច្បាប់ព្រហ្មទណ្ឌត្រូវគោរពគោលការណ៍ ២ គឺគោលការណ៍ប្រតិសកម្ម និងគោលការណ៍មិនប្រតិសកម្ម។ បើនិយាយអំពីដែនអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងកាល គឺការអនុវត្តច្បាប់ព្រហ្មទណ្ឌត្រូវផ្អែកលើគោលការណ៍ពីរផ្ទុយគ្នា ប៉ុន្តែមិនដាច់ដោយឡែកពីគ្នាទេ ពោលគឺគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌដែលធ្ងន់ជាង និងគោលការណ៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង។

គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ គឺជាគោលការណ៍គ្រឹះនៃនីតិព្រហ្មទណ្ឌ។ សញ្ញាណនៃគោលការណ៍នេះចេញមកពីប្រទេសបារាំង ដែលកើតមានតាំងពីឆ្នាំ ១៧៨៩ នៅក្នុងសេចក្ដីថ្លែងការណ៍មួយនៅក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសបារាំង។ ហើយគោលការណ៍នេះ គឺជាគោលការណ៍គ្រឹះនៃនីតិសិទ្ធិមនុស្ស និងនៅក្នុងលិទ្ធិប្រជាធិបតេយ្យ ដើម្បីធានានូវសិទ្ធិសេរីភាព និងសុវត្ថិភាពគតិយុត្តិរបស់ពលរដ្ឋ។ បន្ថែមពីនេះទៀតនោះវាគឺគោលការណ៍មួយដែលសម្រាប់ការពារ ការសងសឹកគ្នារវាង គណបក្សនយោបាយ និងគណបក្សនយោបាយដែលការពារមិនឱ្យអ្នកដែលឡើងកាន់អំណាចក្រោយ សងសឹកទៅលើអ្នកកាន់អំណាចមុន ដែលបាត់បង់អំណាច។ គោលការណ៍នេះ គឺជាគោលការណ៍វិបាកកម្ម ដែលវាត្រូវដើរទន្ទឹមគ្នាជាមួយនឹងគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងទោស។

ជារួមមកគោលការណ៍នេះគឺមានន័យថា ច្បាប់ព្រហ្មទណ្ឌ គឺមានអានុភាពអនុវត្តតែទៅអនាគត ហើយមិនមានអានុភាពអនុវត្តទៅអតីតកាលទេ។ មានន័យថា អនុវត្តតែទៅលើបទល្មើសណាមួយដែលកើតក្រោយច្បាប់ព្រហ្មទណ្ឌចូលជាធរមានតែប៉ុណ្ណោះ។ ដូចនេះច្បាប់ព្រហ្មទណ្ឌដែលធ្ងន់ជាង មិនអាចអនុវត្តទៅនឹងបទល្មើសដែលកើតមុនច្បាប់ព្រហ្មទណ្ឌនោះចូលជាធរមាននោះទេ ពោលគឺមិនប្រតិសកម្មនោះទេ។ ត្រង់ចំណុចនេះដែរ អំពើទាំងឡាយណាដែលបានប្រព្រឹត្តក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាល មិនអាចយកច្បាប់ព្រហ្មទណ្ឌថ្មីទៅអនុវត្តទៅលើបទល្មើសនោះទេ ពីព្រោះច្បាប់ព្រហ្មទណ្ឌថ្មីមានលក្ខណៈធ្ងន់ជាងច្បាប់ព្រហ្មទណ្ឌអន្តរកាល។

ដូចច្នេះហើយគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌខាងលើនេះ ពិតជាមានសារៈសំខាន់ណាស់សម្រាប់អ្នកអនុវត្តច្បាប់នាពេលបច្ចុប្បន្ន ក៏ដូចជាទៅថ្ងៃអនាគត ជាពិសេសគឺចំពោះចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីនគរបាលយុត្តិធម៌។ ដោយសារតែបុគ្គលទាំងអស់នេះ គឺជាអ្នកអនុវត្តច្បាប់ ដូចនេះរាល់ច្បាប់ថ្មីទាំងអស់ដែលអនុម័តរួចដាក់ឱ្យប្រើប្រាស់ គឺត្រូវមានវគ្គបណ្ដុះបណ្ដាលចំពោះមន្ត្រី ឱ្យបានយល់កាន់តែច្បាស់ទាំងគោលការណ៍ច្បាប់ និងនីតិវិធីក្នុងការអនុវត្ត។ ហើយអ្វីដែលពិសេសជាងនេះ វាពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ទណ្ឌិតដែលបានទទួលផលប្រយោជន៍ ពីការចូលជាធរមាននៃអត្ថបទច្បាប់ថ្មី ឬក្រមព្រហ្មទណ្ឌថ្មីនេះទៅលើគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ដែលគោលការណ៍នេះ មានអានុភាពអនុវត្តសម្រាប់ឆ្ពោះទៅអនាគតប៉ុណ្ណោះ និងគោលការណ៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌដែលលុបចោលបទល្មើស

ណាមួយ ដែលខ្លួនបានប្រព្រឹត្តនៅក្នុងសម័យអន្តរកាលហើយក្រោយមកក៏មានក្រមព្រហ្មទណ្ឌថ្មីយើងនេះបានចូលជាធរមាន ហើយបានលុបចោលនូវអំពើល្មើសណាមួយដែលបានប្រព្រឹត្តនោះចេញ ដោយពុំចាត់ទុកថាជាបទល្មើសនោះទេ។ នេះសម្រេចបានថា ក្រោយមានការលុបចោលនូវបទល្មើសណាមួយ ដែលបានប្រព្រឹត្តនៅក្នុងសម័យអន្តរកាល ឬប្រព្រឹត្តមុនការចូលជាធរមាននៃក្រមព្រហ្មទណ្ឌថ្មី ហើយអំពើនោះត្រូវច្បាប់ក្រោយពុំបានចាត់ទុកថាជាបទល្មើសទេនោះ ហេតុនេះនាំឱ្យទណ្ឌិត ឬជនជាប់ចោទទាំងអស់ដែលត្រូវបានចោទប្រកាន់ ឬដំណើរការនីតិវិធីហើយតែមិនទាន់បានសម្រេចសេចក្តី ត្រូវតែបញ្ឈប់ការចោទប្រកាន់ ឬនីតិវិធីទាំងអស់ ឬបញ្ឈប់ការអនុវត្តទោសតែម្តង។ នេះហើយជាអត្ថប្រយោជន៍ដែលជនល្មើសបានទទួលនៅក្រោមអានុភាពនៃច្បាប់ព្រហ្មទណ្ឌថ្មី ដោយសារការលុបចោលនូវបទល្មើសណាមួយ។

ចំពោះការអនុវត្តទោសដែលស្រាលជាង ឬធ្ងន់ជាងវិញ ក៏មានការចាំបាច់សម្រាប់ការអនុវត្តផងដែរ ដោយសារថា ចៅក្រមដែលសម្រេចសេចក្តីពីបញ្ហាណាមួយទៅលើអំពើណាមួយដែលបានប្រព្រឹត្តក្រោមកិច្ចនៃច្បាប់ចាស់ តែពុំទាន់បានចូលជាស្ថាពរនៅឡើយ ដោយសារតែមានការប្តឹងបន្តផ្សេងៗទៀត។ លុះក្រោយមកច្បាប់ថ្មីក៏បានចែងអំពើដែលប្រព្រឹត្តដូចគ្នា គ្រាន់តែខុសគ្នានូវអតិបរមា និងអប្បបរមាប៉ុណ្ណោះ ដែលច្បាប់ថ្មីស្រាលជាងច្បាប់ចាស់នោះ គឺត្រូវអនុវត្តភ្លាមតែម្តង ឬអាចនិយាយបានថាច្បាប់ថ្មីមានអានុភាពប្រតិសកម្មក្រោយការចូលជាធរមានចំពោះទោសដែលស្រាលជាង។ ក៏ប៉ុន្តែក្រមថ្មីនេះបានបញ្ជាក់បន្ថែមថា ការផ្តន្ទាទោសដែលចូលជាស្ថាពរហើយនោះ ត្រូវអនុវត្តទោះបីទោសដែលប្រកាសនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ។ នេះអាចបញ្ជាក់បានថា ច្បាប់ថ្មីមានអានុភាពប្រតិសកម្មទៅលើអំពើណាដែលបានប្រព្រឹត្តហើយត្រូវបានតុលាការសម្រេចផ្តន្ទាទោសដែលមិនទាន់ចូលជាស្ថាពរ ហើយទោសដែលចេញពីសេចក្តីសម្រេចនោះត្រូវតែអនុវត្ត ទោះបីជាទោសនោះធ្ងន់ធ្ងរជាងច្បាប់ថ្មីយ៉ាងណាក៏ដោយ។ ភាពមិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌថ្មីធ្ងន់ជាងដែលច្បាប់ថ្មីដែលកំណត់ស្ថានទម្ងន់នៃបទល្មើស និងទោសធ្ងន់ជាងច្បាប់ចាស់អាចអនុវត្តបានតែចំពោះ អំពើល្មើសដែលបានប្រព្រឹត្តឡើងចាប់ពីថ្ងៃចូលជាធរមាននៃច្បាប់នោះតែប៉ុណ្ណោះ។ ចំណែកឯ ច្បាប់ព្រហ្មទណ្ឌថ្មីស្រាលជាង គឺមានអានុភាពអនុវត្តភ្លាមៗ និងមានអានុភាពប្រតិសកម្ម នៃច្បាប់ព្រហ្មទណ្ឌថ្មីស្រាលជាង។ ក្នុងន័យនេះច្បាប់ព្រហ្មទណ្ឌថ្មីស្រាលជាងអនុវត្តមិនត្រឹមតែចំពោះអំពើ ដែលបានប្រព្រឹត្តនិងមិនទាន់បានជំនុំជំរះដោយសេចក្តីសំរេចស្ថាពរមុនការចូលជាធរមាននៃច្បាប់នោះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអនុវត្តចំពោះនីតិវិធីដែលកំពុងដំណើរការនោះទៀតផង។

ចំពោះគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ក៏មានអញ្ញត្រកម្មផងដែរ ប្រសិនបើអ្នកនីតិបញ្ញត្តិបានចែងយ៉ាងច្បាស់លាស់ទុកជាមុនថា ច្បាប់ដែលនឹងចូលជាធរមានត្រូវតែមានអានុភាពប្រតិសកម្ម។ អញ្ញត្រកម្មនៃគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌមាន ៖ ច្បាប់ថ្មីអាចអនុវត្តលើការបង្កើតស្ថានភាពគតិយុត្ត

លើអានុភាពក្នុងអតីតកាលរបស់ស្ថានភាពគតិយុត្ត ឬលើការបញ្ចប់ស្ថានភាពគតិយុត្ត អញ្ញត្រកម្មទៅនឹងច្បាប់នីតិវិធី និងអញ្ញត្រកម្មទៅនឹងគោលការណ៍នៃការអនុវត្តភ្លាមៗនៃច្បាប់ថ្មី។ ដែលគោលការណ៍អញ្ញត្រកម្មនេះអាចផ្តល់អានុភាពដល់ការប្រតិសកម្ម ឬមិនប្រតិសកម្មនៃច្បាប់ ទាំងច្បាប់ចាស់ ឬច្បាប់ថ្មី និងពិសេសទៅលើអញ្ញត្រកម្មនៃច្បាប់នីតិវិធីដែលត្រូវអនុវត្តភ្លាមៗ។

ដូចនេះការស្រាវជ្រាវលើប្រធានបទនេះបានផ្តល់នូវផលប្រយោជន៍ ការយល់ដឹង ភាពស៊ីជម្រៅបន្ថែមទៀតស្តីពី **គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ**។ នៅក្នុងគោលការណ៍នេះ សំដៅទៅលើស្ថានទម្ងន់ទោស ធ្ងន់ ឬស្រាល អញ្ញត្រកម្ម ផលវិបាកនៃគោលការណ៍នីត្យានុកូល ឬគ្មានច្បាប់ចែង គ្មានបទល្មើស គ្មានទោស ការលុបចោលបទល្មើស ការបន្ធូរបន្ថយ ឬការលើកលែងទោសជាដើម។ មិនតែប៉ុណ្ណោះ ផ្នែកដែលចម្បងមួយទៀតនោះ គឺកិច្ចនីតិវិធី ឬការអនុវត្ត ដែលជាកត្តាចម្បងក្នុងការប្រព្រឹត្តទៅនៃច្បាប់ថ្មីមួយ ថាតើមានអានុភាពក្នុងការគ្រប់គ្រង និងដាក់ឱ្យពលរដ្ឋចូលរួមគោរពតាមបានកម្រិតណា ដែលនេះយើងត្រូវផ្តើមចេញពីមន្ត្រី ជាអ្នកអនុវត្តជាមុនសិន ដោយយើងអាចនិយាយបានថា អង្គការនីតិបញ្ញត្តិបង្កើតច្បាប់ឱ្យទាន់សម័យកាល រីឯមន្ត្រីជាអ្នកអនុវត្តត្រូវរត់តាមច្បាប់ ហើយត្រូវមានតួនាទី ផ្សព្វផ្សាយ ពន្យល់ អប់រំ បណ្តុះបណ្តាលដល់ពលរដ្ឋឱ្យបានយល់ដឹងពីច្បាប់ហើយត្រូវចូលរួមគោរពច្បាប់។ ម្យ៉ាងទៀត យើងក៏បានឃើញថាគោលការណ៍ខាងលើនេះ ក៏មានភាពស្មុគស្មាញមួយចំនួនដែរ ដោយមានភាពមិនប្រតិសកម្ម និងប្រតិសកម្ម ដែលតម្រូវឱ្យយើងត្រូវស្វែងរកច្បាប់ចាស់មកធ្វើការប្រៀបធៀបជាមួយ និងច្បាប់ថ្មី ដើម្បីអាចកំណត់បានថាអត្ថបទច្បាប់ណាមួយដែលយើងត្រូវយកមកប្រើប្រាស់ពិតប្រាដក។

សរុបមកវិញ នៅក្នុងគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌនេះ គឺផ្តោតសំខាន់ទៅលើការបន្ធូរបន្ថយទោស ដែលជាការផ្តល់ប្រយោជន៍ដល់ជនល្មើស ឬជនជាប់ចោទដែលបានប្រព្រឹត្តអំពើល្មើសនៅមុនពេលច្បាប់ថ្មីចូលជាធរមាន ប៉ុន្តែក្រោយអំពីការបង្កើតច្បាប់ថ្មី បានចូលជាធរមាន ច្បាប់ថ្មីនេះទៅសោត ក៏បានលុបចោល ឬបន្ធូរបន្ថយនូវស្ថានទម្ងន់ទោសនៃបទល្មើសនោះ។ យើងអាចបញ្ជាក់បានថាគោលការណ៍នេះគឺមានការទទួលស្គាល់ជាអន្តរជាតិ ដែលផ្តល់ឱកាសដល់ទណ្ឌិតក្នុងការកែប្រែខ្លួន ចរិតកិរិយា មាយាទ ឱ្យសមស្របដោយបង្ហាញឆន្ទៈឱ្យឃើញថា ខ្លួនមានចិត្តចង់កែប្រែពិតប្រាកដមែន។ ជាងនេះទៅទៀតគោលការណ៍នេះគឺមានចរិតក្នុងការបែងចែកឱ្យបានច្បាស់លាស់រវាង គោលការណ៍មិនប្រតិសកម្មធ្ងន់ជាង និងស្រាលជាង ដែលផ្តល់នៅដំណោះស្រាយនិងនីតិវិធីក្នុងការអនុវត្តច្បាប់ថ្មី ដែលអង្គការនីតិប្បញ្ញត្តិបានចែងឡើង ឱ្យមានភាពស៊ីសង្វាក់ទៅនឹងស្ថានភាពសង្គម និងធ្វើឱ្យមានអានុភាព ក្នុងការយកទៅប្រើប្រាស់នៅក្នុងប្រទេសនោះផងដែរ។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានឆ្លងកាត់ការសិក្សាស្រាវជ្រាវទៅលើប្រធានបទ **គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ** រួចមកយើងសង្កេតឃើញថា ការអនុវត្តច្បាប់ព្រហ្មទណ្ឌគឺត្រូវគោរពតាមគោលការណ៍គ្រឹះពីរយ៉ាង គឺគោលការណ៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ និងគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ។ ដើម្បីឱ្យមានការអនុវត្តច្បាប់មួយមានភាពត្រឹមត្រូវ ចាំបាច់ណាស់ត្រូវតែអនុវត្តទៅតាមនីតិវិធី ដែលបានកំណត់នៅក្នុងខ្លឹមសារច្បាប់។ នៅពេលដែលមានបទល្មើសមួយបានកើតឡើង យើងប្រាកដជាត្រូវពិនិត្យមើលថាតើវាស្ថិតនៅក្នុងអានុភាពនៃការអនុវត្តរបស់ច្បាប់អ្វី ប្រភេទបទល្មើសអ្វី ដើម្បីធ្វើការកំណត់អំពីស្ថានទម្ងន់ទោសនៃបទល្មើសនោះ។

ដោយសារសង្គមជាតិតែងតែមានការអភិវឌ្ឍន៍ទៅមុខជាបន្តបន្ទាប់ ដូចនេះច្បាប់ក៏ត្រូវតែមានការកែប្រែ ឬធ្វើវិសោធនកម្ម ដើម្បីដើរឱ្យទាន់សម័យកាលផងដែរ។ សភាបានអនុម័តច្បាប់ដើម្បីថែរក្សាសណ្តាប់ធ្នាប់សង្គម ការពារផលប្រយោជន៍ជាតិ និងបំពេញបន្ថែមនៅចន្លោះខ្វះខាតនៃច្បាប់ចាស់ ប៉ុន្តែយើងសង្កេតឃើញថានៅមានភាពចន្លោះខ្វះនៅក្នុងការអនុវត្តដូចជា ៖

**១. ការផ្សព្វផ្សាយ ៖** យើងបានដឹងស្រាប់ហើយថា ក្រោយការប្រកាសឱ្យប្រើនូវក្រមព្រហ្មទណ្ឌថ្មីនេះ គឺក្រសួងយុត្តិធម៌ បានសហការជាមួយនឹងក្រសួងព័ត៌មានក្នុងការផ្សព្វផ្សាយនូវច្បាប់ថ្មីនេះ តាមរយៈមធ្យោបាយទូរគមនាគមន៍ផ្សេងៗដើម្បីឱ្យអ្នកអនុវត្តច្បាប់ទាំងឡាយ រួមទាំងពលរដ្ឋមានការយល់ដឹងឱ្យបានកាន់តែច្រើនអំពីបញ្ហាផ្លូវច្បាប់។ ប៉ុន្តែការផ្សព្វផ្សាយបែបនេះនៅមានភាពខ្វះចន្លោះ ព្រោះថាបើសិនអាជ្ញាធរបានបង្កើតក្រុមការងារចុះធ្វើការផ្សព្វផ្សាយផ្ទាល់ជាមួយពលរដ្ឋក្នុងមូលដ្ឋាន នោះច្បាប់ដែលបានប្រកាសឱ្យប្រើនេះ គឺកាន់តែមានប្រសិទ្ធិភាពក្នុងការអនុវត្ត ហើយពលរដ្ឋក៏យល់ដឹងច្រើនពីបញ្ហាផ្លូវច្បាប់ដែរ។

**២. ការចូលរួម ៖** ការចូលរួមក្នុងន័យនេះ គឺចង់សំដៅដល់ការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងការចូលរួមតាមដានសម្តែងជាមតិទាំងឡាយណាដែលខ្លួនយល់ឃើញថាគួរ ឬមិនគួរនៅពេលដែលសភាធ្វើការអនុម័ត នូវអត្ថបទច្បាប់ណាមួយ។ ពីព្រោះថាច្បាប់ចែងមកសម្រាប់ឱ្យពលរដ្ឋអនុវត្ត ចុះបើពលរដ្ឋមិនបានដឹងពីច្បាប់ មិនចូលរួមក្នុងការអនុវត្ត ពលរដ្ឋធ្វើការប្រឆាំង មិនពេញចិត្តអញ្ចឹងតើច្បាប់នោះបង្កើតមកដើម្បីអ្វី បើពលរដ្ឋខ្លួន មិនគាំទ្រផងនោះ។

**៣. ការបណ្តុះបណ្តាល ៖** ការបណ្តុះបណ្តាលនេះ គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់ប្រទេសជាតិនានានូវទូទាំងសកលលោក ព្រោះថាបើច្បាប់ចែងមកល្អហើយ តែមន្ត្រីអនុវត្តមិនបានល្អនោះប្រាកដណាស់និងធ្វើឱ្យរាស្ត្ររងទុក្ខជាក់ជាមិនខាន ដូចពាក្យមួយបានពោលថា **ច្បាប់ចែងល្អឥតខ្ចោះ ស្រណោះតែអ្នកអនុវត្ត។** ដូច្នេះគុណភាពមន្ត្រី គឺត្រូវតែមានសមត្ថភាព និងចំណេះជំនាញពិតប្រាកដដែរ ទើបអាចធ្វើឱ្យសង្គមជាតិខ្លួន

មានភាពរីកចម្រើនបន្តទៅមុខបាន ពិសេសក៏បានធ្វើឱ្យពលរដ្ឋខ្លួនមានភាពកក់ក្ដៅ និងទំនុកចិត្តទៅលើច្បាប់ ក៏ដូចជាមន្ត្រីដែលអនុវត្តច្បាប់ផងដែរ។

ជារួមមកយើងមិនចង់ឃើញប្រទេសដែលមានច្បាប់ល្អ ប៉ុន្តែពលរដ្ឋភាគច្រើនប្រព្រឹត្តអំពើល្មើសនោះទេ ការយល់ដឹងរបស់ប្រជាពលរដ្ឋពិតជាមានសារៈសំខាន់ណាស់ នៅក្នុងការចូលរួមអភិវឌ្ឍន៍ប្រទេសជាតិមួយឱ្យមានស្ថេរភាពក្នុងសង្គម សេរីភាព សន្តិសុខសុវត្ថិភាព សន្តិភាព និងភាពរីកចម្រើន។

# ឯកសារយោង

## ឯកសារយោង

### ១. ប្រភពជាបទដ្ឋានគតិយុត្ត

- **បទដ្ឋានគតិយុត្តជាតិ**
    - រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការដោយព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣
    - បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល ដោយសេចក្តីសម្រេច ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២
    - សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៣
    - ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រសម/១១០៩/០២២ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
    - ច្បាប់ព្រហ្មទណ្ឌអន្តរកាល (បទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល) សេចក្តីសម្រេចចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២
    - ច្បាប់ស្តីពីពិសោធនកម្មច្បាប់ព្រហ្មទណ្ឌ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២១៨/០០៣ នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨
    - ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧
    - ពន្យល់ក្រមព្រហ្មទណ្ឌ រៀបរៀងដោយលោក លីន សិលា
    - ក្រមព្រហ្មទណ្ឌ រៀបរៀងដោយលោក ជឹង ប៊ុនឡេង បកប្រែ ភាសាខ្មែរ-អង់គ្លេស បោះពុម្ពលើកទីពីរ ខែមករា ឆ្នាំ២០១៥
    - ក្រឹត្យច្បាប់លេខ ២៨ ឆ្នាំ១៩៨៨ របស់ក្រុមប្រឹក្សានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា
    - ច្បាប់ស្តីពី ពន្ធនាគារកម្ពុជា ឆ្នាំ២០១១
    - សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៣៦/០០២/២០០០ កបធ.ច ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០០
    - ច្បាប់ស្តីពី ការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ ឆ្នាំ១៩៩៤។

- **បទដ្ឋានគតិយុត្តអន្តរជាតិ**
  - កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងពិធីសារបន្ថែម បោះពុម្ពផ្សាយដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ការិយាល័យប្រចាំនៅកម្ពុជា ខែតុលា ឆ្នាំ២០០៩ បានចូលជាធរមានតាមច្បាប់អន្តរជាតិនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦
  - អនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៤៨
  - អនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងការទូតចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៦១
  - អនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងកុងស៊ុលចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៦៣
  - កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦
  - លក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨
  - អនុសញ្ញាស្តីពីសិទ្ធិកុមារ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩
  - សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ដែលត្រូវបានផ្តល់សច្ចាប័ន និងប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ ជស/រកម/០៧៩៩/០៨ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៩
  - សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ដែលត្រូវបានផ្តល់សច្ចាប័ន និងប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០០/០៤ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០០
  - សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដែលត្រូវបានផ្តល់សច្ចាប័ន និងប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៣០៥/០០៦ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៥
  - សន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌដែលត្រូវបានផ្តល់សច្ចាប័ន និងប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០១១០/០១ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១០
  - កិច្ចព្រមព្រៀងស្តីពីបត្យាប័នរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ដែលបានផ្តល់សច្ចាប័ន និងប្រកាសឱ្យប្រើតាមព្រះរាជាក្រមលេខ នស/រកម/០១១១/០០១ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១១

- សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលត្រូវបានផ្តល់សច្ចាប័ន និងប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០២០ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤
- កិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលកម្ពុជា និងប្រធានាធិបតិយ្យអាមេរិកស្តីពីការមិនប្រគល់ខ្លួនជូនតុលាការឧក្រិដ្ឋកម្មអន្តជាតិ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥។

## ២. ឯកសារជាសៀវភៅ

- មេរៀនក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ពន្យល់ដោយ ឯកឧត្តម កើត រិទ្ធិ ឯកឧត្តម ប៊ុន ហ៊ុន ឯកឧត្តម ហ៊ី សោភា ឯកឧត្តម ផូវ សំភី លោកស្រី ចាំង ស៊ីុណាត ចងក្រងដោយលោក សឿន មុន្នីរ័ត្ន ព្រះរាជអាជ្ញារងខេត្តកំពង់ធំ
- នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្រ្តាចារ្យ រុន ពណ្ណារិទ្ធ កែសម្រួលដោយលោកស្រី ចាំង ស៊ីុណាត ឆ្នាំ២០១២
- នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្រ្តាចារ្យ រុន ពណ្ណារិទ្ធ កែសម្រួលដោយលោកស្រី ចាំង ស៊ីុណាត ឆ្នាំ២០២២
- នីតិព្រហ្មទណ្ឌថ្នាក់បរិញ្ញាបត្រ រៀបរៀងដោយសាស្រ្តចារ្យ ហ៊ី សោភា ប្រធានតុលាការខេត្តកណ្តាល
- នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្រ្តាចារ្យ ហ៊ាង ឡេង
- នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្រ្តាចារ្យ កៅ សីហា កំពុងសិក្សាថ្នាក់បណ្ឌិតច្បាប់ សាស្រ្តាចារ្យច្បាប់ និងជាមន្ត្រីរាជការ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចឆ្នាំ២០១៣
- មេរៀននីតិព្រហ្មទណ្ឌ ក្រោមកិច្ចសហកាប្រតិបត្តិការបារាំងគម្រោងទ្រទ្រង់នីតិរដ្ឋ
- សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ដែនអនុវត្តច្បាប់ព្រហ្មទណ្ឌនៅព្រះរាជាណាចក្រកម្ពុជា របស់និស្សិតឈ្មោះ ឡឹក សាលីន និង លី ឆោម សាស្រ្តាចារ្យណែនាំលោក ហោ សុភ័ណ្ឌ
- សេចក្តីផ្តើមនៃនីតិកម្ពុជា រៀបរៀងដោយកញ្ញា បេអាទ្រីស បាលីវ និងលោកស្រី ចាំង ស៊ីុណាត...ឆ្នាំ២០០៣
- បាវចកថាស្តីពីគោលការណ៍គ្រឹះធំៗនៃក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ របស់ក្រសួងយុត្តធម៌ដែលរៀបរៀងដោយ ឯកឧត្តម កើត រិទ្ធិ
- ពិភាក្សាព្រហ្មទណ្ឌច្បាប់កម្ពុជា រៀបរៀងដោយ ស្មួត ខូហៀល ក្រុមអ្នកច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា

- សទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ របស់ទីស្តីការគណៈរដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១១
- សៀវភៅរបស់ ឯកឧត្តម បណ្ឌិត សាយ បូរី ស្តីពី "សេចក្តីផ្តើមចូលសិក្សានីតិរដ្ឋបាលទូទៅខ្មែរ" នៅសាកលវិទ្យាល័យបាត់ដំបង នាថ្ងៃទី១៦ និងទី១៧ ខែមិថុនា ឆ្នាំ២០១២។

## ៣. ប្រភពឯកសារផ្សេងៗ

- ប្រសាសន៍ឯកឧត្តម កើត រិទ្ធិ ក្នុងពេលបង្រៀនសិស្សនិស្សិតនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
- ប្រសាសន៍របស់ ឯកឧត្តម កើត រិទ្ធ អនុប្រធានក្រុមការងារចូលរួមតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ នាកាលបង្រៀនដល់អ្នករៀបរៀង នៅសាលាមធ្យមសិក្សាគរុកោលស្ស មត្តេយ្យមជ្ឈិម ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ (បច្ចុប្បន្នរដ្ឋមន្ត្រី នៃក្រសួងយុត្តិធម៌)
- ប្រសាសន៍ឯកឧត្តម កើត រិទ្ធិ ឯកឧត្តម ប៊ុន ហ៊ុន ឯកឧត្តម ផូវ សំភី ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពីក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌សហការជាមួយក្រសួងព័ត៌មាន តាមរយៈទូរទស្សន៍ជាតិកម្ពុជា ឆ្នាំ២០១០
- Page Facebook (ផេកហ្វេសប៊ុក) Law of Cambodia ប្រធានបទស្តីពី គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ រៀបដោយ ស៊ុយ ច័ន្ទថី។

# ឧបសម្ព័ន្ធ

**UNITED NATIONS**
UNITED NATIONS TRANSITIONAL AUTHORITY IN CAMBODIA
(UNTAC)

**NATIONS UNIES**
AUTORITE PROVISOIRE DES NATIONS UNIES AU CAMBODGE
(APRONUC)

# បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌ សំរាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល




# *PROVISIONS RELATING TO THE JUDICIARY AND CRIMINAL LAW AND PROCEDURE APPLICABLE IN CAMBODIA DURING THE TRANSITIONAL PERIOD*

# *DISPOSITIONS RELATIVES AU SYSTEME JUDICIAIRE AU DROIT PENAL ET ALA PROCEDURE PENALE APPLICABLES AU CAMBODGE PENDANTLA PERIODE TRANSITOIRE*

# បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌ សំរាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល

សេចក្តីសំរេចចុះថ្ងៃទី ១០ កញ្ញា ១៩៩២

**ក្រុមប្រឹក្សាជាតិជាន់ខ្ពស់** ដែលចាប់ពីពេលនេះទៅហៅថា «SNC» អេស អិន ស៊ី

- ដោយសំអាងលើអំណាចទាំងឡាយ ដែលប្រគល់ឡើងតាមមាត្រា ៣ នៃកិច្ចព្រមព្រៀងស្តីអំពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជាចុះថ្ងៃទី ២៣ តុលា ១៩៩១ ដែលចាប់ពីពេលនេះទៅហៅថា «កិច្ចព្រមព្រៀង» ទុកដូចជាអង្គការពេញច្បាប់តែមួយគត់ ហើយជាព្រភពនៃអាជ្ញាធរកម្ពុជា,

- ដោយរំលឹកឡើងវិញនូវមាត្រា៦ នៃកិច្ចព្រមព្រៀងដែលនៅក្នុងនោះ SNC បានប្រគល់ជូនដល់អង្គការសហប្រជាជាតិ នូវអំណាចទាំងអស់ដែលចាំបាច់សំរាប់អនុវត្តកិច្ចព្រមព្រៀង,

- ដោយរំលឹកបន្ថែមទៀតថា ក្រុមប្រឹក្សាសន្តិសុខ នៃអង្គការសហប្រជាជាតិ តាមរយៈសេចក្តីសម្រេចចិត្ត ៧៤៥ (១៩៩២) បានរៀបចំអាជ្ញាធរបណ្តោះអាសន្ន នៃអង្គការសហប្រជាជាតិនៅប្រទេសកម្ពុជា ដែលចាប់ពីពេលនេះតទៅហៅថា «អ៊ុនតាក់» ស្របតាមមាត្រា ២ នៃកិច្ចព្រមព្រៀង ដើម្បីបំពេញតួនាទីភារកិច្ច ដែលចែងឡើងក្នុងឧបសម្ព័ន្ធទី១ នៃកិច្ចព្រមព្រៀង,

- ដោយយល់ថា អ៊ុនតាក់ ត្រូវបានទទួលបេសកកម្មមួយ, ស្របតាមមាត្រា ៦ និង ១៦ នៃកិច្ចព្រមព្រៀងប៉ារីស និងផ្នែក ខ និង ង នៃឧបសម្ព័ន្ធទី១, ក្នុងការត្រួតពិនិត្យផ្ទាល់ ឬ ការពិនិត្យត្រួតត្រាលើវិស័យទាំងឡាយ ស្តីអំពីការរក្សារបៀបរៀបរយ និងការគោរពច្បាប់, ការការពារសិទ្ធិមនុស្ស, ការអនុវត្តន៍ច្បាប់ និងដំណើរការក្នុងប្រព័ន្ធតុលាការ,

- ដោយយល់ឃើញថែមទៀតថា ភាគីទាំងឡាយនៃកិច្ចព្រមព្រៀង បានទទួលស្គាល់ដោយជាក់លាក់, ក្នុងមាត្រា១៥, ថាមនុស្សគ្រប់រូបនៅប្រទេសកម្ពុជា និងជនភៀសខ្លួនទាំងអស់ និងជនផ្លាស់ប្តូរទីកន្លែងទាំងអស់នៅកម្ពុជា ត្រូវមានសិទ្ធិ និងសេរីភាពដែលមានចែងនៅក្នុងសេចក្តីថ្លែងការណ៍សាកលស្តីអំពីសិទ្ធិមនុស្ស និងក្នុងបណ្តាកិច្ចព្រមព្រៀងអន្តរជាតិទាំងឡាយដែលទាក់ទងនឹងសិទ្ធិមនុស្ស

- <u>ដោយយល់ឃើញម្យ៉ាងទៀតថា</u> SNC បានយល់ព្រមចូលរួមក្នុង កតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ព្រមទាំង កតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិខាងវិស័យសេដ្ឋកិច្ចសង្គម និងវប្បធម៌ នៅថ្ងៃទី ២០ មេសា ១៩៩២ ហើយថាឧបករណ៍ទាំងនេះបានចូលជាធរមាននៅប្រទេសកម្ពុជានៅថ្ងៃ ២៦ សីហា ១៩៩២,

- <u>ដោយមានកង្វល់ថា</u> បណ្តារចនាសម្ព័ន្ធ, ច្បាប់ និងស្ថាប័នតុលាការនៅប្រទេសកម្ពុជាមិនបំពេញអោយបានពេញលេញតាមការតម្រូវរបស់កិច្ចព្រមព្រៀងប៉ារីស ព្រមទាំងពេលខ្លះមានការខ្វះខាតមួយផ្នែក ឬពុំទាន់មានអ្វីទាល់តែសោះ ហើយបើតាមការពិនិត្យពិច័យ គឺមិនសមស្របដើម្បីធានាអោយមានរបៀបរៀបរយ និងសិទ្ធិមនុស្ស នៅតាមទីកន្លែងនានាជាច្រើនក្នុងដែនដី,

- <u>ដោយទទួលស្គាល់ថា</u> ការទាំងនេះត្រូវនៅក្រោមការទទួលខុសត្រូវរបស់ UNTAC ដើម្បីសំរួលការរៀបចំរចនាសម្ព័ន្ធទាំងឡាយ ច្បាប់ និងស្ថាប័នតុលាការ នៅកន្លែងណាដែលខ្វះខាត ហើយជួយកែលំអកន្លែងណាដែលមានរួចហើយ ដើម្បីអោយសមស្របតាមការតម្រូវចាំបាច់នៃកិច្ចព្រមព្រៀង,

- <u>ដោយមានជំនឿជាក់</u>ទៅលើសេចក្តីត្រូវការជាបន្ទាន់ ដើម្បីបង្ហាញយ៉ាងច្បាស់ជូនភាតីកម្ពុជា នូវក្បួនច្បាប់ដែលត្រូវអនុវត្តទូទាំងប្រទេសកម្ពុជា និង នីតិវិធីតុលាការ ដែលត្រូវយកមកប្រតិបត្តិ ដើម្បីធានាអោយមានការអនុវត្តន៍ជាក់ស្តែង ក្នុងដំណាក់កាលអន្តរកាល,

- <u>ដោយជឿជាក់ថែមទៀតថា</u> ការអនុវត្តន៍ក្បួនច្បាប់ និងនីតិវិធីនេះ ជាការចាំបាច់ដើម្បីធានាបរិយាកាសនយោបាយអព្យាក្រឹត និងរៀបចំការបោះឆ្នោតសេរី និងតាមសមធម៌,

**ដូច្នេះ អនុម័ត** យកបទបញ្ញត្តិអស់ទាំងនេះ ដែលពាក់ព័ន្ធដល់របៀបចាត់ចែងតុលាការ ច្បាប់ព្រហ្មទ័ណ្ឌ និងនីតិវិធីព្រហ្មទ័ណ្ឌ សំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងរយៈពេលអន្តរកាល ហើយ **ធ្វើសំណូមពរ** ជាឱឡារិកដល់ភាតីកម្ពុជាទាំងអស់ ដើម្បីអោយអនុវត្តដោយសុទ្ធចិត្ត រហូតដល់សភានីតិបញ្ញត្តិ ដែលកើតឡើងពីការបោះឆ្នោត កែសំរួលបញ្ញត្តិទាំងនេះ ឬ អនុម័តយកច្បាប់ថ្មីទៀតនៅក្នុងវិស័យនេះ ។

## មាតិកា មួយ : ប្រព័ន្ធតុលាការ

### មាត្រា១ : ឯករាជភាពនៃក្រុមចៅក្រុម

១ : ឯករាជភាពនៃក្រុមចៅក្រុមត្រូវតែធានាអោយមានលក្ខណៈស្របនឹង *គោលការណ៍មូលដ្ឋានស្តីអំពីឯករាជភាពនៃក្រុមចៅក្រុម* ដែលអង្គការសហប្រជាជាតិបានអនុម័ត ។ ចៅក្រុមទាំងឡាយត្រូវកាត់ក្តីតាមភាពមិនលំអៀង ផ្អែកលើហេតុការណ៍ ដែលមាននៅចំពោះមុខ ហើយក្នុងការគោរពច្បាប់ ដោយមិនព្រមទទួលការគាបសង្កត់, ការគំរាមកំហែង ឬការបំភិតបំភ័យ, ដោយចំពោះ ឬមិនចំពោះ អំពីភាគីណាមួយក្នុងរឿងកាត់ក្តី ឬ អំពីអ្នកឯទៀតណាក៏ដោយ ។

២ : ក្រុមចៅក្រុមមិនត្រូវនៅក្រោមចំណុះអំណាចនីតិប្រតិបត្តិ ឬនីតិបញ្ញត្តិ ឬ ក្រោមភាគីនយោបាយណាឡើយ។ ជនដែលត្រូវគេជ្រើសរើសអោយបំពេញមុខងារក្នុងតុលាការ ត្រូវតែជាអ្នកសុចរិត និងមានសមត្ថភាពផង ។

៣ : គោលការណ៍ឯករាជភាពនៃក្រុមចៅក្រុមប្រគល់សិទ្ធិ និងករណីយកិច្ចជូនចៅក្រុមដើម្បីធានាអោយការកាត់ក្តីប្រព្រឹត្តទៅក្នុងភាពសុចរិត និង ក្នុងការគោរពដល់សិទ្ធិនៃភាគីដែលត្រូវកាត់ក្តីទាំងអស់ ។ ចៅក្រុមត្រូវមានលទ្ធភាពបំពេញមុខងារខ្លួនតាមស្ថានភាពសម្ភារៈសមរម្យ និង គ្រប់គ្រាន់ ។ ចៅក្រុមត្រូវទទួលការហ្វឹកហាត់ត្រឹមត្រូវ មានប្រាក់បៀវត្សគ្រប់គ្រាន់ ដើម្បីធានានូវភាពឥតលំអៀង និង ឯករាជភាពរបស់ពួកគេ ។

### មាត្រា ២ : មុខងារនៃតុលាការ

សមាសភាពនៃក្រុមចៅក្រុមមាន ចៅក្រុម និង រដ្ឋអាជ្ញា ។ មានតែចៅក្រុមទេដែលមានអំណាចសម្រេចសេចក្តី ។ រដ្ឋអាជ្ញាមានបន្ទុកខាងបណ្តឹងអាជ្ញាព្រហ្មទណ្ឌ ដែលមានតែរដ្ឋអាជ្ញាទេដែលមានអំណាចធ្វើកិច្ចការហ្នឹង ។ រដ្ឋអាជ្ញាជាអ្នករៀបចំសំណុំពាក្យចោទប្រកាន់ សំរាប់ដាក់ជូនតុលាការជំនុំជំរះ និងដាក់ជូនអង្គប្រជុំផ្សេងៗទៀត ដែលមានចែងនៅក្នុងបទបញ្ញត្តិនេះ ។ ម្យ៉ាងវិញទៀត អគ្គរដ្ឋអាជ្ញាជាអ្នកលើកយកសំណុំពាក្យចោទប្រកាន់ដាក់ជូនតុលាការកំពូល ក្នុងផលប្រយោជន៍ខាងផ្លូវច្បាប់, ពិនិត្យមើលនូវភាពពេញលក្ខណៈច្បាប់នៃបណ្តឹងចោទទាំងឡាយរបស់រដ្ឋអាជ្ញាខេត្ត, ចាត់ចែង និងណែនាំកិច្ចការរបស់រដ្ឋអាជ្ញា ។

## មាត្រា ៣ : សាលាជំរះក្តី

១ : ដោយមានសហការជាមួយអ៊ុនតាក់ ភាគីកម្ពុជាទាំងអស់សន្យាថានឹងចាត់ចែងអោយមានសាលាដំបូងមួយ យ៉ាងតិច នៅក្នុងតំបន់ ឬខេត្តណាដែលខ្លួនមិនទាន់បានចាត់តាំង ។ ចៅក្រមនានានឹងត្រូវរចនាសម្ព័ន្ធរដ្ឋបាលដែលមានសព្វថ្ងៃតែងតាំងឡើង, តម្លើងឋានន្តរស័ក្តិ ឬបញ្ឈប់ពីតំណែង ក្រោមកិច្ចត្រួតពិនិត្យរបស់អ៊ុនតាក់ ។

២ : សាលាដំបូងត្រូវមានចៅក្រមម្នាក់ និង រដ្ឋអាជ្ញាម្នាក់ ។ សាលាកាត់ក្តីទាំងនេះមានសមត្ថកិច្ចទាំងស្រុងក្នុងការអនុវត្តន៍បទបញ្ញត្តិបច្ចុប្បន្ននេះ ព្រមទាំងមានសមត្ថកិច្ចលើច្បាប់ ឬបទដ្ឋានទាំងឡាយឯទៀតៗជាធរមាន តាមយុត្តាធិការរៀងៗខ្លួន ។

៣ : ចៅក្រមជំនួស អាចត្រូវគេតែងតាំងក្នុងល័ក្ខខ័ណ្ឌដូចគ្នានឹងចៅក្រមដែរ ដើម្បីជំនួសចៅក្រមដែលសុំដកខ្លួនពីការជំនុំជំរះ ក្នុងករណីណាដែលមានទំនាស់ខាងផលប្រយោជន៍ ឬក្នុងករណីអសមត្ថភាព ។

## មាត្រា ៤ : សាលាឧទ្ធរណ៍

១ : ដោយសហការណ៍ជាមួយអ៊ុនតាក់ ភាគីទាំងឡាយសន្យាថានឹងចាត់ចែងអោយមានសាលាឧទ្ធរណ៍មួយ យ៉ាងតិច នៅក្នុងតំបន់ ឬដែនដីណាដែលខ្លួនមិនទាន់បានបង្កើតនៅឡើយ ។ ចៅក្រមទាំងឡាយនឹងត្រូវរចនាសម្ព័ន្ធរដ្ឋបាលដែលមានសព្វថ្ងៃតែងតាំង, តម្លើងឋានន្តរស័ក្តិ ឬបញ្ឈប់ពីតំណែង ក្រោមកិច្ចត្រួតពិនិត្យរបស់អ៊ុនតាក់ ។

២ : សាលាឧទ្ធរណ៍នេះមានចៅក្រមបីនាក់ និង រដ្ឋអាជ្ញាម្នាក់ ដែលតែងតាំងឡើងដោយរចនាសម្ព័ន្ធរដ្ឋបាលដែលមានសព្វថ្ងៃ ក្រោមកិច្ចត្រួតពិនិត្យរបស់ អ៊ុនតាក់ ។ ចៅក្រមជំនួសអាចត្រូវគេតែងតាំងក្នុងល័ក្ខខ័ណ្ឌដូចគ្នា ដើម្បីជំនួសចៅក្រមណាដែលសុំដកខ្លួនពីការជំនុំជំរះ ក្នុងករណីណាដែលមានទំនាស់ខាងផលប្រយោជន៍ ឬ ក្នុងករណីអសមត្ថភាព ។

៣ : បណ្ដាភាគីដែលមានទាក់ទិនក្នុងរឿងក្ដីនេះ, ភាគីរដ្ឋប្បវេណី, ទណ្ឌិត ឬទីប្រឹក្សារបស់ភាគីទាំងសង្ខាង, រដ្ឋអាជ្ញាអាចប្ដឹងឧទ្ធរណ៍ពីសេចក្ដីសំរេចរបស់សាលាដំបូងនានា ក្នុងរយៈពេល ២ ខែ ចាប់ពីថ្ងៃដែលចៅក្រមប្រកាសសាលក្រមនោះ បើសិនជាសាលក្រមនោះធ្វើឡើងចំពោះមុខសាមីខ្លួន, ហើយបន្ថែមពេលបណ្ដឹងជំទាស់ ១៥ ថ្ងៃថែមទៀត បើការកាត់ទោសនេះធ្វើឡើងដោយគ្មានសាមីខ្លួន ។ សាលក្រមចំពោះមុខ គឺធ្វើឡើងដោយមានវត្តមានជនជាប់ចោទក្នុងពេលជំនុំជំរះ ពុំនោះសោតទេ នឹងទុកដូចជាការកាត់ក្ដីមិនចំពោះមុខ ។

៤ : សាលាឧទ្ធរណ៍ជំនុំជំរះទាំងអង្គច្បាប់ ទាំងអង្គហេតុ ។

## មាត្រា ៥ : តុលាការជាន់ខ្ពស់

ដោយអនុលោមតាមសំណូមពររបស់ភាគី «រដ្ឋកម្ពុជា» ដំណើរការនៃតុលាការជាន់ខ្ពស់បច្ចុប្បន្ននឹងត្រូវកែលំអ ដើម្បីអោយមានលទ្ធភាពគោរពតាមកាតព្វកិច្ច ដែលចែងក្នុងមាត្រា ១ ព្រមទាំងបំពេញមុខងារដូចខាងក្រោមនេះ ៖

ក- តុលាការនេះជាតុលាការជំនុំជំរះអង្គច្បាប់

ខ- តុលាការនេះអាចទទួលពាក្យបណ្ដឹងកែតម្រូវចំពោះសេចក្ដីសំរេចរបស់សាលាឧទ្ធរណ៍ ពីអគ្គរដ្ឋអាជ្ញា, ជនជាប់ទោស, ភាគីរដ្ឋប្បវេណី ឬ ទីប្រឹក្សារបស់គេ ក្នុងរយៈពេលពីរខែ ចាប់ពីថ្ងៃដែលចេញសាលដីកាជំនុំជំរះ បើសាលដីកានោះធ្វើឡើងចំពោះមុខ ហើយនិង បន្ថែមពេលបណ្ដឹងជំទាស់ ១៥ ថ្ងៃថែមទៀត បើសាលដីកានេះធ្វើឡើងដោយមិនចំពោះមុខ ។ សាលដីកាចំពោះមុខ គឺធ្វើឡើងដោយមានវត្តមានជនជាប់ចោទក្នុងពេលជំនុំជំរះ ពុំនោះទេនឹងទុកដូចជាមិនចំពោះមុខ ។

គ- តុលាការនេះអាចបញ្ជូនសំណុំរឿងទាំងឡាយត្រឡប់ទៅសាលាឧទ្ធរណ៍មួយដែលមានសមាសភាពផ្សេងខុសពីមុន ហើយបើសាលាឧទ្ធរណ៍ថ្មីនេះមិនសម្រេចតាមសាលដីកាខ្លួនទេនោះ តុលាការនេះអាចទទួលបណ្ដឹងពីអគ្គរដ្ឋអាជ្ញា ទណ្ឌិត ភាគីរដ្ឋប្បវេណី ឬទីប្រឹក្សារបស់គេ ក្នុងរយៈពេលពីរខែ ចាប់ពីថ្ងៃដែលប្រកាសសាលដីកា ក្នុងល័ក្ខខ័ណ្ឌដែលដូចបានចែងនៅក្នុងវគ្គ ខ នៃមាត្រានេះ ។ ពេលនោះ តុលាការជាន់ខ្ពស់អាចជំនុំជំរះទាំងអង្គហេតុ និងទាំងអង្គច្បាប់ ហើយធ្វើសេចក្ដីសំរេចជាស្ថាពរតែម្ដង ។

## មាត្រា ៦ : នគរបាល

១ : នគរបាលត្រូវប្រតិបត្តិតាម *បទបញ្ញាសីលធម៌សំរាប់អ្នកទទួលខុសត្រូវក្នុងការអនុវត្តន៍ច្បាប់*, ហើយបើអាចធ្វើទៅបាន ត្រូវប្រតិបត្តិតាម *គោលច្បាប់ជាមូលដ្ឋានស្តីអំពីការប្រើកម្លាំង និងការប្រើកាំភ្លើងនៃអ្នកទទួលខុសត្រូវក្នុងការអនុវត្តន៍ច្បាប់* ដែលអង្គការសហប្រជាជាតិបានអនុម័ត ។

២ : បណ្តាភាគី ដែលកងកំលាំងរបៀបរៀបរយរបស់ខ្លួនមិនមានលទ្ធភាពបំពេញតាមការតម្រូវនៃបទបញ្ញត្តិនេះ សន្យាសហការជាមួយអ៊ុនតាក់ ដើម្បីរៀបចំអោយមាន និង បង្ហាត់ហ្វឹកហ្វឺនកងកំលាំងនគបាលមួយអោយបានត្រឹមត្រូវ ។

## មាត្រា ៧ : មេធាវី និង ទីប្រឹក្សា

១ : មេធាវីទាំងឡាយនឹងត្រូវអនុញ្ញាតអោយបង្កើតជាអង្គការមេធាវី ដែលមានរូបភាពជាសមាគមមួយ ដោយមានអំណាចខាងវិន័យ និងបទបញ្ជាទៅលើសមាជិកខ្លួនទាំងអស់ ។ អង្គការមេធាវីមិនត្រូវទទួលការបង្គាប់បញ្ជា ជាដាច់ខាត ពីគណៈបក្សនយោបាយណាមួយ, ពីសំណាក់អំណាចនីតិបញ្ញត្តិណាមួយ ឬ ពីអំណាចនីតិប្រតិបត្តិណាមួយ ដែលនៅក្រោមនិវាទនៃភាគីកម្ពុជាណាមួយ ក្នុងកិច្ចព្រមព្រៀងប៉ារីស ។

ក្នុងរយៈពេលអន្តរកាល ជនដែលអាចធ្វើជាមេធាវីបាន គឺជនទាំងឡាយណាដែល យ៉ាងហោចណាស់ មានសញ្ញាប័ត្រស្មើនឹងបរិញ្ញាប័ត្រនីតិសាស្រ្ត ឬមានការពិសោធន៍ប្រាំឆ្នាំក្នុងវិស័យច្បាប់ ឬ វិស័យតុលាការ ប្រកបដោយកិរិតខ្ពស់ទទួសខុសត្រូវក្នុងកិច្ចការបាន ។

២ : ដោយចំនួនមេធាវីមានតិចតួចពេកនៅប្រទេសកម្ពុជា ក្នុងរយៈពេលអន្តរៈកាលនេះ ជនកម្ពុជាគ្រប់រូបដែលមានសញ្ញាប័ត្រមធ្យមសិក្សា អាចតំណាងជនជាប់ចោទនៅចំពោះមុខតុលាការបាន ល្គឹកណាដែលអ្នកនោះគ្មានឋានន្តរស័ក្តិជាអ្នករដ្ឋការក្នុងបណ្តាថ្នាក់ដឹកនាំ, ជាអ្នកជាប់ឆ្នោតក្នុងរចនាសម្ព័ន្ធរដ្ឋបាលដែលមានសព្វថ្ងៃ ឬក្នុងគណៈបក្សនយោបាយដែលគេទទួលស្គាល់ទាំងឡាយ ។ លើសពីនោះទៀត ជនជាប់ចោទអាចពឹងពាក់សមាជិកគ្រួសារខ្លួន អោយធ្វើជាជំនួយការពារខ្លួនបាន ទោះបីមានកិរិតសិក្សាថ្នាក់ណាក៏ដោយ ។

៣ : នៅចំពោះមុខតុលាការ អ្នកតំណាងជនជាប់ចោទមានសិទ្ធិដូចជាមេធាវីដែរ ក្នុងការជូនដំណឹងពីឯកសារ ក្នុងការធ្វើលិខិតនីតិវិធី ឬ ក្នុងការជជែកការពារជនជាប់ចោទ ។ ក្នុងបទបញ្ញត្តិនេះ ពាក្យថា «ទីប្រឹក្សា» មានន័យមិនខុសពីពាក្យមេធាវី ឬ អ្នកតំណាងគ្រប់ប្រភេទរបស់ជនជាប់ចោទឡើយ ។

៤ : មេធាវីបរទេសអាចជជែកការពារចំពោះតុលាការកម្ពុជា ក្នុងកាលៈទេសៈណាដែលគេអាចបង្ហាញភស្តុតាងថា គេបានចុះឈ្មោះក្នុងអង្គការមេធាវីមួយ ឬ ក៏គេបានសេចក្តីអនុញ្ញាតជាផ្លូវការអោយជជែកការពារនៅក្នុងប្រទេសរបស់គេ ។ រចនាសម្ព័ន្ធរដ្ឋបាលដែលមានសព្វថ្ងៃសន្យាថានឹងជួយសម្រួលក្នុងការផ្តល់ទិដ្ឋាការចូល ដល់មេធាវីដែលមកបំពេញការងារនៅក្នុងប្រទេសកម្ពុជា ។

## <u>មាត្រាទី ៨ : ប្រព័ន្ធពន្ធនាគារ</u>

១ : ប្រព័ន្ធពន្ធនាគារមានគោលដៅធ្វើអោយមាននីតិសម្បទាសង្គមឡើងវិញ ។ ការប្រព្រឹត្តិចំពោះអ្នកជាប់ទោស ត្រូវតែស្របទៅតាម <u>*បទដ្ឋានអប្បបរិមានៃបទវិន័យសំរាប់គ្រប់គ្រងអ្នកទោស*</u> ដែលអង្គការសហប្រជាជាតិបានអនុមម័ត ។

២ : បណ្តាអាជ្ញាធរទាំងឡាយណាដែលចាប់ឃាត់ឃាំងជនជាប់សង្ស័យ ឬឃុំឃាំងមនុស្សក្នុងពេលមុន ឬក្រោយការកាត់ទោស ត្រូវមានបញ្ជីគុកដែលមានរដ្ឋអាជ្ញា និង ចៅក្រមម្នាក់ប្រចាំខេត្ត ឬតំបន់ចុះហត្ថលេខារាល់ខែ ដើម្បីពិនិត្យបញ្ជាក់ឈ្មោះ អាយុ, អាស័យដ្ឋាន, ថ្ងៃ ខែ ឆ្នាំ និងមូលហេតុនៃការចាប់ខ្លួន, ថ្ងៃ ខែ ឆ្នាំដែលបានបញ្ជូនខ្លួនទៅចៅក្រម, ហើយនឹងថ្ងៃ ខែ ឆ្នាំដែលត្រូវគេកាត់ទោស និងទោសដែលគេបានកាត់ហើយ ចំពោះទណ្ឌិត ។

## <u>មាត្រា ៩ : ការពិនិត្យកន្លែងឃុំឃាំង</u>

១- រដ្ឋអាជ្ញា ឬ ចៅក្រមទាំងឡាយអាចចូលពិនិត្យពន្ធនាគារ និងអ្នកទោសបានគ្រប់ពេលវេលា ។

២- ភ្នាក់ងារដែលអនុញ្ញាតដោយផ្នែកសិទ្ធិមនុស្ស រដ្ឋបាលស៊ីវិល និង ប៉ូលីសរបស់អ៊ុនតាក់ ក៏មានសិទ្ធិដូចគ្នាដែរ ។ ក្នុងរឿងនេះ ភាគីខ្មែរទាំងអស់នៃកិច្ចព្រមព្រៀងប៉ារីស ត្រូវធ្វើបញ្ជីរាយទីកន្លែងឃុំឃាំងរបស់ខ្លួនទាំងអស់ អោយបានយ៉ាងយឺតបំផុតនៅពេលដែលបទបញ្ញត្តិនេះចូលជាធរមាន ហើយបញ្ជូនបញ្ជីនេះទៅទីចាត់ការកណ្តាលនៃផ្នែករដ្ឋបាលស៊ីវិលរបស់អ៊ុនតាក់ ។

## មាតិកា ពីរ : នីតិវិធីព្រហ្មទណ្ឌ

### មាត្រា ១០ : ជំនួយផ្នែកច្បាប់

១ : សិទ្ធិពឹងពាក់មេធាវី ឬទីប្រឹក្សា ត្រូវបានធានាជូនជនគ្រប់រូបដែលជាប់ចោទពីបទមជ្ឈិម ឬ បទឧក្រិដ្ឋ ។

២ : ទោះបីបទល្មើសនោះធ្ងន់ស្រាលយ៉ាងណាក៏ដោយ គ្មានជនណាម្នាក់ត្រូវជាប់ឃុំឃាំង នៅលើទឹកដីកម្ពុជា លើសពីរយៈពេល ៤៨ម៉ោង ដោយគ្មានបានទទួលជំនួយពីទីប្រឹក្សា, ពីមេធាវី ឬ ពីអ្នកតំណាង ដែលបទបញ្ញត្តិនេះបានអនុញ្ញាតឡើយ ។

### មាត្រា ១១ : តុលាការយោធា

តុលាការយោធាទទួលជំនុំជំរះតែបទល្មើសយោធាទេ។ បទល្មើសយោធា គឺជាបទល្មើសដែលទាក់ទិនដល់យោធិន, ទាំងយោធិនជាប់កិច្ចសន្យា ទាំងយោធិនកំណែន ហើយដែលពាក់ព័ន្ធដល់បទវិន័យយោធា ឬការខូចខាតទ្រព្យសម្បត្តិយោធា ។ បទឧក្រិដ្ឋ ឬ បទល្មើសនឹងច្បាប់សាមញ្ញ ដែលប្រព្រឹត្តដោយយោធិន នឹងត្រូវទទួលការជំនុំជំរះនៅតុលាការស៊ីវិល ។

## មាត្រា ១២ : ការគ្រប់គ្រងជនជាប់ឃុំ

១ : គ្មានជនជាប់ឃុំណាម្នាក់ត្រូវទទួលទណ្ឌកម្ម ឬ ការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅ, អមនុស្សធម៌ ឬនាំអោយបាត់បង់តម្លៃជាមនុស្ស ឬក៏ត្រូវគេវាយដំ និង ធ្វើទារុណកម្មឡើយ ។ ជនជាប់ឃុំម្នាក់ៗត្រូវបានទទួលការថែទាំតាមវិធីពេទ្យត្រឹមត្រូវ ។ អ្នកទោសទាំងឡាយមិនត្រូវបានគេចង ឬ ដាក់អោយនៅឯកោម្នាក់ឯង, ទោះស្ថិតក្នុងការឃុំខ្លួនបណ្ដោះអាសន្នក្ដី ឬត្រូវបានកាត់ទោសរួចហើយក្ដី ។ ទោះក្នុងករណីណាក៏ដោយ គ្រួសារអ្នកជាប់ឃុំ ឬគ្រួសារអ្នកទោសមិនត្រូវមានគេយាយី ដោយសារតែការប្រព្រឹត្តិរបស់ជននោះឡើយ ។

២ : ការចាប់ខ្លួន និងការឃុំខ្លួនត្រូវតែគោរពតាម *បទដ្ឋានអប្បបរិមានៃបទវិន័យសំរាប់គ្រប់គ្រងអ្នកជាប់ឃុំ* ព្រមទាំងត្រូវគោរពតាម *គោលការណ៍ជាមូលដ្ឋានសំរាប់ការពារអ្នកទោស* ដែលអង្គការសហប្រជាជាតិបានអនុម័ត ។

## មាត្រាទី ១៣ : ការចាប់ខ្លួន និង ការឃុំខ្លួន

១ : គ្មានជនណាម្នាក់ត្រូវបានគេឃុំខ្លួនលើសពី ៨៨ម៉ោង ដោយមិនបានបញ្ជូនទៅចៅក្រម តាមរយៈបណ្ដឹងរបស់រដ្ឋអាជ្ញាឡើយ ។ ក្នុងករណីណាដែលពុំអាចគោរពតាមបិរៈវេលានេះបាន ដោយសារស្ថានភាពនៃការដឹកជញ្ជូនក្នុងតំបន់និមួយៗនោះ គេអាចបន្ថបន្ថែមបាននូវពេលវេលាចាំបាច់សំរាប់តែដឹកនាំអ្នកជាប់ឃុំឃាំងនេះ ទៅជូនចៅក្រមតាមមធ្យោបាយយ៉ាងឆាប់ដែលអាចធ្វើបាន ។

២ : រដ្ឋអាជ្ញាសុំអោយចៅក្រមចោទប្រកាន់ ព្រមទាំង ជាយថាហេតុ ឃុំខ្លួនជនជាប់សង្ស័យ ក្រោយពីបានពិនិត្យសំណុំរឿងពីនគរបាល ដោយរៀបរៀងដីកាសន្និដ្ឋានមួយ ទុកជាសេចក្ដីផ្ដើមចោទ យោងតាមអង្គហេតុជាក់ស្ដែង និងដែលកំណត់បទល្មើសតាមច្បាប់អោយស្របទៅតាមបទបញ្ញត្តិព្រហ្មទណ្ឌនេះ ។

៣ : ក្នុងខណៈនោះ ដោយផ្អែកលើសេចក្ដីសំរេចដែលមានចែងមូលហេតុ ចៅក្រមអាចសំរេចថា ៖

- ត្រូវចោទប្រកាន់ជនជាប់សង្ស័យ ដោយអោយឃុំឃាំង ឬ មិនអោយឃុំឃាំង,
- អោយដោះលែងជនជាប់សង្ស័យ ដោយចាត់ទុកថាភស្តុតាងនៃពិរុទ្ធភាពមិនគ្រប់គ្រាន់,

- សំរេចអោយបន្តការស៊ើបអង្កេត ដោយមិនប្រាប់ឈ្មោះជនជាប់សង្ស័យ ។

៤ : ក្នុងរយៈពេលយ៉ាងច្រើន ៤៨ម៉ោងដូចគ្នានេះ ក្រោយការចាប់ខ្លួន ហើយ ជាយថាហេតុ ត្រូវបានពន្យាពេលរយៈវេលាចាំបាច់ក្នុងការដឹកនាំ ដូចបានចែងនៅវគ្គទី១ ទីប្រឹក្សាត្រូវបានទទួលសំណុំរឿង ដែលទាក់ទងក្នុងការចោទប្រកាន់ចំពោះជនជាប់សង្ស័យ ។

## មាត្រាទី ១៤ : ការឃុំខ្លួនជាបណ្ដោះអាសន្ន

១ : មានតែចៅក្រមទេ ដែលអាចសម្រេច ដោយមានចែងមូលហេតុ អោយឃុំខ្លួនជនជាប់ចោទទុកក្នុងមន្ទីរឃុំឃាំងតាមសេចក្ដីស្នើសុំរបស់រដ្ឋអាជ្ញា ហើយមានតែក្នុងករណីដែលបារម្ភខ្លាចក្រែងជននោះរត់គេចខ្លួន និងដោយគ្មានអ្វីអាចអោយធានាបានថា ជនជាប់ចោទប្រាកដជាត្រឡប់មកបង្ហាញខ្លួនចំពោះមុខតុលាការវិញ មានន័យថា សាមីជនគ្មានការងារធ្វើ គ្មានគ្រួសារគ្មានទីលំនៅពិតប្រាកដ ឬដោយខ្លាចជនជាប់ចោទនោះប្រើឥទ្ធិពលលើសាក្សី ឬលើដំណើរការស៊ើបអង្កេត ។

២ : ជនជាប់ចោទមានសិទ្ធិសុំចៅក្រម អោយដោះលែងខ្លួន តាមរយៈខ្លួនឯងផ្ទាល់ ឬតាមរយៈទីប្រឹក្សារបស់ខ្លួន ។ ក្នុងរយៈពេលប្រាំថ្ងៃ ចៅក្រមត្រូវឆ្លើយតាមដីកាដែលមានចែងមូលហេតុ ។

៣ : ក្នុងរយៈពេល៥ថ្ងៃក្រោយពីដីកានោះមក ជនជាប់ចោទ, ភាគីរដ្ឋប្បវេណី ឬទីប្រឹក្សារបស់ភាគីទាំងសងខាង ឬរដ្ឋអាជ្ញាអាចសុំឧទ្ធរណ៍ពីសេចក្ដីសំរេចរបស់ចៅក្រម ។ ក្នុងរយៈពេល១៥ថ្ងៃ សាលាឧទ្ធរណ៍ត្រូវសំរេចលើពាក្យសុំឧទ្ធរណ៍ទាំងឡាយដែលទាក់ទិនក្នុងរឿងឃុំខ្លួននេះ ។

៤ : រយៈពេលឃុំឃាំងជាបណ្ដោះអាសន្ន ទោះស្ថិតក្នុងករណីណាក៏ដោយ មិនត្រូវអោយហួសពីបួនខែទេ ។ ប៉ុន្តែតាមការសំរេច ដែលមានចែងមូលហេតុរបស់ចៅក្រម រយៈពេលនេះអាចបន្តដល់ប្រាំមួយខែ ប្រសិនបើមានការចាំបាច់សំរាប់ធ្វើការស៊ើបអង្កេត ។

៥ : អនីតិជនអាយុតិចជាង ១៣ឆ្នាំមិនត្រូវជាប់ឃុំឃាំងជាបណ្ដោះអាសន្នទេ ។ អនីតិជនដែលមានអាយុ ១៣ ទៅ ១៨ឆ្នាំ មិនត្រូវជាប់ឃុំឃាំងជាបណ្ដោះអាសន្នលើសពី ១ខែទេ ។ រយៈពេលនេះអាចទ្វេឡើងជាពីរ បើសិនជាមានការចោទប្រកាន់ពីបទឧក្រិដ្ឋណាមួយ ។

## មាត្រា ១៥ : ការឃុំខ្លួនតាមបទរដ្ឋបាល

នៅប្រទេសកម្ពុជាមិនត្រូវមានជនណាត្រូវឃុំឃាំង ដោយនគរបាលរដ្ឋបាលណាមួយ ឬពីបទល្មើសណាដែលគ្មានចែងនៅក្នុងបទបញ្ញត្តិនេះ ឬ ក្នុងច្បាប់ឯទៀត ឬអត្ថបទឯទៀតៗខាងវិស័យព្រហ្មទណ្ឌឡើយ ។

## មាត្រា ១៦ : ការដោះលែងជនជាប់ឃុំ

ជនដែលជាប់ឃុំឃាំង ឬឃាត់ខ្លួនទុកនៅតាមមន្ទីរឃុំឃាំងនានា ដែលគ្មានឈ្មោះក្នុងបញ្ជីដូចមានរៀបរាប់នៅក្នុងមាត្រា ៩ នៃបទបញ្ញត្តិនេះ នឹងត្រូវចាត់ទុកថាបានជាប់ឃុំឃាំងខុសច្បាប់ ហើយត្រូវតែដោះលែងភ្លាមមួយរំពេច តាមសេចក្តីសុំរបស់រដ្ឋអាជ្ញា, គ្រប់សាលាដំបូង, ទីប្រឹក្សារបស់អ្នកជាប់ឃុំ ឬបុគ្គលិកដែលមានសេចក្តីអនុញ្ញាតពីផ្នែករដ្ឋបាលស៊ីវិលរបស់អ៊ុនតាក់, ផ្នែកសិទ្ធិមនុស្ស និង នគរបាលស៊ីវិលរបស់អ៊ុនតាក់ ។ រីឯអ្នកដែលត្រូវគេឃុំឃាំង ឬឃាត់ខ្លួនទុកនៅក្នុងមន្ទីរឃុំឃាំងដែលបានប្រកាស ហើយដែលគ្មានឈ្មោះលើបញ្ជីឃុំឃាំង ក៏ត្រូវតែដោះលែងដូចគ្នាដែរ ។

## មាត្រា ១៧ : សិទ្ធិពិនិត្យសំណុំរឿង

១ : ប្រសិនបើចៅក្រមសំរេចថា ចាំបាច់ត្រូវស៊ើបអង្កេតបន្ថែមទៀត, តាមលំដាប់លំដោយនៃការស៊ើបអង្កេតនេះ, ទីប្រឹក្សារបស់ជនជាប់ចោទត្រូវតែបានទទួលដំណឹងជាបន្ទាន់ អំពីភស្តុតាងថ្មីៗទៀត ប្រឆាំងនឹងកូនក្តីរបស់ខ្លួន ។

២ : ទីប្រឹក្សាមានសិទ្ធិពិនិត្យសំណុំរឿងអ្នកជាប់ចោទ ដោយគ្រាន់តែស្នើសុំជាលាយល័ក្ខអក្សរ នៅគ្រប់ដំណាក់កាលនៃនីតិវិធី ហើយអាចទទួលបានពីចៅក្រម នូវគ្រប់លទ្ធផលដែលបានមកអំពីការស៊ើបអង្កេត, អំពីសេចក្តីរាយការណ៍របស់អ្នកជំនាញការ ឬអំពីសវនកម្មដែលខ្លួនយល់ថា មានប្រយោជន៍ក្នុងការការពារកូនក្តីរបស់ខ្លួន ។

## មាត្រា ១៨ : បទល្មើសជាក់ស្តែង

នគរបាលអាចចាប់ខ្លួនជនណាដែលបានប្រព្រឹត្តបទល្មើសជាក់ស្តែង គឺថា ៖

- បើជនសង្ស័យត្រូវគេឃើញទាន់ពេលកំពុងតែប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទល្មើស ឬប្រសិនបើកំពុងត្រូវគេស្រែកដេញប្រផាប់ចាប់ប្រភីង
- បើជនសង្ស័យត្រូវបានសាក្សី ឬ អ្នករងគ្រោះចង្អុលបង្ហាញនៅនឹងកន្លែងដែលប្រព្រឹត្ត ឧក្រិដ្ឋកម្ម ឬ បទល្មើស ថាជាពិរុទ្ធិកជន
- បើជនសង្ស័យកំពុងរកវិធីរត់ចេញពីកន្លែងដែលប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទល្មើស ។

## មាត្រា ១៩ : ការចាប់ខ្លួនដោយសំអាងលើភ័ស្តុតាងជាក់ស្តែងយ៉ាងធ្ងន់

១ : ក្នុងករណីផ្សេងទៀតទាំងអស់ នគរបាលតុលាការអាចចាប់ខ្លួនជនជាប់សង្ស័យបាន លុះត្រាតែមានភ័ស្តុតាងជាក់ស្តែងយ៉ាងខ្លាំង, ច្បាស់លាស់ ហើយស៊ីសង្វាក់គ្នា ដែលបង្ហាញអោយឃើញថា ជននោះបានចូលរួមក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ ឬបទបញ្ជើមមែន ។

២ : បើជនជាប់សង្ស័យលួចរត់គេចខ្លួន ជននោះអាចត្រូវចាប់ខ្លួនបាន តាមដីកាចាប់ខ្លួនរបស់រដ្ឋអាជ្ញា ឬ ចៅក្រម ដែលនឹងត្រូវអនុវត្តដោយនគរបាលតុលាការ ។

៣ : ដីកាចាប់ខ្លួនត្រូវមានបញ្ជាក់អំពីអំពើ និងមូលហេតុទាំងឡាយ ដែលនាំអោយមានការចាប់ខ្លួនជនជាប់សង្ស័យនោះ ។

៤ : ជោគវាសនារបស់ជនដែលត្រូវគេចាប់ខ្លួន ត្រូវបានចាត់ចែង តាមលក្ខន្តិកៈនៅក្នុងមាត្រា១៣ នៃបទបញ្ញត្តិនេះ ។

៥ : ម្យ៉ាងទៀត តាមដីកាបង្គាប់អោយឡើងសាលារបស់រដ្ឋអាជ្ញា ឬ ចៅក្រម នគរបាលអាចនាំខ្លួនជនគ្រប់រូប ដែលមានប្រយោជន៍ក្នុងការស៊ើបអង្កេត ហើយដែលប្រកែកមិនព្រមចូលខ្លួនតាមដីកាកោះ មកបង្ហាញខ្លួនចំពោះមុខនាយនគរបាល ឬចៅក្រម ឬរដ្ឋអាជ្ញា។ ក្រោយពីតុលាការបានសាកសួរហើយ ជននោះត្រូវបានដោះលែងជាបន្ទាន់ លើកលែងតែក្នុងករណីមានភ័ស្តុតាងជាក់ស្តែងយ៉ាងធ្ងន់, ច្បាស់លាស់ ហើយស៊ីសង្វាក់គ្នា ដែលត្រូវអនុវត្តតាមនីតិវិធីនៃមាត្រាទី ១៣ នៃបទបញ្ញត្តិនេះ ។

មាត្រា ២០ : ការឆែកឆេរក្នុងផ្ទះ

១ : ក្នុងករណីបទល្មើសជាក់ស្តែង នគបាលអាចធ្វើការឆែកឆេរ ។

២ : ការឆែកឆេរទាំងនេះត្រូវធ្វើនៅចំពោះមុខជនជាប់សង្ស័យ និងសាក្សីពីរនាក់ ហើយ បើអាចធ្វើបាន សាក្សី គួរយកអ្នកនៅជិតខាង ឬ អ្នកម្ចាស់ផ្ទះ ។

៣ : បើមិនមែនជាបទល្មើសដែលគេទាន់ជាក់ស្តែងទេ ការរឹបអូសទាំងឡាយត្រូវមាន សេចក្តីអនុញ្ញាតអំពីចៅក្រមណាមួយនៃតុលាការពាក់ព័ន្ធ ឬ ពីរដ្ឋអាជ្ញា ។ ការឆែកឆេរទាំងនេះ អាចធ្វើបានតែក្នុងចន្លោះម៉ោង ៦ ព្រឹក ទៅម៉ោង ៦ ល្ងាច ។ ហើយបើអាចធ្វើបាន ការឆែក ឆេរទាំងនេះត្រូវធ្វើនៅចំពោះមុខជនជាប់សង្ស័យ និងចំពោះមុខសាក្សីពីរនាក់ ដែលជ្រើសយកពី ក្នុងចំណោមសមាជិកគ្រួសារជនជាប់សង្ស័យ ។ ភស្តុតាងទាំងឡាយណា ដែលបានមកដោយ រំលោភនឹងមាត្រានេះ មិនអាចយកជាការបានឡើយ ក្នុងពិធីកាត់សេចក្តី ។

មាត្រា ២១ : កំណត់ពេល

១ : គ្រប់ជនជាប់ពិរុទ្ធ ទោះជាប់ឃុំក្តី ឬមិនជាប់ឃុំក្តី ត្រូវតែបានទទួលការកាត់ក្តី យ៉ាង យូរបំផុតប្រាំមួយខែ ក្រោយពីថ្ងៃចាប់ខ្លួន ។

២ : ទីប្រឹក្សា ឬ មេធាវីត្រូវបានទទួលដំណឹង ១៥ ថ្ងៃ មុនថ្ងៃជំនុំជំរះក្តីខ្លួន ។

មាត្រា ២២ : ការដោះលែងដោយមូលហេតុខុសនីតិវិធី

១ : ការមិនបានគោរពតាមនីតិវិធីដែលចែងក្នុងមាត្រា ១០ ទៅមាត្រា ២១ នាំអោយ ដោះលែងជនជាប់ចោទ អោយមានសេរីភាពជាបន្ទាន់ ប្រសិនបើការខុសឆ្គងនោះ ធ្វើអោយប៉ះ ពាល់យ៉ាងខ្លាំងដល់សិទ្ធិនៃការការពារ ។ ការប្រគល់សេរីភាពជាបន្ទាន់នេះ អាចធ្វើឡើងតាម សេចក្តីសុំរបស់ទីប្រឹក្សានៃជនជាប់ចោទ ឬមន្ត្រីដែលមានការអនុញ្ញាតនៃផ្នែករដ្ឋបាលស៊ីវិល, ផ្នែកសិទ្ធិមនុស្ស ឬ ផ្នែកនគរបាលស៊ីវិលរបស់អ៊ុនតាក់ ។ ដល់ថ្ងៃដែលបទបញ្ញត្តិនេះបាន ចូលជាធរមាន ជនជាប់ឃុំឃាំង ឬជាប់ព័ន្ធនាគារទាំងអស់ ត្រូវមានសំណុំរឿងសមស្របតាម លក្ខខ័ណ្ឌនៃបទបញ្ញត្តិនេះ សំរាប់ត្រួតពិនិត្យជាបន្ទាន់ពីសំណាក់ចៅក្រម រដ្ឋអាជ្ញា ឬភ្នាក់ងារ ដែលមានការអនុញ្ញាតរបស់អ៊ុនតាក់ ។ បើគ្មានសំណុំរឿងបែបនេះទេ ជនទាំងនោះនឹងត្រូវបាន

ដោះលែងអោយមានសេរីភាព តាមសេចក្តីសុំរបស់ទីប្រឹក្សា, មន្ត្រីដែលមានការអនុញ្ញាតនៃផ្នែករដ្ឋបាលស៊ីវិល, ផ្នែកសិទ្ធិមនុស្ស ឬ ផ្នែកនគរបាលស៊ីវិលរបស់អ៊ុនតាក់ ចៅក្រម ឬ រដ្ឋអាជ្ញា ។

២ : ការរំលោភ ពីសំណាក់ភ្នាក់ងារសាធារណៈ លើសិទ្ធិបុគ្គល ដូចមានចែងក្នុងមាត្រា ១០ ទៅមាត្រា ២១ នៃបទបញ្ញត្តិនេះ នឹងត្រូវផ្តន្ទាទោសតាមមាត្រា ៥៧ ។

## មាតិកា បី : ពិធីកាត់ក្តី

### មាត្រា ២៣ : ការជំនុំជំរះជាអសាធារណៈ

ការកាត់ក្តីទាំងអស់ត្រូវតែធ្វើជាសាធារណៈ លើកលែងតែអ្នករងគ្រោះ ឬ សិទ្ធិវន្តរបស់គេស្នើសុំអោយជំនុំជំរះជាអសាធារណៈ ហើយចៅក្រមយល់ព្រមផង ។

### មាត្រា ២៤ : មធ្យោបាយបង្ហាញភ័ស្តុតាង

១ : សាក្សីទាំងអស់ដែលមានឈ្មោះក្នុងសំណុំរឿង រួមទាំងបុគ្គលិកនគរបាលផង ត្រូវតែ បាននិយាយជូនតុលាការស្តាប់ ។ សាក្សីទាំងឡាយអាចត្រូវសួរដេញដោលពីសំណាក់ភាគីរដ្ឋប្បវេណី ឬទីប្រឹក្សារបស់គេ, ជនជាប់ចោទ ឬ ទីប្រឹក្សារបស់គេ ហើយនឹងពីសំណាក់រដ្ឋអាជ្ញា ។

២ : ភ័ស្តុតាងទាំងអស់អាចលើកមកជជែកវែកញែកបាននៅពេលជំនុំជំរះ ដោយរួមទាំងរបាយការណ៍នគរបាលផង ដែលមិនអាចចាត់ទុកថាជាភ័ស្តុតាងដែលច្រានចោលមិនបាននោះទេ ។

៣ : បណ្តាពាក្យសារភាពរបស់ជនជាប់ចោទទាំងឡាយ ដែលមិនស៊ីសង្វាក់គ្នាទៅនឹងដើមកំណើតនៃភ័ស្តុតាងទេនោះ ទោះក្នុងករណីណាក៏ដោយ មិនអាចទុកជាមូលដ្ឋានសំរាប់ផ្តន្ទាទោសបានឡើយ ។ ពាក្យសារភាពដែលបានមកអំពីការបង្ខិតបង្ខំ តាមបែបណាមួយក៏ដោយត្រូវទុកជាមោឃៈ ។ ការសុំទុកជាមោឃៈនេះត្រូវស្នើសុំទៅចៅក្រម ដោយទីប្រឹក្សារបស់ជនជាប់ចោទ នៅមុនពេលកាត់ក្តី ។

៤ : អ្នកការពារចុងចោទអាចយកសាក្សីខ្លួនមកបង្ហាញតុលាការ ហើយអាចជូនភស្តុតាងខ្លួនទៅតុលាការ ។

៥ : សាក្សីទាំងអស់ ទាំងខាងដើមចោទ ទាំងខាងចុងចោទ អាចទទួលការបង្ខំអោយបង្ហាញខ្លួនចំពោះមុខតុលាការ តាមរយៈដីកានាំខ្លួនរបស់តុលាការ ដោយត្រូវពិន័យជាប្រាក់ពី ១០០,០០០ ទៅ ១,០០០,០០០ រៀល បើមិនព្រមប្រព្រឹត្តតាម ។

## មាត្រា ២៥ : ការសន្មត់ជាមុនថាគ្មានទោស

គ្រប់ជនដែលគេសង្ស័យ គ្រប់ជនជាប់ពិរុទ្ធ គ្រប់ជនជាប់ចោទ ត្រូវទទួលការសន្មត់ជាមុនថា គ្មានកំហុសជាដាច់ខាត ។

## មាត្រា ២៦ : អំពីសាលក្រម

១ : គ្រប់សាលក្រមព្រហ្មទណ្ឌត្រូវប្រកាស «ក្នុងនាមប្រជាជាតិកម្ពុជា» សាលក្រមត្រូវចង្អុលអំពើដែលចោទប្រកាន់លើជនជាប់ចោទ ចង្អុលសាក្សី ឬ ភស្តុតាង ដែលចាត់ទុកជាត្រឹមត្រូវ ហើយដែលមានចែងមូលហេតុច្បាស់លាស់ ក្នុងការផ្តន្ទាទោស ។

២ : សាលក្រមដែលមានមូលហេតុច្បាស់លាស់ស្តីពីការផ្តន្ទាទោស និងសេចក្តីវិនិច្ឆ័យត្រូវអាននៅក្នុងពេលសវនាការ ។ សេចក្តីចម្លងសាលក្រមមួយច្បាប់ នឹងចែកជូនដល់ភាគីទាំងអស់ តាមសេចក្តីសុំរបស់គេ ។

## មាត្រា ២៧ : ការតាំងខ្លួនជាភាគីរដ្ឋប្បវេណី

១ : ជនរងគ្រោះ ឬ សិទ្ធិវន្តរបស់ជនរងគ្រោះទាំងឡាយ ដោយផ្ទាល់ ឬតាមរយៈទីប្រឹក្សា អាចតាំងខ្លួនជាភាគីរដ្ឋប្បវេណី នៅពេលអង្កេតស៊ើបសួរ ឬពេលសវនាការជំនុំជំរះដើម្បីទារសំណងជម្ងឺចិត្តពីអ្នកប្រព្រឹត្ត ឬដៃគូអ្នកប្រព្រឹត្តបទល្មើស និងអ្នកសមគំនិតក្នុងបទល្មើស ។ ទីប្រឹក្សារបស់អ្នកទាំងនោះ មានសិទ្ធិពិនិត្យសំណុំរឿង ដូចជនជាប់ចោទដែរ ។

២ : ជនប្រព្រឹត្តបទល្មើស និងអ្នកសមគំនិត ត្រូវទទួលខុសត្រូវរួម ក្នុងការជួសជុល ឬសងជំងឺចិត្ត ក្នុងលក្ខណៈទាំងឡាយដែលឆ្លើយតបទៅនឹងការតម្រូវនៃ *សេចក្តីថ្លែងការណ៍ ស្តីអំពីគោលការណ៍មូលដ្ឋាននៃយុត្តិធម៌ ទាក់ទិនទៅនឹងជនរងគ្រោះពីបទឧក្រិដ្ឋ និងជនរងគ្រោះពីការរំលោភអំណាច* ដែលអង្គការសហប្រជាជាតិបានអនុម័ត ។

## មាត្រា ២៨ : បទល្មើសក្នុងការសំដែងមតិ

១ : គ្មានជនណាម្នាក់ត្រូវគេឃាយឃាំខានពីរឿងមតិនយោបាយ ជំនឿសាសនា និងពីការដែលខ្លួនជាប់ពូជសាសន៍ ឬជាតិពន្ធណាមួយឡើយ ។

២ : ច្បាប់ព្រហ្មទណ្ឌទាំងឡាយ ដែលមានជាធរមានសព្វថ្ងៃទូទាំងប្រទេសកម្ពុជា មិនអាចយកមកសំអាងលើបទល្មើសក្នុងការសំដែងមតិនយោបាយ ឬបទល្មើសមនោគមន៍វិជ្ជាទៀតឡើយ ហើយត្រូវទុកជានិរាករណ៍ ។

## មាត្រា ២៩ : ការពិនិត្យសារឡើងវិញលើរឿងក្តីខ្លះ

ជនដែលត្រូវបានជំនុំជំរះរួចហើយក្តី អាច ដោយខ្លួនឯង ឬតាមរយៈទីប្រឹក្សា ឬមេធាវី សុំអោយសើរើពិនិត្យរឿងក្តីសារជាថ្មី បើសិនជាយល់ថាខ្លួនត្រូវគេផ្តន្ទាទោសក្នុងមូលដ្ឋានគំនិតមតិ, សេចក្តីថ្លែងការណ៍, ការដែលខ្លួនជាប់ ឬមិនជាប់ពូជសាសន៍, ជាតិពន្ធ, សាសនា, នយោបាយ និង សង្គម ។

## មាត្រា ៣០ : អាជ្ញាយុកាល

អាជ្ញាយុកាលសំរាប់បទមជ្ឈិមមានរយៈពេលបីឆ្នាំ រីឯអាជ្ញាយុកាលសំរាប់បទឧក្រិដ្ឋមានរយៈពេលដប់ឆ្នាំ។ អាជ្ញាយុកាលត្រូវចប់នៅពេលណាសកម្មភាពនីតិវិធីទាំងអស់បានសម្រេច ។

# មាតិកា បួន : បទឧក្រិដ្ឋ

## មាត្រា ៣១ : ឃាដកម្មគិតទុកជាមុន

១ : ជនណាដែលសម្លាប់ ឬប៉ុនប៉ងសម្លាប់ជនណាម្នាក់ទៀត ក្រោយពីបានគិតទុកជាមុននូវបទឧក្រិដ្ឋរបស់ខ្លួន ឬ ដោយបានរៀបចំការពួនស្ទាក់ ឬដែលបានសម្លាប់ ឬប៉ុនប៉ងសម្លាប់ជនណាម្នាក់ទៀត ក្នុងពេលដែលខ្លួនប្រព្រឹត្តចោរកម្ម ឬរំលោភសេពសន្ថវៈ ត្រូវជាប់ទោសពីបទឧក្រិដ្ឋធ្វើមនុស្សឃាដគិតទុកជាមុន ហើយត្រូវផ្តន្ទាទោសដាក់គុកជាបទឧក្រិដ្ឋពី ១០ឆ្នាំ ទៅ ២០ឆ្នាំ ។

២ : ការគិតទុកជាមុន គឺគំរោងធ្វើឡើងមុនអំពើបៀតបៀនទៅលើរូបបុគ្គលណាមួយ ។ ការពួនស្ទាក់ គឺការឃ្លាំចាំបុគ្គលណាម្នាក់ ក្នុងរយៈពេលមួយរយៈ ដើម្បីប្រព្រឹត្តហឹង្សាទៅលើបុគ្គលនោះ ។

## មាត្រា ៣២ : អំពើមនុស្សឃាតដោយចេតនា

ជនណាដែលសម្លាប់មនុស្សដោយចេតនា ឬ ប៉ុនប៉ងសម្លាប់ជនណាម្នាក់ទៀតដោយចេតនាដោយគ្មានស្ថានទម្ងន់ណាមួយដែលចែងក្នុងមាត្រា ៣១ ដោយបានប្រើ ឬមិនបានប្រើអាវុធក្តី ត្រូវជាប់ទោសពីបទឧក្រិដ្ឋធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវផ្តន្ទាទោសដាក់ជាបទឧក្រិដ្ឋពី ៨ឆ្នាំ ទៅ ១៥ឆ្នាំ ។

## មាត្រា ៣៣ : បទរំលោភសេពសន្ថវៈ

១ : ជនណាក៏ដោយដែលរំលោភសេពសន្ថវៈ ឬ ប៉ុនប៉ងរំលោភសេពសន្ថវៈលើជនម្នាក់ទៀតទោះភេទដូចគ្នា ឬមិនដូចគ្នាក៏ដោយ ត្រូវមានទោសពីបទសេពសន្ថវៈ ហើយផ្តន្ទាទោសដាក់គុកជាបទឧក្រិដ្ឋពី ៥ឆ្នាំ ទៅ ១០ឆ្នាំ ។

២ : បទរំលោភសេពសន្ថវៈ គឺគ្រប់អំពើបញ្ចូលអង្គជាតិដោយឃោរឃៅ ដោយបង្ខំ ឬដោយមិនដឹងខ្លួនជាមុន ។ ប្រសិនបើការរំលោភសេពសន្ថវៈបានត្រូវប្រព្រឹត្តឡើង ដោយការគំរាមកំហែងនឹងអាវុធទៅលើស្ត្រីមានផ្ទៃពោះ លើជនមានជំងឺ ឬ ជនមានសតិវិបល្លាស ឬ ពិការរាងកាយ ឬធ្វើឡើងដោយមានអ្នកប្រព្រឹត្តពីរនាក់ ឬច្រើននាក់ ឬដោយមានអ្នកសមគំនិត ឬបើការសេពសន្ថវៈនោះត្រូវប្រព្រឹត្តឡើង ដោយជនដែលមានអំណាចលើអ្នករងគ្រោះទណ្ឌកម្មដែលត្រូវអនុវត្តគឺជាក់គុកជាបទឧក្រិដ្ឋពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ ។

## មាត្រា ៣៤ : អំពើប្លន់

១ : ជនណាដែលបានលួច ឬប៉ុនប៉ងនឹងលួចជនណាម្នាក់ទៀត ដោយមានស្ថានទម្ងន់ទោសទាំងនេះ ៖

- ការលួចធ្វើដោយអំពើហិង្សា, មានអាវុធ ឬឥតអាវុធ, បណ្ដាល ឬមិនបណ្ដាលឲ្យមានរបួស

- ឬការលួចនោះបានធ្វើឡើងដោយមានគ្នាច្រើន ឬដោយមានគាស់ទំលុះទំលាយ, ត្រូវមានទោសពីបទឧក្រិដ្ឋប្លន់ ហើយត្រូវផ្ដន្ទាទោសជាក់គុកជាបទឧក្រិដ្ឋពី ៣ឆ្នាំ ទៅ ១០ឆ្នាំ ។

២ : អំពើលួចប្លន់គឺការបន្លំយកទ្រព្យសម្បត្តិរបស់អ្នកដទៃ ក្នុងបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ។

## មាត្រា ៣៥ : ការបង្ខាំងមនុស្សដោយខុសច្បាប់

ជនណាដោយគ្មានបញ្ជាពីអាជ្ញាធរតុលាការបានចាប់ខ្លួន ឬឃុំខ្លួន ឬបង្ខាំងខ្លួន មនុស្សណាក៏ដោយត្រូវមានទោស ៖

- ដាក់គុកជាបទឧក្រិដ្ឋ ១០ឆ្នាំ បើការបង្ខាំងខ្លួន ឬ ការឃុំខ្លួននោះមានរយៈពេលលើសពី ១ខែ

- ដាក់គុកពី ៣ឆ្នាំ ទៅ ៥ឆ្នាំ បើការបង្ខាំងខ្លួន ឬការឃុំខ្លួននោះមានរយៈតិចជាង ១ខែ

## មាត្រា ៣៦ : ក្រុមជនប្រដាប់អាវុធ

គ្រប់ជនដែលបានចូលរួមសមាគមមួយ ដែលមានការចាត់តាំង ឬក្នុងការព្រមព្រៀងគ្នាមួយដោយមានសម្ភារៈនៃហេតុមួយ ឬច្រើន ដើម្បីនឹងរៀបចំការប្រព្រឹត្តបទឧក្រិដ្ឋកម្ម ឬបទមជ្ឈិមមួយ ឬច្រើន ប្រឆាំងនឹងមនុស្សឬសម្បត្តិទ្រព្យទាំងឡាយ ត្រូវផ្តន្ទាជាបទឧក្រិដ្ឋពី ៣ឆ្នាំ ទៅ ១៥ឆ្នាំ ។

## មាត្រា ៣៧ : ការកែបំបាត់ធ្វើឡើងដោយអ្នករដ្ឋការ

១ : ជនជាតំណាងជាប់ឆ្នោត អ្នករដ្ឋការស៊ីវិល និង យោធាទាំងអស់ គ្រប់ភ្នាក់ងារផ្លូវការរបស់ភាគីណាមួយ នៃកម្ពុជាទាំងបួន នៃកិច្ចព្រមព្រៀងប៉ារីស គ្រប់អ្នកទទួលខុសត្រូវខាងនយោបាយដែលក្នុងក្របខ័ណ្ឌមុខងារខ្លួន ឬ ក្នុងឱកាសបំពេញមុខងារនេះ បានយកធ្វើជាទ្រព្យសម្បត្តិផ្ទាល់ខ្លួន, លក់, ជួល, កែបំបាត់ជាប្រយោជន៍ខ្លួន ឬ ជាប្រយោជន៍តតិយជនណាមួយនូវសម្បត្តិទ្រព្យ សេវាកម្ម ប្រាក់កាស បុគ្គលិក ផលប្រយោជន៍ ឯកសារ សេចក្តីអនុញ្ញាត ឬមុខងារដែលជារបស់សមូហភាពណាមួយធ្វើជាកម្មសិទ្ធិ ឬជាសិទ្ធិអាស្រ័យផល ត្រូវមានទោសពីបទឧក្រិដ្ឋកែបំបាត់សម្បត្តិសាធារណៈ ហើយត្រូវផ្តន្ទាទោសដាក់គុកពីបទឧក្រិដ្ឋពី ៣ឆ្នាំ ទៅ ១០ឆ្នាំ ។

២ : ជនណាដែលបានប្រព្រឹត្តបទល្មើសខាងលើនោះ នឹងអាចត្រូវតុលាការដកហូតមុខងារចេញពីអាណត្តិនៃការជ្រើសតាំងរបស់ខ្លួន ហើយម្យ៉ាងទៀតនឹងអាចត្រូវហាមឃាត់មិនឲ្យឈរឈ្មោះបោះឆ្នោត ឬមិនឲ្យកាន់មុខតំណែងដែលមានការទទួលខុសត្រូវណាមួយក្នុងរដ្ឋបាលសាធារណៈក្នុងរយៈពីរឆ្នាំ ក្រោយពីបានរងទោសរបស់ខ្លួនរួចហើយ ។

៣ : ម្យ៉ាងទៀត ជនប្រព្រឹត្តបទឧក្រិដ្ឋនោះ នឹងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ស្មើនឹងពីរដងនៃតម្លៃទ្រព្យសម្បត្តិ ឬទឹកប្រាក់ដែលបានកែបំបាត់ដោយបន្លំនោះ ។

## មាត្រា ៣៨ : ការស៊ីសំណូក

១ : ដោយមិនគិតដល់ទណ្ឌកម្មខាងវិន័យជាយថាហេតុ គ្រប់អ្នករដ្ឋបាលស៊ីវិល ឬយោធា គ្រប់ថ្នាក់ងារផ្លូវការរបស់ភាគីណាមួយ ក្នុងចំណោមភាគីទាំងបួននៃកិច្ចព្រមព្រៀងប៉ារីស គ្រប់អ្នកទទួលខុសត្រូវនយោបាយដែលស្នើសុំ ឬប៉ុនប៉ងនឹងស្នើសុំ ឬទទួល ឬប៉ុនប៉ងនឹងទទួល ក្នុងក្របខ័ណ្ឌនៃមុខងារខ្លួន ឬ ក្នុងឱកាសបំពេញការងារ នូវទ្រព្យសម្បត្តិ សេវាកម្ម ប្រាក់កាស បុគ្គល មុខងារ ឯកសារ សេចក្តីអនុញ្ញាតិ ឬ ផលប្រយោជន៍អ្វីមួយ ជាថ្នូរនៃរបស់ណាមួយក្នុងចំណោមរបស់ទាំងនេះ គឺបានប្រព្រឹត្តបទឧក្រិដ្ឋស៊ីសំណូកអកម្ម ហើយត្រូវផ្តន្ទាទោសដាក់គុកជបទឧក្រិដ្ឋពី ៣ឆ្នាំ ទៅ ៧ឆ្នាំ ។

២ : ជនដែលបានប្រព្រឹត្តបទល្មើសខាងលើនោះ នឹងអាចត្រូវតុលាការដកហូតមុខងារចេញពីអាណត្តិនៃការជ្រើសតាំងរបស់ខ្លួន ហើយម្យ៉ាងទៀតនឹងអាចហាមឃាត់មិនឲ្យឈរឈ្មោះក្នុងអាណត្តិនៃការបោះឆ្នោត ឬមិនឲ្យកាន់មុខតំណែងដែលមានការទទួលខុសត្រូវណាមួយក្នុងរដ្ឋបាលសាធារណៈ ក្នុងរយៈពេលពីរឆ្នាំ ក្រោយពីបានរងទោសរបស់ខ្លួនរួចហើយ ។

៣ : ម្យ៉ាងទៀត ជនប្រព្រឹត្តបទឧក្រិដ្ឋនោះ នឹងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ស្មើនឹងពីរដងនៃតម្លៃទ្រព្យសម្បត្តិ ឬ ទឹកប្រាក់ដែលបានតែបំបាត់ដោយបន្លំនោះ ។

## មាត្រា ៣៩ : ជំនួញគ្រឿងញៀនខុសច្បាប់

១ : លើកលែងតែមានការបញ្ជាផ្ទុយ ក្នុងមូលហេតុសុខភាពសាធារណៈ ដោយមានការយល់ព្រមពីមន្ទីសុខាភិបាលសាធារណៈ នៃរចនាសម្ព័ន្ធរដ្ឋបាលនីមួយៗដែលមានសព្វថ្ងៃ ការផលិត ការដឹកជញ្ជូន ការនាំចូល ការនាំចេញ ការរក្សាទុក ជំនួន ការផ្ទេរសម្បត្តិឲ្យ ការទទួលយក និង ការប្រើប្រាស់រុក្ខជាតិមានជាតិពុល គ្រឿងញៀន នឹង គ្រឿងស្រវឹង ដែលមានរាយក្នុងបញ្ជីកំណត់របស់អនុសញ្ញាសហប្រជាជាតិស្តីអំពីការប្រឆាំងនឹងជំនួញខុសច្បាប់នៃគ្រឿងញៀន និង គ្រឿងស្រវឹង ចុះថ្ងៃទី ២០ ធ្នូ ១៩៨៨, ថ្ងៃទី ២៧ មិនា ១៩៧២, ថ្ងៃទី ២១ កុម្ភៈ ១៩៧១ និងថ្ងៃទី ៣០ មិនា ១៩៦១ ត្រូវហាមឃាត់នៅក្នុងដែនដីកម្ពុជាទាំងមូល ។

២ : ជនដែលប្រព្រឹត្តបទល្មើសនឹងមាត្រានេះ ត្រូវផ្តន្ទាទោសដាក់គុកតម្រូវឲ្យធ្វើការពី ៥ឆ្នាំ ទៅ ១៥ឆ្នាំ ម្យ៉ាងទៀតសារជាតិហាមឃាត់ទាំងអស់ត្រូវរឹបអូស ហើយតុលាការបញ្ជាឲ្យ

បំផ្លាញចោល ក្រោយពីបានធ្វើវិភាគហើយ ។

## មាតិកា ប្រាំ : បទល្មើសមជ្ឈិម

### មាត្រា ៤០ : អំពើមនុស្សឃាដដោយអចេតនា

ជនណា ដោយខ្វះការប្រុងប្រយ័ត្ន ដោយការធ្វេសប្រហែស ដោយមិនប្រយ័ត្ន ឬ ដោយមិនគោរពតាមបទបញ្ជា ធ្វើអោយស្លាប់ជនម្នាក់ទៀតដោយគ្មានចេតនា ត្រូវមានទោសពីបទមជ្ឈិមធ្វើមនុស្សឃាតដោយអចេតនា ហើយត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៣ឆ្នាំ ។

### មាត្រា ៤១ : អំពើបង្ករបួសដោយចេតនា

ជនណាវាយតប់ បណ្តាលអោយមានរបួស ដែលនាំអោយពិការជាអចិន្ត្រៃយ៍ ឬ ពិការបណ្តោះអាសន្ន ក្នុងរយៈពេលលើសពី ៦ខែ ដោយចេតនា ត្រូវមានទោសពីបទបង្ករបួសដោយចេតនា ហើយត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៥ឆ្នាំ ។

- បើពិការភាពបណ្តោះអាសន្ននោះតិចជាង ៦ខែ ត្រូវផ្តន្ទាទោសដាក់គុកជននោះពី ៦ខែ ដល់ ២ឆ្នាំ ។
- បើគ្មានពិការភាពទេ ទោសដែលត្រូវកំណត់ផ្តន្ទាគឺដាក់គុកពី ២ខែ ទៅ ១ឆ្នាំ ។
- បើការវាយតប់នោះ ធ្វើឡើងដោយប្រើអាវុធប្រភេទណាមួយ កំរិតទោសត្រូវទ្វេមួយជាពីរ ។

## មាត្រា ៤២ : អំពើបៀតបៀនដល់កេរ្តិ៍ខ្មាស់

១ : ជនណាដែលបៀតបៀនដល់កេរ្តិ៍ខ្មាស់នៃជនណាម្នាក់ទៀត ដែលមានភេទដូចគ្នា ឬ មិនដូចគ្នា ដោយប្រព្រឹត្តទៅលើជននោះ តាមការស្ទាប អង្អែល ឬ អំពើផ្សេងទៀតទាក់ទងនឹងរឿងភេទ ប៉ុន្តែពុំបានដល់ទីជម្រៅ ត្រូវមានទោសពីបទបៀតបៀនដល់កេរ្តិ៍ខ្មាស់ ហើយត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៣ឆ្នាំ ។

២ : បើការបៀតបៀនដល់កេរ្តិ៍ខ្មាស់នោះ ធ្វើឡើងដោយការបង្ខំ ដោយអំពើហិង្សា ដោយការគំរាមកំហែង, បើអ្នករងគ្រោះមានអាយុតិចជាង ១៦ឆ្នាំ ឬ អ្នកប្រព្រឹត្តអំពើនោះជាអ្នកមានអំណាចលើជនរងគ្រោះ កំរិតផ្តន្ទាទោសត្រូវទ្វេមួយជាពីរ ។

៣ : នឹងត្រូវផ្តន្ទាទោសដាក់គុកពី ២ឆ្នាំ ទៅ ៦ឆ្នាំដែរ ចំពោះជនណាដែលបានល្បួង, អូសទាញ ឬបង្វែងត់និតអនីតិជនដើម្បីធ្វើពេស្យាចារ ឬធ្វើអាជីវកម្មពេស្យាចារលើអនីតិជន ទោះបីមានការព្រមព្រៀងក៏ដោយ ។

## មាត្រា ៤៣ : អំពើចោរកម្ម

គ្រប់ជនដែលលួច ឬប៉ុនប៉ងលួចទ្រព្យសម្បត្តិរបស់រូបវ័ន្តបុគ្គល ឬនីតិបុគ្គល ដោយពុំមានស្ថានទម្ងន់ទោសដូចមានចែងក្នុងមាត្រា៣៤ ត្រូវមានទោសពីបទលួច ហើយត្រូវផ្តន្ទាទោសដាក់គុកពី ៦ខែ ទៅ ៥ឆ្នាំ ។

## មាត្រា ៤៤ : បទល្មើសទាក់ទងទៅនឹងសម្បត្តិវប្បធម៌

១- គ្រប់ជនដែលលួច ឬប៉ុនប៉ងលួចទ្រព្យសម្បត្តិវប្បធម៌ដែលជារបស់រដ្ឋ ឬរបស់ឯកជនជារូបវ័ន្តបុគ្គល ឬនីតិបុគ្គល ហើយសម្បត្តិវប្បធម៌នោះចូលជាបេតិកភ័ណ្ឌជាតិកម្ពុជា ត្រូវផ្តន្ទាទោសដាក់គុកពី ៦ខែ ទៅ ១០ឆ្នាំ ។ ជនណាដែលនាំចេញ ឬប៉ុនប៉ងនឹងនាំចេញ ឬផ្ទេរកម្មសិទ្ធិសម្បត្តិវប្បធម៌ដោយខុសច្បាប់ ត្រូវមានទោសដូចគ្នា ។

២- តាមគោលបំណងនៃបទបញ្ញត្តិនេះ សម្បត្តិវប្បធម៌ គឺសម្បត្តិទាំងឡាយដែលកំណត់ដោយ *អនុសញ្ញារបស់អ៊ុយណេស្កូ ស្តីអំពីវិធានការដែលត្រូវចាត់ ដើម្បីហាមឃាត់ និងរារាំងការនាំចូល, ការនាំចេញ និងការផ្ទេរកម្មសិទ្ធិសម្បត្តិវប្បធម៌ ដោយខុសច្បាប់* ចុះថ្ងៃទី ១៤ វិច្ឆិកា ១៩៧០ ដែលប្រទេសកម្ពុជាបានអោយសច្ចានុម័តនៅថ្ងៃទី ២៦ កញ្ញា ១៩៧២ ។ ដែលសន្មតថាជាបេតិកភ័ណ្ឌជាតិកម្ពុជា គឺសម្បត្តិវប្បធម៌ទាំងអស់ ដែលមិនបានទទួលការអនុញ្ញាតពីក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ឬ អង្គការចាត់តាំងដើម្បីគោលបំណងនេះ ដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់នេះ អោយផ្ទេរ ឬ នាំចេញ ។

៣ : ការធ្វើអោយខូចគុណភាពដោយចេតនា នូវសម្បត្តិវប្បធម៌ដែលជាបេតិកភ័ណ្ឌជាតិកម្ពុជា ដោយការរុករកគ្មានការអនុញ្ញាត ឬដោយលួចលាក់, ដោយអំពើបំផ្លេចបំផ្លាញ ឬដោយមធ្យោបាយផ្សេងទៀត នឹងត្រូវមានទោសដូចគ្នា ។

## មាត្រា ៤៥ : អំពើឆបោក

ជនណាដែលធ្វើអោយគេអោយមកខ្លួន ឬប៉ុនប៉ងធ្វើអោយគេអោយមកខ្លួន នូវទ្រព្យសម្បត្តិទាំងអស់ ឬមួយចំណែកនៃទ្រព្យសម្បត្តិរបស់រូបវ័ន្តបុគ្គល ឬនីតិបុគ្គល ដោយប្រើល្បិចបន្លំ ឬក្លែងឈ្មោះ ឬក្លែងគុណភាព ដើម្បីបញ្ឆោះបញ្ឆោលជនរងគ្រោះ អោយជឿតាមអំណាចក្នុងការស្រម៉ៃ ឬដោយធ្វើអោយជនរងគ្រោះខ្លាច ឬសង្ឃឹមលើព្រឹត្តិការណ៍អ្វីមួយ ត្រូវមានទោសមជ្ឈិមពីបទឆបោក ហើយត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៥ឆ្នាំ ។

## មាត្រា ៤៦ : ការរំលោភលើសេចក្តីទុកចិត្ត

ជនណាដែលកែបន្លំ ឬបំបាត់ អោយខូចប្រយោជន៍ដល់ម្ចាស់កម្មសិទ្ធិ ម្ចាស់ទីកន្លែង ឬអ្នកកាន់កាប់ទ្រព្យសម្បត្តិ ប្រាក់កាស ទំនិញ ឬគ្រប់ឯកសារដែលមាន ឬដែលចែងអំពីកាតព្វកិច្ច ឬការដោះបន្ទុកដែលគេប្រគល់អោយមកខ្លួន ក្នុងលក្ខណៈជាការជួល ជាការដាក់ដឹកល់ទុក ជាអាណត្តិ ជាការអោយខ្ចីប្រើ ឬដើម្បីការងារមានបៀវត្ស ឬគ្មានបៀវត្ស, ដែលត្រូវប្រគល់អោយគេវិញ ឬធ្វើជាតំណាង ឬសំរាប់ប្រើប្រាស់ ឬជាមុខការមានកំណត់ ត្រូវមានទោសមជ្ឈិមពីបទរំលោភលើទំនុកចិត្ត ហើយត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៥ឆ្នាំ ។

## មាត្រា ៨៧ : អំពើក្លែងត្រា ក្រដាសប្រាក់ ផលប័ត្រសាធារណៈ និង ដែកបោះ, តែមប្រៃ និង ម៉ាកសញ្ញាផ្សេងៗ

១ : ជនណាដែលបានក្លែងត្រារបស់រចនាសម្ព័ន្ធរដ្ឋបាលដែលមានសព្វថ្ងៃ ឬប្រើប្រាស់ត្រាក្លែងក្លាយទាំងនោះ,

២ : ជនណាដែលក្លែង ឬបន្លំក្រដាសប្រាក់, តែមប្រៃប្រៃសណីយ៍, និមិត្តសញ្ញា, ធនប័ត្រ, ភាគហ៊ុន, កាតព្វកិច្ច ឬរូបិយវត្ថុដែលប្រើប្រាស់បានត្រឹមត្រូវតាមច្បាប់នៅក្នុងប្រទេសកម្ពុជា លិខិតឆ្លងដែន ឬ អត្តសញ្ញាណប័ណ្ណនៃរចនាសម្ព័ន្ធរដ្ឋបាលដែលមានសព្វថ្ងៃ ឬដែលបានប្រើប្រាស់ ឬបាននាំយករបស់ទាំងនោះចូលមកក្នុងដែនដីនៃប្រទេសកម្ពុជា,

៣ : ជនណាដែលបានក្លែងឬបន្លំក្រដាសប្រាក់ តែមប្រៃប្រៃសណីយ៍ និមិត្តសញ្ញា, ធនប័ត្រ, ភាគហ៊ុន, សញ្ញាប័ណ្ណ ឬរូបិយវត្ថុដែលប្រើប្រាស់បានត្រឹមត្រូវតាមច្បាប់នៅប្រទេសក្រៅ, លិខិតឆ្លងដែន ឬអត្តសញ្ញាណប័ណ្ណនៃប្រទេសក្រៅណាមួយ ឬដែលបានប្រើប្រាស់ ឬបាននាំយករបស់ទាំងនោះចូលមកក្នុងដែនដីនៃប្រទេសកម្ពុជា,

ត្រូវមានទោសមជ្ឈិមពីបទក្លែងបន្លំ ហើយផ្តន្ទាទោសដាក់គុកពី ៥ឆ្នាំ ទៅ ១៥ឆ្នាំ ។

## មាត្រា ៨៨ : អំពើក្លែងកម្មសិទ្ធិនៃបញ្ញា

១ : ការបោះពុម្ពផ្សាយគ្រប់ជំពូក នូវអត្ថបទសរសេរ, ការតែងបទភ្លេង, គំនូរ, វិចិត្រកម្ម, ខ្សែភាពយន្ត, រូបថត ឬផលិតកម្មបោះពុម្ព ឬ ចម្លាក់ផ្សេងៗទាំងអស់ ដោយរំលោភសិទ្ធិនៃបញ្ញារបស់អ្នកនិពន្ធ គឺជាការក្លែងបន្លំ ។

២ : គ្រប់ការនាំចូល ឬនាំចេញ, គ្រប់ផលិតកម្មចម្លង ការសំដែង ឬការផ្សាយផលិតកម្មចម្លងនៃស្នាដៃខាងផ្លូវគំនិត ដោយរំលោភសិទ្ធិអ្នកនិពន្ធ គឺជាការក្លែងបន្លំមួយដែរ ។

៣ : សិទ្ធិរបស់អ្នកនិពន្ធដែលបទបញ្ញត្តិនេះយោងដល់ គឺសិទ្ធិដែលការពារដោយអនុសញ្ញាក្រុងប៊ែន ចុះថ្ងៃទី ៩ កញ្ញា ១៨៨៦, ពិនិត្យឡើងវិញនៅក្រុងប៉ារីស ថ្ងៃទី ២៤ កក្កដា ១៩៧១ និងដោយអនុសញ្ញាជាសាកលស្តីអំពីសិទ្ធិអ្នកនិពន្ធ ដែលចុះហត្ថលេខានៅហ្សឺណែវ ថ្ងៃទី ៦ កញ្ញា ១៩៥២ ហើយពិនិត្យឡើងវិញនៅប៉ារីស ថ្ងៃទី ២៤ កក្កដា ១៩៧១ ។

## មាត្រា ៤៩ : ការក្លែងបន្លំអក្សរក្នុងឯកសារសាធារណៈ

គ្រប់ជនជ្រើសតាំងដោយការបោះឆ្នោត, គ្រប់អ្នករដ្ឋការស៊ីវិល ឬយោធា, គ្រប់ភ្នាក់ងារផ្លូវការរបស់ភាគីណាមួយ ក្នុងបណ្ដាភាគីខ្មែរទាំងបួន នៃកិច្ចព្រមព្រៀងក្រុងប៉ារីស ឬរបស់គ្រប់គណៈបក្សនយោបាយដែលបានចុះក្នុងបញ្ជី, អ្នកទទួលខុសត្រូវរបស់ភាគីណាមួយ ក្នុងបណ្ដាភាគីខ្មែរទាំងបួន នៃកិច្ចព្រមព្រៀងក្រុងប៉ារីស ឬ របស់គ្រប់គណៈបក្សនយោបាយដែលបានចុះក្នុងបញ្ជី ដែលក្នុងការបំពេញមុខងាររបស់ខ្លួន បានប្រព្រឹត្តបទក្លែង ដោយក្លែងហត្ថលេខា ឬដោយលួចកែលិខិតផ្លូវការ, កែអក្សរ ឬកែហត្ថលេខា, ដោយសន្មតជនម្នាក់ថាជាជនម្នាក់ទៀត, ដោយធ្វើអក្សរ ឬសិកបញ្ចូលអក្សរលើបញ្ជី ឬលិខិតសាធារណៈឯទៀតៗ, ចាប់ពីការធ្វើ ឬការបញ្ចប់បញ្ជី ឬលិខិតសាធារណៈទាំងនោះ, អ្នកណាដែលបានប្រើប្រាស់ ដោយដឹងខ្លួន នូវរបស់ក្លែងបន្លំអស់ទាំងនេះ នឹងត្រូវមានទោសឧក្រិដ្ឋពីបទក្លែងលិខិតសាធារណៈ ហើយត្រូវផ្ដន្ទាទោសពី ៥ឆ្នាំ ទៅ ១៥ឆ្នាំ ។

## មាត្រា ៥០ : ការក្លែងបន្លំលិខិតឯកជន, លិខិតពាណិជ្ជកម្ម ឬលិខិតធនាគារ

១ : ជនណាបានប្រព្រឹត្ត ឬប៉ុនប៉ងនឹងប្រព្រឹត្តការក្លែងលិខិតឯកជន, លិខិតពាណិជ្ជកម្ម ឬលិខិតធនាគារ តាមមធ្យោបាយណាមួយនៃមធ្យោបាយដែលបានចែងនៅក្នុងមាត្រា៤៩ នឹងត្រូវផ្ដន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៥ឆ្នាំ ហើយត្រូវពិន័យជាប្រាក់ពី ១,០០០,០០០ រៀល ទៅ ១០,០០០,០០០ រៀល ។

២ : ជនណាដែលបានប្រើប្រាស់ ដោយដឹងខ្លួននូវ លិខិតឯកជនក្លែង, លិខិតពាណិជ្ជកម្មក្លែង និង លិខិតធនាគារក្លែង នឹងត្រូវផ្ដន្ទាទោសដូចគ្នា ។

## មាត្រា ៥១ : អំពើទទួលផលចោរកម្ម

ជនណាដែលទទួល ឬទិញទ្រព្យសម្បត្តិដែលខ្លួនបានដឹងថា ទ្រព្យសម្បត្តិនោះបានមកអំពីអំពើចោរកម្ម, ពីការឆបោក ឬមកអំពីបទមជ្ឈិម ឬបទឧក្រិដ្ឋណាមួយ ត្រូវមានទោសមជ្ឈិម

ពីបទទទួលផលចោរកម្ម ហើយត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៥ឆ្នាំ ។ អំពើទទួលផលចោរកម្ម ជាបទល្មើសមិនចេះរលត់ ដែលអាយុកាលឈប់ចោទប្រកាន់ *(អាជ្ញាយុកាល)* របស់វាចាប់ផ្តើមនៅថ្ងៃណាដែលការទទួលផលចោរកម្មនេះបានចប់ ។

## មាត្រា ៥២ : ការធ្វើអោយខូចខាតដោយចេតនា

ជនណាដែលធ្វើអោយខូចខាត ឬប៉ុនប៉ងធ្វើអោយខូចខាត ដោយចេតនានូវទ្រព្យសម្បត្តិអ្នកដទៃ ត្រូវមានទោសមជ្ឈិមពីបទធ្វើអោយខូចខាតដោយចេតនា ហើយផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៣ឆ្នាំ ។ បើការខូចខាតនោះមានលក្ខណៈស្រាល ឬទ្រព្យនោះមានតំលៃតិចតួច ទោសដាក់គុកត្រូវបញ្ចុះមកត្រឹម ២ខែ ទៅ ១ឆ្នាំ ។ ការធ្វើអោយខូចខាតសម្បត្តិវប្បធម៌ ដែលជាបេតិកភ័ណ្ឌជាតិកម្ពុជា ត្រូវមានទោសតាមមាត្រា ៨៨ ។

## មាត្រា ៥៣ : អំពើបង្កអគ្គីភ័យដោយចេតនា

១ : ជនណាដែលធ្វើអោយខូចខាត ឬប៉ុនប៉ងធ្វើអោយខូចខាតដោយចេតនា នូវទ្រព្យសម្បត្តិអ្នកដទៃ ដោយបង្កអគ្គីភ័យ ឬដោយប្រើជាតិផ្ទុះ ត្រូវមានទោសមជ្ឈិមពីបទបង្កអគ្គីភ័យដោយចេតនា ហើយផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៣ឆ្នាំ ។

២ : បើទ្រព្យដែលភ្លើងឆេះនោះ ជាទ្រព្យដែលមានមនុស្សអាស្រ័យនៅពី ១នាក់ ទៅច្រើននាក់ កំរិតកំណត់ទណ្ឌកម្មនឹងត្រូវទ្វេមួយជាពីរ ។

## មាត្រា ៥៤ : ការកាន់អាវុធ ឬដឹកជញ្ជូនអាវុធដែលហាមឃាត់

១ : ជនណាដែលកាន់ ឬ ដឹកជញ្ជូនកាំភ្លើង, គ្រឿងផ្ទុះ ឬ អាវុធយុទ្ធភ័ណ្ឌ ដោយគ្មានការអនុញ្ញាតតាមល័ក្ខខ័ណ្ឌកំណត់តាមការណែនាំរបស់អ៊ិនតាក់ ស្តីអំពីការរក្សាទុក និងការកាន់កាប់អាវុធ ត្រូវមានទោសពីបទកាន់អាវុធ ឬដឹកជញ្ជូនអាវុធហាមឃាត់ដោយខុសច្បាប់ ហើយត្រូវផ្តន្ទាទោសដាក់គុកពី ៦ខែ ទៅ ៣ឆ្នាំ ។

២ : គ្រប់ជនគ្មានឯកសណ្ឋានប្រដាប់អាវុធ ត្រូវមានលទ្ធភាពបង្ហាញដល់អាជ្ញាធរ ដែលត្រួតពិនិត្យទាំងអស់ ជាអាទិតិភ្នាក់ងារ អ៊ុនតាក់ នូវលិខិតអនុញ្ញាតអោយកាន់អាវុធរបស់ខ្លួន ។ បើគ្មានលិខិតអនុញ្ញាតទេ អាវុធនោះត្រូវរឹបអូស និងបំផ្លាញចោលភ្លាម ហើយរបាយការណ៍មួយដែលមានតម្លៃដូចកំណត់ហេតុ ត្រូវសរសេរជូនដល់អាជ្ញាធរតុលាការមានសមត្ថកិច្ច ។

## មាត្រា ៥៥ : ការគៀបសង្កត់លើសាក្សី

ជនណាដែលគំរាមកំហែង, សំឡុត ឬធ្វើការគៀបសង្កត់លើសាក្សីណាមួយ ក្នុងនីតិវិធីតុលាការ ត្រូវមានទោសមជ្ឈិមពីបទសំឡុត ហើយត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ២ឆ្នាំ ។

## មាត្រា ៥៦ : សក្ខីភាពក្លែងក្លាយ.

ជនណាដែលបានបង្ហាញនូវសក្ខីភាពក្លែងក្លាយ ក្នុងនីតិវិធីតុលាការ ដោយបង្ហាញនូវហេតុផលដែលខ្លួនដឹងថាភាន់ច្រឡំ ឬមិនពិត ហើយដែលក្រោយមកតុលាការទទួលស្គាល់ថាដូច្នោះមែន ត្រូវមានទោសពីបទធ្វើសក្ខីភាពក្លែងក្លាយ ហើយត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ២ឆ្នាំ ។

## មាត្រា ៥៧ : អំពើរំលោភលើសិទ្ធិបុគ្គល

គ្រប់ភ្នាក់ងារសាធារណៈ រួមទាំងភ្នាក់ងារនគរបាល និងយោធិន ដែលរំលោភដោយមិនរួញរាទៅលើសិទ្ធិបូរណភាពបុគ្គល និងភាពមិនអាចរំលោភបាននៃលំនៅដ្ឋាន ដែលត្រូវបានការពារដោយបទបញ្ញត្តិនេះ នឹងត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៥ឆ្នាំ ។

## មាត្រា ៥៨ : អំពើសូកប៉ាន់

ជនណាដែលសូក ឬប៉ុនប៉ងសូក គ្រប់អ្នកតំណាងជាប់ឆ្នោត គ្រប់អ្នករដ្ឋការស៊ីវិល និងយោធា គ្រប់ភ្នាក់ងារផ្លូវការរបស់ភាគីណាមួយ ក្នុងចំណោមភាគីខ្មែរទាំងបួន នៃកិច្ចព្រមព្រៀង

ប៉ារីស ឬគ្រប់គណៈបក្សនយោបាយដែលបានចុះឈ្មោះក្នុងបញ្ជី ក្នុងក្របខ័ណ្ឌមុខងាររបស់ខ្លួន ឬក្នុងឱកាសបំពេញមុខងាររសទាំងនេះ ដោយសន្យាប្រគល់ដល់អ្នកទាំងនោះ នូវទ្រព្យសម្បត្តិ, សេវាកម្ម, ប្រាក់, បុគ្គលិក, មុខងារ, ឯកសារ, សេចក្តីអនុញ្ញាត ឬក៏វត្ថុមួយជាថ្នូរ ដើម្បីអោយបានរបស់ណាមួយក្នុងចំណោមរបស់ទាំងនោះ គឺជាការប្រព្រឹត្តបទមជ្ឈិមសូកប៉ាន់សកម្ម ហើយត្រូវមានទោសជាប់គុកពី ១ឆ្នាំ ទៅ ៣ឆ្នាំ ។

## មាត្រា ៥៩ : ការញុះញង់អោយប្រព្រឹត្តបទឧក្រិដ្ឋដោយបានសំរេចផល

នឹងត្រូវផ្តន្ទាទោសពីបទសមគំនិត ក្នុងអំពើដែលចាត់ថាជាបទឧក្រិដ្ឋតាមបទបញ្ញត្តិនេះ ជនទាំងឡាយណាដែល តាមរយៈសន្ទរកថា, តាមសម្រែក ឬ ការគំរាមកំហែង បន្ទរឡើងក្នុងកន្លែងនានាឬ ក្នុងទីប្រជុំជនសាធារណៈ, តាមការសរសេរ, ការបោះពុម្ព, គំនូរ, ចម្លាក់, វិចិត្រកម្ម, និម្មិតរូប, រូបភាព ឬគ្រប់ការគាំទ្រនៃការសរសេរ, សំដី ឬរូបភាព ដែលដាក់លក់ ឬដាក់តាំងនៅកន្លែងនានា ឬក្នុងទីប្រជុំជនសាធារណៈ, តាមផ្ទាំងបដា ឬប័ណ្ណប្រកាសដែលតាំងអោយសាធារណៈជនឃើញ, តាមគ្រប់មធ្យោបាយទំនាក់ទំនងសោតទស្សន៍ បានបង្កដោយផ្ទាល់អោយមនុស្សម្នាក់ ឬច្រើននាក់ ប្រព្រឹត្តអំពើដូចពោលខាងលើនេះ បើការញុះញង់នោះបានសំរេចផល ។

លក្ខន្តិកៈនេះអាចអនុវត្តបានដែរ កាលណាការញុះញង់នោះបានផលត្រឹមតែការប៉ុនប៉ងប្រព្រឹត្តអំពើឧក្រិដ្ឋប៉ុណ្ណោះ ។

## មាត្រា ៦០ : ការញុះញង់អោយប្រព្រឹត្តបទល្មើសឧក្រិដ្ឋ និងមជ្ឈិមដោយពុំបានសំរេចផល

ជនណា តាមមធ្យោបាយណាមួយដូចមានរៀបរាប់ក្នុងមាត្រាខាងលើនេះ ដែលបានញុះញង់ដោយផ្ទាល់អោយមានបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ ដែលមានចែងក្នុងបទបញ្ញត្តិនេះ នឹងត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៥ឆ្នាំ ក្នុងករណីណាដែលការញុះញង់នោះពុំបានសំរេចផល ។

## មាត្រា ៦១ : ការញុះញង់អោយមានការរើសអើង

១ : ជនណា តាមមធ្យោបាយណាមួយ ដូចមានចែងក្នុងមាត្រា ៥៩ ដែលបានញុះញង់អោយមានសម្អប់ជាតិ, ពូជសាសន៍ ឬសាសនា ដែលជាការញុះញង់អោយមានការរើសអើង, អរិភាព ឬហិង្សា នឹងត្រូវផ្តន្ទាទោសដាក់គុកពី ១ខែ ទៅ ១ឆ្នាំ ហើយត្រូវពិន័យជាប្រាក់ពី ១,០០០,០០០ ទៅ ១០,០០០,០០០រៀល ឬផ្តន្ទាតែទោសណាមួយនៃទោសទាំងពីរនេះក៏បាន ។

២ : ម្យ៉ាងទៀត ក្នុងករណីដែលមានការផ្តន្ទាទោសអំពីអំពើណាមួយ ដែលមានចែងក្នុងកថាខ័ណ្ឌខាងលើ តុលាការអាចបញ្ជាអោយបិទផ្សាយសេចក្តីសម្រេចរបស់ខ្លួន នៅទីកន្លែងទាំងឡាយដែលតុលាការនឹងបញ្ជាក់ ដោយអោយជនជាប់ទោសទទួលបន្ទុកចេញសោហ៊ុយ ហើយតុលាការអាចចុះផ្សាយសាលក្រមនេះក្នុងសារពត៌មានមួយ ឬច្រើន ដោយអោយជនជាប់ទោសទទួលបន្ទុកចេញសោហ៊ុយ រហូតដល់កំរិតច្រើនបំផុត ១០,០០០,០០០ រៀល ។ បណ្តឹងអាជ្ញាដែលទាក់ទងនឹងបទមជ្ឈិមដែលមានចែងក្នុងមាត្រានេះ អាចធ្វើឡើងបានតាមរយៈគ្រប់សមាគមដែលតាំងឡើងតាមវិធាន ដែលកំណត់ដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ដោយដាក់ពាក្យបណ្តឹងជាភាគីរដ្ឋប្បវេណី ជូនរដ្ឋអាជ្ញាមានសមត្ថកិច្ច ។

៣ : ក្នុងករណីណាក៏ដោយ និយោជក, អ្នកបោះពុម្ព, ក្រុមហ៊ុនបោះពុម្ពផ្សាយ ឬ ក្រុមហ៊ុនផ្សព្វផ្សាយ ត្រូវទទួលខុសត្រូវរួមក្នុងការសងជំងឺចិត្តផ្សេងៗ ដែលអាចនឹងត្រូវផ្តល់អោយជនរងគ្រោះម្នាក់ ឬច្រើននាក់ ។

## មាត្រា ៦២ : ការផ្សាយពត៌មានមិនពិត

ពេលណាមានការចុះផ្សាយ, ការផ្សព្វផ្សាយ ឬការផ្សាយបន្ត តាមមធ្យោបាយណាក៏ដោយ នូវពត៌មានមិនពិត, ពត៌មានប្រឌិត, ពត៌មានក្លែងក្លាយ ឬដោយកុហក់ ទំលាក់កំហុសដោយអសុទ្ធចិត្តទៅលើជនទីបី ក្នុងបំណងបំផ្លិចបំផ្លាញ ធ្វើអោយកើតកោលាហលដល់សន្តិសុខសាធារណៈ ឬអាចបណ្តាលអោយកើតកោលាហលដល់សន្តិសុខសាធារណៈ នាយក ឬអ្នកទទួលខុសត្រូវផ្សេងទៀតនៃការផ្សាយ ឬ អ្នកទទួលខុសត្រូវលើមធ្យោបាយគមនាគមន៍ឯទៀត

ដែលពាក់ព័ន្ធ ដែលបានសំរេចទទួលចុះផ្សាយ, ផ្សព្វផ្សាយ ឬ ផ្សាយបន្តនូវពត៌មានទាំងនោះ នឹងត្រូវផ្តន្ទាទោសដាក់គុកពី ៦ខែ ទៅ ៣ឆ្នាំ ហើយត្រូវពិន័យជាប្រាក់ពី ១,០០០,០០០ ទៅ ១០,០០០,០០០ រៀល ឬផ្តន្ទាតែទោសណាមួយនៃទោសទាំងពីរនេះក៏បាន ។

## មាត្រា ៦៣ : ការបរិហារកេរ្តិ៍ និង ការជេរប្រមាថ

១ : គ្រប់ការពោលអះអាង ឬគ្រប់ការទំលាក់កំហុសដោយអសុទ្ធចិត្ត នូវអំពើជាកំណត់ណាមួយ ដែលប៉ះពាល់ដល់កិត្តិយស ឬកេរ្តិ៍ឈ្មោះរបស់បុគ្គលឯកជន អំពើដែលនាំអោយកើតសៅហ្មងដល់ជននោះ គឺចាត់ជាការបរិហារកេរ្តិ៍ ។ ការផ្សាយដោយផ្ទាល់ ឬផ្សាយបន្តនូវនូវការពោលអះអាងនោះ ឬការទម្លាក់កំហុសនោះ ត្រូវមានទោស ទោះបីសំដៅទៅលើជនណាមួយដោយមិនចេញឈ្មោះជាក់លាក់ក៏ដោយ ប៉ុន្តែភិនភាគបានបញ្ជាក់ច្បាស់តាមន័យក្នុងសុន្ទរកថា, តាមសម្រែក, តាមការគំរាមកំហែង, តាមការសរសេរ ឬតាមការបោះពុម្ព, តាមផ្ទាំងបដារឬប័ណ្ណប្រកាស, តាមការផ្សាយសោតទស្សនៈដែលជាប់ចោទ ។ គ្រប់ការពោលអះអាង ឬការទំលាក់កំហុស ដែលអ្នកនិពន្ធ, អ្នកសារពត៌មាន, អ្នកទទួលខុសត្រូវខាងការផ្សាយ, អ្នកទទួលខុសត្រូវខាងបោះពុម្ពផ្សាយ នាយកកម្មវិធី ដែលដឹងថាមិនពិតហើយ នៅតែផ្សាយ, បោះពុម្ពផ្សាយ, សរសេរ ឬ ផ្សព្វផ្សាយ ក្នុងបំណងបំផ្លាញបុគ្គលសាធារណៈណាមួយ អំពើដែលនាំអោយកើតសៅហ្មងដល់ជននោះ គឺជាការបរិហារកេរ្តិ៍ ។

២ : គ្រប់ពាក្យជេរប្រមាថធ្ងន់ៗ, ពាក្យមើលងាយ ឬពាក្យជេរដែលគ្មានការទម្លាក់កំហុសទៅលើអំពើណាមួយ គឺជាការជេរប្រមាថ ។

៣ : ការបរិហារកេរ្តិ៍ ឬការជេរប្រមាថ ប្រព្រឹត្តឡើងតាមមធ្យោបាយណាមួយ ដែលមានចែងក្នុងមាត្រា ៥៩ នឹងត្រូវផ្តន្ទាទោសដាក់គុកពី ៨ថ្ងៃ ទៅ ១ឆ្នាំ ហើយត្រូវពិន័យជាប្រាក់ពី ១,០០០,០០០រៀល ទៅ ១០,០០០,០០០រៀល ឬត្រូវផ្តន្ទាតែទោសណាមួយនៃទោសទាំងពីរនេះក៏បាន ។

៤ : ម្យ៉ាងទៀត ក្នុងករណីដែលមានការផ្តន្ទាទោសអំពីអំពើណាមួយ ដែលមានចែងក្នុងកថាខ័ណ្ឌខាងលើ តុលាការអាចបញ្ជាអោយបិទផ្សាយសេចក្តីសម្រេចរបស់ខ្លួន នៅទីកន្លែងទាំងឡាយដែលតុលាការនឹងបញ្ជាក់ ដោយអោយជនជាប់ទោសទទួលបន្ទុកចេញសោហ៊ុយ ហើយតុលាការអាចចុះផ្សាយសាលក្រមនេះក្នុងសារពត៌មានមួយ ឬច្រើន ដោយអោយជនជាប់ទោស

ទទួលបន្ទុកចេញសោហ៊ុយ រហូតដល់កំរិតច្រើនបំផុត ១០,០០០,០០០ រៀល ។ បណ្តឹងអាជ្ញាដែលទាក់ទងនឹងបទមជ្ឈិមដែលមានចែងក្នុងមាត្រានេះ អាចធ្វើឡើងបានតាមរយៈគ្រប់សមាគមដែលតាំងឡើងតាមវិធានដែលកំណត់ដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ដោយដាក់ពាក្យបណ្តឹងជាភាគីរដ្ឋប្បវេណី ជូនរដ្ឋអាជ្ញាមានសមត្ថកិច្ច ។

៥ : ក្នុងករណីណាក៏ដោយ និយោជក, អ្នកបោះពុម្ព, ក្រុមហ៊ុនបោះពុម្ពផ្សាយ ឬ ក្រុមហ៊ុនផ្សព្វផ្សាយ ត្រូវទទួលខុសត្រូវរួមក្នុងការសងជំងឺចិត្តផ្សេងៗ ដែលអាចនឹងត្រូវផ្តល់អោយជនរងគ្រោះម្នាក់ ឬច្រើននាក់ ។

## មាត្រា ៦៤ : ការបន្លំក្នុងការបោះឆ្នោត

ជនណាក៏ដោយ តាមការគំរាមកំហែង, ការឈ្លានពានលើរូបកាយ, ការបង្ខិតបង្ខំប្រភេទណាក៏ដោយ ធ្វើអោយប៉ះពាល់ដល់ការប្រព្រឹត្តដោយសេរីនៃសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះអោយគេបោះឆ្នោត ឬប៉ះពាល់ដល់ភាពត្រឹមត្រូវនៃប្រតិបត្តិការបោះឆ្នោតទាំងឡាយ នឹងត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៣ឆ្នាំ ។

## មាត្រា ៦៥ : ការប្រើប្រាស់គ្រឿងញៀន

ជនណា ដែលប្រើប្រាស់ ដោយផ្ទាល់ខ្លួន នូវរុក្ខជាតិមានជាតិពុល, គ្រឿងញៀន ឬសារជាតិទាក់ទិននឹងសរសៃប្រសាទ ដូចដែលមានចែងក្នុងអនុសញ្ញាអង្គការសហប្រជាជាតិ ក្នុងមាត្រា ៣៩ និងត្រូវផ្តន្ទាទោសដាក់គុកពី ១ខែ ទៅ ១ឆ្នាំ ម្យ៉ាងទៀត សារជាតិហាមឃាត់ទាំងនេះនឹងត្រូវរឹបអូស ហើយតុលាការនឹងបញ្ជាអោយបំផ្លាញចោល ក្រោយពីធ្វើការវិភាគហើយ ។

## មាតិកា ប្រាំមួយ : អំពីទណ្ឌកម្ម

### មាត្រា ៦៦ : សមភាពនៃទណ្ឌកម្ម

គោលការណ៍សមភាពនៃពលរដ្ឋទាំងអស់ចំពោះមុខច្បាប់ព្រហ្មទណ្ឌ តម្រូវអោយទណ្ឌកម្មទាំងឡាយ ដែលត្រូវអនុវត្តន៍នៅប្រទេសកម្ពុជា មានភាពដូចគ្នានៅគ្រប់ខេត្ត ឬតំបន់។ ដូច្នេះ ទណ្ឌកម្ម ដែលមានចែងក្នុងបទបញ្ញត្តិនេះ ចាប់ពីពេលនេះតទៅ ត្រូវអនុវត្តនៅទូទាំងប្រទេសកម្ពុជា ។

### មាត្រា ៦៧ : ទោសប្រហារជីវិត

ទោសប្រហារជីវិតត្រូវបានលប់ចោលនៅប្រទេសកម្ពុជា ។

### មាត្រា ៦៨ : ស្ថានសំរាលទោស និង គ្រាប្រណីចំពោះអនីតិភាព

១ : ចៅក្រមទាំងឡាយត្រូវគិតដល់ស្ថានសំរាលទោស ដើម្បីបញ្ចុះទោសរហូតដល់ក្រោមអប្បបរិមា នៃទោសដែលមានចែងនៅក្នុងបទបញ្ញត្តិនេះ ហើយជាអាទិ៍គឺ ៖

- យុវភាពនៃអ្នកជាប់ទោស,
- ប្រវត្តិរូបផ្ទាល់នៃអ្នកជាប់ទោស ដែលមានលក្ខណៈអាចអោយបន្ថយភាពទទួលខុសត្រូវរបស់ខ្លួន,
- ស្ថានភាពចិត្តសាស្ត្រ ឬសរសៃប្រសាទនៃអ្នកត្រូវចោទ ដោយមានសញ្ញាប័ត្របញ្ជាក់ពីគ្រូពេទ្យខាងសរសៃប្រសាទ ឬគ្រូពេត្យខាងចិត្តសាស្ត្រ,
- កាលៈទេសៈនៃអំពើឧក្រិដ្ឋ ឬមជ្ឈិម ដែលបណ្តាលអោយអ្នកជាប់ទោសមានប្រត្តិកម្មដោយខានពុំបាន ។

២ : ចំពោះជនជាប់ចោទដែលមានអាយុតិចជាង ១៨ឆ្នាំ ទណ្ឌកម្មដែលមានក្នុងបណ្តាមាត្រាមុនៗ ត្រូវកាត់បន្ថយពាក់កណ្តាល នេះដោយមិនទាន់គិតដល់លក្ខន្តិកៈអនុគ្រោះផ្សេងៗលើសពីនេះទៀត ដែលមាននៅក្នុងបទដ្ឋានកំណត់ដោយរចនាសម្ព័ន្ធរដ្ឋបាលដែលមានសព្វថ្ងៃ ។

## មាត្រា ៦៩ : អំពើសមគំនិត

ជនណា ដែលបានផ្តល់មធ្យោបាយសំរាប់ប្រព្រឹត្តបទល្មើស, ដែលបានអោយបញ្ជាអោយគេប្រព្រឹត្តបទល្មើស, ដែលបានសំរួលដល់ការប្រព្រឹត្តបទល្មើស នឹងត្រូវចាត់ទុកថាជាអ្នកសមគំនិត ហើយត្រូវផ្តន្ទាទោសដូចគ្នានឹងអ្នកប្រព្រឹត្តបទល្មើសនោះដែរ ។

## មាត្រា ៧០ : ការរព្យួរទោស

ទោសជាប់ព័ន្ធនាគារ ប៉ុន្តែមិនមែនជាទោសឧក្រិដ្ឋបង្ខំអោយធ្វើការទេនោះ ជានិច្ចជាកាលតែងតែអាចនឹងត្រូវព្យួរទោសទាំងមូល ឬមួយផ្នែកបាន ។ ក្នុងករណីនេះ ជនដែលបានប្រព្រឹត្តបទល្មើសមិនត្រូវរងទណ្ឌកម្មចប់ចុងចប់ដើមទេ ប្រសិនបើខ្លួនពុំបានប្រព្រឹត្តិបទល្មើសមួយផ្សេងទៀត ដែលមានចែងនៅក្នុងបណ្តាមាត្រាមុនៗ ក្នុងរយៈពេល ៥ឆ្នាំ ក្រោយការកាត់ទោសរបស់ខ្លួន ។

## មាត្រា ៧១ : ការដោះលែងដោយមានល័ក្ខខ័ណ្ឌ

១ : ក្រោយពីបានរងទោសបានពាក់កណ្តាលនៃទោសគុក ឬ ២ ភាគ ៣ នៃទោសគុកបង្ខំអោយធ្វើការ ជនជាប់គុក ឬជាប់គុកបង្ខំអោយធ្វើការ អាចទទួលផលនៃវិធានការមួយ ស្តីពីការដោះលែងដោយមានល័ក្ខខ័ណ្ឌ តាមការកំណត់របស់តុលាការដែលកាត់ទោសខ្លួន ក្រោយពីបានឃោបល់ពីអាជ្ញាធរព័ន្ធនាគារ ហើយប្រសិនបើតុលាការយល់ឃើញថា ការដោះលែងនេះអាចជួយសម្រួលដល់ការចូលរួបរួមក្នុងសង្គមវិញជាថ្មីរបស់ជនជាប់ទោស ។

២ : គ្រប់បទល្មើសកំណត់នៅក្នុងបណ្តាមាត្រាមុនៗ ដែលត្រូវបានប្រព្រឹត្តក្នុងកំឡុងពេលដោះលែងដោយមានល័ក្ខខ័ណ្ឌនេះ នឹងបណ្តាលអោយមានការដាក់អនុវត្តន៍ជាបន្ទាន់ នូវទោសដែលនៅសល់ ។

## មាត្រា ៧២ : ការកំណត់អោយទុកប្រាក់ពិន័យ

គ្រប់ប្រាក់ពិន័យដែលទទួលក្នុងរយៈអន្តរកាលនេះ នឹងត្រូវដាក់ចូលទៅក្នុងគណនីបញ្ញើរចាំមួយ ក្រោមការទទួលខុសត្រូវរបស់ អ៊ុនតាក់ ដើម្បីទុកបង់ជូនអនាគតរដ្ឋាភិបាល ដែលកើតឡើងពីការបោះឆ្នោត ។

# មាតិកា ប្រាំពីរ : វិធានអនុវត្តន៍

## មាត្រា ៧៣ : ការទុកជានិរាករណ៍នៃវិធានដែលមិនស្របគ្នា

១ : គ្រប់អត្ថបទ, គ្រប់លក្ខន្តិកៈ, គ្រប់វិធានសរសេរ ឬមិនសរសេរ ដែលផ្ទុយនឹងបទបញ្ញត្តិនេះ, ទាំងខ្លឹមសារ ទាំងស្មារតី, ត្រូវទុកជានិរាករណ៍សុទ្ធសាធតែម្តង ។

២ : របនាសម្ព័ន្ធរដ្ឋបាលនិមួយៗដែលមានសព្វថ្ងៃ សន្យាថានឹងអនុវត្ត តាមគ្រប់មធ្យោបាយ, ទាំងសម្ភារៈ និងបុគ្គលិក, ចាំបាច់ដើម្បី ក្នុងរយៈពេលយ៉ាងគួរបំផុត សម្របនូវអត្ថបទនិងការប្រតិបត្តិរបស់ខ្លួន តាមបទបញ្ញត្តិនេះ និងតាមឧបករណ៍ទាំងឡាយរបស់អង្គការសហប្រជាជាតិដែលបានចែង ។

## មាត្រា ៧៤ : ឧបករណ៍អន្តរជាតិ

១ : ឧបករណ៍ទាំងឡាយនៃអង្គការសហប្រជាជាតិ ដែលមានចែងនៅក្នុងបទបញ្ញត្តិនេះត្រូវអនុវត្តជាគោលច្បាប់ក្នុងប្រទេសកម្ពុជា ពេលណាអត្ថបទទាំងនោះត្រូវបានផ្សាយជាផ្លូវការដោយ អ៊ុនតាក់ ។

២ : ឧបករណ៍អន្តរជាតិឯទៀតៗ ដែលសមហេតុផល អាចយកមកប្រើប្រាស់ដើម្បីធ្វើការបកស្រាយបទបញ្ញត្តិនេះបាន ។

<u>មាត្រា ៧៥ : ការចូលជាធរមាន</u>

អត្ថបទនេះត្រូវចូលជាធរមាន ៩៥ ថ្ងៃគត់ ក្រោយថ្ងៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់បានអនុម័ត លើកលែងតែអ្វីៗដែលទាក់ទងនឹងមាតិកា បួន, ប្រាំ, ប្រាំមួយ និងប្រាំពីរ ដែលត្រូវចូលជាធរមានមួយថ្ងៃ ក្រោយថ្ងៃដែលក្រុមប្រឹក្សាជាតិជាន់ខ្ពស់បានអនុម័ត ។

****************************

# កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

## និងពិធីសារបន្ថែម





អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស - ការិយាល័យប្រចាំកម្ពុជា

# កតិកាសញ្ញាអន្តរជាតិ

# ស្តីពី

# សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

# និងពិធីសារបន្ថែម

ខែតុលា ២០០៩

កូនសៀវភៅនេះ គឺជាការបោះពុម្ពផ្សាយដោយ
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ
ទទួលបន្ទុកសិទ្ធិមនុស្ស
ការិយាល័យប្រចាំនៅកម្ពុជា

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស

# មាតិការឿង

១- សេចក្តីផ្តើម ទំព័រទី៧

២- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ទំព័រ១៥

៣-ពិធីសារបន្ថែមទី១លើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ
និងសិទ្ធិនយោបាយ ពាក់ព័ន្ធនឹងការទទួលយកនីតិវិធីបណ្តឹងបុគ្គល ទំព័រទី៤៩

៤-ពិធីសារបន្ថែមទី១លើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិង
សិទ្ធិនយោបាយពាក់ព័ន្ធនឹងការលុបបំបាត់ទោសប្រហារជីវិត ទំព័រទី៥៥

# សញ្ញាអន្តរជាតិ
# ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ
# និងពិធីសារបន្ថែម

## សេចក្តីផ្តើម

មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ហើយចូលជាធរមានតាមច្បាប់អន្តរជាតិ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦។

កតិកាសញ្ញានេះ គឺជាសន្ធិសញ្ញាអន្តរជាតិមួយ ក្នុងចំណោមសន្ធិសញ្ញាអន្តរជាតិពីរ ដែលត្រូវបានព្រាងឡើង ដើម្បីផ្តល់អានុភាពតាមផ្លូវច្បាប់ដល់សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ឆ្នាំ១៩៤៨។ ចេតនាដើម គឺចង់ព្រាងសន្ធិសញ្ញាសិទ្ធិមនុស្សតែមួយប៉ុណ្ណោះ ក៏ប៉ុន្តែដោយសារតែនិន្នាការនយោបាយខុសគ្នាក្នុងសហគមន៍អន្តរជាតិនាពេលនោះ ទើបដំណោះស្រាយដែលអាចចេញរួច គឺការព្រមព្រៀងគ្នាព្រាងសន្ធិសញ្ញាចំនួនពីរស្របគ្នា។ ហេតុដូច្នេះ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយ គឺជាកញ្ចក់ឆ្លុះជាមួយនឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ ឯកសារទាំងពីរនេះ ធ្វើតាមទម្រង់ដូចគ្នា និងមានបទបញ្ញត្តិរួមដូចគ្នាជាច្រើន។ កតិកាសញ្ញាទាំងពីរនេះ បូករួមនឹងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សជារឿយៗ ត្រូវបានហៅថា "ធម្មនុញ្ញអន្តរជាតិស្តីពីសិទ្ធិមនុស្ស"។

ដោយមិនគិតពី ការបែងចែកសិទ្ធិមនុស្សជាពីរកតិកាសញ្ញា ដាច់ពីគ្នា និងការអនុម័តជាបន្តបន្ទាប់នូវសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលគ្របដណ្តប់លើវិស័យផ្សេងៗគ្នា អង្គការសហប្រជាជាតិ តែងតែបានសង្កត់ធ្ងន់លើពាក្យ *សកលភាព ភាពទាក់ទងគ្នា និងភាពពុំនាក់អាស្រ័យគ្នា* នៃសិទ្ធិមនុស្ស

ទាំងអស់។ និយាយម្យ៉ាងទៀត សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មិនសំខាន់ជាងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ហើយសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក៏មិនសំខាន់ជាងសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែរ។ មនុស្សទាំងអស់ មានសិទ្ធិទទួលបានសិទ្ធិមនុស្សទាំងអស់ស្មើគ្នា។

ទំនាក់ទំនងស្អិតរមួតរវាងសិទ្ធិទាំងពីរប្រភេទនេះ នៅពេលខ្លះ មានលក្ខណៈច្បាស់លាស់ណាស់៖ ទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានបញ្ញត្តិពីសិទ្ធិស្វ័យសំរេច ការមិនរើសអើង និងសមតាព ព្រមទាំង សិទ្ធិសហជីព និងការការពារគ្រួសារ។

**តើមានគោលការណ៍អ្វីខ្លះណែនាំរដ្ឋក្នុងការអនុវត្តន៍កតិកាសញ្ញានេះ**?

ពីរផ្នែកដំបូងនៃកតិកាសញ្ញានេះ បង្កើតគោលការណ៍ទូទៅដែលតាមរយៈបទបញ្ញត្តក្នុងផ្នែកទាំងពីរនេះ សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ត្រូវបានការពារ។ គោលការណ៍ទាំងនេះមាន៖

- *សិទ្ធិស្វ័យសំរេច*របស់ប្រជាជនទាំងអស់ ដើម្បីធ្វើសេចក្តីសំរេចពីឋានៈនយោបាយរបស់ខ្លួន ដោយសេរី និងដើម្បីចូលរួមក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ (មាត្រា១)
- គោលការណ៍នៃ*ការមិនរើសអើង*(មាត្រា២) ក្នុងការអនុវត្តន៍សិទ្ធិ តាមកតិកាសញ្ញានេះ។ និង
- គោលការណ៍*សមភាពរវាងបុរស និងស្ត្រី*(មាត្រា៣) ក្នុងការអាស្រ័យសិទ្ធិទាំងនេះ។

សិទ្ធិភាគច្រើននៅក្នុងអនុសញ្ញានេះ គឺជាសិទ្ធិដាច់ខាត ហើយត្រូវតែអនុវត្តភ្លាម និងទាំងស្រុង ខណៈដែលសិទ្ធិទាំងនេះ ចូលជាធរមាន។ ជា

ឧទាហរណ៍៖ ការទទួលយកបំរាមនៃអំពើទារុណកម្ម មានន័យថា រាល់ទារុណកម្ម ត្រូវតែបញ្ចប់ ដោយគ្មានលេសអ្វីទាំងអស់។ ទោះបីយ៉ាងណាក៏ដោយ ក្នុងកាលៈទេសៈកំណត់មួយចំនួនតូច រដ្ឋអាចព្យួរសិទ្ធិទាំងនេះ ឲ្យផុតពីកាតព្វកិច្ចរបស់ខ្លួន តាមកតិកាសញ្ញានេះជាបណ្តោះអាសន្នបាន ដូចជា៖ ក្នុងពេលមានគ្រាអាសន្នជាទូទៅ គំរាមកំហែងដល់អាយុជីវិតជាតិ រដ្ឋអាចចាត់វិធានការនានាដែលតម្រូវចាំបាច់បំផុត ដើម្បីដោះស្រាយការគំរាមកំហែងនោះ។

ទោះបីយ៉ាងណាក៏ដោយ កាតព្វកិច្ចនៃការមិនរើសអើង និងសិទ្ធិសំខាន់ៗមួយចំនួនទៀត រួមមានសិទ្ធិមានជីវិត សេរីភាពរួចចាកផុតពីការធ្វើទារុណកម្ម និងទាសភាព សេរីភាពខាងមនសិការ និងសាសនា ព្រមទាំងកិច្ចធានាការពារតាមផ្លូវច្បាប់មួយចំនួន ត្រូវបានចាត់ទុកថា *មិនអាចព្យួរជាបណ្តោះអាសន្ន* បានទេ មានន័យថា រដ្ឋមិនដែលអាចព្យួរសិទ្ធិទាំងនេះជាបណ្តោះអាសន្ន បានទេ ទោះជាស្ថិតក្នុងកាលៈទេសៈ រដ្ឋប្រកាសស្ថានភាពគ្រាអាសន្នក៏ដោយ។

### តើមានសិទ្ធិអ្វីខ្លះចែងនៅក្នុងកតិកាសញ្ញានេះ?

ផ្នែកទី៣ នៃកតិកាសញ្ញានេះ ចែងពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយសំខាន់ៗ ដែលមនុស្សម្នាក់ៗ ត្រូវទទួលបាន។ សិទ្ធិទាំងនេះរួមមាន៖

- សិទ្ធិមានជីវិត(មាត្រា៦) រួមមានគោលការណ៍ណែនាំពីពេលវេលា និងរបៀបនៃការដាក់ទោសប្រហារជីវិត។
- សេរីភាពរួចផុតពីការធ្វើទារុណកម្ម និងការប្រព្រឹត្ត ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ និងបន្ថោកបន្ទាប(មាត្រា៧) ព្រមទាំងសេរីភាពរួចផុតពី ទាសភាព ភាពជាខ្ញុំកញ្ជះគេ និងការងារដោយបង្ខំ (មាត្រា៨)។
- សិទ្ធិមានសេរីភាពនិងសន្តិសុខបុគ្គល រួមមានសេរីភាពរួចផុតពីការចាប់ខ្លួនតាមទំនើង

ចិត្ត និងសិទ្ធិការពារមួយចំនួន ក្នុងកំឡុងពេលនៃការចាប់ខ្លួន ការឃុំខ្លួន និងការដាក់ពន្ធនាគារតាមផ្លូវច្បាប់ (មាត្រា៩-១០ និង១១)។

- សេរីភាពនៃការដើរហើរ រួមមានសិទ្ធិចាកចេញពីប្រទេសណាមួយ(មាត្រា១២) និងសិទ្ធិរបស់ជនបរទេស ទទួលបាននីតិវិធីត្រឹមត្រូវ មុននឹងត្រូវបណ្តេញចេញពីប្រទេសណាមួយ (មាត្រា១៣)។
- សិទ្ធិទទួលបាន ភាពស្មើគ្នាចំពោះមុខច្បាប់ និងតុលាការ និងសិទ្ធិទទួលបានសវនាការប្រកបដោយភាពយុត្តិធម៌ជាមូលដ្ឋាន រួមមាន ការសន្មត់ជាមុនថាគ្មានទោស សិទ្ធិទទួលបានសវនាការមួយប្រកបដោយភាពយុត្តិធម៌ពីតុលាការមួយឯករាជ្យ សិទ្ធិការពារខ្លួន សិទ្ធិមានមេធាវី និងសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ (មាត្រា២៦ មាត្រា១៤ និងមាត្រា១៥)។
- សិទ្ធិក្នុងការទទួលស្គាល់ថាជា មនុស្សនៅចំពោះមុខច្បាប់ (មាត្រា១៦)។
- សិទ្ធិមានជីវិតឯកជន និងទទួលបានការការពារពីការវាយប្រហារលើកិត្តិយស ឬកិត្តិស័ព្ទរបស់ខ្លួន(មាត្រា១៧)។
- សេរីភាពនៃគំនិត មនសិការ និងសាសនា(មាត្រា១៨) សេរីភាពនៃការបញ្ចេញមតិ និងយោបល់(មាត្រា១៩) តែត្រូវបានហាមឃាត់ ចំពោះការឃោសនាឲ្យមានសង្គ្រាម និងការតស៊ូមតិឲ្យមានការស្អប់ជាតិ ពូជសាសន៍ ឬសាសនា (មាត្រា២០)។
- សិទ្ធិជួបប្រជុំដោយសន្តិវិធី (មាត្រា២១) ជួនកាលហៅថា សេរីភាពនៃការជួបប្រជុំ ព្រមទាំងសេរីភាពសមាគម រួមទាំងសិទ្ធិបង្កើត និងចូលរួមសហជីព (មាត្រា២២)
- សិទ្ធិរៀបអាពាហ៍ពិពាហ៍ និងបង្កើតគ្រួសារមួយ(មាត្រា២៣) និងការការពារសិទ្ធិកុមារ(មាត្រា២៤)

- សិទ្ធិប្រជាធិបតេយ្យ រួមមាន សិទ្ធិបោះឆ្នោត សិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោត និងសិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈ(មាត្រា២៥) និង
- សិទ្ធិរបស់ជនភាគតិច (មាត្រា២៧)

## តើកតិកាសញ្ញានេះអនុវត្តយ៉ាងដូចម្ដេចនៅកម្ពុជា?

ព្រះរាជាណាចក្រកម្ពុជា បានក្លាយជារដ្ឋភាគីនៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩២។ មាត្រា៣១ នៃរដ្ឋធម្មនុញ្ញ ធានាការពារអនុសញ្ញានេះ ថាជាផ្នែកមួយនៃច្បាប់កម្ពុជា ហើយមាត្រាដទៃទៀត គូសបញ្ជាក់ឡើងវិញពីការប្ដេជ្ញាចិត្តរបស់កម្ពុជាក្នុងការធានាថា ប្រជាជនកម្ពុជាទាំងអស់ អាចអាស្រ័យនូវសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរបស់ពួកគេ តាមវិសាលភាពពេញលេញបំផុតតាមតែអាចធ្វើបាន៖ សេចក្ដីប្រកាសនៃសិទ្ធិក្នុងជំពូកទី៣នៃរដ្ឋធម្មនុញ្ញ រួមមានការការពារអាយុជីវិត សន្តិសុខ និងសេរីភាព(មាត្រា៣២) សិទ្ធិប្រជាធិបតេយ្យ(មាត្រា៣៤ មាត្រា៣៥ និងមាត្រា៤២) សិទ្ធិបង្កើតសហជីព(មាត្រា៣៦) ការធានាការពារតាមផ្លូវច្បាប់ជាមូលដ្ឋានចំពោះការចាប់ខ្លួន និងការឃុំខ្លួន(មាត្រា៣៨) សេរីភាពក្នុងការដើរហើរ(មាត្រា៤០) សេរីភាពនៃការបញ្ចេញមតិ(មាត្រា៤១) សេរីភាពខាងសាសនា(មាត្រា៤៣)។ ឯករាជ្យភាពតុលាការ ត្រូវបានធានាការពារ នៅក្នុងជំពូកទី១១ នៃរដ្ឋធម្មនុញ្ញ។

ក្នុងសេចក្ដីសំរេចរបស់ខ្លួន កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ក្រុមប្រឹក្សាធម្មនុញ្ញបានគូសបញ្ជាក់ឡើងវិញថា សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ រួមទាំង កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គឺជាផ្នែកមួយនៃច្បាប់ជាតិកម្ពុជា ដោយសារតែសន្ធិសញ្ញាទាំងនេះ ត្រូវបានការពារដោយរដ្ឋធម្មនុញ្ញ ហើយជាផលវិបាក ចៅក្រមត្រូវតែគោរពតាមឲ្យបានខ្ជាប់ខ្ជួននូវបទបញ្ញត្តិនៃសន្ធិសញ្ញាទាំងនេះ នៅពេលដែលខ្លួនធ្វើការបកស្រាយច្បាប់ និងធ្វើសេចក្ដីសំរេច។

**គណៈកម្មាធិការសិទ្ធិមនុស្ស**

នៅពេលដែលរដ្ឋមួយ បានក្លាយជាភាគីនៃកតិកាសញ្ញា រដ្ឋនោះត្រូវជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ ពីការប្ដេជ្ញាចិត្ត ចំពោះប្រជាពលរដ្ឋរបស់ខ្លួន និងចំពោះសហគមន៍អន្តរជាតិ ក្នុងការអនុវត្តន៍បទបញ្ញត្តិនៃសន្ធិសញ្ញានេះ ដើម្បីលើកស្ទួយ និងការពារសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរបស់ប្រជាពលរដ្ឋគ្រប់រូបនៅក្នុងប្រទេស។ ការប្ដេជ្ញាចិត្តនេះ តំរូវឲ្យមានកិច្ចខិតខំប្រឹងប្រែងបន្តទៀតពីរដ្ឋាភិបាល។

ដើម្បីជួយរដ្ឋភាគីក្នុងការបំពេញបាននូវការប្ដេជ្ញាចិត្តនេះ កតិកាសញ្ញាបានបង្កើតគណៈកម្មាធិការអន្តរជាតិមួយ ដែលមានសុទ្ធតែអ្នកជំនាញការឯករាជ្យ ហើយត្រូវបានស្គាល់ជាទូទៅថា គណៈកម្មាធិការសិទ្ធិមនុស្ស ដើម្បីឃ្លាំមើលការរីកចំរើន និងផ្ដល់ប្រឹក្សាយោបល់ទៀងទាត់ដល់រដ្ឋភាគី។ រដ្ឋភាគីទាំងអស់ ត្រូវបានតម្រូវឲ្យរាយការណ៍ជាទៀងទាត់ ទៅគណៈកម្មាធិការនេះ ពីការចាត់វិធានការរបស់ខ្លួន ដើម្បីអនុវត្តកតិកាសញ្ញានេះ។ បន្ទាប់មក របាយការណ៍ទាំងនេះ ត្រូវបានយកមកពិភាក្សាជាមួយរដ្ឋាភិបាលសាមី រួចទើបផ្ដល់អនុសាសន៍ដល់រដ្ឋនោះ។

កម្ពុជា បានដាក់របាយការណ៍ដំបូងរបស់ខ្លួន ជូនអង្គការសហប្រជាជាតិ កាលពីឆ្នាំ១៩៩៨ ហើយគណៈកម្មាធិការ បានយករបាយការណ៍នោះមកធ្វើការពិនិត្យ នៅខែកក្កដា ឆ្នាំ១៩៩៩។ របាយការណ៍តាមកាលកំណត់បន្ទាប់ត្រូវបានហួសកាលកំណត់ជាយូរមកហើយ តាំងពីឆ្នាំ២០០២ម្ល៉េះ។

*យន្តការត្រួតពិនិត្យបន្ថែម ក្នុងពិធីសារបន្ថែមទី១ លើកតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយ*

នៅពេលដែល មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តកតិកាសញ្ញានេះ កាលពីឆ្នាំ១៩៦៦ មហាសន្និបាតនេះ ក៏បានអនុម័តពិធីសារ

បន្ថែមមួយដែរ ដែលផ្តល់ឲ្យរដ្ឋភាគីជ្រើសរើស ដើម្បីអនុញ្ញាតឲ្យគណៈកម្មាធិការសិទ្ធិមនុស្ស នៅហ្សឺណែវ ពិនិត្យពិចារណាលើបណ្តឹងពីឯកត្តបុគ្គល ដែលអះអាងថា សិទ្ធិរបស់គេត្រូវបានរំលោភបំពាន។ គណៈកម្មាធិការ អាចទទួលបណ្តឹងបែបនេះបាន តែពីបណ្តាប្រទេសណាដែលបានជ្រើសរើសផ្តល់សច្ចាប័នលើពីធីសារនេះប៉ុណ្ណោះ ហើយអាចពិនិត្យបណ្តឹង តែនៅពេលណា បណ្តឹងនោះបំពេញបាននូវលក្ខណៈវិនិច្ឆ័យមួយចំនួន៖ ជាពិសេស បណ្តឹងនេះ អាចយកមកពិនិត្យ បានលុះត្រាតែ ឯកត្តបុគ្គលនោះ បានប្រើប្រាស់អស់ដំណោះស្រាយក្នុងស្រុកទៅហើយ។

ប្រទេសកម្ពុជា បានចុះហត្ថលេខាលើពិធីសារបន្ថែមនេះ កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៤ ក៏ប៉ុន្តែនៅមិនទាន់បានផ្តល់សច្ចាប័ននៅឡើយទេ។ ការចុះហត្ថលេខាលើសន្ធិសញ្ញាអន្តរជាតិ ប្រាប់ដល់សហគមន៍អន្តរជាតិថា រដ្ឋនោះ មានបំណងនឹងផ្តល់សច្ចាប័នពេញលេញភ្លាម នៅពេលដែលនីតិវិធីផ្តល់សច្ចាប័នក្នុងស្រុក ត្រូវបានបំពេញរួចរាល់។

*កាតព្វកិច្ចជ្រើសរើសបន្ថែម តាមពិធីសារបន្ថែមទី២ ស្តីពីការលប់ចោលទោសប្រហារជីវិត*

មាត្រា៦ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយ ធានាការពារសិទ្ធិមានជីវិតពីកំណើតរបស់មនុស្សទាំងអស់ ក៏ប៉ុន្តែ កតិកាសញ្ញានេះ មិនបានហាមឃាត់ការប្រើប្រាស់ទោសប្រហារជីវិតនៅក្នុងរដ្ឋភាគីទាំងអស់នោះទេ។ ជំនួសមកវិញ រដ្ឋភាគី ត្រូវផ្តល់ការធានាការពារមួយចំនួន ដើម្បីធានាថា ទោសប្រហារជីវិត ត្រូវបានអនុវត្តតែក្នុងរឿងក្តីធ្ងន់ធ្ងរបំផុត ហើយមិនដែលត្រូវអនុវត្តចំពោះជនទាំងឡាយណា ដែលមានអាយុក្រោម១៨ឆ្នាំនោះទេ។ ទោះជាយ៉ាងណាក៏ដោយ ការធានាការពារល្អបំផុតនៃសិទ្ធិមានជីវិត គឺនៅតែជាការលប់បំបាត់ទាំងស្រុងនៃទោសប្រហារជីវិត។

កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៨៩ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តពិធីសារបន្ថែមទី២ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលតាមរយៈនេះ រដ្ឋអាចប្តេជ្ញាចិត្តខ្លួនឯង ចំពោះការលប់ចោលទោសប្រហារជីវិតទាំងស្រុង និងដាច់ខាត។

មាត្រា៣២ នៃរដ្ឋធម្មនុញ្ញកម្ពុជា បានហាមឃាត់ជាចំហ ចំពោះការដាក់ទោសប្រហារជីវិតនៅកម្ពុជា ថាជាផ្នែកមួយនៃការការពារសិទ្ធិមានជីវិត និងសន្តិសុខរបស់បុគ្គល។ ក៏ប៉ុន្តែ កម្ពុជា នៅមិនទាន់បានចុះហត្ថលេខា ឬផ្តល់សច្ចាប័នលើពិធីសារបន្ថែមនៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយទេ។ ការផ្តល់សច្ចាប័នលើពិធីសារនេះ នឹងគ្មានចំណាយលើអ្វីទាំងអស់ ប៉ុន្តែនឹងបង្កើតជាសញ្ញាដ៏សំខាន់មួយ ដល់សហគមន៍អន្តរជាតិ នៃការមិនអនុវត្តន៍ទោសប្រហារជីវិតរបស់កម្ពុជា នៅក្នុងតំបន់ដែលទោសប្រហារជីវិត កំពុងតែអនុវត្តជាទូទៅនៅឡើយ។

ការិយាល័យឧត្តមស្នងការ
អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
ការិយាល័យប្រចាំនៅកម្ពុជា

ខែវិច្ឆិកា ឆ្នាំ២០០៩។

# កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

ត្រូវបានអនុម័ត និងបើកឱ្យចុះហត្ថលេខា ឱ្យសច្ចាប័ន និងឱ្យចូលជាសមាជិក
តាមសេចក្ដីសម្រេចចិត្តលេខ២២០០A (XXI)
ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ របស់មហាសន្និបាតអង្គការសហប្រជាជាតិ
ចូលជាធរមាននៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦ ស្របតាមមាត្រា៤៩

## បុព្វកថា

*រដ្ឋភាគីនៃកតិកាសញ្ញានេះ*

*យល់ឃើញថា* ស្របតាមគោលការណ៍នានា ដែលបានប្រកាសនៅក្នុងធម្មនុញ្ញសហប្រជាជាតិ ការទទួលស្គាល់សេចក្ដីថ្លៃថ្នូរជាប់ពីកំណើត សិទ្ធិស្មើភាពគ្នា និងសិទ្ធិដែលមិនអាចលក់ដូរ ផ្ទេរ ដកហូតបាន របស់សមាជិកគ្រួសារមនុស្ស គឺជាគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាពក្នុងពិភពលោក ។

*ទទួលស្គាល់ថា* សិទ្ធិទាំងនេះ កើតមកពីសេចក្ដីថ្លៃថ្នូរជាប់ពីកំណើតរបស់មនុស្ស ។

*ទទួលស្គាល់ថា* ស្របតាមសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស ឧត្តមគតិរបស់មនុស្សសេរី ដែលអាស្រ័យផលសេរីភាពពលរដ្ឋ និងនយោបាយ និងភាពរួចផុតពីការភ័យខ្លាច និងទុគ៌តភាព អាចសម្រេចជោគជ័យទៅបាន លុះត្រាតែបង្កើតបានលក្ខខណ្ឌដែលឱ្យមនុស្សម្នាក់ៗ អាចប្រើប្រាស់បាននូវសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ព្រមទាំងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ខ្លួន ។

*យល់ឃើញថា* ធម្មនុញ្ញសហប្រជាជាតិ តម្រូវឱ្យរដ្ឋនូវកាតព្វកិច្ចជំរុញឱ្យមានការគោរពជាសកល និងការអនុវត្តន៍នូវសិទ្ធិ និងសេរីភាពរបស់មនុស្ស ។

*យល់ឃើញថា* បុគ្គលគ្រប់រូប មានករណីយកិច្ចចំពោះអ្នកដទៃ និងចំពោះសហគមន៍ដែលខ្លួនរស់នៅ ហើយត្រូវខិតខំលើកស្ទួយ និងគោរពសិទ្ធិទាំងឡាយដែលទទួលស្គាល់ក្នុងកតិកាសញ្ញានេះ ។

*ព្រមព្រៀងលើមាត្រាទាំងឡាយដូចតទៅ :*

## ផ្នែកទី ១

### មាត្រា ១

១. ប្រជាជាតិទាំងអស់ មានសិទ្ធិស្វ័យសម្រេច ។ អាស្រ័យដោយសិទ្ធិនេះ ប្រជាជាតិទាំងនេះ សម្រេចដោយសេរីនូវឋានៈនយោបាយ និងខិតខំអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ខ្លួនដោយសេរី ។

២. ដើម្បីសម្រេចគោលដៅរបស់ខ្លួន ប្រជាជាតិទាំងអស់ អាចចាត់ចែងដោយសេរីនូវភោគទ្រព្យ និងធនធានធម្មជាតិរបស់ខ្លួន ដោយមិនធ្វើឱ្យប៉ះពាល់ដល់កាតព្វកិច្ច ដែលចេញមកពីសហប្រតិបត្តិការសេដ្ឋកិច្ចអន្តរជាតិ ដែលផ្អែកលើគោលការណ៍នៃផលប្រយោជន៍ទៅវិញទៅមក និងគោលការណ៍នៃច្បាប់អន្តរជាតិ ។ តែទោះយ៉ាងណាក៏ដោយ ប្រជាជាតិនីមួយៗ មិនត្រូវបានដកហូតមធ្យោបាយចិញ្ចឹមជីវិតផ្ទាល់ខ្លួនឡើយ ។

៣. រដ្ឋភាគីនៃកតិកាសញ្ញានេះ រួមទាំងរដ្ឋនានាដែលមានការទទួលខុសត្រូវគ្រប់គ្រងទឹកដីអស្វយ័ត និងទឹកដីអាណាព្យាបាល ត្រូវលើកស្ទួយធ្វើឱ្យបានសម្រេច នូវសិទ្ធិស្វ័យសម្រេច និងត្រូវគោរពសិទ្ធិនេះ ស្របតាមបទបញ្ញត្តិទាំងឡាយនៃធម្មនុញ្ញសហប្រជាជាតិ ។

## ផ្នែកទី ២

## មាត្រា ២

១. រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាគោរព និងធានាជូនបុគ្គលគ្រប់រូបដែលរស់នៅលើទឹកដី និងស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួននូវសិទ្ធិដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ ដោយគ្មានការបែងចែកណាមួយ មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃៗទៀតឡើយ ។

២. បើមិនទាន់មានចែងក្នុងច្បាប់ដែលមានស្រាប់ ឬក្នុងវិធានការដទៃទៀតទេ រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាចាត់វិធានការចាំបាច់ ស្របតាមនីតិវិធីនៃរដ្ឋធម្មនុញ្ញរបស់ខ្លួន និងស្របតាមបទបញ្ញត្តិទាំងឡាយ នៃកតិកាសញ្ញានេះ ដោយសម្រួលដល់ការអនុម័តវិធានការច្បាប់ ឬវិធានការផ្សេងទៀតដែលចាំបាច់ ដើម្បីធ្វើឱ្យសម្រេចបាននូវសិទ្ធិទាំងឡាយដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ ។

៣. រដ្ឋភាគីនៃកាតិកាសញ្ញានេះ សន្យា ៖

(ក) ធានាថា ជនណាដែលត្រូវគេរំលោភសិទ្ធិ និងសេរីភាពរបស់ខ្លួនដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ ជននោះ មានសិទ្ធិឱ្យមានការដោះស្រាយដោយស័ក្តិសិទ្ធិ ទោះបីការរំលោភនោះ បានប្រព្រឹត្តដោយជនដែលបំពេញមុខនាទីរាជការក៏ដោយ ។

(ខ) ធានាថា ជនណាដែលប្តឹងឱ្យមានការដោះស្រាយបែបនេះ ត្រូវមានសិទ្ធិឱ្យអាជ្ញាធរមានសមត្ថកិច្ចខាងយុត្តិធម៌ ខាងរដ្ឋបាល ឬខាងនីតិបញ្ញត្តិ ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀត សម្រេចឱ្យខ្លួន ដោយយោងតាមច្បាប់របស់រដ្ឋនោះ និងត្រូវបង្កើតលទ្ធភាពនៃការប្តឹងទៅតុលាការផង ។

(គ) ធានាថា អាជ្ញាធរមានសមត្ថកិច្ច ត្រូវអនុវត្តឱ្យបាននូវដំណោះស្រាយ ដែលបានសម្រេចហើយ ។

មាត្រា ៣

រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាធានាសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី ក្នុងការប្រើប្រាស់សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដូចមានចែងក្នុងកតិកាសញ្ញានេះ ។

មាត្រា ៤

១. ក្នុងករណីមានភាពអាសន្នសាធារណៈពិសេស ដែលគំរាមកំហែងដល់អត្ថិភាពជាតិ និងដែលត្រូវបានប្រកាសជាផ្លូវការ រដ្ឋភាគីនៃកតិកាសញ្ញានេះ អាចចាត់វិធានការបដិប្បញ្ញត្តិនឹងកាតព្វកិច្ចដែលមានចែងក្នុងកតិកាសញ្ញានេះ ក្នុងកម្រិតដែលស្ថានភាពតម្រូវតែប៉ុណ្ណោះ កុំឱ្យតែវិធានការទាំងនេះ មានវិសមិតភាពទៅនឹងកាតព្វកិច្ចដទៃទៀត ដែលច្បាប់អន្តរជាតិតម្រូវ ហើយមិនពាក់ព័ន្ធនឹងការរើសអើងដែលផ្អែកលើពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ឬដើមកំណើតសង្គម។

២. បទបញ្ញត្តិខាងលើនេះ មិនអនុញ្ញាតឱ្យមាន បដិប្បញ្ញត្តិនឹង មាត្រា៦ មាត្រា៧ មាត្រា៨ (កថាខណ្ឌ១ និង២) មាត្រា១១ មាត្រា១៥ មាត្រា១៦ និង មាត្រា១៨ ។

៣. រដ្ឋភាគីណាមួយនៃកតិកាសញ្ញានេះដែលប្រើប្រាស់សិទ្ធិបដិប្បញ្ញត្តិ ត្រូវផ្តល់ព័ត៌មានដល់រដ្ឋភាគីឯទៀតជាបន្ទាន់ តាមរយៈអន្តរការីនៃអគ្គលេខាធិការអង្គការសហប្រជាជាតិ នូវបទបញ្ញត្តិ និងមូលហេតុ ដែលខ្លួនបានធ្វើបដិប្បញ្ញត្តិនេះ។ ការផ្តល់ព័ត៌មានបន្ថែមស្តីពីកាលបរិច្ឆេទ នៃការបញ្ចប់បដិប្បញ្ញត្តិរបស់ខ្លួន ត្រូវធ្វើឡើងតាមរយៈអន្តរការីនៃអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

## មាត្រា ៥

១. គ្មានបទបញ្ញត្តិណាមួយនៃកតិកាសញ្ញានេះ អាចត្រូវបានបកស្រាយតម្រូវថា រដ្ឋមួយ ក្រុមមួយ បុគ្គលម្នាក់ មានសិទ្ធិធ្វើសកម្មភាព ឬប្រព្រឹត្តអំពើអ្វីមួយដែលសំដៅទៅបំផ្លិចបំផ្លាញសិទ្ធិ និងសេរីភាព ដែលទទួលស្គាល់ក្នុងកតិកាសញ្ញានេះ ឬសំដៅទៅដាក់កម្រិត ដែលមានវិសាលភាពធំជាងកម្រិត ដែលបានចែងនៅក្នុងកតិកាសញ្ញានេះ ។

២. មិនត្រូវធ្វើការរិតត្បិត ឬធ្វើបដិប្បញ្ញត្តិណាមួយឡើយ ទៅលើសិទ្ធិមូលដ្ឋានរបស់មនុស្ស ដែលត្រូវបានទទួលស្គាល់ ឬដែលនៅជាធរមាន ក្នុងរដ្ឋភាគីនៃកតិកាសញ្ញានេះ ដោយអនុលោមទៅតាមច្បាប់ អនុសញ្ញា បទបញ្ជា ឬទំនៀមទំលាប់ ដោយយកលេសថា កតិកាសញ្ញានេះ មិនទទួលស្គាល់សិទ្ធិទាំងនោះ ឬទទួលស្គាល់សិទ្ធិទាំងនោះក្នុងកម្រិតតិចជាង ។

## ផ្នែកទី ៣

## មាត្រា ៦

១. ជនគ្រប់រូប មានសិទ្ធិមានជីវិតជាប់ពីកំណើត ។ សិទ្ធិនេះ ត្រូវការពារដោយច្បាប់ ។ គ្មានជនណាម្នាក់ ត្រូវគេប្រហារជីវិតតាមអំពើចិត្តបានឡើយ ។

២. ក្នុងប្រទេសទាំងឡាយណា ដែលមិនទាន់បានលប់ចោលទោសប្រហារជីវិត សាលក្រមកាត់ទោសប្រហារជីវិត អាចប្រកាសបានចំពោះតែបទឧក្រិដ្ឋណាដែលធ្ងន់ធ្ងរបំផុតស្របតាមច្បាប់ជាធរមាន ក្នុងពេលដែលបទឧក្រិដ្ឋនោះកើតឡើង ហើយមិនផ្ទុយនឹងបទបញ្ញត្តិនៃកតិកាសញ្ញានេះ និងអនុសញ្ញាស្តីពីការបង្ការ និងការផ្តន្ទាទោសបទឧក្រិដ្ឋប្រល័យពូជសាសន៍។ ទណ្ឌកម្មនេះអាចអនុវត្តបាន ដោយអនុលោមតែតាមសាលក្រមស្ថាពរ ដែលចេញដោយតុលាការមានសមត្ថកិច្ចប៉ុណ្ណោះ ។

៣. នៅពេលដែលការប្រហារជីវិតជាបទឧក្រិដ្ឋប្រល័យពូជសាសន៍ ត្រូវយល់ថា គ្មានបទបញ្ញត្តិណាមួយនៃមាត្រានេះ ដែលអនុញ្ញាតឱ្យរដ្ឋភាគីនៃកតិកាសញ្ញានេះ ធ្វើបដិប្បញ្ញត្តិតាមបែបណាមួយពីកាតព្វកិច្ចណាដែលបានសន្មត់ ស្របតាមបទបញ្ញត្តិនៃអនុសញ្ញាស្តីពីការបង្ការ និងការផ្តន្ទាទោស បទឧក្រិដ្ឋប្រល័យពូជសាសន៍នោះបានឡើយ ។

៤. ជនដែលទទួលទោសប្រហារជីវិត មានសិទ្ធិសុំអភ័យទោស ឬបន្ធូរបន្ថយទោស ។ ការលើកលែងទោស ការអភ័យទោស ឬការបន្ធូរបន្ថយទោសប្រហារជីវិត អាចផ្តល់ឱ្យបានគ្រប់ករណីទាំងអស់ ។

៥. ទោសប្រហារជីវិត មិនត្រូវអនុវត្តចំពោះបទឧក្រិដ្ឋទាំងឡាយណា ដែលប្រព្រឹត្តដោយជនមានអាយុក្រោម ១៨ឆ្នាំ និងមិនត្រូវអនុវត្ត ចំពោះស្ត្រីមានផ្ទៃពោះឡើយ ។

៦. គ្មានបទបញ្ញត្តិណាមួយក្នុងមាត្រានេះ អាចយកមកសំអាង ដើម្បីធ្វើឱ្យយឺតយ៉ាវ ឬរារាំងដល់ការលុបចោលទោសប្រហារជីវិតដោយរដ្ឋភាគីនៃកតិកាសញ្ញានេះឡើយ ។

## មាត្រា ៧

គ្មានជនណាម្នាក់ត្រូវរងទារុណកម្ម ឬប្រព្រឹត្តកម្ម ឬទណ្ឌកម្ម ដែលឃោរឃៅអមនុស្សធម៌ ឬធ្វើឱ្យថោកទាបឡើយ ។ ជាពិសេស ហាមយកជនណាម្នាក់ មកធ្វើការពិសោធន៍ខាងវេជ្ជសាស្ត្រ ឬវិទ្យាសាស្ត្រ ដោយគ្មានការយល់ព្រមដោយសេរីពីសាមីខ្លួនឡើយ ។

## មាត្រា ៨

១. គ្មានជនណាម្នាក់ ត្រូវជាប់ក្នុងទាសភាពឡើយ ។ ទាសភាព និងទាសពាណិជ្ជកម្ម តាមគ្រប់ទម្រង់ទាំងអស់ ត្រូវហាមឃាត់ ។

២. គ្មានជនណាម្នាក់ ត្រូវជាប់ក្នុងភាពជាខ្ញុំបម្រើដាច់ថ្លៃឡើយ ។

៣. (ក) គ្មានជនណាម្នាក់ តម្រូវឱ្យធ្វើការដោយបង្ខំ ឬខានមិនបានឡើយ។

(ខ) កថាខណ្ឌ៣. (ក) មិនត្រូវយកមកបកស្រាយថា ហាមឃាត់ការអនុវត្តន៍ទោសឱ្យធ្វើការ ដោយបង្ខំ ស្របតាមការវិនិច្ឆ័យទោស ដោយតុលាការមានសមត្ថកិច្ចក្នុងប្រទេស ដែលបទឧក្រិដ្ឋខ្លះ អាចមានទោសជាប់គុកឱ្យធ្វើការដោយបង្ខំ។

(គ) បំណងនៃកថាខណ្ឌនេះ ពាក្យថា "ការងារដោយបង្ខំ ឬដោយខានមិនបាន" មិនត្រូវរាប់បញ្ចូល ៖

(i) ការងារ ឬសេវាដែលគ្មានចែងក្នុងអនុកថាខណ្ឌ (ខ) និងដែលតម្រូវជាធម្មតា ចំពោះជនជាប់ឃុំ តាមបទបញ្ជាស្របច្បាប់របស់តុលាការ ឬចំពោះជនដែលតុលាការសម្រេចដោះលែងឱ្យមានសេរីភាព ដោយមានលក្ខខណ្ឌ ។

(ii) សេវាដែលមានលក្ខណៈយោធា និងកិច្ចការបំរើជាតិដែលតម្រូវតាមច្បាប់សម្រាប់អ្នកប្រឆាំងសង្គ្រាម នៅក្នុងប្រទេសដែលទទួលស្គាល់សិទ្ធិប្រឆាំងសង្គ្រាម ។

(iii) សេវាដែលតម្រូវក្នុងករណីមានអាសន្ន ឬគ្រោះមហន្តរាយ ដែលគំរាមកំហែងដល់អាយុជីវិត និងសុខមាលភាពសហគមន៍ ។

(iv) ការងារ ឬសេវាដែលជាផ្នែកនៃកាតព្វកិច្ចធម្មតារបស់ប្រជាពលរដ្ឋ ។

## មាត្រា ៩

១. ជនគ្រប់រូប មានសិទ្ធិមានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន ។ គ្មានជនណាម្នាក់ ត្រូវចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្តបានឡើយ ។ គ្មានជនណាម្នាក់ ត្រូវដកហូតសេរីភាពបានឡើយ លើកលែងតែមានហេតុផល និងស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់ ។

២. ជនណាដែលត្រូវបានចាប់ខ្លួន ត្រូវមានសិទ្ធិឱ្យគេ ប្រាប់ឱ្យដឹងនៅពេលចាប់ខ្លួន អំពីមូលហេតុនៃការចាប់ខ្លួន និងត្រូវប្រាប់ឱ្យដឹងភ្លាមអំពីការចោទប្រកាន់ ។

៣. បុគ្គលណាដែលបានចាប់ខ្លួន ឬឃុំខ្លួនពីបទព្រហ្មទណ្ឌ នឹងត្រូវបាននាំខ្លួនទៅចំពោះមុខចៅក្រម ឬអាជ្ញាធរណាមួយផ្សេងទៀត ដែលអនុញ្ញាតដោយច្បាប់ឱ្យបំពេញមុខងារតុលាការ ក្នុងរយៈពេលយ៉ាងខ្លីបំផុត និងត្រូវបានជំនុំជំរះក្នុងរយៈពេលសមស្រប ឬត្រូវដោះលែង ។ ការឃុំខ្លួនមនុស្ស ដើម្បីរង់ចាំការជំនុំជំរះ គឺមិនមែនជាវិធានទូទៅទេ ប៉ុន្តែការឱ្យនៅក្រៅឃុំ ត្រូវតែមានការធានា ការចូលខ្លួនរបស់ជននោះ នៅពេលសវនាការ ឬនៅគ្រប់ដំណាក់ការដទៃទៀតនៃនីតិវិធី ហើយត្រូវមានមុខក្នុងការអនុវត្តន៍សាលក្រម ។

៤. ជនណាដែលត្រូវដកហូតសេរីភាព ដោយការឃាត់ខ្លួន ឬឃុំខ្លួន ត្រូវតែមានសិទ្ធិដាក់ពាក្យបណ្តឹង ដើម្បីឱ្យតុលាការអាចសម្រេចដោយមិនពន្យារពេល អំពីនីត្យានុកូលភាពនៃការឃុំខ្លួន និងការបង្គាប់ឱ្យនៅក្រៅឃុំ បើការឃុំខ្លួននោះមិនស្របច្បាប់ ។

៥. ជនណាដែលបានរងគ្រោះដោយសារការឃាត់ខ្លួនឬឃុំខ្លួនដោយខុសច្បាប់ មានសិទ្ធិទាមទារសំណង ។

## មាត្រា ១០

១. ជនណាដែលត្រូវបានដកហូតសេរីភាព ត្រូវទទួលបានការប្រព្រឹត្តមកលើខ្លួន តាមលក្ខណៈមនុស្សធម៌និងការគោរពចំពោះសេចក្តីថ្លៃថ្នូរពីកំណើតរបស់មនុស្ស។

២. (ក) ជនជាប់ចោទ ត្រូវដាក់ឱ្យនៅផ្សេងពីទណ្ឌិត លើកលែងតែក្នុងកាលៈទេសៈពិសេស ។ ជនជាប់ចោទ ត្រូវស្ថិតនៅក្រោមរបបដាច់ដោយឡែកដែលសមស្របទៅតាមលក្ខខណ្ឌរបស់ជនពុំទាន់មានទោស ។

(ខ) ជនជាប់ចោទជាអនីតិជន ត្រូវដាក់ផ្សេងពីនីតិជន ហើយត្រូវទទួលការជំនុំជំរះឱ្យបានឆាប់តាមដែលអាចធ្វើបាន ។

៣. ប្រព័ន្ធគ្រប់គ្រងពន្ធនាគារ ត្រូវមានការប្រព្រឹត្តទៅលើទណ្ឌិត ដែលមានគោលបំណងជាសារវ័ន្ត ដើម្បីស្តារនីតិសម្បទា និងបញ្ចូលពួកគេទៅក្នុងសង្គមវិញ ។ ទណ្ឌិតជាអនីតិជន ត្រូវបំបែកចេញពីនីតិជន ហើយត្រូវស្ថិតនៅក្នុងការប្រព្រឹត្តទៅលើពួកគេ សមស្របតាមអាយុ និងស្ថានភាពនីត្យានុកូលភាពរបស់គេ ។

## មាត្រា ១១

គ្មានជនណាម្នាក់ ត្រូវជាប់ពន្ធនាគារ ដោយសារតែខ្លួន ពុំអាចបំពេញតាមកាតព្វកិច្ចនៃកិច្ចសន្យានោះឡើយ ។

## មាត្រា ១២

១. ជនណាដែលរស់នៅត្រឹមត្រូវ តាមលក្ខណៈច្បាប់ ក្នុងប្រទេសណាមួយមានសិទ្ធិធ្វើដំណើរ និងជ្រើសរើសនិវេសនដ្ឋានរបស់ខ្លួនដោយសេរី ។

២. ជនគ្រប់រូប មានសេរីភាពចាកចេញពីប្រទេសណាមួយ រួមទាំងប្រទេសរបស់ខ្លួនផង ។

៣. សិទ្ធិដែលមានចែងខាងលើនេះ មិនត្រូវមានការរិតត្បិតឡើយ លើកលែងតែការរិតត្បិតនេះ មានចែងក្នុងច្បាប់ ចាំបាច់ដើម្បីការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាពសាធារណៈ ឬសីលធម៌ ឬសិទ្ធិ និងសេរីភាពអ្នកដទៃ ហើយមិនទំនាស់ជាមួយសិទ្ធិដទៃទៀត ដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ ។

៤. គ្មានជនណាម្នាក់ ត្រូវបានដកសិទ្ធិតាមអំពើចិត្ត មិនឱ្យចូលក្នុងប្រទេសរបស់ខ្លួនឡើយ ។

## មាត្រា ១៣

ជនបរទេស ឋិតនៅដោយស្របច្បាប់ លើដែនដីរដ្ឋភាគីនៃកតិកាសញ្ញានេះ នឹងអាចត្រូវបានបណ្ដេញចេញពីរដ្ឋនោះបាន លុះត្រាតែធ្វើឡើង ដោយអនុលោមតាមសេចក្ដីសម្រេចស្របតាមច្បាប់ លើកលែងតែការបណ្ដេញចេញ ដោយហេតុផលបង្ខំសម្រាប់រក្សាសន្តិសុខជាតិ ហើយជនបរទេសនេះ ត្រូវបានអនុញ្ញាតឱ្យដាក់ហេតុផលជំទាស់នឹងការបណ្ដេញចេញនេះ និងសុំឱ្យអាជ្ញាធរមានសមត្ថកិច្ច ឬមនុស្សម្នាក់ ឬច្រើននាក់ ដែលអាជ្ញាធរបានតែងតាំងជាពិសេស ពិនិត្យករណីរបស់ខ្លួនឡើងវិញ រួមទាំងឱ្យមានអ្នកការពារសិទ្ធិផងដែរ ។

## មាត្រា ១៤

១. ជនគ្រប់រូប ត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជំរះក្ដី ។ ជនគ្រប់រូប ត្រូវមានសិទ្ធិឱ្យសាលាក្ដីមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង ដែលបង្កើតឡើងដោយច្បាប់ ជំនុំជំរះរឿងក្ដីរបស់ខ្លួន ដោយសមធម៌ និងជាសាធារណៈ ដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួន ក្នុងវិស័យព្រហ្មទណ្ឌ ឬលើសិទ្ធិ និងករណីយកិច្ច ក្នុងវិស័យរដ្ឋប្បវេណី ។ សារព័ត៌មាន និងសាធារណៈជន អាចមិនឱ្យចូលរួមទាំងស្រុង ឬផ្នែកមួយនៃសវនាការ សម្រាប់ផលប្រយោជន៍នៃទំនៀមទំលាប់ល្អ សណ្ដាប់ធ្នាប់សាធារណៈ ឬសន្តិសុខជាតិក្នុងសង្គមប្រជាធិបតេយ្យ ឬនៅពេលផលប្រយោជន៍នៃជីវិតឯកជនរបស់គូភាគី តម្រូវឱ្យធ្វើដូច្នេះ ឬក្នុងកម្រិតដែលចាំបាច់បំផុត តាមការយល់ឃើញរបស់តុលាការ ក្នុងស្ថានភាពពិសេស ដែលថាការធ្វើជាសាធារណៈ នឹងនាំឱ្យខូចដល់ផលប្រយោជន៍យុត្តិធម៌ ។ ប៉ុន្តែ ការចេញសាលក្រមទាំងអស់ អំពីរឿងព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី ត្រូវប្រកាសជាសាធារណៈ លើកលែងតែផលប្រយោជន៍អនីតិជន តម្រូវផ្សេងពីនេះ ឬរឿងក្ដីអំពីទំនាស់គ្រួសារ ឬអាណាព្យាបាលរបស់កុមារ ។

២. ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌត្រូវបានសន្មត់ជាមុនថា ជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួន ត្រូវបានកំណត់ស្របតាមច្បាប់ ។

៣. ក្នុងការសម្រេចសេចក្តី ចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយ ប្រឆាំងមកលើខ្លួន ជនគ្រប់រូប មានសិទ្ធិទទួលបានការធានាជាអប្បបរិមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ដូចខាងក្រោម ៖

(ក) ត្រូវបានព័ត៌មានភ្លាមៗ និងដោយលំអិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួន ជាភាសាដែលជននោះចេះ ។

(ខ) ត្រូវមានពេលវេលា និងសម្ភារៈរូបវ័ន្តគ្រប់គ្រាន់ សម្រាប់រៀបចំការពារខ្លួន និងឆ្លើយឆ្លងជាមួយមេធាវីដែលជ្រើសរើសដោយខ្លួនឯង ។

(គ) ត្រូវបានជំនុំជំរះដោយឥតពន្យារពេលយូរហួសហេតុ ។

(ឃ) ត្រូវបានជំនុំជំរះដោយមានវត្តមានរបស់ខ្លួននិងការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់ តាមការជ្រើសរើសរបស់ខ្លួន និងត្រូវបានប្រាប់ឱ្យដឹងអំពីសិទ្ធិនេះ ប្រសិនបើខ្លួនគ្មានជំនួយការច្បាប់ ហើយត្រូវទទួលបានជំនួយការច្បាប់សម្រាប់ខ្លួន ក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌ តម្រូវឱ្យធ្វើដូច្នេះ និងដោយឥតបង់ថ្លៃ នៅគ្រប់ករណីបែបនេះ បើជនជាប់ចោទ គ្មានមធ្យោបាយគ្រប់គ្រាន់ដើម្បីចំណាយទៅលើជំនួយការច្បាប់ទេ ។

(ង) ត្រូវមានការសួរចម្លើយ ឬសុំឱ្យសួរចម្លើយ ទៅលើសាក្សីដាក់បន្ទុក និងសុំឱ្យសាក្សីដោះបន្ទុកចូលខ្លួន ដើម្បីសួរចម្លើយក្នុងនាមខ្លួន ក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក ។

(ច) ត្រូវទទួលបានអ្នកបកប្រែភាសាដោយឥតគិតឈ្នួល បើជនជាប់ចោទមិនយល់ ឬមិនចេះភាសាដែលប្រើប្រាស់ក្នុងសវនាការ ។

(ឆ) មិនត្រូវបានបង្ខិតបង្ខំ ឱ្យឆ្លើយដាក់កំហុសលើខ្លួនឯង ឬសារភាពថាមានពិរុទ្ធ ។

៤. នីតិវិធីអនុវត្តចំពោះយុវជន-យុវនារី ដែលមិនទាន់មាននីតិភាពតាមច្បាប់កំណត់ ត្រូវគិតដល់អាយុ និងអត្ថប្រយោជន៍នៃការអប់រំរបស់ពួកគេឡើងវិញ ។

៥. ជនគ្រប់រូបដែលជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌត្រូវមានសិទ្ធិសុំឱ្យសាលាក្តីជាន់ខ្ពស់ ពិនិត្យទៅលើការប្រកាសពិរុទ្ធភាព និងការផ្តន្ទាទោសឡើងវិញ ស្របតាមច្បាប់ ។

៦. នៅពេលជនណាម្នាក់ ត្រូវបានប្រកាសឱ្យជាប់ពិរុទ្ធពីបទព្រហ្មទណ្ឌជាស្ថាពរ ហើយក្រោយមក ការប្រកាសឱ្យជាប់ពិរុទ្ធនេះ ត្រូវបានបដិសេធ ឬត្រូវបានលើកលែងទោស ដោយហេតុថា អង្គហេតុថ្មី ឬដែលបានរកឃើញថ្មី បញ្ជាក់យ៉ាងច្បាស់ថា មានការខុសឆ្គងពីសំណាក់តុលាការ ជនដែលទទួលរងគ្រោះ ដោយសារការដាក់ទោសនេះ ត្រូវទទួលសំណងស្របតាមច្បាប់ លើកលែងតែមានការកំណត់បង្ហាញថា ការមិនលាតត្រដាងអាថ៌កំបាំងនៃការពិតទាន់ពេល បណ្តាលមកពីជននោះទាំងស្រុង ឬមួយផ្នែក ។

៧. គ្មានជនណាម្នាក់ ត្រូវយកមកចោទប្រកាន់ ឬយកមកផ្តន្ទាទោសសារជាថ្មីឡើយ ចំពោះបទល្មើស ដែលបានផ្តន្ទាទោសជាស្ថាពរ ឬបានលើកលែងទោសស្របតាមច្បាប់ និងនិតិវិធីព្រហ្មទណ្ឌ របស់រដ្ឋនីមួយៗរួចហើយ ។

## មាត្រា ១៥

១. គ្មានជនណាម្នាក់ ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ចំពោះអំពើ ឬការខកខានណាមួយដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ ក្នុងខណៈពេលប្រព្រឹត្តនោះឡើយ។ ដូចគ្នានេះ មិនត្រូវដាក់ទោស

ឱ្យធ្ងន់ជាងទោស ដែលអនុវត្ត ក្នុងខណៈពេលប្រព្រឹត្តបទល្មើសឡើយ ។ ប្រសិនបើក្រោយពីការប្រព្រឹត្តបទល្មើសហើយ ច្បាប់ បានបញ្ញត្តិឱ្យមានការដាក់ទោសស្រាលជាងមុន ជនល្មើសត្រូវទទួលអត្ថប្រយោជន៍ពីការដាក់ទោសស្រាលជាងនេះ ។

២. គ្មានបញ្ញត្តិណាមួយក្នុងមាត្រានេះប្រឆាំងនឹងការជំនុំជំរះក្តី ឬការផ្តន្ទាទោសដល់ជនណាម្នាក់ ចំពោះអំពើ ឬការខកខានណាមួយដែលជននោះបានប្រព្រឹត្តក្នុងខណៈពេលដែលអំពើ ឬការខកខាននោះ ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមគោលការណ៍ទូទៅនៃច្បាប់ ដែលទទួលស្គាល់ដោយសហគមន៍នៃប្រជាជាតិ ។

## មាត្រា ១៦

ជនគ្រប់រូប មានសិទ្ធិឱ្យគេទទួលស្គាល់បុគ្គលិកលក្ខណៈគតិយុត្តិរបស់ខ្លួននៅគ្រប់ទីកន្លែង ។

## មាត្រា ១៧

១. គ្មានជនណាម្នាក់ ត្រូវទទួលរងការជ្រៀតជ្រែកតាមអំពើចិត្ត ឬដោយខុសច្បាប់ ក្នុងជីវិតឯកជន គ្រួសារ លំនៅដ្ឋាន សំបុត្រឆ្លើយឆ្លងរបស់ខ្លួន ឬត្រូវរងការប៉ះពាល់ដោយខុសច្បាប់ ទៅលើកិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ខ្លួនឡើយ ។

២. ជនគ្រប់រូប មានសិទ្ធិឱ្យច្បាប់ការពារប្រឆាំងនឹងការជ្រៀតជ្រែក ឬការប៉ះពាល់បែបនេះ ។

## មាត្រា ១៨

១. ជនគ្រប់រូបមានសិទ្ធិសេរីភាពខាងការគិត សតិសម្បជញ្ញៈ និងសាសនា។ សិទ្ធិនេះត្រូវរាប់បញ្ចូលទាំងសេរីភាពក្នុងការកាន់ ឬគោរពសាសនា ឬជំនឿណាមួយតាមការជ្រើសរើសរបស់ខ្លួន និងសេរីភាពក្នុងការសម្តែងសាសនា ឬជំនឿរបស់ខ្លួនដោយម្នាក់ៗឯង ឬដោយរួមជាមួយអ្នកដទៃ និងជាសាធារណៈ ឬជាឯកជន តាម

ការគោរពបូជា ការប្រតិបត្តិតាម ការអនុវត្តន៏ និងការបង្ហាត់បង្រៀន ។

២. គ្មានជនណាម្នាក់ ត្រូវរងការបង្ខិតបង្ខំឱ្យកាន់ ឬគោរពសាសនា ដែលបំពារបំពានធ្វើឱ្យខូចខាត ដល់សេរីភាពនៃការកាន់ ឬកាគោរពសាសនា ឬជំនឿតាមការជ្រើសរើសរបស់ខ្លួនឡើយ ។

៣. សេរីភាពសម្តែងការគោរពសាសនា ឬជំនឿរបស់ខ្លួន នឹងអាចដាក់កម្រិតព្រំដែនបាន លុះត្រាតែមានបញ្ញត្តិដោយច្បាប់ និងចាំបាច់ ដល់ការការពារសន្តិសុខសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ សុខភាពសាធារណៈ ឬសីលធម៏ ឬសិទ្ធិ និងសេរីភាពមូលដ្ឋានរបស់អ្នកដទៃ ។

៤. រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាគោរពសេរីភាពរបស់ឪពុកម្តាយ និងអ្នកអាណាព្យាបាលស្របច្បាប់ ប្រសិនជាមានក្នុងការធានាដល់ការអប់រំខាងសាសនា និងសីលធម៏ដល់បុត្រធីតារបស់គេ ស្របតាមជំនឿរបស់គេ ។

## មាត្រា ១៩

១. ជនគ្រប់រូបមានសិទ្ធិប្រកាន់យកមតិយោបល់ដោយគ្មានការជ្រៀតជ្រែក។

២. ជនគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ សិទ្ធិនេះ ត្រូវរាប់បញ្ចូលទាំងសេរីភាព ស្រាវជ្រាវព័ត៏មាន ទទួល និងផ្សព្វផ្សាយព័ត៏មាន និងគំនិតសព្វបែបយ៉ាង ដោយមិនគិតពីព្រំដែន ដោយផ្ទាល់មាត់ សរសេរ ឬបោះពុម្ព តាមទម្រង់សិល្បៈក្តី ឬក៏ដោយមធ្យោបាយផ្សព្វផ្សាយដទៃទៀតក្តី តាមការជ្រើសរើសរបស់ខ្លួន ។

៣. ការប្រើប្រាស់សិទ្ធិដែលចែងក្នុងកថាខណ្ឌ២ នៃមាត្រានេះ តម្រូវឱ្យមានករណីយកិច្ច និងការទទួលខុសត្រូវពិសេស ។ ដូច្នេះ ការប្រើប្រាស់សិទ្ធិនេះ អាចមានការរិតត្បិតមួយចំនួន ដែលត្រូវកំណត់ដាច់ខាតដោយច្បាប់ និងដែលចាំបាច់ដើម្បី ៖

(ក) គោរពសិទ្ធិ និងកិត្តិសព្ទរបស់អ្នកដទៃ ។

(ខ) ការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាព ឬសីលធម៌សាធារណៈ ។

## មាត្រា ២០

១. ការឃោសនាណាជាគុណប្រយោជន៍ដល់សង្គ្រាម ត្រូវហាមឃាត់ដោយច្បាប់ ។

២. ការអំពាវនាវណាឱ្យមានការស្អប់ខ្ពើមជាតិ ពូជសាសន៍ ឬសាសនាដែលជាការញុះញង់ នាំឱ្យកើតមានការរើសអើង ការប្រទូស្តរាយ ឬអំពើហិង្សា ត្រូវហាមឃាត់ដោយច្បាប់ ។

## មាត្រា ២១

សិទ្ធិប្រជុំដោយសន្តិវិធីត្រូវតែទទួលស្គាល់។ ការប្រើប្រាស់សិទ្ធិនេះ អាចមានការរឹតត្បិត ដែលកំណត់ដោយច្បាប់តែប៉ុណ្ណោះ និងដែលចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ ក្នុងផលប្រយោជន៍នៃសន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការការពារសុខភាពសាធារណៈ ឬសីលធម៌ ឬការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ ។

## មាត្រា ២២

១. ជនគ្រប់រូប មានសិទ្ធិចូលរួមជាសមាគមដោយសេរីជាមួយអ្នកដទៃ រាប់បញ្ចូលទាំងសិទ្ធិបង្កើតសហជីព និងសិទ្ធិចូលជាសមាជិកសហជីព ដើម្បីការពារផលប្រយោជន៍របស់ខ្លួន ។

២. ការប្រើប្រាស់សិទ្ធិនេះ អាចមានការរឹតត្បិត ដែលកំណត់ដោយច្បាប់តែប៉ុណ្ណោះ និងដែលចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ ក្នុងផលប្រយោជន៍នៃសន្តិសុខ

ជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការការពារសុខភាពសាធារណៈ ឬសីលធម៌ ឬការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ ។ មាត្រានេះ មិនរារាំងដល់ការរិតត្បិតខាងផ្លូវច្បាប់លើសមាជិកយោធា និងនគរបាលក្នុងការប្រើប្រាស់សិទ្ធិនេះទេ ។

៣. គ្មានបទបញ្ញត្តិណាមួយនៃមាត្រានេះ អនុញ្ញាតឱ្យរដ្ឋភាគីនៃអនុសញ្ញាឆ្នាំ១៩៤៨ របស់អង្គការពលកម្មអន្តរជាតិស្តីពីសេរីភាពខាងសហជីព និងការការពារសិទ្ធិខាងសហជីព ចាត់វិធានការខាងផ្លូវច្បាប់ ឬអនុវត្តច្បាប់ តាមរបៀបដែលធ្វើឱ្យប៉ះពាល់ដល់ការធានា ដែលមានចែងក្នុងអនុសញ្ញានោះឡើយ ។

## មាត្រា ២៣

១. គ្រួសារជាអង្គភាពធម្មជាតិ និងជាអង្គភាពមូលដ្ឋានរបស់សង្គម ហើយគ្រួសារ មានសិទ្ធិទទួលការការពារពីសង្គម និងរដ្ឋ ។

២. សិទ្ធិរបស់មនុស្សប្រុស-ស្រីពេញវ័យ ក្នុងការរៀបអាពាហ៍ពិពាហ៍ និងក្នុងការកសាងគ្រួសារ ត្រូវតែទទួលស្គាល់ ។

៣. គ្មានអាពាហ៍ពិពាហ៍ណាអាចធ្វើឡើងដោយគ្មានការយល់ព្រម ដោយសេរី និងពេញលេញពីអនាគតប្តី-ប្រពន្ធឡើយ ។

៤. រដ្ឋភាគីនៃកតិកាសញ្ញានេះ ត្រូវចាត់វិធានការសមស្រប ដើម្បីធានាសមភាពខាងសិទ្ធិ និងការទទួលខុសត្រូវរបស់ប្តីប្រពន្ធ ចំពោះការរៀបអាពាហ៍ពិពាហ៍ ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ និងនៅពេលរំលាយអាពាហ៍ពិពាហ៍ ។ ក្នុងគ្រាដែលមានការរំលាយអាពាហ៍ពិពាហ៍ ត្រូវមានបទបញ្ញត្តិ សម្រាប់ការការពារជាចាំបាច់ចំពោះកូន ។

## មាត្រា ២៤

១. កុមារគ្រប់រូប មានសិទ្ធិទទួលបានវិធានការការពារ តម្រូវនឹងស្ថានភាពរបស់ខ្លួនជាអនីតិជន ពីសំណាក់គ្រួសាររបស់ខ្លួន សង្គម និងរដ្ឋ ដោយគ្មានការរើសអើងពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ ឬកំណើតឡើយ ។

២. កុមារគ្រប់រូប ត្រូវបានចុះឈ្មោះក្នុងបញ្ជីជាបន្ទាន់ បន្ទាប់ពីពេលកើត និងត្រូវមានឈ្មោះ ។

៣. កុមារគ្រប់រូប មានសិទ្ធិបានសញ្ជាតិមួយ ។

## មាត្រា ២៥

ដោយគ្មានការបែងចែក ដូចដែលបានចែងក្នុងមាត្រា២ និងដោយគ្មានការរិតត្បិត ដែលមិនសមហេតុផល ប្រជាពលរដ្ឋគ្រប់រូប មានសិទ្ធិ និងមានឱកាសៈ

(ក) រួមចំណែកក្នុងការដឹកនាំកិច្ចការសាធារណៈដោយផ្ទាល់ ឬតាមរយៈតំណាង ដែលខ្លួនជ្រើសរើសដោយសេរី ។

(ខ) បោះឆ្នោត និងឈរឈ្មោះបោះឆ្នោត នៅក្នុងការបោះឆ្នោតពិតប្រាកដតាមកាលកំណត់ ទៀងទាត់ ជាសកល ស្មើភាព និងដោយសម្ងាត់ ដែលធានាការបញ្ចេញមតិដោយសេរី ពីឆន្ទៈអ្នកបោះឆ្នោត ។

(គ) ចូលបម្រើមុខងារសាធារណៈក្នុងប្រទេសរបស់ខ្លួន ក្នុងលក្ខខណ្ឌទូទៅដោយសមភាព ។

## មាត្រា ២៦

ជនគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិការពារពីច្បាប់ស្មើគ្នាដោយឥតរើសអើង។ ក្នុងប្រការនេះ ច្បាប់ត្រូវហាមការរើសអើង និងត្រូវធានាឱ្យ

ជនគ្រប់រូបនូវការការពារស័ក្តិសិទ្ធិស្មើគ្នាប្រឆាំងការរើសអើងទាំងឡាយ មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃទៀត ។

## មាត្រា ២៧

ក្នុងរដ្ឋដែលមានក្រុមជនភាគតិចខាងជាតិពន្ធុ សាសនា ឬភាសា ជនដែលជាសមាជិកជនភាគតិចទាំងនេះ ដោយរួមនឹងសមាជិកដទៃទៀតនៃក្រុមរបស់ខ្លួន មិនត្រូវទទួលរងការរារាំង សិទ្ធិអាស្រ័យផលវប្បធម៌របស់ពួកគេ សិទ្ធិកាន់ និងប្រតិបត្តិសាសនា តាមទម្លាប់ពួកគេ ឬសិទ្ធិប្រើប្រាស់ភាសារបស់ពួកគេឡើយ ។

## ផ្នែកទី ៤

## មាត្រា ២៨

១. គណៈកម្មាធិការសិទ្ធិមនុស្សមួយ (បន្ទាប់ពីនេះទៅហៅថា គណៈកម្មាធិការ) ត្រូវបង្កើតឡើង ។ គណៈកម្មាធិការ មានសមាជិក ១៨រូប និងបំពេញមុខងារតាមការកំណត់ខាងក្រោម ។

២. គណៈកម្មាធិការ ត្រូវមានសមាជិកជាប្រជាពលរដ្ឋនៃរដ្ឋសមាជិកកតិកាសញ្ញានេះ ដែលជាមនុស្ស មានអត្តចរិកសីលធម៌ខ្ពស់ និងសមត្ថភាពដែលគេទទួលស្គាល់ ក្នុងវិស័យសិទ្ធិមនុស្ស ដោយការគិតដល់ប្រយោជន៍ ដែលបានមកពីការចូលរួមពីមនុស្សមួយចំនួន ដែលមានបទពិសោធន៍ខាងវិស័យច្បាប់ ។

៣. សមាជិកគណៈកម្មាធិការ ត្រូវជ្រើសរើសតាមការបោះឆ្នោត ហើយត្រូវធ្វើការក្នុងឋានៈជាបុគ្គល ។

## មាត្រា ២៩

១. សមាជិកគណៈកម្មាធិការ ត្រូវជ្រើសរើសតាមការបោះឆ្នោតជាសម្ងាត់ ពីបញ្ជីឈ្មោះបេក្ខជន ដែលមានគុណសម្បត្តិ តាមលក្ខខណ្ឌបញ្ញត្តិក្នុងមាត្រា ២៨ ហើយដែលជ្រើសតាំងដោយរដ្ឋភាគីនៃកតិកាសញ្ញានេះ ។

២. រដ្ឋភាគីនីមួយៗ នៃកតិកាសញ្ញានេះ អាចជ្រើសតាំងបេក្ខជន ២ រូប យ៉ាងច្រើន។ បេក្ខជនទាំងនេះ ត្រូវតែជាជនជាតិនៃរដ្ឋដែលជ្រើសតាំងបេក្ខជន ។

៣. បេក្ខជនដដែល អាចមានសិទ្ធិជ្រើសតាំងជាថ្មីទៀតបាន ។

## មាត្រា ៣០

១. ការបោះឆ្នោតលើកដំបូង ត្រូវធ្វើយ៉ាងយូរបំផុត ៦ខែ ក្រោយពីកាលបរិច្ឆេទនៃការចូលជាធរមាននៃកតិកាសញ្ញានេះ ។

២. យ៉ាងតិច៤ខែ មុនកាលបរិច្ឆេទ នៃការបោះឆ្នោតជ្រើសរើសសមាជិកសម្រាប់គណៈកម្មាធិការ ក្រៅពីការជ្រើសរើស ឱ្យបំពេញមុខងារទំនេរ ស្របតាមមាត្រា៣៤ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវចេញលិខិតអញ្ជើញឱ្យរដ្ឋភាគីនៃកតិកាសញ្ញានេះ បញ្ជូនបញ្ជីបេក្ខជនរបស់ខ្លួន ក្នុងរយៈពេល៣ខែ សម្រាប់ធ្វើជាសមាជិកគណៈកម្មាធិការ ។

៣. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវធ្វើបញ្ជីឈ្មោះបេក្ខជនទាំងអស់ តាមឈ្មោះលំដាប់អក្ខរៈក្រម ដោយបញ្ជាក់ឈ្មោះរដ្ឋភាគីដែលបានជ្រើសតាំងបេក្ខជន ហើយផ្ញើបញ្ជីនេះ ទៅរដ្ឋភាគីទាំងអស់នៃកតិកាសញ្ញានេះ យ៉ាងហោច ១ខែ មុនកាលបរិច្ឆេទនៃការបោះឆ្នោតនីមួយៗ ។

៤. ការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការ ត្រូវធ្វើក្នុងពេលប្រជុំ

រដ្ឋភាគី នៃកតិកាសញ្ញានេះ ដែលកោះអញ្ជើញដោយ អគ្គលេខាធិការអង្គការសហប្រជាជាតិ នៅទីស្នាក់ការនៃអង្គការនេះ ។ កូរ៉ុមសម្រាប់កិច្ចប្រជុំ គឺពីរភាគបីនៃរដ្ឋភាគីនៃកតិកាសញ្ញានេះ។ បេក្ខជនដែលជាប់ជាសមាជិកគណៈកម្មាធិការ ត្រូវតែជាបេក្ខជនដែលទទួលបានសម្លេងច្រើនបំផុត និងសម្លេងភាគច្រើនដាច់ខាតពីតំណាងរបស់រដ្ឋភាគីដែលមានវត្តមាន និងបានបោះឆ្នោត ។

## មាត្រា ៣១

១. គណៈកម្មាធិការ មិនអាចមានសមាជិកលើសពី ១រូប ដែលជាជនជាតិនៃរដ្ឋដដែលឡើយ ។

២. ក្នុងការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការ ត្រូវធ្វើការពិចារណាបែងចែកសមាជិកភាព ទៅតាមភូមិសាស្ត្រដោយសមធម៌ និងឱ្យមានតំណាងទម្រង់ផ្សេងៗនៃអារ្យធម៌ ព្រមទាំងទៅតាមប្រព័ន្ធច្បាប់ធំៗផង ។

## មាត្រា ៣២

១. សមាជិកគណៈកម្មាធិការ ត្រូវជ្រើសរើសតាមការបោះឆ្នោត សម្រាប់រយៈពេល ៤ឆ្នាំ ។ សមាជិកគណៈកម្មាធិការ អាចមានសិទ្ធិឈរឈ្មោះបោះឆ្នោតឡើងវិញ ប្រសិនបើមានការជ្រើសតាំងជាថ្មី ។ ប៉ុន្តែអាណត្តិសមាជិក៩រូប ដែលជាប់ឆ្នោតលើកទី១ ត្រូវផុតកំណត់ក្នុងរយៈពេល២ឆ្នាំ ហើយក្រោយពីការបោះឆ្នោតលើកទី១ ឈ្មោះសមាជិកទាំង៩រូបនេះ ត្រូវចាប់ឆ្នោតជ្រើសរើសជាបន្ទាន់ ដោយប្រធានអង្គប្រជុំ ដែលមានចែងក្នុងកថាខណ្ឌ៤ នៃមាត្រា៣០ ។

២. ពេលផុតអាណត្តិការងារ ការបោះឆ្នោត ត្រូវធ្វើឡើងឱ្យស្របតាមបទបញ្ញត្តិនៃមាត្រាមុនៗ នៅក្នុងផ្នែកទី៤ នៃកតិកាសញ្ញានេះ ។

## មាត្រា ៣៣

១. ប្រសិនបើមានសមាជិកណាមួយនៃគណៈកម្មាធិការបានឈប់ធ្វើការងាររបស់ខ្លួន ក្រៅពីមូលហេតុអវត្តមានជាលក្ខណៈបណ្តោះអាសន្ន ប្រធានគណៈកម្មា-ធិការ តាមមតិឯកច្ឆ័ន្ទពីសមាជិកឯទៀត ត្រូវជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិហើយអគ្គលេខាធិការត្រូវប្រកាសពីអាសនៈទំនេររបស់សមាជិកនោះ។

២. ក្នុងគ្រាមានមរណភាព ឬការលាឈប់ពីតំណែង របស់សមាជិកណាម្នាក់ ប្រធានគណៈកម្មាធិការ ត្រូវជូនដំណឹងភ្លាមទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយអគ្គលេខាធិការ ត្រូវប្រកាសពីអាសនៈទំនេរ ចាប់ពីកាលបរិច្ឆេទមរណភាព ឬការសុំលាលែង មានអានុភាព ។

## មាត្រា ៣៤

១. នៅពេលអាសនៈទំនេរ ត្រូវបានប្រកាសស្របតាមមាត្រា ៣៣ និងបើអាណត្តិរបស់សមាជិកដែលត្រូវជាក់ជំនួស មិនទាន់ផុតកំណត់ក្នុងរយៈពេល ៦ខែ បន្តពីកាលបរិច្ឆេទ នៃការប្រកាសអាសនៈទំនេរ អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវជូនដំណឹងឱ្យរដ្ឋភាគីទាំងអស់នៃកតិកាសញ្ញានេះ ក្នុងរយៈពេល២ខែ ឱ្យជ្រើសតាំងបេក្ខជន ស្របតាមបទបញ្ញត្តិនៃមាត្រា២៩ ដើម្បីបំពេញអាសនៈទំនេរនេះ ។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវរៀបចំបញ្ជីឈ្មោះបេក្ខជនជ្រើសតាំងតាមលំដាប់អក្ខរក្រម ហើយត្រូវផ្ញើបញ្ជីនេះ ទៅរដ្ឋភាគីនៃកតិកាសញ្ញានេះ ។ ការបោះឆ្នោតបំពេញអាសនៈទំនេរ ត្រូវធ្វើស្របតាមបទបញ្ញត្តិពាក់ព័ន្ធ នៃផ្នែកទី៤ នៃកតិកាសញ្ញានេះ ។

៣. សមាជិកគណៈកម្មាធិការដែលជាប់ឆ្នោតបំពេញអាសនៈទំនេរ ដូចបានប្រកាសស្របតាមមាត្រា៣៣ ត្រូវបំពេញភារកិច្ចរហូតដល់ចប់អាណត្តិរបស់សមាជិកដែលទុកអាសនៈឱ្យទំនេរនៅក្នុងគណៈកម្មាធិការ ស្របតាមបទបញ្ញត្តិនៃមាត្រានោះ។

### មាត្រា ៣៥

សមាជិកគណៈកម្មាធិការ ទទួលបរិលាភពីធនធានរបស់អង្គការសហប្រជាជាតិ តាមការយល់ព្រមពីមហាសន្និបាតអង្គការសហប្រជាជាតិ ក្នុងលក្ខខណ្ឌកំណត់ដោយមហាសន្និបាតអង្គការសហប្រជាជាតិ ទៅតាមសារសំខាន់ នៃមុខងាររបស់គណៈកម្មាធិការ ។

### មាត្រា ៣៦

អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវផ្តល់បុគ្គលិក និងសម្ភារៈរូបវ័ន្តចាំបាច់ ដើម្បីឱ្យគណៈកម្មាធិការ បំពេញមុខងារឱ្យបានស័ក្តិសិទ្ធិ ស្របតាមកតិកាសញ្ញានេះ ។

### មាត្រា ៣៧

១. អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវកោះសមាជិកគណៈកម្មាធិការឱ្យមកប្រជុំជាលើកទី១ នៅទីស្នាក់ការអង្គការសហប្រជាជាតិ ។

២. ក្រោយពីកិច្ចប្រជុំលើកទី១ គណៈកម្មាធិការ ត្រូវរៀបចំសម័យប្រជុំគ្រប់ពេល ដូចបានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

៣. តាមធម្មតា គណៈកម្មាធិការ ត្រូវប្រជុំ នៅទីស្នាក់ការអង្គការសហប្រជាជាតិ ឬនៅការិយាល័យអង្គការសហប្រជាជាតិ នៅទីក្រុងហ្សឺណែវ ។

### មាត្រា ៣៨

មុននឹងទទួលតំណែង សមាជិកគណៈកម្មាធិការទាំងអស់ត្រូវប្រកាសជាឧឡារិក នៅចំពោះមុខអង្គប្រជុំថា នឹងបំពេញមុខងាររបស់ខ្លួន ដោយគ្មានលំអៀង និងដោយសតិសម្បជញ្ញៈ ។

## មាត្រា ៣៩

១. គណៈកម្មាធិការ ត្រូវបោះឆ្នោតជ្រើសរើស មន្ត្រីការិយាល័យរបស់ខ្លួន សម្រាប់រយៈពេល២ឆ្នាំ ។ មន្ត្រីការិយាល័យទាំងអស់ អាចត្រូវបានបោះឆ្នោតជ្រើសរើសជាថ្មីទៀតបាន ។

២. គណៈកម្មាធិការត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។ ប៉ុន្តែ បទបញ្ជាផ្ទៃក្នុងនេះ ត្រូវមានបទបញ្ញត្តិដូចខាងក្រោមនេះ បន្ថែមលើបទបញ្ញត្តិដទៃទៀត ៖

(ក) កូរ៉ុម ត្រូវមានសមាជិក ១២នាក់ ។

(ខ) សេចក្តីសម្រេចរបស់គណៈកម្មាធិការ ត្រូវធ្វើឡើងដោយសម្លេងភាគច្រើននៃសមាជិកវត្តមាន ។

## មាត្រា ៤០

១. រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាបង្ហាញរបាយការណ៍ ស្តីពីវិធានការដែលបានអនុម័ត អនុវត្ត សិទ្ធិដែលទទួលស្គាល់ក្នុងកតិកាសញ្ញានេះ និងរបាយការណ៍ស្តីពីការរីកចម្រើនដែលសម្រេចបាន ក្នុងការអាស្រ័យផលនៃសិទ្ធិទាំងនេះ ៖

(ក) ក្នុងរយៈពេល១ឆ្នាំ គិតពីថ្ងៃចូលជាធរមាននៃកតិកាសញ្ញានេះចំពោះរដ្ឋភាគីពាក់ព័ន្ធ ។

(ខ) រាល់លើកដែលគណៈកម្មាធិការធ្វើសំណើ ។

២. របាយការណ៍ទាំងអស់ ត្រូវដាក់ជូនទៅ អគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយអគ្គលេខាធិការ ត្រូវបញ្ជូនរបាយការណ៍ទាំងនោះ ទៅគណៈកម្មាធិការដើម្បីពិនិត្យ ។ ប្រសិនបើមាន របាយការណ៍ ត្រូវបញ្ជាក់ពីកត្តា និងឧបសគ្គដែលនាំឱ្យប៉ះពាល់ដល់ការអនុវត្តន៍នៃកតិកាសញ្ញានេះ ។

៣. ក្រោយពីការពិគ្រោះជាមួយគណៈកម្មាធិការ អគ្គលេខាធិការអង្គការសហប្រជាជាតិ អាចបញ្ជូនទៅស្ថាប័នឯកទេសពាក់ព័ន្ធ នូវសេចក្ដីចម្លងគ្រប់ភាគនៃរបាយការណ៍ដែលអាចស្ថិតក្នុងវិស័យនៃសមត្ថកិច្ចរបស់ស្ថាប័នទាំងនោះ ។

៤. គណៈកម្មាធិការ ត្រូវសិក្សារបាយការណ៍ដែលដាក់ជូនដោយរដ្ឋភាគីនៃកតិកាសញ្ញានេះ ។ គណៈកម្មាធិការ ត្រូវបញ្ជូនរបាយការណ៍របស់ខ្លួន ព្រមទាំងយោបល់ទូទៅដែលគណៈកម្មាធិការពិនិត្យឃើញថាសមស្របទៅឱ្យរដ្ឋភាគីទាំងអស់។ គណៈកម្មាធិការ អាចបញ្ជូនយោបល់ទាំងនេះទៅក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច ដោយភ្ជាប់ជាមួយច្បាប់ចម្លងនៃរបាយការណ៍នានា ដែលគណៈកម្មាធិការបានទទួលពីរដ្ឋភាគីនៃកតិកាសញ្ញានេះ ។

៥. រដ្ឋភាគីនៃកតិកាសញ្ញានេះអាចដាក់ជូនគណៈកម្មាធិការនូវសេចក្ដីសង្កេតលើការផ្ដល់យោបល់ ដែលអាចត្រូវធ្វើឡើង ស្របតាមកថាខណ្ឌ៤ នៃមាត្រានេះ ។

## មាត្រា ៤១

១. រដ្ឋភាគីណាមួយនៃកតិកាសញ្ញានេះ អាចប្រកាសនៅគ្រប់ពេលវេលាស្របតាមមាត្រានេះ ថាខ្លួនទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការក្នុងការទទួល និងពិនិត្យបណ្ដឹងពីរដ្ឋភាគី ដែលអះអាងថា រដ្ឋភាគីមួយទៀត មិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន ស្របតាមកតិកាសញ្ញានេះ ។ បណ្ដឹងនេះ អាចទទួល និងពិនិត្យបានលុះត្រាតែរដ្ឋភាគី បានធ្វើសេចក្ដីប្រកាសទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការចំពោះរដ្ឋនេះ ។ គណៈកម្មាធិការ មិនត្រូវទទួលបណ្ដឹងរបស់រដ្ឋភាគី ដែលមិនបានធ្វើសេចក្ដីប្រកាសទទួលស្គាល់ឡើយ ។ បណ្ដឹងស្របតាមមាត្រានេះ ត្រូវដោះស្រាយស្របតាមនីតិវិធីខាងក្រោម៖

(ក) បើរដ្ឋភាគីមួយនៃកតិកាសញ្ញានេះ យល់ឃើញថា រដ្ឋភាគីមួយទៀត

មិនអនុវត្តបទបញ្ញត្តិនៃកតិកាសញ្ញានេះ រដ្ឋភាគីម្ខាង អាចនាំយកបញ្ហា តាមរយៈបណ្តឹងជាលាយល័ក្ខណ៍អក្សរ មកបង្ហាញឱ្យរដ្ឋភាគីម្ខាងទៀត ពិនិត្យពិចារណា ។ ក្នុងរយៈពេល ៣ខែ ក្រោយពីបានទទួលបណ្តឹង រដ្ឋចុងបណ្តឹង ត្រូវផ្តល់ការពន្យល់ ឬសេចក្តីប្រកាសជាលាយល័ក្ខណ៍អក្សរ បំភ្លឺបញ្ហាតាមកម្រិត ដែលអាចធ្វើបាន និងដោយចំៗ ជូនរដ្ឋដើមបណ្តឹង ដែលមានយោងនីតិវិធី និងដំណោះស្រាយ នៅក្នុងប្រទេសដែលបានធ្វើ ហើយដែលមិនទាន់សម្រេច ឬដែលនៅបើកចំហ ។

(ខ) បើបញ្ហាមិនត្រូវបានដោះស្រាយឱ្យពេញចិត្ត រវាងរដ្ឋជាប់ពាក់ព័ន្ធទាំងពីរ ក្នុងរយៈពេល៦ខែ ចាប់ពីថ្ងៃទទួលបណ្តឹងដំបូងដោយរដ្ឋចុងបណ្តឹង រដ្ឋណាមួយក៏បាន មានសិទ្ធិបញ្ជូនបញ្ហាទៅគណៈកម្មាធិការ ដោយជូនដំណឹងទៅគណៈកម្មា-ធិការ និងរដ្ឋម្ខាងទៀត ។

(គ) គណៈកម្មាធិការ អាចដោះស្រាយបញ្ហា ដែលបញ្ជូនឱ្យមកខ្លួនបាន លុះត្រាតែគណៈកម្មាធិការ បានរកឃើញថា មធ្យោបាយខាងផ្លូវច្បាប់ទាំងអស់ដែលមាននៅក្នុងប្រទេសនោះ ត្រូវបានយកមកប្រើអស់លទ្ធភាព ស្របតាមគោលការណ៍នៃច្បាប់អន្តរជាតិ ដែលទទួលស្គាល់ជាទូទៅ ។ វិធាននេះ នឹងមិនត្រូវយកមកអនុវត្តទេ បើនីតិវិធីនៃការដោះស្រាយបន្តយូរហួសហេតុ ។

(ឃ) គណៈកម្មាធិការ ត្រូវរៀបចំសម័យប្រជុំរបស់ខ្លួនដោយសម្ងាត់ នៅពេលពិនិត្យបណ្តឹង ស្របតាមមាត្រានេះ ។

(ង) យោងតាមបទបញ្ញត្តិក្នុងអនុកថាខណ្ឌ (គ) គណៈកម្មាធិការ ត្រូវដាក់សេវារបស់ខ្លួនឱ្យរដ្ឋភាគីពាក់ព័ន្ធប្រើប្រាស់ ដើម្បីឈានទៅដល់ដំណោះស្រាយស្រុះស្រួល លើបញ្ហា ផ្អែកលើមូលដ្ឋាននៃការគោរពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ដែលទទួលស្គាល់ក្នុងកតិកាសញ្ញានេះ ។

(ច) បញ្ហាណាដែលបញ្ជូនមកគណៈកម្មាធិការស្របតាមអនុកថាខណ្ឌ (ខ) គណៈកម្មាធិការ អាចសុំឱ្យរដ្ឋភាគីពាក់ព័ន្ធ ផ្តល់ព័ត៌មានពាក់ព័ន្ធបន្ថែម មកគណៈកម្មាធិការ ។

(ឆ) រដ្ឋភាគីពាក់ព័ន្ធ យោងតាមអនុកថាខណ្ឌ (ខ) មានសិទ្ធិមានវត្តមានតំណាងរបស់ខ្លួននៅពេលគណៈកម្មាធិការកំពុងពិនិត្យបញ្ហា និងមានសិទ្ធិស្នើយោបល់ដោយផ្ទាល់មាត់ និង/ ឬជាលាយល័ក្ខណ៍អក្សរ ។

(ជ) ក្នុងរយៈពេល ១២ខែ ក្រោយពីកាលបរិច្ឆេទទទួលដំណឹង ដូចចែងក្នុងអនុកថាខណ្ឌ (ខ) គណៈកម្មាធិការ ត្រូវដាក់ជូនរបាយការណ៍មួយ ៖

(i) ប្រសិនបើដំណោះស្រាយមួយ ត្រូវបានរកឃើញ ស្របតាមបទបញ្ញត្តិនៅក្នុងអនុកថាខណ្ឌ (ង) គណៈកម្មាធិការ ត្រូវកម្រិតរបាយការណ៍របស់ខ្លួន ត្រឹមតែជាសេចក្តីថ្លែងការណ៍សង្ខេបស្តីពីអង្គហេតុ និងដំណោះស្រាយដែលបានរកឃើញ ។

(ii) ប្រសិនបើដំណោះស្រាយណាមួយមិនអាចរកឃើញ ស្របតាមបទបញ្ញត្តិនៃអនុកថាខណ្ឌ (ង)ទេ គណៈកម្មាធិការ ត្រូវកម្រិតរបាយការណ៍របស់ខ្លួន ត្រឹមតែជាសេចក្តីថ្លែងការណ៍សង្ខេបស្តីពីអង្គហេតុ។ ការស្នើយោបល់ជាលាយល័ក្ខណ៍អក្សរ និងកំណត់ត្រានៃការស្នើយោបល់ផ្ទាល់មាត់ ដោយរដ្ឋភាគីពាក់ព័ន្ធ ត្រូវភ្ជាប់ទៅនឹងរបាយការណ៍ ។ នៅគ្រប់បញ្ហាទាំងអស់ របាយការណ៍ ត្រូវផ្សាយឱ្យរដ្ឋភាគីពាក់ព័ន្ធបានដឹង ។

២. បទបញ្ញត្តិនៃមាត្រានេះនឹងចូលជាធរមាន នៅពេលដែលរដ្ឋភាគីចំនួន ១០ នៃកតិកាសញ្ញានេះ បានធ្វើសេចក្តីប្រកាស ស្របតាមកថាខណ្ឌ១នៃមាត្រានេះ។ សេចក្តីប្រកាសនេះ ត្រូវតំកល់ទុកដោយរដ្ឋភាគី នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយអគ្គលេខាធិការ ត្រូវធ្វើច្បាប់ចម្លងទៅឱ្យរដ្ឋភាគីទាំងអស់។

សេចក្តីប្រកាស អាចដកទៅវិញបានគ្រប់ពេលដោយជូនដំណឹងទៅអគ្គលេខាធិការ។ ការដកទៅវិញនេះ មិនត្រូវធ្វើឱ្យប៉ះពាល់ដល់ការពិនិត្យបញ្ហាណា ដែលជាកម្មវត្ថុនៃបណ្តឹងដែលផ្ញើរួចហើយ ស្របតាមមាត្រានេះឡើយ ហើយបណ្តឹងបន្ថែមពីរដ្ឋភាគីនឹងឈប់ទទួល ក្រោយពីអគ្គលេខាធិការ បានទទួលការជូនដំណឹងពីការដក លើកលែងតែរដ្ឋភាគីពាក់ព័ន្ធបានធ្វើសេចក្តីប្រកាសជាថ្មី ។

## មាត្រា ៤២

១. (ក) បើបញ្ហាដែលដាក់ជូនគណៈកម្មាធិការ ស្របតាមមាត្រា៤១ មិនត្រូវបានដោះស្រាយជាទីពេញចិត្តដល់រដ្ឋភាគីពាក់ព័ន្ធទេ គណៈកម្មាធិការ ដោយមានការយល់ព្រមជាមុនពីរដ្ឋភាគីពាក់ព័ន្ធ អាចចាត់តាំងគណៈកម្មការផ្សះផ្សារចំពោះកិច្ចមួយ (បន្ទាប់ពីនេះទៅហៅថា គណៈកម្មការ)។ គណៈកម្មការ ត្រូវដាក់សេវារបស់ខ្លួន ឱ្យរដ្ឋភាគីពាក់ព័ន្ធប្រើប្រាស់ ដើម្បីរកដំណោះស្រាយសម្រុះសម្រួលលើបញ្ហានោះ ដោយគោរពតាមកតិកាសញ្ញានេះ ។

(ខ) គណៈកម្មការត្រូវមានសមាជិក៥រូប ដែលមានការយល់ព្រមពីរដ្ឋភាគីពាក់ព័ន្ធ។ បើរដ្ឋភាគីពាក់ព័ន្ធ មិនឈានដល់ការព្រមព្រៀងគ្នាទាំងស្រុង ឬផ្នែកខ្លះលើសមាសភាពគណៈកម្មការ ក្នុងរយៈពេល ៣ខែទេ សមាជិកគណៈកម្មការណាដែលមិនបានទទួលការយល់ព្រម ត្រូវដាក់ឱ្យជ្រើសរើសដោយការបោះឆ្នោតជាសម្ងាត់ដោយយកសម្លេងភាគច្រើនពីរភាគបី នៃចំណោមសមាជិកគណៈកម្មាធិការ ។

២. សមាជិកគណៈកម្មការ ត្រូវបំពេញតួនាទីជាបុគ្គល។ សមាជិកគណៈកម្មការ មិនត្រូវជាជនជាតិនៃរដ្ឋភាគីពាក់ព័ន្ធ ឬនៃរដ្ឋដែលមិនមែនជាភាគីនៃកតិកាសញ្ញានេះ ឬនៃរដ្ឋភាគីដែលមិនបានធ្វើសេចក្តីប្រកាសដូចចែងក្នុងមាត្រា៤១ ។

៣. គណៈកម្មការ ត្រូវបោះឆ្នោតជ្រើសរើសប្រធាន និងអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

៤. គណៈកម្មការ ត្រូវប្រជុំជាធម្មតានៅទីស្នាក់ការអង្គការសហប្រជាជាតិ ឬនៅការិយាល័យអង្គការសហប្រជាជាតិនៅទីក្រុងហ្សឺណែវ។ ប៉ុន្តែ កិច្ចប្រជុំ អាចធ្វើទៅបាន នៅកន្លែងសមស្របដទៃទៀត ដែលគណៈកម្មការអាចកំណត់ ដោយពិគ្រោះយោបល់ជាមួយអគ្គលេខាធិការអង្គការសហប្រជាជាតិ និងរដ្ឋភាគីពាក់ព័ន្ធ។

៥. លេខាធិការដ្ឋាន ដែលមានចែងក្នុងមាត្រា៣៦ ត្រូវជួយគណៈកម្មការដែលបានចាត់តាំង ស្របតាមមាត្រានេះ ។

៦. ព័ត៌មានដែលគណៈកម្មាធិការ ទទួល និងប្រមូលបាន ត្រូវទុកឱ្យគណៈកម្មការប្រើប្រាស់ ហើយគណៈកម្មការ អាចសុំឱ្យរដ្ឋភាគីពាក់ព័ន្ធ ផ្តល់ព័ត៌មានពាក់ព័ន្ធផ្សេងទៀត ។

៧. នៅពេលដែលគណៈកម្មការបានពិនិត្យបញ្ហាសព្វគ្រប់ហើយ យ៉ាងយូរ ១២ខែ ក្រោយពីការសិក្សាបញ្ហាចប់ គណៈកម្មការ ត្រូវធ្វើរបាយការណ៍ទៅប្រធានគណៈកម្មាធិការ ដើម្បីឆ្លើយឆ្លងទៅរដ្ឋភាគីពាក់ព័ន្ធ ៖

(ក) បើគណៈកម្មការមិនអាចបញ្ចប់ការពិនិត្យបញ្ហា ក្នុងរយៈពេល១២ខែទេ គណៈកម្មការ ត្រូវកម្រិតរបាយការណ៍ ត្រឹមតែជាសេចក្តីថ្លែងការណ៍សង្ខេបស្តីពីស្ថានភាពនៃការពិនិត្យបញ្ហាតែប៉ុណ្ណោះ។

(ខ) ផ្អែកលើការគោរពសិទ្ធិមនុស្សដូចបានទទួលស្គាល់នៅក្នុងកតិកាសញ្ញានេះ បើដំណោះស្រាយស្រុះស្រួលគ្នាលើបញ្ហា អាចធ្វើបានសម្រេចហើយ នោះគណៈកម្មការ ត្រូវកម្រិតរបាយការណ៍របស់ខ្លួន ត្រឹមតែជាសេចក្តីថ្លែងការណ៍សង្ខេបលើអង្គហេតុ និងដំណោះស្រាយដែលសម្រេចបាន ។

(គ) បើដំណោះស្រាយ តាមលក្ខខណ្ឌ នៃអនុកថាខណ្ឌ (ខ) មិនអាចសម្រេចបានទេ របាយការណ៍របស់គណៈកម្មការ ត្រូវបង្ហាញសេចក្តីសន្និដ្ឋានលើគ្រប់ចំណុចនៃអង្គហេតុទាក់ទងនឹងបញ្ហានានា រវាងរដ្ឋភាគីពាក់ព័ន្ធ និងបង្ហាញយោបល់ស្តីពីលទ្ធភាពនៃដំណោះស្រាយស្រុះស្រួលគ្នាលើបញ្ហា។ របាយការណ៍នេះ ត្រូវមានផងដែរនូវការផ្តល់យោបល់ជាលាយល័ក្ខណ៍អក្សរ និងសំណុំរឿងទាំងមូលនៃការផ្តល់យោបល់ផ្ទាល់មាត់ដោយភាគីពាក់ព័ន្ធ ។

(ឃ) បើរបាយការណ៍របស់គណៈកម្មការ បានដាក់ជូន ស្របតាមអនុកថាខណ្ឌ (គ) ខាងលើនោះ រដ្ឋភាគីពាក់ព័ន្ធ ត្រូវជំរាបទៅប្រធាននៃគណៈកម្មាធិការក្នុងរយៈពេល៣ខែ ចាប់ពីថ្ងៃបានទទួលរបាយការណ៍ ថាតើព្រមទទួលឬមិនព្រមទទួលអត្ថន័យនៃរបាយការណ៍របស់គណៈកម្មការ ។

៨. បទបញ្ញត្តិនៃមាត្រានេះ មិនប៉ះពាល់ដល់មុខការរបស់គណៈកម្មាធិការ ដូចមានចែងក្នុងមាត្រា៤១ ឡើយ ។

៩. ចំណាយទាំងអស់របស់សមាជិកគណៈកម្មការ ត្រូវបែងចែកស្មើគ្នារវាងរដ្ឋភាគីពាក់ព័ន្ធ ស្របតាមការប៉ាន់ស្មាន ដែលកំណត់ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

១០. ប្រសិនបើចាំបាច់ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវមានសិទ្ធិចំណាយជួស ទៅលើសមាជិកគណៈកម្មការ មុនមានសំណងពីរដ្ឋភាគីពាក់ព័ន្ធ ស្របតាមកថាខណ្ឌ៩ នៃមាត្រានេះ ។

### មាត្រា ៤៣

សមាជិកនៃគណៈកម្មាធិការ និងគណៈកម្មការសម្រុះសម្រួលចំពោះកិច្ចដែលតែងតាំង ស្របតាមមាត្រា៤២ មានសិទ្ធិប្រើប្រាស់សម្ភារៈរូបវ័ន្ត មានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិនៃអ្នកជំនាញការ ក្នុងបេសកកម្មរបស់អង្គការសហប្រជាជាតិ ដូចមាន

ចែងក្នុងផ្នែកពាក់ព័ន្ធ នៃអនុសញ្ញាស្តីអំពីបុព្វសិទ្ធ និងអភ័យឯកសិទ្ធរបស់អង្គការសហប្រជាជាតិ ។

## មាត្រា ៤៤

បទបញ្ញត្តិសម្រាប់អនុវត្តអនុសញ្ញានេះ ត្រូវអនុវត្តដោយមិនត្រូវធ្វើឱ្យប៉ះពាល់ដល់នីតិវិធីដែលបានចែងក្នុងវិស័យសិទ្ធិមនុស្ស ស្របតាមលិខិតុបករណ៍ផ្សេងៗ និងអនុសញ្ញារបស់សហប្រជាជាតិ និងស្ថាប័នឯកទេសឡើយ ហើយមិនត្រូវរារាំងរដ្ឋភាគីនៃអនុសញ្ញានេះ ក្នុងការប្រើនីតិវិធីដទៃទៀត ដើម្បីដោះស្រាយជម្លោះ ស្របតាមកិច្ចព្រមព្រៀងអន្តរជាតិទូទៅ ឬពិសេសដែលចងរដ្ឋភាគីឡើយ ។

## មាត្រា ៤៥

គណៈកម្មាធិការត្រូវបញ្ជូនរបាយការណ៍ប្រចាំឆ្នាំ ស្តីពីសកម្មភាពរបស់ខ្លួនទៅឱ្យមហាសន្និបាតអង្គការសហប្រជាជាតិ តាមរយៈក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច។

## ផ្នែកទី ៥

## មាត្រា ៤៦

គ្មានបទបញ្ញត្តិណាមួយក្នុងកតិកាសញ្ញានេះ ត្រូវយកមកបកស្រាយធ្វើឱ្យប៉ះពាល់ដល់បទបញ្ញត្តិទាំងឡាយ នៃធម្មនុញ្ញសហប្រជាជាតិ និងរដ្ឋធម្មនុញ្ញនៃស្ថាប័នឯកទេសនានា ដែលកំណត់ការទទួលខុសត្រូវរបស់អង្គការនានា នៃសហប្រជាជាតិ និងស្ថាប័នឯកទេស ចំពោះបញ្ហាពាក់ព័ន្ធនឹងកតិកាសញ្ញានេះឡើយ ។

## មាត្រា ៤៧

គ្មានបទបញ្ញត្តិណាមួយនៃកតិកាសញ្ញានេះ ត្រូវយកមកបកស្រាយ ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិពីកំណើតរបស់ប្រជាជាតិទាំងអស់ ក្នុងការអាស្រ័យផល និងប្រើប្រាស់ពេញលេញ និងដោយសេរីនូវភោគទ្រព្យ និងធនធានធម្មជាតិរបស់ខ្លួនឡើយ ។

## ផ្នែកទី ៦

### មាត្រា ៤៨

១. កតិកាសញ្ញានេះ ត្រូវបើកចំហឱ្យចុះហត្ថលេខាសម្រាប់រដ្ឋសមាជិកសហប្រជាជាតិ ឬសមាជិកនៃស្ថាប័នឯកទេសណាមួយឬជាភាគីនៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ ឬជារដ្ឋផ្សេងទៀត ដែលត្រូវបានអញ្ជើញដោយមហាសន្និបាតសហប្រជាជាតិ ដើម្បីក្លាយជាភាគីនៃកតិកាសញ្ញានេះ ។

២. កតិកាសញ្ញានេះជាកម្មវត្ថុនៃការឱ្យសច្ចាប័ន។ លិខិតុបករណ៍ឱ្យសច្ចាប័នត្រូវតំកល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៣. កតិកាសញ្ញានេះ ត្រូវបើកចំហឱ្យរដ្ឋទាំងអស់ចូលជាសមាជិក ដូចចែងក្នុងកថាខណ្ឌ១ នៃមាត្រានេះ ។

៤. ការចូលជាសមាជិក ត្រូវធ្វើឡើងដោយការតំកល់លិខិតុបករណ៍សុំចូលជាសមាជិក នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៥. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវជូនដំណឹងដល់រដ្ឋទាំងអស់ដែលបានចុះហត្ថលេខាលើកតិកាសញ្ញានេះឬដែលបានចូលជាសមាជិកនៃកតិកាសញ្ញានេះអំពីការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬលិខិតុបករណ៍សុំចូលជាសមាជិក ។

### មាត្រា ៤៩

១. កតិកាសញ្ញានេះចូលជាធរមានក្នុងរយៈពេល៣ខែ ក្រោយពីកាលបរិច្ឆេទនៃការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬលិខិតុបករណ៍សុំចូលជាសមាជិកទី៣៥ នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

២. ចំពោះរដ្ឋដែលឱ្យសច្ចាប័ន ឬសុំចូលជាសមាជិក នៃកតិកាសញ្ញានេះ

បន្ទាប់ពីសមាជិកទី៣៥ កតិកាសញ្ញានេះនឹងចូលជាធរមានក្នុងរយៈពេល៣ខែ ក្រោយពីកាលបរិច្ឆេទ នៃការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬលិខិតុបករណ៍សុំចូលជាសមាជិករបស់រដ្ឋនោះ ។

## មាត្រា ៥០

បទបញ្ញត្តិនៃកតិកាសញ្ញានេះ ត្រូវអនុវត្តលើគ្រប់ផ្នែកទាំងអស់នៃរដ្ឋសហព័ន្ធ ដោយគ្មានការកម្រិត ឬលើកលែងឡើយ ។

## មាត្រា ៥១

១. រដ្ឋភាគីណាមួយនៃកតិកាសញ្ញានេះ អាចស្នើធ្វើវិសោធនកម្ម និងដាក់សេចក្តីស្នើនោះជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ។ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនសេចក្តីស្នើវិសោធនកម្មនេះ ទៅរដ្ឋភាគីនៃកតិកាសញ្ញានេះ ដោយសុំឱ្យរដ្ឋភាគីបញ្ជាក់ថា តើយល់ព្រមឱ្យមានសន្និសីទនៃរដ្ឋភាគីទាំងអស់ដើម្បីពិនិត្យ និងបោះឆ្នោតលើសេចក្តីស្នើវិសោធនកម្មឬទេ ។ ក្នុងករណីមានសម្លេង១ភាគ៣យ៉ាងតិចនៃរដ្ឋភាគីទាំងអស់ ប្រកាសយល់ព្រមឱ្យមានសន្និសីទ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវកោះប្រជុំសន្និសីទ ក្រោមការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ។ គ្រប់វិសោធនកម្មដែលអនុម័តដោយមតិភាគច្រើននៃរដ្ឋភាគីវត្តមាន និងបោះឆ្នោតក្នុងសន្និសីទ ត្រូវដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិ ដើម្បីសុំការយល់ព្រម ។

២. វិសោធនកម្មទាំងនេះ នឹងចូលជាធរមាន នៅពេលទទួលបានការយល់ព្រមពីមហាសន្និបាតអង្គការសហប្រជាជាតិ និងទទួលបានការអនុម័ត ដោយមតិភាគច្រើន២ភាគ៣ នៃរដ្ឋភាគីនៃកតិកាសញ្ញានេះ ស្របតាមបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញរបស់រដ្ឋនីមួយៗ ។

៣. នៅពេលដែលវិសោធនកម្មទាំងនោះចូលជាធរមានហើយ វិសោធនកម្មទាំងនោះ នឹងក្លាយជាកាតព្វកិច្ចសម្រាប់រដ្ឋភាគីដែលព្រមទទួលយកវិសោធនកម្មទាំងនោះ ឯរដ្ឋភាគីផ្សេងទៀតដែលមិនបានទទួលយល់ព្រម ត្រូវស្ថិតនៅក្រោមបទបញ្ញត្តិនៃកតិកាសញ្ញានេះ និងវិសោធនកម្មមុនៗ ដែលខ្លួនបានព្រមទទួលយករួចហើយ ។

## មាត្រា ៥២

ក្រៅពីការជូនដំណឹងទាំងឡាយដែលមានចែងនៅក្នុងកថាខណ្ឌ៥នៃមាត្រា៤៨ អគ្គលេខាធិការ អង្គការសហប្រជាជាតិ ត្រូវជម្រាបជូនរដ្ឋទាំងឡាយ ស្របតាមកថាខណ្ឌ១ នៃមាត្រានេះ នូវ ៖

(ក) ការចុះហត្ថលេខា ការឱ្យសច្ចាប័ន និងការសុំចូលជាសមាជិក យោងតាមមាត្រា៤៨ ។

(ខ) កាលបរិច្ឆេទ នៃការចូលជាធរមាន នៃកតិកាសញ្ញានេះ យោងតាមមាត្រា៤៩ និងកាលបរិច្ឆេទនៃការចូលជាធរមាននៃវិសោធនកម្មទាំងឡាយ យោងតាមមាត្រា៥១ ។

## មាត្រា ៥៣

១. កតិកាសញ្ញានេះដែលមានអត្ថបទជាភាសាចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ មានតម្លៃស្មើគ្នា និងត្រូវតំកល់ទុកនៅបណ្ណសារដ្ឋានរបស់អង្គការសហប្រជាជាតិ ។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនច្បាប់ចម្លងនៃកតិកាសញ្ញានេះ ដោយមានបញ្ជាក់ការចម្លងតាមច្បាប់ដើម ជូនដល់រដ្ឋទាំងឡាយ យោងតាមមាត្រា៤៨ ។

# ពិធីសារបន្ថែមទី១ លើកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ពាក់ព័ន្ធនឹងការទទួលយកនីតិវិធីបណ្តឹងបុគ្គល

ត្រូវបានអនុម័ត និងបើកឱ្យចុះហត្ថលេខា ផ្តល់សច្ចាប័ន និងចូលជាសមាជិក ដោយ សេចក្តីសម្រេចចិត្តរបស់មហាសន្និបាតលេខ២២០០A (XXI) ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ចូលជាធរមានថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦ ស្របតាមមាត្រា៩

***រដ្ឋភាគីនៃពិធីសារនេះ***

*យល់ឃើញថា* ដើម្បីធ្វើឱ្យប្រសើរឡើងទៀត នូវការសម្រេចទិសដៅនៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ពីនេះតទៅហៅត្រឹមថា កតិកាសញ្ញា) និងការអនុវត្តនីបទបញ្ញត្តិនៃកតិកាសញ្ញា វាជាការសមស្របក្នុងការធ្វើឱ្យគណៈកម្មាធិការសិទ្ធិមនុស្ស ដែលបង្កើតឡើង ស្របតាមផ្នែកទី៤ នៃកតិកាសញ្ញា (ពីនេះតទៅហៅត្រឹមថា គណៈកម្មាធិការ) អាចទទួល និងពិនិត្យបណ្តឹង ដូចចែងក្នុងពិធីសារនេះ ពីបុគ្គលទាំងឡាយដែលអះអាងថា ជាជនរងគ្រោះនៃការរំលោភសិទ្ធិណាមួយ ដូចចែងក្នុងកតិកាសញ្ញា ។

*បានព្រមព្រៀងគ្នាដូចតទៅ* ៖

### មាត្រា ១

រដ្ឋភាគីនៃកតិកាសញ្ញា ដែលក្លាយជាភាគីនៃពិធីសារនេះ ទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការ ក្នុងការទទួល និងពិនិត្យបណ្តឹង ពីបុគ្គលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួនដែលអះអាងថាជាជនរងគ្រោះនៃការរំលោភពីរដ្ឋភាគីនោះទៅលើសិទ្ធិណាមួយ ដូចចែងនៅក្នុងកតិកាសញ្ញា។ គ្មានបណ្តឹងណាមួយ ត្រូវទទួលដោយគណៈកម្មាធិការទេ បើបណ្តឹងនោះទាក់ទងនឹងរដ្ឋភាគីនៃកតិកាសញ្ញាដែលមិនមែនជាភាគីនៃពិធីសារនេះ ។

### មាត្រា ២

ស្របតាមបទបញ្ញត្តិនៃមាត្រា១ បុគ្គលទាំងឡាយដែលអះអាងថា សិទ្ធិណាមួយរបស់ពួកគេ ដូចបានរៀបរាប់នៅក្នុងកតិកាសញ្ញា ត្រូវរងការរំលោភ និងបានប្រើអស់នូវការដោះស្រាយដែលមាននៅក្នុងប្រទេស អាចដាក់បណ្តឹងជាលាយលក្ខណ៍អក្សរជូនគណៈកម្មាធិការដើម្បីពិនិត្យ ។

### មាត្រា ៣

គណៈកម្មាធិការ ត្រូវចាត់ទុកមិនអាចទទួលយកនូវរាល់បណ្តឹងក្រោមពិធីសារនេះ ដែលជាបណ្តឹងអនាមិក ឬដែលគណៈកម្មាធិការចាត់ទុកថា ជាការរំលោភសិទ្ធិដាក់ពាក្យបណ្តឹង ឬចាត់ទុកថាមានវិសមិតភាពនឹងបទបញ្ញត្តិនៃកតិកាសញ្ញា ។

### មាត្រា ៤

១. ពាក់ព័ន្ធនឹងបទបញ្ញត្តិនៃមាត្រា៣ គណៈកម្មាធិការ ត្រូវផ្តល់ព័ត៌មានអំពីបណ្តឹងណាមួយដែលដាក់ជូនខ្លួនស្របតាមពិធីសារនេះ ដល់រដ្ឋភាគីនៃពិធីសារនេះ ដែលជាប់ចោទពីការរំលោភបទបញ្ញត្តិណាមួយនៃកតិកាសញ្ញា ។

២. ក្នុងរយៈពេល៦ខែ រដ្ឋដែលទទួលព័ត៌មាននេះ ត្រូវដាក់ជូនគណៈកម្មាធិការ នូវការពន្យល់ជាលាយលក្ខណ៍អក្សរ ឬសេចក្តីថ្លែងការណ៍បំភ្លឺអំពីបញ្ហា និងការដោះស្រាយ ប្រសិនជាមាន ដែលរដ្ឋនោះអាចធ្វើ ។

### មាត្រា ៥

១. គណៈកម្មាធិការ ត្រូវពិនិត្យបណ្តឹងដែលទទួលបាន ស្របតាមពិធីសារនេះ ដោយយកមកគិត នូវរាល់ព័ត៌មានជាលាយលក្ខណ៍អក្សរ ដែលផ្តល់មកឱ្យខ្លួនដោយបុគ្គល និងដោយរដ្ឋភាគីពាក់ព័ន្ធ ។

២. គណៈកម្មាធិការ មិនត្រូវពិនិត្យបណ្តឹងណាមួយពីបុគ្គលណាម្នាក់ លើកលែងតែគណៈកម្មាធិការប្រាកដថា៖

(ក) បញ្ហាដដែលនោះ មិនមានការពិនិត្យតាមនីតិវិធី នៃការស៊ើបអង្កេត ឬការដោះស្រាយអន្តរជាតិផ្សេងទៀត ។

(ខ) បុគ្គលនោះ បានប្រើអស់នូវការដោះស្រាយដែលមាននៅក្នុងប្រទេស។ វិធាននេះនឹងមិនត្រូវយកមកអនុវត្តទេ បើនីតិវិធីនៃការដោះស្រាយបន្តយូរហួសហេតុ។

៣. គណៈកម្មាធិការ ត្រូវរៀបចំសម័យប្រជុំរបស់ខ្លួនដោយសម្ងាត់ នៅពេលពិនិត្យបណ្តឹង ស្របតាមពិធីសារនេះ ។

៤. គណៈកម្មាធិការ ត្រូវបញ្ជូនការយល់ឃើញរបស់ខ្លួនទៅរដ្ឋភាគី និងបុគ្គលពាក់ព័ន្ធ ។

## មាត្រា ៦

គណៈកម្មាធិការ ត្រូវបញ្ចូលទៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន ស្របតាមមាត្រា៤៥ នៃកតិកាសញ្ញានូវសេចក្តីសង្ខេបនៃសកម្មភាពរបស់ខ្លួនក្រោមពិធីសារនេះ។

## មាត្រា ៧

ទំរាំដល់ការសម្រេចបាន នូវទិសដៅ នៃសេចក្តីសម្រេចចិត្តលេខ១៥១៤ (XV) អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៦០ ស្តីពីសេចក្តីប្រកាសផ្តល់ឯករាជ្យដល់ប្រទេស និងប្រជាជាតិក្រោមអាណានិគម បទបញ្ញត្តិនៃពិធីសារនេះ ជាដាច់ខាតមិនអាចកម្រិតសិទ្ធិប្តឹងទាមទារ ដែលផ្តល់ឱ្យដល់ប្រជាជាតិទាំងនេះ ដោយធម្មនុញ្ញសហប្រជាជាតិ និងអនុសញ្ញានិងលិខិតុបករណ៍អន្តរជាតិផ្សេងទៀត ក្រោមអង្គការសហប្រជាជាតិ និងស្ថាប័នឯកទេសរបស់អង្គការសហប្រជាជាតិឡើយ ។

## មាត្រា ៨

១. ពិធីសារនេះ បើកចំហឱ្យរដ្ឋហត្ថលេខីនៃកតិកាសញ្ញាចុះហត្ថលេខា ។

២. ពិធីសារនេះត្រូវជាកម្មវត្ថុនៃការឱ្យសច្ចាប័នដោយរដ្ឋដែលបានឱ្យសច្ចាប័ន ឬបានចូលជាសមាជិកនៃកតិកាសញ្ញា។ លិខិតុបករណ៍ឱ្យសច្ចាប័ន ត្រូវតំកល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៣. ពិធីសារនេះ ត្រូវបើកឱ្យចូលជាសមាជិកដោយរដ្ឋ ដែលបានឱ្យសច្ចាប័ន ឬបានចូលជាសមាជិកនៃកតិកាសញ្ញា ។

៤. ការសុំចូលជាសមាជិក មានអនុភាព ដោយការដាក់តំកល់លិខិតុបករណ៍ សុំចូលជាសមាជិក នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៥. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវផ្តល់ព័ត៌មានដល់រដ្ឋហត្ថលេខី នៃពិធីសារនេះ ឬរដ្ឋសមាជិកនៃពិធីសារនេះ អំពីការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬចូលជាសមាជិក ។

## មាត្រា ៩

១. ស្របតាមការចូលជាធរមាននៃកតិកាសញ្ញា ពិធីសារនេះ ត្រូវចូលជាធរមានក្នុងរយៈពេល៣ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬចូលជាសមាជិកទី១០ នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

២. ចំពោះរដ្ឋនីមួយៗ ដែលឱ្យសច្ចាប័នលើពិធីសារនេះ ឬចូលជាសមាជិកនៃពិធីសារនេះ បន្ទាប់ពី ការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬលិខិតុបករណ៍ចូលជាសមាជិកទី១០ ពិធីសារនេះ ត្រូវចូលជាធរមានក្នុងរយៈពេល៣ខែ បន្ទាប់ពីកាលបរិច្ឆេទដែលរដ្ឋនីមួយៗ ដាក់តំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬលិខិតុបករណ៍ចូលជាសមាជិករបស់ខ្លួន ។

## មាត្រា ១០

បទបញ្ញត្តិទាំងឡាយ នៃពិធីសារនេះ ត្រូវអនុវត្តលើគ្រប់ផ្នែកនៃរដ្ឋសហព័ន្ធ ដោយគ្មានការដាក់កម្រិតព្រំដែន ឬការលើកលែងឡើយ ។

## មាត្រា ១១

១. រដ្ឋភាគីនៃពិធីសារនេះអាចស្នើសុំធ្វើវិសោធនកម្ម និងបញ្ជូនសេចក្តីស្នើសុំធ្វើវិសោធនកម្មនេះ ជូនទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។ នៅពេលនោះ អគ្គលេខាធិការ ត្រូវបញ្ជូនសេចក្តីស្នើសុំធ្វើវិសោធនកម្ម ជូនទៅរដ្ឋភាគីនៃពិធីសារនេះ ដោយសុំឱ្យរដ្ឋភាគីបញ្ជាក់ថា តើយល់ព្រមឱ្យមានសន្និសីទនៃរដ្ឋភាគីទាំងអស់ ដើម្បីពិនិត្យ និងបោះឆ្នោតលើសេចក្តីស្នើសុំធ្វើវិសោធនកម្មឬទេ។ ក្នុងករណីមានសម្លេង១ភាគ៣ យ៉ាងតិចនៃរដ្ឋភាគីទាំងអស់ ប្រកាសយល់ព្រមឱ្យមានសន្និសីទ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវកោះប្រជុំសន្និសីទ ក្រោមការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ។ គ្រប់វិសោធនកម្មដែលអនុម័តដោយមតិភាគច្រើននៃរដ្ឋភាគីវត្តមាន និងបោះឆ្នោតក្នុងសន្និសីទ ត្រូវដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិ ដើម្បីសុំការយល់ព្រម ។

២. វិសោធនកម្មទាំងនេះ នឹងចូលជាធរមាន នៅពេលទទួលបានការយល់ព្រមពីមហាសន្និបាតអង្គការសហប្រជាជាតិ និងទទួលបានការអនុម័ត ដោយមតិភាគច្រើន២ភាគ៣ នៃរដ្ឋភាគីនៃពិធីសារនេះ ស្របតាមបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញរបស់រដ្ឋនីមួយៗ ។

៣. នៅពេលវិសោធនកម្មទាំងនោះ ចូលជាធរមានហើយ វិសោធនកម្មទាំងនោះនឹងក្លាយជាកាតព្វកិច្ចសម្រាប់រដ្ឋភាគី ដែលព្រមទទួលយកវិសោធនកម្មទាំងនោះ រីឯរដ្ឋភាគីផ្សេងទៀតដែលមិនបានទទួលយល់ព្រម ត្រូវស្ថិតនៅក្រោមបទបញ្ញត្តិនៃកតិកាសញ្ញានេះ និងវិសោធនកម្មមុនៗ ដែលខ្លួនបានព្រមទទួលយករួចហើយ ។

## មាត្រា ១២

១. រដ្ឋភាគី អាចប្រកាសដកខ្លួនចេញពីពិធីសារនេះបានគ្រប់ពេល ដោយការ

ជូនដំណឹងជាលាយល័ក្ខណ៍អក្សរ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ការប្រកាសដកខ្លួននេះ ចូលជាធរមានក្នុងរយៈពេល៣ខែ បន្ទាប់ពីកាលបរិច្ឆេទ ដែលអគ្គលេខាធិការទទួលការជូនដំណឹង ។

២. ការប្រកាសដកខ្លួន មិនប៉ះពាល់ដល់ការបន្តអនុវត្តបទបញ្ញត្តិ នៃពិធីសារនេះ លើបណ្តឹងដែលដាក់ជូនស្របតាមមាត្រា២ មុនកាលបរិច្ឆេទចូលជាធរមាននៃការប្រកាសដកខ្លួនឡើយ ។

## មាត្រា ១៣

ដោយមិនគិតដល់ការជូនដំណឹង ដែលធ្វើឡើងស្របតាមមាត្រា៨ កថាខណ្ឌ៥ នៃពិធីសារនេះ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវជូនដំណឹងដល់រដ្ឋទាំងអស់ ដូចមានចែងក្នុងមាត្រា៤៨ កថាខណ្ឌ១នៃកតិកាសញ្ញាអំពីព័ត៌មានលំអិតខាងក្រោម៖

(ក) ហត្ថលេខា ការឱ្យសច្ចាប័ន និងការចូលជាសមាជិកស្រមតាមមាត្រា៨

(ខ) កាលបរិច្ឆេទនៃការចូលជាធរមាននៃពិធីសារនេះ ស្របតាមមាត្រា៩ និងកាលបរិច្ឆេទនៃការចូលជាធរមាននៃវិសោធនកម្ម ស្របតាមមាត្រា១១ ។

(គ) ការប្រកាសដកខ្លួន ស្របតាមមាត្រា១២ ។

## មាត្រា ១៤

១. ពិធីសារនេះដែលមានអត្ថបទជាភាសាចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ មានតម្លៃស្មើគ្នាត្រូវតំកល់ទុកនៅបណ្ណសារដ្ឋាននៃអង្គការសហប្រជាជាតិ។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនច្បាប់ចម្លងនៃកតិកាសញ្ញានេះ ដោយមានបញ្ជាក់ការចម្លងតាមច្បាប់ដើម ទៅរដ្ឋទាំងឡាយ ដែលមានយោងក្នុងមាត្រា៤៨ នៃកតិកាសញ្ញា ។

# ពិធីសារបន្ថែមទីពីរ លើកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ពាក់ព័ន្ធនឹងការលុបបំបាត់ទោសប្រហារជីវិត

ត្រូវបានអនុម័ត និងប្រកាសដោយសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតលេខ៤៤/១២៨
ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៨៩

*រដ្ឋភាគីនៃពិធីសារនេះ*

*ជឿថា* ការលុបបំបាត់ទោសប្រហារជីវិត នាំឱ្យសេចក្តីថ្លៃថ្នូររបស់មនុស្ស កាន់តែប្រសើរឡើង និងនាំឱ្យសិទ្ធិមនុស្ស មានការអភិវឌ្ឍន៍ជាលំដាប់ ។

*រំលឹកឡើងវិញ* នូវមាត្រា៣ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ដែលអនុម័តនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ និងមាត្រា៦ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលអនុម័តនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ។

*កត់សំគាល់ថា* មាត្រា៦ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បាននិយាយយោងអំពីការលុបបំបាត់ទោសប្រហារជីវិត ដោយពាក្យសំដីសង្កត់ធ្ងន់លើការប៉ងប្រាថ្នា ឱ្យមានការលប់ចោលនេះ ។

*ជឿជាក់ថា* រាល់វិធានការលុបបំបាត់ទោសប្រហារជីវិត ត្រូវចាត់ទុកថាជាការរីកចម្រើននៃការអាស្រ័យផលនៃសិទ្ធិរស់រានមានជីវិត ។

*មានបំណងយ៉ាងខ្លាំង* ធ្វើការសន្យាជាអន្តរជាតិតាមរយៈនេះ ដើម្បីលុបបំបាត់ទោសប្រហារជីវិត ។

*បានព្រមព្រៀងគ្នាដូចតទៅ* ៖

## មាត្រា ១

១. គ្មានជនណាម្នាក់ ស្ថិតក្រោមដែនសមត្ថកិច្ចរដ្ឋភាគីនៃពិធីសារនេះ ត្រូវប្រហារជីវិតឡើយ ។

២. រដ្ឋភាគីនីមួយៗ ត្រូវចាត់វាល់វិធានការចាំបាច់ ដើម្បីលុបបំបាត់ទោសប្រហារជីវិត ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

## មាត្រា ២

១. ពិធីសារនេះ មិនអនុញ្ញាតឱ្យមានលក្ខខណ្ឌណាមួយឡើយ លើកលែងតែលក្ខខណ្ឌលើកឡើង នៅពេលឱ្យសច្ចាប័ន ឬចូលជាសមាជិក ដែលមានចែងអំពីការដាក់ទោសប្រហារជីវិតក្នុងពេលមានសង្គ្រាម ចំពោះទោសឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតខាងយោធា ដែលប្រព្រឹត្តឡើងក្នុងពេលមានសង្គ្រាម ។

២. រដ្ឋភាគីដែលស្នើលក្ខខណ្ឌបែបនេះនៅពេលឱ្យសច្ចាប័នឬចូលជាសមាជិក ត្រូវផ្ញើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ នូវបទបញ្ញត្តិពាក់ព័ន្ធក្នុងច្បាប់ជាតិរបស់ខ្លួន ដែលអនុវត្តក្នុងពេលសង្គ្រាម ។

៣. រដ្ឋភាគីដែលដាក់លក្ខខណ្ឌបែបនេះ ត្រូវជំរាបជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ អំពីការចាប់ផ្តើម និងការបញ្ចប់ស្ថានភាពសង្គ្រាមនៅលើទឹកដីរបស់ខ្លួន ។

## មាត្រា ៣

រដ្ឋភាគីនៃពិធីសារនេះ ត្រូវបញ្ចូលទៅក្នុងរបាយការណ៍ ដែលដាក់ជូនគណៈកម្មាធិការសិទ្ធិមនុស្ស ស្របតាមមាត្រា៤០នៃកតិកាសញ្ញា នូវព័ត៌មានស្តីពីវិធានការដែលខ្លួនបានអនុម័ត ដើម្បីផ្តល់អានុភាពដល់ពិធីសារនេះ ។

## មាត្រា ៤

ចំពោះរដ្ឋភាគីនៃកតិកាសញ្ញា ដែលបានធ្វើសេចក្តីថ្លែងការណ៍ ស្របតាមមាត្រា៤១ សមត្ថកិច្ចគណៈកម្មាធិការសិទ្ធិមនុស្ស ក្នុងការទទួល និងពិនិត្យបណ្តឹង

ត្រូវពង្រីកដល់បទបញ្ញត្តិនៃពិធីសារនេះ នៅពេលរដ្ឋភាគីមួយអះអាងថា រដ្ឋភាគីមួយទៀត មិនបំពេញកាតព្វកិច្ចរបស់ខ្លួន លើកលែងតែរដ្ឋភាគីពាក់ព័ន្ធ បានធ្វើសេចក្តីថ្លែងការណ៍ផ្ទុយ នៅពេលឱ្យសច្ចាប័ន ឬចូលជាសមាជិក ។

## មាត្រា ៥

ចំពោះរដ្ឋភាគីនៃពិធីសារបន្ថែមទី១ លើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលអនុម័តនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ សមត្ថកិច្ចរបស់គណៈកម្មាធិការសិទ្ធិមនុស្ស ក្នុងការទទួល និងពិនិត្យបណ្តឹងពីបុគ្គល ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់រដ្ឋភាគី ត្រូវពង្រីកដល់បទបញ្ញត្តិនៃពិធីសារនេះ លើកលែងតែរដ្ឋភាគីពាក់ព័ន្ធ បានធ្វើសេចក្តីថ្លែងការណ៍ផ្ទុយនៅពេលផ្តល់សច្ចាប័នឬចូលជាសមាជិក។

## មាត្រា ៦

១. បទបញ្ញត្តិនៃពិធីសារនេះត្រូវអនុវត្តជាបទបញ្ញត្តិបន្ថែមលើកតិកាសញ្ញា។

២. ដោយមិនធ្វើឱ្យប៉ះពាល់ដល់លទ្ធភាព នៃការដាក់លក្ខខណ្ឌ ស្របតាមមាត្រា២ នៃពិធីសារនេះ សិទ្ធិដែលធានាក្នុងមាត្រា១ កថាខណ្ឌ១ នៃពិធីសារនេះ មិនត្រូវជាកម្មវត្ថុនៃការធ្វើបដិប្បញ្ញត្តិណាមួយ ក្រោមមាត្រា៤នៃកតិកាសញ្ញាឡើយ។

## មាត្រា ៧

១. ពិធីសារនេះ ត្រូវបើកចំហឱ្យរដ្ឋហត្ថលេខីនៃកតិកាសញ្ញា ចុះហត្ថលេខា។

២. ពិធីសារនេះ គឺជាកម្មវត្ថុនៃការឱ្យសច្ចាប័នដោយរដ្ឋដែលបានឱ្យសច្ចាប័នដល់កតិកាសញ្ញា ឬបានចូលជាសមាជិកនៃកតិកាសញ្ញា។ លិខិតុបករណ៍ឱ្យសច្ចាប័នត្រូវតំកល់ទុក នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៣. ពិធីសារនេះ ត្រូវបើកឱ្យចូលជាសមាជិកដោយរដ្ឋ ដែលបានឱ្យសច្ចាប័នដល់កតិកាសញ្ញា ឬបានចូលជាសមាជិកនៃកតិកាសញ្ញា ។

៤. ការចូលជាសមាជិក ត្រូវធ្វើតាមរយៈ ការតំកល់លិខិតុបករណ៍ចូលជាសមាជិក នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៥. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវជូនព័ត៌មានទៅរដ្ឋទាំងអស់ដែលចុះហត្ថលេខាលើពិធីសារនេះ ឬចូលជាសមាជិកនៃពិធីសារនេះ អំពីការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬការចូលជាសមាជិក ។

## មាត្រា ៨

១. ពិធីសារនេះ ត្រូវចូលជាធរមានក្នុងរយៈពេល៣ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការតំកល់ទុកលិខិតុបករណ៍ឱ្យសច្ចាប័ន និងចូលជាសមាជិកទី១០នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

២. ចំពោះរដ្ឋនីមួយៗ ដែលឱ្យសច្ចាប័នដល់ពិធីសារនេះ ឬចូលជាសមាជិកនៃពិធីសារនេះ បន្ទាប់ពីការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬលិខិតុបករណ៍ចូលជាសមាជិកទី១០នៃពិធីសារនេះ ត្រូវចូលជាធរមាន ក្នុងរយៈពេល៣ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬលិខិតុបករណ៍ចូលជាសមាជិករបស់ខ្លួន ។

## មាត្រា ៩

បទបញ្ញត្តិនៃពិធីសារនេះ ត្រូវអនុវត្តលើគ្រប់ផ្នែកនៃរដ្ឋសហព័ន្ធ ដោយគ្មានការដាក់កម្រិតព្រំដែន ឬការលើកលែងឡើយ ។

## មាត្រា ១០

អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវជូនដំណឹងទៅរដ្ឋទាំងអស់ ដូចចែងក្នុងមាត្រា៤៨ កថាខណ្ឌ១ នៃកតិកាសញ្ញា នូវព័ត៌មានលំអិតខាងក្រោមៈ

(ក) លក្ខខណ្ឌ បណ្ដឹង និងការជូនដំណឹងស្របតាមមាត្រា២នៃពិធីសារនេះ

(ខ) សេចក្តីថ្លែងការណ៍ដែលធ្វើស្របតាមមាត្រា៤ ឬ៥ នៃពិធីសារនេះ ។

(គ) ការចុះហត្ថលេខា ការឱ្យសច្ចាប័ន និងការចូលជាសមាជិក ស្រប តាមមាត្រា៧ នៃពិធីសារនេះ ។

(ឃ) កាលបរិច្ឆេទនៃការចូលជាធរមាននៃពិធីសារនេះស្របតាមមាត្រា៨។

### មាត្រា ១១

១. ពិធីសារនេះដែលមានអត្ថបទជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ មានតម្លៃស្មើគ្នា ត្រូវតំកល់ទុកក្នុងបណ្ណសារដ្ឋាននៃអង្គការសហប្រជាជាតិ ។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនច្បាប់ចម្លងនៃកតិកាសញ្ញានេះ ដោយមានបញ្ជាក់ការចម្លងតាមច្បាប់ដើម ទៅរដ្ឋទាំងឡាយដែលមានយោងក្នុងមាត្រា៤៨ នៃកតិកាសញ្ញា ។

# សេចក្តីប្រកាស
# ជាសកល
# ស្តីពី
# សិទ្ធិមនុស្ស

ការិយាល័យឧត្តមស្នងការអង្គការសហ ប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំកម្ពុជា

# សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស

## អារម្ភកថា

*" មនុស្សទាំងអស់កើតមកមានសេរីភាព និងសមភាព ក្នុងផ្នែកសេចក្ដីថ្លៃថ្នូរ និងសិទ្ធិ " ( មាត្រា ២)*

សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្សត្រូវបានអនុម័ត ដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។

មហាសន្និបាត អ.ស.ប បានប្រកាសជាសាធារណៈថា សេចក្ដីប្រកាសជាសកលនេះគឺជា " ឧត្តមគតិរួមដែល ប្រជាពលរដ្ឋគ្រប់ៗប្រទេស និងប្រជាជាតិទាំងអស់ត្រូវធ្វើឱ្យ-បានសម្រេច" ។ សេចក្ដីប្រកាសជាសកលនេះចែងអំពី ទស្សនៈរួមមួយ ស្ដីអំពីសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន-ទាំងឡាយ ដែលរដ្ឋជាសមាជិកបានប្ដេជ្ញាចិត្តអនុវត្តបញ្ញត្តិ

នៃធម្មនុញ្ញសហប្រជាជាតិឱ្យបានសំរេច។ សេចក្តីប្រកាសនេះ ទទួលស្គាល់សេចក្តីថ្លៃថ្នូរជាប់ពីកំណើត និងសិទ្ធិស្មើភាពគ្នា និងសិទ្ធិមិនអាចលក់ ដូរ ផ្ទេរ ឬដកហូតបានរបស់មនុស្សជាតិទាំងអស់ ដោយគ្មានការបែងចែក។ រយៈពេលច្រើនឆ្នាំកន្លងមក សេចក្តីប្រកាសនេះបានទទួលកំលាំងខាងសីលធម៌មួយដែលមិនអាចវាស់វែងបាន។

សេចក្តីប្រកាសជាសាកលនេះ ភ្ជាប់កាតព្វកិច្ចខាងផ្លូវច្បាប់ក្នុងប្រទេសកម្ពុជា ដោយបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ មាត្រា ៣១។

បទបញ្ញត្តិនៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ត្រូវបានបកប្រែបញ្ចូលដោយផ្ទាល់ទៅក្នុងឯកសារច្បាប់ចំនួនពីរគឺ : កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងកតិកាសញ្ញាអន្តរជាតិស្តីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ កតិកាសញ្ញាទាំងនេះ រួមទាំងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដទៃទៀត ចែងលំអិតអំពី

របៀបដែលរដ្ឋនានាត្រូវអនុវត្តសិទ្ធិ និងសេរីភាពទាំងឡាយ ដែលមានចែងក្នុងសេចក្ដីប្រកាស ។

សន្ធិសញ្ញាអន្តរជាតិដទៃទៀត បានកើតចេញពីសេចក្ដីប្រកាសជាសាកល រួមមានអនុសញ្ញាអន្តរជាតិស្ដីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ អនុសញ្ញាស្ដីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាប និងអនុសញ្ញាស្ដីពីសិទ្ធិកុមារ ។ ប្រទេសកម្ពុជាគឺជាភាគីនៃសន្ធិសញ្ញាទាំងនេះ ហើយដែលបានដាក់បញ្ចូលទៅក្នុងច្បាប់ជាតិតាមរយៈរដ្ឋធម្មនុញ្ញ ។

ពាក្យពេចន៍នៅក្នុងសេចក្ដីប្រកាសជាសកលចែងថា បុគ្គលគ្រប់ៗរូប និងអង្គការសង្គមទាំងអស់ត្រូវ *"ខិតខំប្រឹងប្រែង បណ្ដុះបណ្ដាលការគោរពសិទ្ធិ និងសេរីភាពទាំងនេះ*

*តាមរយៈការបង្រៀន និងការអប់រំ ហើយនិងខំប្រឹងប្រែង ធានាឱ្យមានការទទួលស្គាល់ និងការអនុវត្តជាសាកល ជាក់ស្តែងនូវសិទ្ធិនិងសេរីភាព ដោយវិធានការជាតិ និងអន្តរ-ជាតិ ដែលមាន លក្ខណៈរីកចម្រើនជាលំដាប់ " ។*

ដើម្បីរំលឹកនូវថ្ងៃអនុម័តសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ថ្ងៃទី១០ ខែធ្នូ ត្រូវបានគេកំណត់យកដើម្បីប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិនៅប្រទេសកម្ពុជា និងនៅទូទាំងពិភពលោក ។

# សេចក្តីប្រកាសជាសកល
# ស្តីពីសិទ្ធិមនុស្ស

អនុម័តនិងប្រកាសដោយសេចក្តីសម្រេចចិត្តនៃមហាសន្និបាត លេខ ២១៧ **A**（**III**）នៅថ្ងៃទី ១០ ខែធ្នូ ឆ្នាំ១៩៤៨

## បុព្វកថា

*ដោយយល់ឃើញថា* ការទទួលស្គាល់សេចក្តីថ្លៃថ្នូរ ជាប់ពីកំណើតរបស់សមាជិកទាំងអស់នៃគ្រួសារមនុស្ស ហើយ និងការទទួលស្គាល់សិទ្ធិស្មើភាពគ្នានិងសិទ្ធិមិនអាចលក់ ដូរ ផ្ទេរ ឬដកហូតបាន ជាគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាព ក្នុងពិភពលោក។

*ដោយយល់ឃើញថា* ការមិនទទួលស្គាល់និងការប្រមាថ មើលងាយសិទ្ធិមនុស្ស បាននាំទៅកាន់អំពើព្រៃផ្សៃសាហាវ យង់ឃ្នង ធ្វើឱ្យក្តៅក្រហាយដល់សតិសម្បជញ្ញៈមនុស្សជាតិ

និង *ដោយយល់ឃើញថា* ការកើតឡើងនូវពិភពលោកមួយដែលមនុស្សជាតិត្រូវមានសេរីភាពក្នុងការនិយាយស្តី និងជំនឿរួចផុតពីភាពភ័យខ្លាចនិងទុគ៌តភាព ត្រូវបានប្រកាសថាជាសេចក្តីប្រាថ្នាដ៏ខ្ពស់បំផុតរបស់មនុស្សទូទៅ ។

*ដោយយល់ឃើញថា* ជាការចាំបាច់ដែលសិទ្ធិមនុស្សត្រូវតែបានការពារដោយនីតិរដ្ឋ ដើម្បីជៀសវាង កុំឱ្យមនុស្សបង្ខំចិត្តជាចុងក្រោយបង្អស់ បះបោរប្រឆាំងទល់នឹងអំណាចផ្តាច់ការ និងការគាបសង្កត់ ។

*ដោយយល់ឃើញថា* ជាការចាំបាច់ដែលត្រូវលើកស្ទួយការពង្រីកទំនាក់ទំនងជាមិត្តភាព រវាងប្រជាជាតិនានា ។

*ដោយយល់ឃើញថា* ប្រជាពលរដ្ឋទាំងអស់នៃសហប្រជាជាតិ បានប្រកាសបញ្ជាក់សារជាថ្មីក្នុងធម្មនុញ្ញសហប្រជាជាតិ នូវជំនឿរបស់ខ្លួនទៅលើសិទ្ធិមូលដ្ឋាននៃមនុស្សលើសេចក្តីថ្លៃថ្នូរ លើតម្លៃរបស់មនុស្សនិងលើសមភាពនៃ

សិទ្ធិរវាងបុរសនិងស្ត្រី ហើយប្តេជ្ញាលើកស្ទួយវឌ្ឍនភាពសង្គមនិងកម្រិតជីវភាពរស់នៅឱ្យកាន់តែប្រសើរឡើងក្នុងសេរីភាពកាន់តែទូលំទូលាយ ។

*ដោយយល់ឃើញថា* ក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិ រដ្ឋជាសមាជិកទាំងអស់សន្យានិងធានាគោរពសិទ្ធិសកល និងសេរីភាពមូលដ្ឋានឱ្យបានសម្រេច ។

*ដោយយល់ឃើញថា* ទស្សនៈរួមមួយស្តីអំពីសិទ្ធិ និងសេរីភាពទាំងនេះ មានសារសំខាន់បំផុត ដើម្បីបំពេញនូវការសន្យាខាងលើ

## *អាស្រ័យហេតុនេះមហាសន្និបាតប្រកាសថា ៖*

*សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សនេះ* ជាឧត្តមគតិរួមដែលប្រជាពលរដ្ឋគ្រប់ៗប្រទេស និង ប្រជាជាតិទាំងអស់ត្រូវធ្វើឱ្យបានសម្រេច ដើម្បីឱ្យបុគ្គលគ្រប់ៗរូបនិងអង្គការ

សង្គមទាំងអស់ ដោយរក្សាខ្ជាប់ជានិច្ចក្នុងស្មារតីរបស់ខ្លួន នូវសេចក្តីប្រកាសនេះ ខិតខំប្រឹងប្រែងបណ្តុះបណ្តាលការគោរពសិទ្ធិ និងសេរីភាពទាំងនេះតាមរយៈការបង្រៀន និងការអប់រំ ហើយនិងខំប្រឹងប្រែងធានាឱ្យមានការទទួលស្គាល់ និងការអនុវត្តជាសកលជាក់ស្តែងនូវសិទ្ធិនិងសេរីភាព ដោយវិធានការជាតិនិងអន្តរជាតិ ដែលមានលក្ខណៈរីកចម្រើនជាលំដាប់ ទាំងក្នុងចំណោមប្រជាពលរដ្ឋនៃរដ្ឋសមាជិក ទាំងក្នុងចំណោមប្រជាពលរដ្ឋដែនដី ដែលស្ថិតនៅក្រោមអំណាចនៃរដ្ឋទាំងនោះផង ។

**មាត្រា ១**

មនុស្សទាំងអស់កើតមកមានសេរីភាពនិងសមភាពក្នុងផ្នែកសេចក្តីថ្លៃថ្នូរនិងសិទ្ធិ។ មនុស្សមានវិចារណញ្ញាណ និងសតិសម្បជញ្ញៈជាប់ពីកំណើត ហើយគប្បីប្រព្រឹត្តចំពោះគ្នាទៅវិញទៅមកក្នុងស្មារតីភាតរភាពជាបងប្អូន ។

**មាត្រា ២**

១. មនុស្សម្នាក់ៗអាចប្រើប្រាស់សិទ្ធិនិងសេរីភាពទាំងអស់ ដែលបានប្រកាសក្នុងសេចក្តីប្រកាសនេះ ដោយគ្មានការប្រកាន់បែងចែកបែបណាមួយ មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិឬសង្គម ព្រទ្យសម្បត្តិ កំណើត ឬស្ថានភាពដទៃៗទៀតឡើយ ។

២. លើសពីនេះ មិនត្រូវធ្វើការប្រកាន់បែងចែកណាមួយ ដោយសំអាងទៅលើឋានៈខាងនយោបាយ ខាងយុត្តាធិការ ឬខាងអន្តរជាតិរបស់ប្រទេសឬដែនដីដែលបុគ្គលណាម្នាក់រស់នៅ ទោះបីជាប្រទេស ឬដែនដីនោះឯករាជ្យក្តី ស្ថិត-ក្រោមអាណាព្យាបាលក្តី ឬគ្មានស្វ័យគ្រប់គ្រងក្តី ឬស្ថិតក្រោមការដាក់កម្រិតផ្សេងទៀតណាមួយនៃអធិបតេយ្យភាពក្តី ។

**មាត្រា ៣**

បុគ្គលម្នាក់ៗ មានសិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខផ្ទាល់ខ្លួន ។

**មាត្រា ៤**

គ្មានជនណាម្នាក់ត្រូវស្ថិតក្នុងទាសភាព ឬស្ថិតក្នុងភាពជាអ្នកបម្រើដាច់ថ្លៃឡើយ ។ ទាសភាព និងទាសពាណិជ្ជកម្ម ត្រូវហាមឃាត់ ទោះតាមទម្រង់ណាក៏ដោយ ។

**មាត្រា ៥**

គ្មានជនណាម្នាក់ ត្រូវទទួលទារុណកម្ម ឬទណ្ឌកម្ម ឬប្រព្រឹត្តិកម្មកាចសាហាវ ឥតមនុស្សធម៌ ឬថោកទាបបានឡើយ ។

**មាត្រា ៦**

មនុស្សម្នាក់ៗ មានសិទ្ធិឱ្យទទួលស្គាល់ពីបុគ្គលិក

លក្ខណៈគតិយុត្តរបស់ខ្លួន នៅគ្រប់ទីកន្លែង ។

**មាត្រា ៧**

មនុស្សគ្រប់រូប មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងមាន-សិទ្ធិទទួលការការពារពីច្បាប់ស្មើៗគ្នា ដោយគ្មានការរើសអើង ។ មនុស្សគ្រប់រូប មានសិទ្ធិទទួលការការពារស្មើៗគ្នា ប្រឆាំងនឹងការរើសអើងណា ដែលរំលោភលើសេចក្ដីប្រកាសនេះ ព្រមទាំងប្រឆាំងនឹងការញុះញង់ឱ្យមានការរើសអើង ។

**មាត្រា ៨**

មនុស្សគ្រប់រូប មានសិទ្ធិរកដំណោះស្រាយជាក់ស្ដែងមួយ នៅចំពោះមុខសាលាជំរះក្ដីជាតិ ដែលមានសមត្ថកិច្ចចំពោះអំពើទាំងឡាយណាដែលរំលោភសិទ្ធិមូលដ្ឋានរបស់ខ្លួន ដែលត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ ឬដោយច្បាប់ ។

### មាត្រា ៩

គ្មានជនណាម្នាក់ ត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬនិរទេសខ្លួនដោយបំពានឡើយ ។

### មាត្រា ១០

មនុស្សគ្រប់រូប មានសិទ្ធិស្មើគ្នាពេញលេញ សុំឱ្យតុលាការឯករាជ្យនិងមិនលំអៀង ពិនិត្យរឿងក្ដីរបស់ខ្លួនជាសាធារណៈ និងដោយសមធម៌ ដើម្បីសម្រេចលើសិទ្ធិកាតព្វកិច្ច និងភាពសមហេតុផលចំពោះការចោទប្រកាន់ទាំងឡាយខាងបទព្រហ្មទណ្ឌ ។

### មាត្រា ១១

១. ជនណាដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ត្រូវសន្មតជាជនគ្មានទោសរហូតដល់ពិរុទ្ធភាព ត្រូវបានរកឃើញនៅក្នុងសវនាការជាសាធារណៈ ដែលមានការធានាចាំបាច់ដើម្បីការពារសិទ្ធិជនជាប់ចោទ ពីបទល្មើសព្រហ្មទណ្ឌ ។

២. គ្មានជនណាម្នាក់ត្រូវបានផ្តន្ទាទោសពីបទល្មើសព្រហ្មទណ្ឌ ដោយបានប្រព្រឹត្ត ឬភ្លាំងភ្លាត់ប្រព្រឹត្ត ដែលអំពើ-នេះមិនបានចែងក្នុងច្បាប់ជាតិ ឬអន្តរជាតិ ។ មិនត្រូវផ្តន្ទា-ទោសឱ្យធ្ងន់ជាងទោសដែលបានកំណត់ឱ្យអនុវត្តក្នុងអំឡុងពេលបទល្មើសបានកើតឡើងឡើយ ។

**មាត្រា ១២**

គ្មានមនុស្សណាម្នាក់ ត្រូវរងការរំលោភជ្រៀតជ្រែក-តាមអំពើចិត្តក្នុងជីវិតឯកជន គ្រួសារ ទីលំនៅ ការឆ្លើយឆ្លង ឬការធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ខ្លួនបានឡើយ ។ ជនគ្រប់រូប មានសិទ្ធិទទួលការការពារពីច្បាប់ប្រឆាំងនឹងការជ្រៀតជ្រែក ឬការប៉ះពាល់ទាំងនេះ ។

**មាត្រា ១៣**

១. មនុស្សគ្រប់រូបមានសិទ្ធិធ្វើដំណើរដោយសេរី និងមានសិទ្ធិជ្រើសរើសនិវេសនដ្ឋានក្នុងរដ្ឋមួយ ។

២. មនុស្សគ្រប់រូប មានសិទ្ធិចាកចេញពីប្រទេសណាមួយ រួមទាំងប្រទេសរបស់ខ្លួនផង និងមានសិទ្ធិវិលត្រឡប់មកប្រទេសរបស់ខ្លួនវិញ ។

**មាត្រា ១៤**

១. មនុស្សគ្រប់រូប មានសិទ្ធិស្វែងរកនិងទទួលកន្លែងជ្រកកោនក្នុងប្រទេសដទៃទៀត ក្នុងករណីមានការធ្វើទុក្ខបុកម្នេញមកលើខ្លួន ។

២. សិទ្ធិសុំជ្រកកោននេះមិនអាចលើកមកសំអាងបានទេ ក្នុងករណីមានការចោទប្រកាន់ពីបទល្មើស នៃនីតិរួម ឬពីការប្រព្រឹត្តណាដែលផ្ទុយពីគោលបំណង និងគោលការណ៍ទាំងឡាយរបស់សហប្រជាជាតិ ។

**មាត្រា ១៥**

១. មនុស្សគ្រប់រូបមានសិទ្ធិទទួលបានសញ្ជាតិមួយ ។

២. គ្មានជនណាម្នាក់អាចត្រូវដកហូតសញ្ជាតិ ឬរារាំងសិទ្ធិប្តូរសញ្ជាតិរបស់ខ្លួន ដោយរំលោភបានឡើយ ។

**មាត្រា ១៦**

១. បុរសនិងស្ត្រី មានសិទ្ធិរៀបអាពាហ៍ពិពាហ៍និងកសាងគ្រួសារ ដោយមិនប្រកាន់ពូជសាសន៍ សញ្ជាតិ ឬសាសនាឡើយ ។ បុរសនិងស្ត្រី មានសិទ្ធិស្មើគ្នាក្នុងការរៀបអាពាហ៍ពិពាហ៍ ក្នុងចំណងអាពាហ៍ពិពាហ៍ និងក្នុងពេលរំលាយអាពាហ៍ពិពាហ៍ ។

២. អាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅបាន លុះត្រាតែមានការព្រមព្រៀងដោយសេរី និងពេញលេញ ពីអនាគតប្តីប្រពន្ធ ។

៣. គ្រួសារជាធាតុធម្មជាតិ និងជាធាតុមូលដ្ឋានរបស់សង្គម ហើយគ្រួសារមានសិទ្ធិទទួលការការពារពីសង្គម និងរដ្ឋ ។

**មាត្រា ១៧**

១. មនុស្សគ្រប់រូប ទោះជាបុគ្គលក្តី សមូហភាពក្តី មាន-សិទ្ធិជាម្ចាស់កម្មសិទ្ធិ ។

២. គ្មានជនណាម្នាក់ត្រូវបានដកហូតកម្មសិទ្ធិដោយបំពានឡើយ ។

**មាត្រា ១៨**

មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពខាងការគិត សតិសម្បជញ្ញៈ និងសាសនា។ សិទ្ធិនេះ រាប់បញ្ចូលទាំង-សេរីភាពផ្លាស់ប្តូរសាសនា ឬជំនឿ ព្រមទាំងសេរីភាពសម្តែង-សាសនា ឬជំនឿរបស់ខ្លួនតែម្នាក់ឯង ឬ ជារួម ជាសាធារណៈ ឬជាឯកជន តាមការបង្ហាត់បង្រៀន ការអនុវត្តជាទម្លាប់ ការគោរពបូជា ព្រមទាំងតាមការប្រារព្ធពិធីសក្ការៈផ្សេងៗ។

**មាត្រា ១៩**

មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការមានមតិ និង-

ការសម្ដែងមតិ ។ សិទ្ធិនេះ រាប់បញ្ចូលទាំង សេរីភាពក្នុងការ ប្រកាន់មតិដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុងការ ស្វែងរកការទទួល និងការផ្សព្វផ្សាយពតិមាននិងគំនិតនានា ដោយគ្មានព្រំដែន ទោះតាមរយៈមធ្យោបាយសម្ដែងមតិណា មួយក៏ដោយ ។

**មាត្រា ២០**

១. មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការប្រជុំ ឬការ បង្កើតសមាគមដោយសន្តិវិធី ។

២. គ្មានជនណាម្នាក់ ត្រូវបានបង្ខិតបង្ខំឱ្យចូលរួមក្នុង សមាគមណាមួយឡើយ ។

**មាត្រា ២១**

១. មនុស្សគ្រប់រូប មានសិទ្ធិចូលរួមក្នុងការដឹកនាំកិច្ចការ សាធារណៈនៃប្រទេសរបស់ខ្លួនដោយផ្ទាល់ ឬតាមរយៈ តំណាងដែលបានជ្រើសរើសដោយសេរី ។

២. មនុស្សគ្រប់រូប មានសិទ្ធិចូលបម្រើមុខងារសា-ធារណៈនៃប្រទេសរបស់ខ្លួន ក្នុងល័ក្ខខ័ណ្ឌសមភាព។

៣. ឆន្ទៈរបស់ប្រជាពលរដ្ឋ ជាមូលដ្ឋានអំណាចនៃការដឹកនាំកិច្ចការសាធារណៈ។ ឆន្ទៈនេះ ត្រូវសម្ដែងចេញតាម-រយៈការបោះឆ្នោតយ៉ាងទៀងទាត់ តាមពេលកំណត់ និងពិតប្រាកដ មានលក្ខណៈសកល ស្មើភាព និងបោះឆ្នោតដោយសម្ងាត់ ឬតាមនីតិវិធីសមមូល ដែលធានាសេរីភាពនៃការ-បោះឆ្នោត។

**មាត្រា ២២**

ក្នុងឋានៈជាសមាជិកនៃសង្គម មនុស្សគ្រប់រូប មានសិទ្ធិទទួលបានសន្តិសុខសង្គម និងមានបុព្វសិទ្ធិ ទទួលបានសិទ្ធិខាងសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលចាំបាច់សម្រាប់សេចក្ដីថ្លៃថ្នូរ និងការរីកចំរើនដោយសេរីនៃបុគ្គលិកលក្ខណៈរបស់ខ្លួន តាមរយៈការខិតខំរបស់ជាតិ និងកិច្ចសហប្រតិបត្តិ-ការអន្តរជាតិ ស្របតាមការរៀបចំ និងតាមធនធានរបស់

ប្រទេសនីមួយៗ។

**មាត្រា ២៣**

១. មនុស្សគ្រប់រូប មានសិទ្ធិធ្វើការងារ ជ្រើសរើសការងារដោយសេរី និងធ្វើការងារក្នុងល័ក្ខខ័ណ្ឌ ត្រឹមត្រូវនិងពេញចិត្ត ព្រមទាំងការពារប្រឆាំងនឹងភាពអត់ការងារធ្វើ។

២. មនុស្សគ្រប់រូប មានសិទ្ធិទទួលប្រាក់បៀវត្សស្មើគ្នាចំពោះការងារដូចគ្នា ដោយគ្មានការរើសអើង។

៣. អ្នកធ្វើការងារ មានសិទ្ធិទទួលបានលាភការដោយសមធមិនិងពេញចិត្ត ដើម្បីធានាអត្ថិភាពរស់នៅរបស់ខ្លួន និងគ្រួសារ ឱ្យសមស្របនឹងសេចក្តីថ្លៃថ្នូរនៃមនុស្ស និងត្រូវបានបំពេញបន្ថែមទៀត តាមមធ្យោបាយផ្សេងៗនៃការការពារផ្នែកសង្គមប្រសិនបើចាំបាច់។

៤. មនុស្សគ្រប់រូប មានសិទ្ធិបង្កើត និងចូលរួមសហជីព

ដើម្បីការពារផលប្រយោជន៍របស់ខ្លួន។

**មាត្រា ២៤**

មនុស្សគ្រប់រូប មានសិទ្ធិឈប់សម្រាកនិងលំហែកំសាន្ត រួមបញ្ចូលទាំងកម្រិតម៉ោងការងារសមហេតុផល និងការឈប់សម្រាកដោយបានប្រាក់បៀវត្សតាមពេលកំណត់។

**មាត្រា ២៥**

១. មនុស្សគ្រប់រូប មានសិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់ ដើម្បីធានាសុខភាពនិងសុខុមាលភាពរបស់ខ្លួននិងគ្រួសារ រួមមានចំណីអាហារ សម្លៀកបំពាក់ លំនៅដ្ឋាន ការថែទាំសុខភាព និងសេវាសង្គម កិច្ចចាំបាច់ផ្សេងៗទៀត។ មនុស្សគ្រប់រូបមាន សិទ្ធិទទួលបានការគាំពារ នៅពេលគ្មានការងារធ្វើ មានជំងឺ ពិការ មេម៉ាយឬពោះម៉ាយ ចាស់ជរា ឬនៅពេលបាត់បង់មធ្យោបាយធានាជីវភាព ដែលបណ្ដាលមកពី កាលៈទេសៈផុតពីឆន្ទៈរបស់ខ្លួន។

២. មាតុភាព និងកុមារភាព មានសិទ្ធិទទួលជំនួយ និង-ការថែទាំពិសេស ។ កុមារគ្រប់រូប ទោះកើតពីឪពុកម្ដាយមានខាន់ស្លា ឬឥតខាន់ស្លាក្ដី ត្រូវបានទទួលការពារខាងសង្គមកិច្ចដូចគ្នា ។

**មាត្រា ២៦**

១. មនុស្សគ្រប់រូប មានសិទ្ធិទទួលបានការអប់រំ ។ ការអប់រំត្រូវឥតបង់ថ្លៃ យ៉ាងហោចណាស់ សម្រាប់ការអប់រំបឋមសិក្សា និងអប់រំមូលដ្ឋាន ។ ការអប់រំបឋមសិក្សាគឺជាកាតព្វកិច្ច ។ ការអប់រំខាងបច្ចេក ទេសនិងវិជ្ជាជីវៈ ត្រូវរៀបចំឱ្យមានជាទូទៅ ។ ការអប់រំឧត្ដមសិក្សា ត្រូវបើកឱ្យចូលរៀនស្មើភាពគ្នាដោយឈរលើមូលដ្ឋានសមត្ថភាព ។

២. ការអប់រំត្រូវសំដៅទៅរកការរីកលូតលាស់ពេញ-លេញនៃបុគ្គលិកលក្ខណៈរបស់មនុស្ស និងការពង្រឹងការគោរពសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាន ។ ការអប់រំនេះ

ត្រូវលើកកំពស់ការយល់ដឹងការអត់ឱន អធ្យាស្រ័យគ្នានិង មិត្តភាពរវាងប្រជាជាតិ និងក្រុមពូជសាសន៍ ឬក្រុមសាសនាទាំងអស់ ព្រមទាំងការអភិវឌ្ឍន៍សកម្មភាពរបស់សហប្រជាជាតិ ក្នុងការថែរក្សាសន្តិភាព។

៣. មាតាបិតា មានសិទ្ធិជាអាទិភាព ក្នុងការជ្រើសរើសប្រភេទនៃការអប់រំសម្រាប់បុត្រធីតារបស់ខ្លួន។

**មាត្រា ២៧**

១. មនុស្សគ្រប់រូប មានសិទ្ធិចូលរួមដោយសេរី ក្នុងជីវភាពវប្បធម៌របស់សហគមន៍ រីករាយនឹងសិល្បៈ និងចូលរួមចំណែកក្នុងវឌ្ឍនភាពវិទ្យាសាស្ត្រ និងបានទទួលផលប្រយោជន៍ពីលទ្ធផលវឌ្ឍនភាពនេះ។

២. មនុស្សគ្រប់រូប មានសិទ្ធិទទួលបានការការពារផលប្រយោជន៍ខាងសីលធម៌ និងសម្ភារៈ ដែលបានមកពីផលិតកម្មខាងវិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬសិល្បៈ ដែល-

ជាស្នាដៃរបស់ខ្លួន ។

**មាត្រា ២៨**

មនុស្សគ្រប់រូប មានសិទ្ធិចូលរួមគ្រប់គ្រងសណ្ដាប់ធ្នាប់សង្គមនិងអន្តរជាតិ ដែលសិទ្ធិនិងសេរីភាព ចែងក្នុងសេចក្ដីប្រកាសនេះ អាចត្រូវសម្រេចឱ្យបានដោយពេញលេញ ។

**មាត្រា ២៩**

១. មនុស្សគ្រប់រូប មានករណីយកិច្ចចំពោះសហគមន៍ដែលជាកន្លែងតែមួយគត់ អាចបង្កើតបានការរីកចម្រើនដោយសេរីនិងពេញបរិបូរណ៍នូវបុគ្គលិកលក្ខណៈរបស់ខ្លួន ។

២. ក្នុងការប្រើសិទ្ធិនិងសេរីភាពរបស់ខ្លួន មនុស្សគ្រប់រូបត្រូវស្ថិតនៅត្រឹមកម្រិតដែលច្បាប់បានកំណត់តែប៉ុណ្ណោះ ក្នុងគោលបំណងធានាការទទួលស្គាល់ និងការគោរពសិទ្ធិនិងសេរីភាពរបស់អ្នកដទៃ និង ដើម្បីបំពេញសេចក្ដីត្រូវការយ៉ាងត្រឹមត្រូវខាងសីលធម៌ សណ្ដាប់ធ្នាប់សាធារណៈ និង-

សុខុមាលភាពទូទៅ នៅក្នុងសង្គមប្រជាធិបតេយ្យ ។

៣. គ្មានករណីណាមួយ ដែលសិទ្ធិនិងសេរីភាពទាំងនេះ អាចយកទៅប្រើប្រាស់ផ្ទុយនឹងគោលការណ៍ទាំងឡាយរបស់សហប្រជាជាតិឡើយ ។

**មាត្រា ៣០**

គ្មានបទបញ្ញត្តិណាមួយនៃសេចក្តីប្រកាសនេះ អាចត្រូវ-បានបកស្រាយ ដែលបណ្តាលឱ្យរដ្ឋណាមួយ ក្រុមណាមួយ ឬបុគ្គលណាម្នាក់ មានសិទ្ធិបែបណាមួយដើម្បីធ្វើសកម្មភាព ឬប្រព្រឹត្តអំពើអ្វីមួយ សំដៅបំផ្លិចបំផ្លាញនូវសិទ្ធិនិងសេរី-ភាពទាំងឡាយ ដែលមានចែងនៅក្នុងសេចក្តីប្រកាស-នេះឡើយ ។

# ច្បាប់
# ស្តីពី
# ពន្ធនាគារ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

ខ/២២

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលបំណងកំណត់អំពីការគ្រប់គ្រងពន្ធនាគារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ច្បាប់នេះ មានគោលដៅដូចតទៅ :

- អប់រំ កែប្រែ ស្តារនីតិសម្បទា ដើម្បីធ្វើសមាហរណកម្មជនជាប់ឃុំទៅក្នុងសង្គមវិញ និង ទប់ស្កាត់ការប្រព្រឹត្តបទល្មើសសាជាថ្មី
- គ្រប់គ្រងជនជាប់ឃុំឲ្យបានធានាបានសន្តិសុខ សុវត្ថិភាព សុខភាព និង មនុស្សធម៌ ស្របតាមគោលការណ៍អន្តរជាតិ និង វិធានសហប្រជាជាតិ សម្រាប់ការពារអនីតិជនដែលត្រូវបានដកហូតសិទ្ធិសេរីភាព ។

**មាត្រា ៣.-**

ច្បាប់នេះ មានវិសាលភាពអនុវត្តលើពន្ធនាគារទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែពន្ធនាគារយោធា ឬកន្លែងឃាត់ខ្លួនរបស់នគរបាលយុត្តិធម៌ ឬមណ្ឌលឃុំខ្លួនដទៃទៀត ដែលកំណត់ដោយច្បាប់ផ្សេង ។

**មាត្រា ៤.-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ :

**ពន្ធនាគារ** សំដៅដល់កន្លែងប្រើសម្រាប់ធ្វើការឃុំឃាំងជនជាប់ឃុំតាមលិខិតឃុំខ្លួនចេញដោយអាជ្ញាធរតុលាការ រួមមានមណ្ឌលឃុំខ្លួន និងមណ្ឌលអប់រំកែប្រែផង ។

**អនីតិជន** សំដៅដល់បុគ្គលទាំងឡាយណា ដែលមានអាយុចាប់ពី ១៤ ឆ្នាំ ឡើង ដល់ក្រោម ១៨ ឆ្នាំ ។

**ជនជាប់ឃុំ** សំដៅដល់ជនត្រូវចោទ ឬជនជាប់ចោទ ឬពិរុទ្ធជន ឬទណ្ឌិតដែលត្រូវបានបញ្ជូនមកឃុំខ្លួននៅក្នុងពន្ធនាគារ តាមលិខិតឃុំខ្លួនចេញដោយអាជ្ញាធរតុលាការ ។

**មន្ត្រីពន្ធនាគារ** សំដៅដល់មន្ត្រីដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ។

**មន្ត្រីពេទ្យពន្ធនាគារ** សំដៅដល់មន្ត្រីដែលត្រូវបានតែងតាំងឲ្យផ្តល់សេវាថែទាំសុខភាពជនជាប់ឃុំក្នុងពន្ធនាគារ និងត្រូវបានទទួលស្គាល់ ឬបានចុះបញ្ជីជាគ្រូពេទ្យ ឬមន្ត្រីពេទ្យនៅក្រសួងសុខាភិបាល ។

**អ្នកសួរសុខទុក្ខ** សំដៅដល់ជនដែលត្រូវបានអនុញ្ញាតឲ្យចូលក្នុងពន្ធនាគារ ដើម្បីសួរសុខទុក្ខ ឬផ្តល់ជំនួយដល់ជនជាប់ឃុំ ។

**អ្នកសួរសុខទុក្ខផ្លូវការ** សំដៅដល់មន្ត្រីសាធារណៈ ឬតំណាងបុគ្គលមកពីអង្គការនានា ដែលទទួលបានការអនុញ្ញាតឲ្យទៅធ្វើទស្សនកិច្ចឃ្លាំមើលតាមពន្ធនាគារនានា ឬផ្តល់ជំនួយដល់ជនជាប់ឃុំ ។

**យន្តការបង្ការថ្នាក់ជាតិ** សំដៅដល់យន្តការឯករាជ្យមួយ ស្របតាមពិធីសារបន្ថែមស្តីពីការបង្ការអំពើទារុណកម្ម អំពើឃោរឃៅអមនុស្សធម៌ ឬបន្ទាបបន្ថោក ។

## ជំពូកទី ២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា ៥.-**

ក្រសួងមហាផ្ទៃជាស្ថាប័នមានសមត្ថកិច្ច ក្នុងការគ្រប់គ្រងពន្ធនាគារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៦.-**

អគ្គនាយកដ្ឋានពន្ធនាគារជាសេនាធិការឲ្យក្រសួងមហាផ្ទៃ ក្នុងការគ្រប់គ្រងពន្ធនាគារ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានពន្ធនាគារ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧.-**

មន្ត្រីពន្ធនាគារត្រូវស្ថិតក្រោមលក្ខន្តិកៈដោយឡែក ដែលត្រូវកំណត់ដោយព្រះរាជក្រឹត្យ ស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៨.-**

មន្ត្រីពន្ធនាគារមានឯកសណ្ឋាន សញ្ញាសក្តិ គ្រឿងបំពាក់ ឧបករណ៍ និងសម្ភារៈការពារសមស្រប ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

**មាត្រា ៩.-**

ក្រសួងមហាផ្ទៃត្រូវធ្វើប្រតិភូកម្មមុខងារឲ្យរដ្ឋបាលរាជធានី ខេត្ត ក្នុងការគ្រប់គ្រងពន្ធនាគារ រាជធានី ខេត្ត ។

ពន្ធនាគាររាជធានី ខេត្ត ស្ថិតក្រោមការគ្រប់គ្រងរបស់គណៈអភិបាលរាជធានី ខេត្ត ។

## ជំពូកទី ៣
## ហេដ្ឋារចនាសម្ព័ន្ធពន្ធនាគារ

**មាត្រា ១០.-**

ហេដ្ឋារចនាសម្ព័ន្ធរបស់ពន្ធនាគារត្រូវគោរពតាមបទដ្ឋានអប្បបរមា សម្រាប់ការសាងសង់ពន្ធនាគារ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១១.-**

អគារ និងបន្ទប់ឃុំឃាំង ត្រូវមានពន្លឺគ្រប់គ្រាន់ មានខ្យល់ធម្មជាតិ មានបន្ទប់អនាម័យ មានប្រព័ន្ធផ្គត់ផ្គង់ទឹក និងអគ្គិសនីសម្រាប់ប្រើប្រាស់ ។

**មាត្រា ១២.-**

ពន្ធនាគារត្រូវមានប៉ុស្តិ៍សុខភាព មានបន្ទប់សម្រាកព្យាបាលជនជាប់ឃុំ និងត្រូវមានមន្ត្រីពេទ្យពន្ធនាគារបម្រើការងារជាប្រចាំ ។

សេវាសុខាភិបាលពន្ធនាគារត្រូវស្ថិតក្រោមការគ្រប់គ្រងបច្ចេកទេសរបស់ក្រសួងសុខាភិបាល ។

**មាត្រា ១៣.-**

ពន្ធនាគារត្រូវមានកន្លែងសម្រាប់គោរពជំនឿសាសនា មានបណ្ណាល័យ និងអគារអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ ។

**មាត្រា ១៤.-**

ពន្ធនាគារត្រូវរៀបចំឲ្យមានកន្លែងហាត់ប្រាណសម្រាប់ជនជាប់ឃុំ ។

**មាត្រា ១៥.-**

ពន្ធនាគារត្រូវមានកន្លែងធ្វើការ និងផ្ទះមុខងារ សម្រាប់មន្ត្រីពន្ធនាគារក្នុងអំឡុងពេលនៃការបំពេញមុខងាររបស់ខ្លួន ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ព្រះរាជវាំង

**មាត្រា ១៦.-**

ការបង្កើត ការដាក់ឈ្មោះ ការកំណត់ទីតាំង ការកំណត់ចំនួនជនជាប់ឃុំ ការផ្លាស់ប្តូរឈ្មោះ ការផ្លាស់ប្តូរទីតាំង និងការលែលាយពន្ធនាគារ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៤
## ការឃុំឃាំង

**មាត្រា ១៧.-**

ការទទួល ឬការឃុំខ្លួនជនណាម្នាក់នៅក្នុងពន្ធនាគារបាន លុះត្រាតែមានលិខិតឃុំខ្លួនដែលចេញពីអាជ្ញាធរតុលាការ ។

**មាត្រា ១៨.-**

មុនពេលទទួលយកជនជាប់ឃុំចូលក្នុងពន្ធនាគារ ប្រធានពន្ធនាគារ ឬមន្ត្រីពន្ធនាគារដែលបានទទួលការចាត់តាំង ត្រូវត្រួតពិនិត្យអត្តសញ្ញាណរបស់ជនជាប់ឃុំឲ្យបានត្រឹមត្រូវ តាមលិខិតឃុំខ្លួនដែលចេញដោយអាជ្ញាធរតុលាការ ។

**មាត្រា ១៩.-**

មន្ត្រីពេទ្យពន្ធនាគារត្រូវពិនិត្យសុខភាពជនជាប់ឃុំ មុននឹងទទួលយកចូលក្នុងពន្ធនាគារ ដោយត្រូវកត់ត្រាបញ្ចូលក្នុងកំណត់ហេតុនូវព័ត៌មានអំពីស្ថានភាពសុខភាពរបស់ជនជាប់ឃុំ ។

**មាត្រា ២០.-**

បន្ទាប់ពីទទួលយកជនជាប់ឃុំចូលក្នុងពន្ធនាគារ មន្ត្រីពន្ធនាគារត្រូវណែនាំដល់ជនជាប់ឃុំ អំពីច្បាប់ បទបញ្ជាផ្ទៃក្នុងពន្ធនាគារ សិទ្ធិស្វែងរកអ្នកតំណាងផ្លូវច្បាប់ សិទ្ធិផ្តល់ដំណឹងទៅគ្រួសារ ឬសាច់ញាតិ ឬស្ថាប័នពាក់ព័ន្ធផ្សេងៗ អំពីការជាប់ពន្ធនាគារ និងទីតាំងនៃពន្ធនាគារ ព្រមទាំងសិទ្ធិ និងករណីយកិច្ចផ្សេងៗទៀត ដូចមានចែងក្នុងច្បាប់នេះ ។

ក្នុងករណីជនជាប់ឃុំជាជនបរទេស ប្រធានពន្ធនាគារត្រូវអនុញ្ញាតឲ្យជនជាប់ឃុំជូនដំណឹងទៅស្ថានទូត ឬស្ថានកុងស៊ុល ឬស្ថានតំណាងរបស់ខ្លួន ។ ប្រសិនបើជនជាប់ឃុំមិនមានលទ្ធភាពជូនដំណឹងបាន ប្រធានពន្ធនាគារត្រូវធ្វើកិច្ចការនេះ ។

ក្រោយពីបានទទួលការណែនាំនេះ ជនជាប់ឃុំត្រូវផ្តិតស្រាមដៃ និង បិទ ឬស្តេនរូបថតបញ្ចូលក្នុងកំណត់ទ្រីរ ដើម្បីរក្សាទុកជាអចិន្ត្រៃយ៍ក្នុងសំណុំឯកសារ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**មាត្រា ២១.-**

ពន្ធនាគារនីមួយៗ ត្រូវមានបញ្ជីជនជាប់ឃុំដែលបញ្ជាក់អំពីអត្តសញ្ញាណរបស់ជនជាប់ឃុំ ហើយចុះទិដ្ឋាការដោយតំណាងអង្គការអយ្យការនៅគ្រប់ទំព័រ ។

ចំពោះជនជាប់ឃុំជាស្ត្រីភេទ និងជនជាប់ឃុំជាអនីតិជន ត្រូវមានបញ្ជីដោយឡែក ហើយត្រូវយកចិត្តទុកដាក់ជាពិសេសដល់ការគ្រប់គ្រងជនជាប់ឃុំទាំងពីរប្រភេទនេះ ។

**មាត្រា ២២.-**

បញ្ជីជនជាប់ឃុំត្រូវបានត្រួតពិនិត្យដោយតំណាងអង្គការអយ្យការ និងត្រូវជូនទៅចៅក្រមពិនិត្យ មើលតាមការស្នើសុំ ព្រមទាំងបង្ហាញដល់មន្ត្រីនគរបាលយុត្តិធម៌ដែលបំពេញភារកិច្ច តាមការប្រគល់អំណាចពីអាជ្ញាធរតុលាការ ។

**មាត្រា ២៣.-**

គ្រប់ពន្ធនាគារត្រូវបង្កើតសំណុំឯកសារផ្ទាល់ខ្លួន សម្រាប់ជនជាប់ឃុំម្នាក់ៗ រាប់ទាំងជនជាប់ឃុំជាអនីតិជនផង ។ ព័ត៌មាន និងឯកសារពាក់ព័ន្ធទាំងអស់របស់ជនជាប់ឃុំ ត្រូវរក្សាទុកជាការសម្ងាត់ក្នុងសំណុំរឿងផ្ទាល់ខ្លួន ។

**មាត្រា ២៤.-**

ជនជាប់ឃុំ ត្រូវបានពិនិត្យវាយតម្លៃសុខភាពដោយមន្ត្រីពេទ្យពន្ធនាគារ ។ ត្រូវកត់បញ្ចូលទៅក្នុងសំណុំរឿងជនជាប់ឃុំ នូវព័ត៌មានអំពីរបួសស្នាម ជំងឺផ្លូវចិត្ត ពិការភាពផ្នែកកាយសម្បទា ឬ ព័ត៌មានពាក់ព័ន្ធផ្សេងទៀត ។

ក្នុងការចូលរួមការងារពលកម្មក្នុងពន្ធនាគារ ពេលពិនិត្យវាយតម្លៃសុខភាពលើកដំបូង មន្ត្រីពេទ្យពន្ធនាគារត្រូវកំណត់អំពីសមត្ថភាពកាយសម្បទា និងត្រូវកត់បញ្ចូលទៅក្នុងសំណុំរឿងផ្ទាល់ខ្លួនរបស់ទណ្ឌិត ដោយត្រូវយកចិត្តទុកដាក់ដល់សេចក្តីត្រូវការជាក់លាក់ និងខុសៗគ្នារបស់ស្ត្រី និងអនីតិជន ។

**មាត្រា ២៥.-**

រាល់ការធ្វើទារុណកម្ម ទង្វើអមនុស្សធម៌ ឬការប្រើប្រាស់ឧបករណ៍ផ្សេងៗ ដើម្បីដាក់ទណ្ឌកម្មដល់ជនជាប់ឃុំ ត្រូវហាមឃាត់ លើកលែងតែខ្នោះដៃដែលត្រូវបានអនុញ្ញាតតាមមាត្រា ៥០ នៃច្បាប់នេះ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**មាត្រា ២៦.-**

ជនជាប់ឃុំជាជនត្រូវចោទ ជនជាប់ចោទ ឬពិរុទ្ធជន ត្រូវដាក់បំបែកពីជនជាប់ឃុំជាទណ្ឌិត ។

ជនជាប់ឃុំជាស្ត្រី ត្រូវដាក់បំបែកពីជនជាប់ឃុំជាបុរស ។

ជនជាប់ឃុំជាអនីតិជន ត្រូវដាក់បំបែកពីជនជាប់ឃុំជានីតិជន ។

ជនជាប់ឃុំដែលមានជំងឺឆ្លង ត្រូវដាក់បំបែកចេញពីជនជាប់ឃុំដទៃទៀត ។

**មាត្រា ២៧.-**

ក្រោយពីទទួលយកជនជាប់ឃុំចូលក្នុងពន្ធនាគារ ប្រធានពន្ធនាគារត្រូវចាត់ឲ្យមានការវាយតម្លៃ កំណត់អំពីចំណាត់ថ្នាក់សន្តិសុខ ដើម្បីធានាសន្តិសុខ សុវត្ថិភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងពន្ធនាគារ ។

## ជំពូកទី ៥
## សិទ្ធិ និងលក្ខខណ្ឌរស់នៅរបស់ជនជាប់ឃុំ

**មាត្រា ២៨.-**

ជនជាប់ឃុំ មានសិទ្ធិប្ដឹងតវ៉ាទៅប្រធានពន្ធនាគារ ឬទៅអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ ឬព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ពីអំពើរំលោភរបស់ជនជាប់ឃុំដូចគ្នា ឬអំពើរំលោភរបស់មន្ត្រីពន្ធនាគារ ។

ពាក្យបណ្ដឹងតវ៉ារបស់ជនជាប់ឃុំ ត្រូវធ្វើឡើងតាមរយៈមន្ត្រីពន្ធនាគារ ឬអ្នកសួរសុខទុក្ខផ្លូវការ ឬអ្នកសួរសុខទុក្ខសាច់ញាតិ ឬមេធាវីរបស់ជនជាប់ឃុំ ឬតំណាងអង្គការអយ្យការ ។

រាល់បណ្ដឹងតវ៉ាត្រូវតែបានដោះស្រាយនិងឆ្លើយតប ក្នុងរយៈពេលសមស្រប ។

គ្មានជនជាប់ឃុំណាម្នាក់ត្រូវបានដាក់ទណ្ឌកម្ម ឬត្រូវបានរើសអើងដោយសារតែបានដាក់ពាក្យបណ្ដឹង ឬការដាក់ពាក្យស្នើសុំនោះឡើយ ។

**មាត្រា ២៩.-**

ជនជាប់ឃុំមានសិទ្ធិប្រតិបត្តិសាសនាតាមជំនឿរបស់ខ្លួន និងមិនត្រូវបានបង្ខិតបង្ខំឲ្យប្រតិបត្តិសាសនាណាមួយឡើយ ។



**មាត្រា ៣០.-**

ជនជាប់ឃុំដែលមិនតម្រូវឲ្យធ្វើការនៅខាងក្រៅបាន ដោយមូលហេតុខាងផ្លូវច្បាប់ ឬមូលហេតុខាងសន្តិសុខ អាចអនុញ្ញាតឲ្យធ្វើលំហាត់ប្រាណប្រចាំថ្ងៃបាន ។

**មាត្រា ៣១.-**

ជនជាប់ឃុំជាជនបរទេស មានសិទ្ធិទាក់ទងជាមួយស្ថានទូត ឬស្ថានកុងស៊ុល ឬស្ថានតំណាងរបស់ខ្លួន ។

រាល់ទំនាក់ទំនងរវាងជនជាប់ឃុំនិងមេធាវី ត្រូវបានធ្វើឡើងដោយសម្ងាត់ ។

**មាត្រា ៣២.-**

ជនជាប់ឃុំ មានសិទ្ធិទទួល និង ផ្ញើលិខិតឆ្លងឆ្លើយ ។ លិខិតឆ្លងឆ្លើយរបស់ជនជាប់ឃុំត្រូវបើកនៅចំពោះមុខមន្ត្រីពន្ធនាគារ ដែលត្រូវបានប្រគល់សិទ្ធិ លើកលែងតែលិខិតរបស់មេធាវី ។

លិខិតឆ្លងឆ្លើយរបស់ជនជាប់ឃុំ ត្រូវបានដកហូត ប្រសិនបើមានការពាក់ព័ន្ធដល់សន្តិសុខសុវត្ថិភាព សណ្តាប់ធ្នាប់ទូទៅ ទាំងក្នុង និងក្រៅពន្ធនាគារ ។

**មាត្រា ៣៣.-**

ជនជាប់ឃុំ ត្រូវបានទទួលរបបជីវភាព ដែលកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៣៤.-**

ការផ្តល់អាហារដល់ជនជាប់ឃុំ ត្រូវយកចិត្តទុកដាក់គិតគូរអំពីអាហារតម ស្របតាមតម្រូវការខាងសុខភាព ដែលបញ្ជាក់ពីមន្ត្រីពេទ្យពន្ធនាគារ ឬស្របតាមតម្រូវការខាងសាសនារបស់ពួកគេ ។

ជនជាប់ឃុំ អាចទទួល ឬទិញអាហារដោយថវិកាផ្ទាល់ខ្លួនពីប្រភពខាងក្រៅបាន តែអាហារទាំងនេះត្រូវបានត្រួតពិនិត្យពីមន្ត្រីពន្ធនាគារ ។

**មាត្រា ៣៥.-**

ជនជាប់ឃុំ អាចត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ថវិកាផ្ទាល់ខ្លួន ដើម្បីទិញសម្ភារៈប្រើប្រាស់ ឬទទួលសម្ភារៈប្រើប្រាស់ពីគ្រួសារ ញាតិមិត្ត ឬពីប្រភពផ្សេងទៀត ប្រសិនបើមានការយល់ព្រម និងការត្រួតពិនិត្យពីប្រធានពន្ធនាគារ ។

ជនជាប់ឃុំ មិនត្រូវបានអនុញ្ញាតឲ្យទិញ ឬផ្តល់ ឬឲ្យខ្ចី ឬលក់សម្ភារៈទៅឲ្យជនជាប់ឃុំផ្សេងទៀតបានឡើយ ។

ROYAUME DU CAMBODGE
ROYAL

**មាត្រា ៣៦.-**

ថវិកា ឬទ្រព្យសម្បត្តិមានតម្លៃជាប់ខ្លួនរបស់ជនជាប់ឃុំ ត្រូវបានដកហូត កត់ត្រាត្រឹមត្រូវ ក្នុងសៀវភៅបញ្ជី និងរក្សាទុកក្នុងគណនីពន្ធនាគារ ឬត្រូវប្រគល់ជូនក្រុមគ្រួសារ ញាតិមិត្តរក្សាទុក ប្រសិនបើមានការយល់ព្រមពីជនជាប់ឃុំ ដោយត្រូវមានហត្ថលេខា ឬស្នាមម្រាមដៃរបស់ជនជាប់ឃុំ ។

ក្នុងករណីចាំបាច់និងមានការយល់ព្រមពីប្រធានពន្ធនាគារ ជនជាប់ឃុំអាចប្រើប្រាស់ថវិកាបញ្ញើរបស់ខ្លួនបាន ។

ថវិកា និងទ្រព្យសម្បត្តិមានតម្លៃរបស់ជនជាប់ឃុំដែលពន្ធនាគារទទួលខុសត្រូវរក្សាទុក ត្រូវប្រគល់ជូនជនជាប់ឃុំវិញ នៅពេលដោះលែង ។

ជនជាប់ឃុំអាចរក្សាទុកឱសថជាកម្មសិទ្ធិផ្ទាល់ខ្លួនបាន ក្នុងករណីមានការយល់ព្រមពីមន្ត្រីពេទ្យពន្ធនាគារ ។

**មាត្រា ៣៧.-**

ជនជាប់ឃុំត្រូវបានអនុញ្ញាតឲ្យទទួលដំណឹង ឬព័ត៌មានសំខាន់ៗ តាមរយៈកម្មវិធីផ្សព្វផ្សាយរបស់វិទ្យុ ទូរទស្សន៍ ទស្សនាវដ្តី សារព័ត៌មាន និងទំនាក់ទំនងទូរសព្ទជាមួយក្រុមគ្រួសារ ដែលរៀបចំឡើងដោយពន្ធនាគារ ។

ជនជាប់ឃុំ អាចអនុញ្ញាតឲ្យចូលសិក្សាស្រាវជ្រាវនៅក្នុងបណ្ណាល័យពន្ធនាគារ ឬអាចអនុញ្ញាតឲ្យខ្ចីសៀវភៅយកទៅស្រាវជ្រាវនៅក្នុងបន្ទប់ឃុំឃាំងដើម្បីបង្កើនចំណេះដឹង ។

ពន្ធនាគារត្រូវជូនដំណឹងទាក់ទងនឹងជំងឺ ឬមរណភាពរបស់ជនជាប់ឃុំ ឬរបស់គ្រួសារជនជាប់ឃុំឲ្យបានដឹងទៅវិញទៅមក ។

**មាត្រា ៣៨.-**

ជនជាប់ឃុំដែលមានជំងឺត្រូវបានទទួលសេវាថែទាំសុខភាពប្រចាំថ្ងៃដោយមន្ត្រីពេទ្យពន្ធនាគារ ។

ជនជាប់ឃុំមានជំងឺធ្ងន់ ហើយតម្រូវឲ្យមានការព្យាបាលនៅមន្ទីរពេទ្យខាងក្រៅតាមសំណើរបស់មន្ត្រីពេទ្យពន្ធនាគារ ត្រូវមានការអនុញ្ញាតពីព្រះរាជអាជ្ញាក្នុងដែនសមត្ថកិច្ច ។ ក្នុងករណីជនជាប់ឃុំមានជំងឺធ្ងន់ ដែលតម្រូវឲ្យមានការសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យខាងក្រៅ ប្រធានពន្ធនាគារត្រូវបញ្ជូនអ្នកជំងឺទៅមន្ទីរពេទ្យជាបន្ទាន់តាមសំណើរបស់មន្ត្រីពេទ្យពន្ធនាគារ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ព្រះរាជអាជ្ញាក្នុងដែនសមត្ថកិច្ច និងដល់គ្រួសារសាច់ញាតិ ឬមិត្តភក្តិជិតស្និទ្ធបំផុត តាមសំណើរបស់ជនជាប់ឃុំ ។ បន្ទាប់ពីការព្យាបាលបានធូរស្រាល តាមការបញ្ជាក់ពីមន្ទីរពេទ្យដែលបានទទួលព្យាបាល ត្រូវបញ្ជូនជនជាប់ឃុំមកពន្ធនាគារវិញ ។

ជនជាប់ឃុំដែលមានជំងឺផ្លូវចិត្ត ឬពិការកាយសម្បទា ឬស្ថិតក្រោមឥទ្ធិពលគ្រឿងញៀនត្រូវបានទទួលសេវាថែទាំសុខភាពដោយឡែក ។

**មាត្រា ៣៩.-**

អគារឃុំឃាំងជនជាប់ឃុំជាស្ត្រីត្រូវមានមន្ត្រីពន្ធនាគារជាស្ត្រី ប្រចាំការជាអចិន្ត្រៃយ៍ ។

មិនអនុញ្ញាតឲ្យមន្ត្រីពន្ធនាគារជាបុរសចូលក្នុងតំបន់ជនជាប់ឃុំជាស្ត្រី ដោយគ្មានការអមដំណើរពីមន្ត្រីពន្ធនាគារជាស្ត្រីឡើយ លើកលែងតែក្នុងករណីមានឧប្បត្តិហេតុសង្គ្រោះបន្ទាន់ ឬក្នុងហេតុផលសន្តិសុខ សុវត្ថិភាពពន្ធនាគារ ។

**មាត្រា ៤០.-**

ជនជាប់ឃុំជាស្ត្រីត្រូវបានផ្តល់សេវាគាំពារមាតា និងទារក នៅមុននិងក្រោយពេលសម្រាលកូន ។

ជនជាប់ឃុំជាស្ត្រីដែលមានផ្ទៃពោះ ត្រូវបានអនុញ្ញាតឲ្យសម្រាលកូននៅមន្ទីរពេទ្យខាងក្រៅ ។

ក្នុងករណីមានជនជាប់ឃុំជាស្ត្រីសម្រាលកូនក្នុងពន្ធនាគារ មិនត្រូវចុះសំបុត្រកំណើតថាទារកនោះកើតនៅក្នុងពន្ធនាគារទេ ។

**មាត្រា ៤១.-**

កូនតាមម្តាយ ត្រូវបានអនុញ្ញាតឲ្យស្នាក់នៅក្នុងពន្ធនាគារជាមួយម្តាយត្រឹមអាយុក្រោម ៣ (បី) ឆ្នាំ និងត្រូវបានផ្តល់ម្ហូបអាហារ សម្លៀកបំពាក់ និងសេវាថែទាំសុខភាព ។

កូនតាមម្តាយដែលមានអាយុចាប់ពី ៣ (បី) ឆ្នាំ ឡើង បើគ្មានអាណាព្យាបាលទទួលខុសត្រូវការចិញ្ចឹមបីបាច់ថែរក្សាបន្តនៅខាងក្រៅជាបន្ទុករបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ។

## ជំពូកទី ៦
## ការគ្រប់គ្រងពន្ធនាគារ

**មាត្រា ៤២.-**

គោលដៅជាសារវន្តនៃការគ្រប់គ្រងជនជាប់ឃុំ គឺការអប់រំកែប្រែនិងការស្តារនីតិសម្បទារបស់ជនជាប់ឃុំ ដែលជាស្នូលនៃក្របខ័ណ្ឌគោលនយោបាយកំណែទម្រង់ពន្ធនាគារ ។

ការដាក់វិន័យទៅលើជនជាប់ឃុំ ត្រូវធ្វើឡើងក្នុងកម្រិតអប្បបរមាដែលចាំបាច់ ដើម្បីធានាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ប៉ុណ្ណោះ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

មាត្រា ៤៣.-

ប្រធានពន្ធនាគារត្រូវទទួលខុសត្រូវដោយផ្ទាល់ ក្នុងការគ្រប់គ្រងពន្ធនាគារឲ្យបានត្រឹមត្រូវតាមនីតិវិធី និងបទបញ្ជាផ្ទៃក្នុងដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ៤៤.-

មន្ត្រីពន្ធនាគារអាចធ្វើការឆែកឆេរជនជាប់ឃុំនិងកន្លែងនានាក្នុងពន្ធនាគារ ដើម្បីធានាសន្តិសុខ និងសុវត្ថិភាពរបស់ពន្ធនាគារ ។

ជនជាប់ឃុំដែលបដិសេធមិនឲ្យមន្ត្រីពន្ធនាគារឆែកឆេរ ត្រូវចាត់ទុកជាការល្មើសនឹងបទបញ្ជាផ្ទៃក្នុងពន្ធនាគារ ។

មាត្រា ៤៥.-

ដើម្បីធានាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ពន្ធនាគារ មន្ត្រីពន្ធនាគារ និងអ្នកមកសួរសុខទុក្ខជនជាប់ឃុំ ត្រូវបានត្រួតពិនិត្យមុនពេលចូលទៅក្នុងពន្ធនាគារ ។

មាត្រា ៤៦.-

ការរក្សាទុក ឬការប្រើប្រាស់គ្រឿងស្រវឹងក្នុងពន្ធនាគារត្រូវហាមឃាត់ ។

ជនជាប់ឃុំមិនត្រូវបានអនុញ្ញាតឲ្យរក្សាទុក ឬប្រើប្រាស់វត្ថុទាំងឡាយណាដែលអាចគំរាមកំហែងដល់សន្តិសុខពន្ធនាគារឡើយ ។

ប្រភេទវត្ថុហាមឃាត់ត្រូវបានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ ។

មាត្រា ៤៧.-

ប្រធានពន្ធនាគារអាចអនុញ្ញាតឲ្យមន្ត្រីពន្ធនាគារដែលបានបណ្តុះបណ្តាលហ្វឹកហាត់ត្រឹមត្រូវឲ្យប្រើប្រាស់អាវុធ និងឧបករណ៍បច្ចេកទេសដើម្បីធានាសន្តិសុខ សុវត្ថិភាពក្នុងកិច្ចប្រតិបត្តិការរបស់ពន្ធនាគារ ។

ប្រធានពន្ធនាគារត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងអាវុធ និងឧបករណ៍បច្ចេកទេសឲ្យមានសុវត្ថិភាព ។

មាត្រា ៤៨.-

ប្រធានពន្ធនាគារត្រូវរាយការណ៍ជាបន្ទាន់ទៅព្រះរាជអាជ្ញា គណៈអភិបាលរាជធានី ខេត្ត និងអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អំពីព័ត៌មាន ឬឧប្បត្តិហេតុទាំងឡាយណាដែលគំរាមកំហែង ឬដែលអាចគំរាមកំហែងដល់សន្តិសុខ សុវត្ថិភាពពន្ធនាគារ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

**មាត្រា ៤៩.-**

ប្រធានពន្ធនាគារអាចប្រើប្រាស់កម្លាំងប្រតិបត្តិការដើម្បីរក្សាសន្តិសុខ សុវត្ថិភាពពន្ធនាគារ ។ ក្នុងករណីធ្ងន់ធ្ងរ ប្រធានពន្ធនាគារត្រូវរាយការណ៍សុំកម្លាំងអន្តរាគមន៍ទៅគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ។

**មាត្រា ៥០.-**

ការប្រើប្រាស់ខ្នោះដៃដើម្បីដាក់ទណ្ឌកម្មជនជាប់ឃុំត្រូវហាមឃាត់ លើកលែងតែប្រើប្រាស់ក្នុងស្ថានភាពដូចខាងក្រោម :

- ពេលមានចលាចលក្នុងពន្ធនាគារ
- ពេលផ្ទេរ ឬបញ្ជូន ឬនាំខ្លួនចេញពីពន្ធនាគារ
- ពេលមានហេតុផលខាងពេទ្យ
- ដើម្បីការពារជនជាប់ឃុំកុំឲ្យបង្ករបួសស្នាមដោយខ្លួនឯង ឬបង្ករបួសស្នាមដល់អ្នកដទៃ ឬបង្កការខូចខាតទ្រព្យសម្បត្តិអ្នកដទៃ ។

**មាត្រា ៥១.-**

ជនជាប់ឃុំត្រូវគោរព និងអនុវត្តតាមបទបញ្ជាផ្ទៃក្នុងពន្ធនាគារ និងការណែនាំរបស់មន្ត្រីពន្ធនាគារ ។

**មាត្រា ៥២.-**

ជនជាប់ឃុំដែលបានប្រព្រឹត្តល្មើសនឹងបទបញ្ជាផ្ទៃក្នុង ដែលធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់ពន្ធនាគារ មិនត្រូវលើកយកមកពិនិត្យលក្ខណវិនិច្ឆ័យសម្រាប់ការបន្ធូរបន្ថយទោស និងលើកលែងទោសក្នុងរយៈពេលមួយឆ្នាំ ។ ក្នុងករណីមិនរាងចាល ត្រូវឃុំខ្លួននៅក្នុងបន្ទប់ដោយឡែក ។

ប្រធានពន្ធនាគារដែលចេញបទបញ្ជាឲ្យឃុំខ្លួននៅក្នុងបន្ទប់ដោយឡែក ត្រូវបញ្ជាក់ពីមូលហេតុ និងត្រូវរាយការណ៍ភ្លាមមកអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ ។

បទបញ្ជាឃុំខ្លួនដោយឡែកអាចមានរយៈពេលពី ១៤ (ដប់បួន) ថ្ងៃ ដល់ ២០ (ម្ភៃ) ថ្ងៃ ។ ក្នុងករណីមិនរាងចាល បទបញ្ជានេះអាចត្រូវបានចេញបន្តទៀត ។

ក្នុងរយៈពេលនៃការរងទណ្ឌកម្មដោយត្រូវឃុំខ្លួនក្នុងបន្ទប់ដោយឡែក ជនជាប់ឃុំមិនត្រូវបានអនុញ្ញាត :

- ឲ្យជួបគ្រួសារសាច់ញាតិដែលមកសួរសុខទុក្ខ
- ចូលរួមសកម្មភាពផ្សេងៗក្នុងពន្ធនាគារ ។

**មាត្រា ៥៣.-**

ការធ្វើទារុណកម្មមកលើរាងកាយគ្រប់រូបភាព ការឃុំខ្លួនក្នុងបន្ទប់ងងឹត ការកាត់បន្ថយម្ហូបអាហារ ការដាក់ទណ្ឌកម្មជាសមូហភាពដល់ជនជាប់ឃុំ និងការប្រើប្រាស់ជនជាប់ឃុំឲ្យធ្វើទារុណកម្មជនជាប់ឃុំដូចគ្នា ត្រូវហាមឃាត់ ។

**មាត្រា ៥៤.-**

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញា ប្រធានសការស៊ើបសួរ និងចៅក្រមស៊ើបសួរ ត្រូវធ្វើអធិការកិច្ចពន្ធនាគារស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។ បែបបទ នីតិវិធី និងការប្រព្រឹត្តទៅនៃការធ្វើអធិការកិច្ច ត្រូវកំណត់ដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

យន្តការបង្ការថ្នាក់ជាតិ ត្រូវបានអនុញ្ញាតឲ្យធ្វើទស្សនកិច្ចតាមពន្ធនាគារនានា គ្រប់ពេលវេលា និងធ្វើសម្ភាសន៍ជាសម្ងាត់ជាមួយជនជាប់ឃុំ ដើម្បីត្រួតពិនិត្យមើលលក្ខខណ្ឌនៃការឃុំខ្លួន និងការប្រព្រឹត្តចំពោះជនជាប់ឃុំ ផ្តល់អនុសាសន៍កែលម្អ សំដៅបង្ការទារុណកម្ម អំពើឃោរឃៅអមនុស្សធម៌ ឬ បន្ថាបបន្ថោក ។

**មាត្រា ៥៥.-**

ជនជាប់ឃុំត្រូវបានអនុញ្ញាតឲ្យគ្រួសារ ឬញាតិមិត្តមកសួរសុខទុក្ខតាមការកំណត់ លើកលែងតែមានការហាមឃាត់ពីអាជ្ញាធរតុលាការ ។

ប្រធានពន្ធនាគារ ត្រូវបិទផ្សាយជាសាធារណៈនូវពេលវេលា និងរយៈពេលសួរសុខទុក្ខ ដែលមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ ។

**មាត្រា ៥៦.-**

មន្ត្រីស្ថានទូត ឬស្ថានកុងស៊ុល ឬស្ថានតំណាងដែលមានបំណងចូលជួបសួរសុខទុក្ខជន ជាប់ឃុំជាពលរដ្ឋរបស់ខ្លួន ឬពលរដ្ឋដែលខ្លួនធ្វើជាតំណាង ត្រូវជូនដំណឹងជាមុនទៅអគ្គនាយកដ្ឋានពន្ធនាគារ ។

គ្រួសារ ឬញាតិមិត្តជាជនបរទេសដែលមានបំណងចូលជួបសួរសុខទុក្ខជនជាប់ឃុំ ត្រូវស្នើមកអគ្គនាយកដ្ឋានពន្ធនាគារ តាមរយៈស្ថានទូត ឬស្ថានកុងស៊ុល ឬស្ថានតំណាងរបស់ខ្លួន ។

**មាត្រា ៥៧.-**

អ្នកសួរសុខទុក្ខជនជាប់ឃុំ មិនត្រូវយកវត្ថុ ឬសម្ភារៈហាមឃាត់ ដូចមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងពន្ធនាគារចូលពន្ធនាគារឡើយ ។

**មាត្រា ៥៨.-**

អ្នកសួរសុខទុក្ខជនជាប់ឃុំ អាចត្រូវបានហាមឃាត់ ឬបញ្ឈប់ ឬឲ្យចេញជាបណ្ដោះអាសន្នពីពន្ធនាគារ ក្នុងករណីដែលមានឧប្បត្តិហេតុចៃដន្យកើតឡើង ។

ក្នុងករណីអ្នកសួរសុខទុក្ខជនជាប់ឃុំធ្វើសកម្មភាពនាំឲ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់ សន្តិសុខ សុវត្ថិភាពពន្ធនាគារ ត្រូវឃាត់ខ្លួននិងចាត់វិធានការតាមផ្លូវច្បាប់ ។

**មាត្រា ៥៩.-**

បើអ្នកសួរសុខទុក្ខផ្លូវការមានបំណងធ្វើទស្សនកិច្ចពន្ធនាគារណាមួយ ត្រូវផ្ដល់ដំណឹងជាមុនទៅអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អំពីគោលបំណង និងសំណូមពរនៃទស្សនកិច្ចនោះ ។

លទ្ធផលនៃទស្សនកិច្ចខាងលើ ត្រូវផ្ដល់ព័ត៌មានដោយផ្ទាល់មាត់ ឬដោយលាយលក្ខណ៍អក្សរទៅប្រធានពន្ធនាគារ និងអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ ។ ព័ត៌មាននោះត្រូវចាត់ទុកជាព័ត៌មានសម្ងាត់ លើកលែងតែមានការឯកភាពពីក្រសួងមហាផ្ទៃ ។

**មាត្រា ៦០.-**

ជនជាប់ឃុំអាចត្រូវបានឲ្យចាកចេញជាបណ្ដោះអាសន្នពីពន្ធនាគារ តាមដីកាបង្គាប់របស់តុលាការ ដើម្បីឡើងសវនាការ ឬធ្វើការស៊ើបអង្កេត ឬចង្អុលបង្ហាញកស្តុតាង ។

**មាត្រា ៦១.-**

ប្រធានពន្ធនាគារត្រូវទទួលខុសត្រូវអំពីសន្តិសុខ សុវត្ថិភាពចំពោះការនាំខ្លួន ឬការបញ្ជូនជនជាប់ឃុំទៅកាន់តុលាការ ឬទៅកាន់មន្ទីរពេទ្យខាងក្រៅ ។

**មាត្រា ៦២.-**

ការផ្ទេរបញ្ជូនទណ្ឌិតពីពន្ធនាគារមួយទៅពន្ធនាគារមួយ ត្រូវមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជូនដំណឹងភ្លាម ឬយ៉ាងយូរ ៣ (បី) ថ្ងៃ ដោយប្រធានពន្ធនាគារទៅព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដីបញ្ជូន និងសមត្ថកិច្ចខាងដែនដីទទួល ។

ការផ្ទេរជនជាប់ឃុំក្រៅពីទណ្ឌិត ពីពន្ធនាគារមួយទៅពន្ធនាគារមួយ ត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាមានសមត្ថកិច្ចខាងដែនដីបញ្ជូន និងព្រះរាជអាជ្ញាមានសមត្ថកិច្ចខាងដែនដីទទួល ឬអគ្គព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចកំពុងចាត់ការរឿងក្តី ។

ក្នុងករណីចាំបាច់ អគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាអាចចេញដីកាបង្គាប់ឲ្យផ្ទេរជនជាប់ឃុំក្រៅពីទណ្ឌិត ពីពន្ធនាគារមួយទៅពន្ធនាគារមួយ តាមតម្រូវការនៃនីតិវិធី ។ ដីកាបង្គាប់នេះត្រូវចម្លងជូនទៅក្រសួងមហាផ្ទៃ ។

ការផ្ទេរបញ្ជូនជនជាប់ឃុំពីពន្ធនាគារមួយទៅពន្ធនាគារមួយ ត្រូវភ្ជាប់ទៅជាមួយនូវទ្រព្យសម្បត្តិ សំណុំរឿង និងឯកសារសុខភាពរបស់ជនជាប់ឃុំ ។

**មាត្រា ៦៣.-**

ក្នុងករណីជនជាប់ឃុំលួចរត់គេចខ្លួន ប្រធានពន្ធនាគារ និងអាជ្ញាធរមានសមត្ថកិច្ចត្រូវជូនដំណឹងជាបន្ទាន់ទៅគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ទៅអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ និងទៅព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដី ដើម្បីស្វែងរកចាប់ខ្លួនជនជាប់ឃុំមកវិញ ដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ៦៤.-**

ក្នុងករណីជនជាប់ឃុំទទួលមរណភាពក្នុងពន្ធនាគារ ត្រូវចាត់ទុកជាការសង្ស័យ ។ មន្ត្រីពន្ធនាគារត្រូវការពារកន្លែងសាកសព និងរក្សាទុកជនជាប់ឃុំដែលអាចធ្វើសាក្សី ។ ប្រធានពន្ធនាគារត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាដើម្បីចាត់វិធានការស៊ើបអង្កេត ។

ប្រសិនបើជនជាប់ឃុំស្លាប់នៅក្នុងមន្ទីរពេទ្យ ប្រធានពន្ធនាគារត្រូវជូនដំណឹងទៅព្រះរាជអាជ្ញា បើមានការសង្ស័យ ព្រះរាជអាជ្ញាត្រូវចាត់ឲ្យនគរបាលបច្ចេកទេសវិទ្យាសាស្ត្រធ្វើការពិនិត្យសាកសព ។

**មាត្រា ៦៥.-**

ប្រធានពន្ធនាគារត្រូវជូនដំណឹងភ្លាមទៅគ្រួសារសព ឬស្ថានទូត ឬស្ថានកុងស៊ុល ឬស្ថានតំណាងនៃសព ដើម្បីរៀបចំទុកដាក់សព ។

ក្នុងករណីគ្មានក្រុមគ្រួសារ ឬសាច់ញាតិ ប្រធានពន្ធនាគារត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីស្ថានភាពនៃសព ជូនព្រះរាជអាជ្ញា អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ និងមន្ត្រីអត្រានុកូលដ្ឋាននៃលំនៅឋានរបស់សព ។ ការចំណាយលើការរៀបចំទុកដាក់សពជាបន្ទុករបស់រដ្ឋដែលកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៧
## ការអប់រំ កែប្រែ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និង ការស្តារនីតិសម្បទាទណ្ឌិត

**មាត្រា ៦៦.-**

ទណ្ឌិតត្រូវបានចាត់តាំងឲ្យចូលរួមក្នុងកម្មវិធីអប់រំច្បាប់និងសីលធម៌សង្គម ដែលបានរៀបចំឡើងក្នុងពន្ធនាគារ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

**មាត្រា ៦៧.-**

ទណ្ឌិតត្រូវបានផ្តល់មធ្យោបាយដើម្បីចូលរួមកម្មវិធីសិក្សាចំណេះទូទៅ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងពន្ធនាគារ ។

កម្មវិធីសិក្សាអប់រំ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងពន្ធនាគារ ត្រូវបានធ្វើសមាហរណកម្មជាមួយប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ជាតិ ។

ទណ្ឌិតជាអនីតិជនត្រូវបានយកចិត្តទុកដាក់ដោយឡែក ទាក់ទងនឹងតម្រូវការសិក្សាអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការស្តារនីតិសម្បទា និងសមាហរណកម្មដោយសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងអប់រំ យុវជន និងកីឡា ។

ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវសហការជាមួយក្រសួងមហាផ្ទៃរៀបចំកម្មវិធី និងដំណើរការអនុវត្តកម្មវិធីសិក្សាអប់រំ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈដល់ទណ្ឌិតនៅក្នុងពន្ធនាគារ ។

**មាត្រា ៦៨.-**

ទណ្ឌិតដែលមានកម្រិតសន្តិសុខទាប ហើយត្រូវបានវាយតម្លៃថា មានសមត្ថភាពកាយសម្បទា ត្រូវបានចាត់តាំងឲ្យធ្វើការងារពលកម្មប្រចាំថ្ងៃនៅក្នុងពន្ធនាគារ ឬការងារជាអត្ថប្រយោជន៍សម្រាប់សហគមន៍ និងផលប្រយោជន៍សាធារណៈ ឬចាត់តាំងឲ្យចូលរួមក្នុងកម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ ។

**មាត្រា ៦៩.-**

កម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ ត្រូវបានរៀបចំឡើងនៅតាមពន្ធនាគារនីមួយៗ ដើម្បីផ្តល់ឱកាសឲ្យទណ្ឌិតមានសមត្ថភាពប្រកបមុខរបរចិញ្ចឹមជីវិត នៅពេលធ្វើសមាហរណកម្មចូលក្នុងសហគមន៍វិញ ។

**មាត្រា ៧០.-**

ទណ្ឌិតដែលចូលរួមក្នុងកម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ ត្រូវបានបំពាក់សម្ភារៈ និងឧបករណ៍ការពារសុវត្ថិភាពការងារ ក្នុងពេលបំពេញការងារ ។

**មាត្រា ៧១.-**

បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ មានសិទ្ធិចុះកិច្ចសន្យាជាមួយរូបវន្តបុគ្គល ឬនីតិបុគ្គល ឬអង្គការជាតិ អន្តរជាតិដើម្បីបង្កើតការងារ

សម្រាប់កម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ និងមានសិទ្ធិចុះកិច្ចសន្យាលក់ផលិតផលឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ ។

**មាត្រា ៧២.-**

ការគ្រប់គ្រង និងការប្រើប្រាស់ប្រាក់ចំណូលដែលបានមកពីកម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

នីតិវិធីគ្រប់គ្រងកម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៧៣.-**

មុនផុតរយៈពេលទទួលរងទោស ៦ (ប្រាំមួយ) ខែ ទណ្ឌិតត្រូវបានទទួលកម្មវិធីសមាហរណកម្មដែលរៀបចំដោយពន្ធនាគារ ដើម្បីឲ្យគេក្លាយជាពលរដ្ឋអាចរស់នៅក្នុងសង្គមជាតិនិងសហគមន៍មូលដ្ឋានបានល្អ ។

## ជំពូកទី ៨
## ការបន្ធូរបន្ថយទោស ការលើកលែងទោស
## និង ការដោះលែងទណ្ឌិត

**មាត្រា ៧៤.-**

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវបង្កើតគណៈកម្មការមួយដើម្បីពិនិត្យ និងវាយតម្លៃអំពីកម្រិតកែប្រែរបស់ទណ្ឌិត ក្នុងរយៈពេលជាប់ឃុំនៅក្នុងពន្ធនាគារដែលស្ថិតក្នុងការគ្រប់គ្រងរបស់ខ្លួន ។ គណៈកម្មការនេះ ត្រូវធ្វើបញ្ជីទណ្ឌិតដែលមានលក្ខណសម្បត្តិអាចស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស បញ្ជូនទៅគណៈកម្មការថ្នាក់ជាតិ តាមរយៈអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ យ៉ាងយឺតបំផុត ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃកំណត់នៃពិធីបុណ្យនីមួយៗ ។

គណៈកម្មការនេះ មានសមាសភាពដូចខាងក្រោម :

- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ជាប្រធាន
- តំណាងអង្គការអយ្យការអមសាលាដំបូងរាជធានី ខេត្ត ជាអនុប្រធាន
- ប្រធានក្រុមការងារប្រឡងប្រណាំងនៃពន្ធនាគាររាជធានី ខេត្ត ជាអនុប្រធានអចិន្ត្រៃយ៍
- អនុប្រធានពន្ធនាគាររាជធានី ខេត្តទទួលបន្ទុកអប់រំកែប្រែ ជាសមាជិក
- អនុប្រធានពន្ធនាគាររាជធានី ខេត្តទទួលបន្ទុកប្រតិបត្តិ ជាសមាជិក

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

គណៈកម្មការនេះអាចមានសមាសភាពមួយចំនួនទៀត តាមការចាំបាច់ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការនេះ ត្រូវកំណត់ដោយដីការបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវបង្កើតគណៈកម្មការមួយ ដើម្បីពិនិត្យ និងវាយតម្លៃអំពីកម្រិតកែប្រែរបស់ទណ្ឌិត ក្នុងរយៈពេលជាប់ឃុំនៅតាមមណ្ឌលអប់រំកែប្រែដែលស្ថិតក្នុងការគ្រប់គ្រងរបស់ខ្លួន ។ គណៈកម្មការនេះត្រូវធ្វើបញ្ជីឈ្មោះទណ្ឌិតដែលមានលក្ខណសម្បត្តិអាចស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស បញ្ជូនទៅគណៈកម្មការថ្នាក់ជាតិ យ៉ាងយឺតបំផុត ៣០ ( សាមសិប ) ថ្ងៃ មុនថ្ងៃកំណត់នៃពិធីបុណ្យនីមួយៗ ។

គណៈកម្មការនេះ មានសមាសភាពដូចខាងក្រោម :

- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកពន្ធនាគារ ជាប្រធាន
- តំណាងអង្គការអយ្យការអមសាលាដំបូងដែលមានសមត្ថកិច្ចលើមណ្ឌលអប់រំ កែប្រែសាមី ជាអនុប្រធាន
- ប្រធានក្រុមប្រឹក្សានីតិកម្មនៃក្រសួងមហាផ្ទៃ ជាអនុប្រធាន
- អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ ជាអនុប្រធានអចិន្ត្រៃយ៍
- ប្រធាននាយកដ្ឋានអប់រំកែប្រែ ជាសមាជិក
- ប្រធាននាយកដ្ឋានប្រតិបត្តិ ជាសមាជិក
- ប្រធានក្រុមការងារប្រឡងប្រណាំងនៃមណ្ឌលអប់រំកែប្រែនីមួយៗ ជាសមាជិក

គណៈកម្មការនេះអាចមានសមាសភាពមួយចំនួនទៀត តាមការចាំបាច់ ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៧៥.-**

រាជរដ្ឋាភិបាលត្រូវបង្កើតគណៈកម្មការថ្នាក់ជាតិមួយ ដើម្បីពិនិត្យ និងវាយតម្លៃបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស ដែលបានផ្ញើមកពីគណៈកម្មការរាជធានី ខេត្ត និងពីគណៈកម្មការក្រសួងមហាផ្ទៃ ។ ក្រោយពីបានពិនិត្យវាយតម្លៃរួចហើយ គណៈកម្មការនេះត្រូវធ្វើបែបបទជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ដើម្បីដាក់សំណើថ្វាយព្រះមហាក្សត្រសុំបន្ធូរបន្ថយទោស និងលើកលែងទោសឲ្យទណ្ឌិត យ៉ាងយឺតបំផុត ១០ (ដប់) ថ្ងៃ មុនថ្ងៃកំណត់នៃពិធីបុណ្យនីមួយៗ ។

គណៈកម្មការនេះមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | ជាប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃទទួលបន្ទុកពន្ធនាគារ | ជាអនុប្រធានអចិន្ត្រៃយ៍ |
| - អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ | ជាអនុប្រធាន |
| - តំណាងក្រុមប្រឹក្សាអ្នកច្បាប់ ចំនួន ០១ រូប | ជាសមាជិក |
| - ប្រធានក្រុមប្រឹក្សានីតិកម្មនៃក្រសួងមហាផ្ទៃ | ជាសមាជិក |
| - តំណាងក្រសួងយុត្តិធម៌ ចំនួន០១ រូប | ជាសមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ | ជាសមាជិក |
| - ប្រធាននាយកដ្ឋានជំនាញនៃអគ្គនាយកដ្ឋានពន្ធនាគារ ចំនួន ០២ រូប | ជាសមាជិក |

គណៈកម្មការនេះអាចមានសមាសភាពមួយចំនួនទៀត តាមការចាំបាច់ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការនេះ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៧៦.-**

លក្ខណសម្បត្តិ និងចំណាត់ថ្នាក់ប្រឡងប្រណាំង សំដៅជំរុញលើកទឹកចិត្តដល់ទណ្ឌិតម្នាក់ៗឲ្យខិតខំកសាងកែប្រែគំនិតមារយាទ ក្លាយជាពលរដ្ឋល្អដើម្បីធ្វើសមាហរណកម្មបញ្ចូលទៅក្នុងសង្គមជាតិវិញបាននៅពេលអនាគត ត្រូវកំណត់ដោយសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ទណ្ឌិតដែលយល់ឃើញថា ខ្លួនបានបំពេញលក្ខខណ្ឌក្នុងការស្នើសុំបន្ធូរបន្ថយទោស ឬលើកលែងទោស ប៉ុន្តែមិនត្រូវបានប្រធានពន្ធនាគារធ្វើការស្នើសុំឲ្យខ្លួន សាមីខ្លួនមានសិទ្ធិប្តឹងតវ៉ាទៅ គណៈកម្មការថ្នាក់ជាតិ ដូចមានចែងក្នុងមាត្រា ៧៥ នៃច្បាប់នេះ ដោយមានការគាំទ្រពីក្រុមការងារប្រឡងប្រណាំងនៃពន្ធនាគារ ។

**មាត្រា ៧៧.-**

ក្នុងករណីចាំបាច់ ប្រមុខរាជរដ្ឋាភិបាលមានបុព្វសិទ្ធិធ្វើសំណើថ្វាយព្រះមហាក្សត្រសុំលើកលែងទោសឲ្យទណ្ឌិតនៅពេលណាក៏បាន ។

**មាត្រា ៧៨.-**

ពិធីបុណ្យ លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការបន្ធូរបន្ថយទោសនិងការលើកលែងទោស ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

**មាត្រា ៧៩.-**

គ្រប់ទណ្ឌិតដែលត្រូវទទួលទោសពន្ធនាគារមួយ ឬ ច្រើន អាចត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតនោះបានបង្ហាញឲ្យឃើញថា ខ្លួនមានគំនិតមារយាទល្អក្នុងរយៈពេលជាប់ឃុំ និងមានសម្បទាដែលអាចបញ្ចូលខ្លួនទៅក្នុងសង្គមវិញបាន ។

លក្ខខណ្ឌ និងបែបបទនៃការអនុវត្តការដោះលែងដោយមានលក្ខខណ្ឌក្នុងច្បាប់នេះ ត្រូវអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៨០.-**

ប្រធានពន្ធនាគារត្រូវធ្វើការដោះលែងជនជាប់ឃុំ ក្រោយពីបានទទួលលិខិតសម្រេចពីអាជ្ញាធរតុលាការ ។ ជាគោលការណ៍ ទណ្ឌិតដែលទោសរបស់ខ្លួនត្រូវបញ្ចប់នៅថ្ងៃសៅរ៍ ឬថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាកផ្សេងទៀតដែលច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តបានកំណត់ ត្រូវតែដោះលែងឲ្យមានសេរីភាពវិញ នៅមុនថ្ងៃឈប់សម្រាកនោះ ស្របតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៩
## ទោសប្បញ្ញត្តិ

**មាត្រា ៨១.-**

ការធ្វើទារុណកម្ម អំពើឃោរឃៅ និងរាល់ទម្រង់ផ្សេងទៀតនៃការរំលោភបំពានដែលប្រព្រឹត្តទៅលើជនជាប់ឃុំ ត្រូវផ្តន្ទាទោសដោយយោងតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៨២.-**

ជនជាប់ឃុំដែលបានលួចរត់ចេញពីការឃុំខ្លួនតាមគ្រប់មធ្យោបាយ ត្រូវផ្តន្ទាទោសដោយយោងតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៨៣.-**

អំពើរបស់មន្ត្រីពន្ធនាគារដែលទទួលឃុំបុគ្គលណាម្នាក់ ឬពន្យាររយៈពេលឃុំ ឬដោះលែងជនជាប់ឃុំដោយខុសច្បាប់ ត្រូវផ្តន្ទាទោសដោយយោងតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ក្រសួងព្រះបរមរាជវាំង

## ជំពូកទី ១០
## អន្តរប្បញ្ញត្តិ

**មាត្រា ៨៤.-**

លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងពន្ធនាគារដែលបានអនុវត្តកន្លងមក នៅមានសុពលភាពរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមគោលការណ៍នៃច្បាប់នេះ ។

## ជំពូកទី ១១
## អវសានប្បញ្ញត្តិ

**មាត្រា ៨៥.-**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកម/១២១១/០២៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
**ហត្ថលេខា**
**ស ខេង**

លេខ [illegible] ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ២០១១
**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**

**ស៊យ សុខា**

៧

ច្បាប់ចម្លង

**ព្រះរាជក្រឹត្យ**

**ស្តីពី**

នស/រកត/០១២១/ ០៣០

**ការបន្ធូរបន្ថយទោស និងការលើកលែងទោស**

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហាតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពី ការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើក្រមព្រហ្មទណ្ឌ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**ត្រាស់បង្គាប់**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

មាត្រា១.-

ព្រះរាជក្រឹត្យនេះកំណត់អំពីពិធីបុណ្យ លក្ខខណ្ឌ បែបបទ និងនីតិវិធីក្នុងការបន្ធូរបន្ថយទោស និងការលើកលែងទោសចំពោះទណ្ឌិត ក្នុងគោលបំណងដើម្បីធ្វើសមាហរណកម្មទណ្ឌិតនោះឱ្យចូលទៅរួមរស់ក្នុងសង្គមវិញ ឬក្នុងគោលបំណងផ្នែកមនុស្សធម៌។

មាត្រា២.-

ព្រះរាជក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់ទៅលើការបន្ធូរបន្ថយទោស និងការលើកលែងទោសចំពោះទណ្ឌិតទាំងអស់ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារដោយសាលក្រម ឬសាលដីកាស្ថាពររបស់តុលាការនៃព្រះរាជាណាចក្រកម្ពុជា និងចំពោះទណ្ឌិតដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារដោយតុលាការនៃរដ្ឋបរទេស ប៉ុន្តែ ត្រូវបានបញ្ជូនមកឱ្យអនុវត្តទោសនៅព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកតាមការព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋបរទេសនោះ។

ព្រះរាជក្រឹត្យនេះមិនអនុវត្តចំពោះការលើកលែងទោសឱ្យទណ្ឌិត ដូចមានបញ្ញត្តិក្នុងមាត្រា ៧៧ នៃច្បាប់ស្តីពីពន្ធនាគារឡើយ។

## ជំពូកទី២
## ពិធីបុណ្យដែលអាចស្នើសុំការបន្ធូរបន្ថយទោស និងការលើកលែងទោស

មាត្រា៣.-

ពិធីបុណ្យដែលអាចស្នើសុំការបន្ធូរបន្ថយទោស និងការលើកលែងទោសចំពោះទណ្ឌិត ត្រូវកំណត់ ៥ (ប្រាំ) ដង ក្នុងមួយឆ្នាំ ដូចតទៅ៖

១-ទិវាជ័យជម្នះលើរបបប្រល័យពូជសាសន៍។

២-ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ។

៣-ពិធីបុណ្យវិសាខបូជា។

៤-ពិធីបុណ្យឯករាជ្យជាតិ។

៥-ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក។

ការបន្ធូរបន្ថយទោស និងការលើកលែងទោស ក៏អាចធ្វើផងដែរក្នុងពិធីបុណ្យ ឬព្រឹត្តិការណ៍ធំៗរបស់ជាតិ។

ការបន្ធូរបន្ថយទោស និងការលើកលែងទោស ក៏អាចធ្វើសម្រាប់ពិធីបុណ្យនីមួយៗខាងលើដាច់ដោយឡែកពីគ្នា ឬរួមគ្នា។

## ជំពូកទី៣
## លក្ខខណ្ឌនៃការបន្ធូរបន្ថយទោស និងការលើកលែងទោស
### ផ្នែកទី១
### លក្ខខណ្ឌទូទៅនៃការបន្ធូរបន្ថយទោស និងការលើកលែងទោស

ការទទួលបានការបន្ធូរបន្ថយទោស និងការលើកលែងទោស មិនមែនជាសិទ្ធិរបស់ទណ្ឌិតនោះទេ ប៉ុន្តែទណ្ឌិតដែលបានបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងព្រះរាជក្រឹត្យនេះ អាចទទួលបានការអនុគ្រោះ ជាការបន្ធូរបន្ថយទោស ឬជាការលើកលែងទោសបាន។

ការបន្ធូរបន្ថយទោស និងការលើកលែងទោស អាចអនុវត្តបានតែចំពោះទណ្ឌិតដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារដោយសាលក្រម ឬសាលដីកាស្ថាពរប៉ុណ្ណោះ។

មាត្រា៥.-

ការបន្ធូរបន្ថយទោស និងការលើកលែងទោស អាចអនុវត្តចំពោះទណ្ឌិតដែលបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ភ្ញាក់រលឹកខិតខំកែប្រែគំនិតមារយាទឱ្យក្លាយជាពលរដ្ឋសុចរិត ដើម្បីធ្វើសមាហរណកម្មចូលរួមរស់ក្នុងសង្គមវិញ
- គោរពប្រតិបត្តិបានយ៉ាងហ្មត់ចត់ និងត្រឹមត្រូវ តាមបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ និងជាគំរូល្អដល់ទណ្ឌិត និងជនជាប់ឃុំដទៃទៀត
- ចូលរួមអនុវត្តយ៉ាងសកម្ម និងទៀងទាត់នូវកម្មវិធីអប់រំកែប្រែ កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងកម្មវិធីសមាហរណកម្ម
- គោរពប្រតិបត្តិបានយ៉ាងហ្មត់ចត់ និងត្រឹមត្រូវ តាមសេចក្តីណែនាំផ្សេងទៀតរបស់ពន្ធនាគារ។

ប្រធានពន្ធនាគារត្រូវធ្វើការវាយតម្លៃ និងបញ្ជាក់អំពីការបំពេញលក្ខខណ្ឌខាងលើរបស់ទណ្ឌិតដែលត្រូវបញ្ចូលឈ្មោះក្នុងបញ្ជីទណ្ឌិតដែលត្រូវស្នើសុំទៅគណៈកម្មការរាជធានី ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ និងវាយតម្លៃអំពីកម្រិតកែប្រែរបស់ទណ្ឌិត។

មាត្រា៦.-

ការបន្ធូរបន្ថយទោស និងការលើកលែងទោស អាចអនុវត្តផងដែរក្នុងហេតុផលមនុស្សធម៌ចំពោះទណ្ឌិតដែលមានវ័យចាស់ជរា ជាស្ត្រីមានគភ៌ ឬមានជំងឺរ៉ាំរ៉ៃធ្ងន់ធ្ងរ វិបល្លាសស្មារតី ឬពិការភាព ដោយមានលិខិតបញ្ជាក់ពីគ្រូពេទ្យដែលទទួលស្គាល់ដោយក្រសួងមានសមត្ថកិច្ច។

ប្រធានពន្ធនាគារត្រូវធ្វើការបញ្ជាក់អំពីការបំពេញលក្ខខណ្ឌតាមស្ថានភាពនីមួយៗរបស់ទណ្ឌិតដូចមានចែងក្នុងកថាខណ្ឌខាងលើ ដើម្បីរៀបចំបញ្ជីឈ្មោះទណ្ឌិតដែលត្រូវស្នើសុំទៅគណៈកម្មការរាជធានី ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃ។

## ផ្នែកទី២
## លក្ខខណ្ឌដោយឡែកនៃការបន្ធូរបន្ថយទោស

មាត្រា៧.-

ទណ្ឌិតដែលបានបំពេញលក្ខខណ្ឌតាមបញ្ញត្តិនៃមាត្រា៥ នៃព្រះរាជក្រឹត្យនេះ អាចទទួលការបន្ធូរបន្ថយទោសបាន លុះត្រាតែទណ្ឌិតនោះបានទទួលរងទោស ១/៣ (មួយភាគបី) នៃទោសដាក់ពន្ធនាគារដែលតុលាការបានកំណត់។

ចំពោះទោសដាក់ពន្ធនាគារមួយជីវិត ទណ្ឌិតត្រូវទទួលរងទោស ១០ (ដប់) ឆ្នាំជាមុនសិន។

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL

មាត្រា៨.-

រយៈពេលនៃការបន្ធូរបន្ថយទោសត្រូវកំណត់ ដូចខាងក្រោម៖

១-ទោសដាក់ពន្ធនាគារកំណត់ពី ១ (មួយ) ឆ្នាំ ដល់ក្រោម ៥ (ប្រាំ) ឆ្នាំ អាចនឹងបន្ថយរយៈពេលជាប់ពន្ធនាគារចំនួន ៣ (បី) ខែ។

២-ទោសដាក់ពន្ធនាគារកំណត់ពី ៥ (ប្រាំ) ឆ្នាំ ដល់ក្រោម ១០ (ដប់) ឆ្នាំ អាចនឹងបន្ថយរយៈពេលជាប់ពន្ធនាគារចំនួន ៦ (ប្រាំមួយ) ខែ ឬ៣ (បី) ខែ។

៣-ទោសដាក់ពន្ធនាគារកំណត់ពី ១០ (ដប់) ឆ្នាំ ដល់ក្រោម ២០ (ម្ភៃ) ឆ្នាំ អាចនឹងបន្ថយរយៈពេលជាប់ពន្ធនាគារចំនួន ៩ (ប្រាំបួន) ខែ ឬ៦ (ប្រាំមួយ) ខែ ឬ៣ (បី) ខែ។

៤-ទោសដាក់ពន្ធនាគារកំណត់ពី ២០ (ម្ភៃ) ឆ្នាំ ដល់ ៣០(សាមសិប) ឆ្នាំ អាចនឹងបន្ថយរយៈពេលជាប់ពន្ធនាគារចំនួន ១២ (ដប់ពីរ) ខែ ឬ៩ (ប្រាំបួន) ខែ ឬ៦ (ប្រាំមួយ) ខែ ឬ៣ (បី) ខែ។

៥-ទោសដាក់ពន្ធនាគារមួយជីវិត អាចនឹងបន្ថយទោសលើកទី១ មកនៅត្រឹម ៣០ (សាមសិប) ឆ្នាំ។

មាត្រា៩.-

ទណ្ឌិតអាចទទួលការបន្ធូរបន្ថយទោសបានតែម្តងគត់ ក្នុងរយៈពេល ១២ (ដប់ពីរ) ខែ។

ទណ្ឌិតអាចទទួលការបន្ធូរបន្ថយទោសច្រើនដងបាន លុះត្រាតែទណ្ឌិតនោះបានទទួលរងទោសពាក់កណ្តាលនៃទោសដាក់ពន្ធនាគារដែលតុលាការបានកំណត់ ប៉ុន្តែត្រូវគោរពតាមលក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ។

ចំពោះទណ្ឌិតដែលត្រូវបានកំណត់ទោសដាក់ពន្ធនាគារមួយជីវិត ក្រោយពីបានបន្ថយមកនៅត្រឹម ៣០(សាមសិប)ឆ្នាំ អាចនឹងបានទទួលការបន្ធូរបន្ថយទោសច្រើនដងទៀតបាន។ ប៉ុន្តែ ទោះជាទណ្ឌិតនោះបានទទួលការបន្ធូរបន្ថយទោសច្រើនដងក៏ដោយ ក៏រយៈពេលនៃការទទួលរងទោសទាំងអស់ត្រូវឱ្យបានយ៉ាងតិច ២០(ម្ភៃ)ឆ្នាំ។

## ផ្នែកទី៣
## លក្ខខណ្ឌដោយឡែកនៃការលើកលែងទោស

មាត្រា១០.-

ទណ្ឌិតដែលបានបំពេញលក្ខខណ្ឌតាមបញ្ញត្តិនៃមាត្រា៥ នៃព្រះរាជក្រឹត្យនេះ អាចទទួលការលើកលែងទោស ក្នុងករណីទណ្ឌិតបានទទួលរងទោសដាក់ពន្ធនាគារ៖

១-ចំនួនពីរភាគបីនៃទោស។

២-ទណ្ឌិតដែលទទួលទោសដាក់ពន្ធនាគារអស់មួយជីវិត អាចទទួលការលើកលែងទោស ប្រសិនបើទណ្ឌិតនោះបានអនុវត្តទោសយ៉ាងតិច ៣០(សាមសិប)ឆ្នាំ ឬ២០(ម្ភៃ)ឆ្នាំ ក្នុងករណីដែលមានការបន្ធូរបន្ថយទោស។

## ជំពូកទី៤
## បែបបទ និងនីតិវិធីនៃការបន្ធូរបន្ថយទោស និងការលើកលែងទោស

មាត្រា១១.-

ប្រធានពន្ធនាគារត្រូវរៀបចំបញ្ជីឈ្មោះទណ្ឌិតដែលមានលក្ខណសម្បត្តិអាចស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស រួមនិងសំណុំឯកសារពាក់ព័ន្ធបញ្ជូនមកគណៈកម្មការរាជធានី ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃ។

គណៈកម្មការរាជធានី ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃ ត្រូវពិនិត្យ និងវាយតម្លៃអំពីលទ្ធភាពនៃលក្ខណសម្បត្តិរបស់ទណ្ឌិតម្នាក់ៗដែលបំពេញគ្រប់លក្ខខណ្ឌអាចស្នើសុំបន្ធូរបន្ថយទោស និងលើកលែង

ទោស និងត្រូវរៀបចំបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស រួមនិងសំណុំឯកសារពាក់ព័ន្ធបញ្ជូនទៅគណៈកម្មការថ្នាក់ជាតិ ពិនិត្យ និងវាយតម្លៃបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស យ៉ាងយឺតបំផុត ៣០ (សាមសិប)ថ្ងៃមុនថ្ងៃកំណត់ដូចមានចែងក្នុងមាត្រា ៣ នៃព្រះរាជក្រឹត្យនេះ។

គំរូបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស រួមនិងសំណុំឯកសារពាក់ព័ន្ធ ដូចមានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើ ត្រូវកំណត់ដោយគណៈកម្មការថ្នាក់ជាតិ។

មាត្រា១២.-

ទណ្ឌិតដែលយល់ឃើញថា ខ្លួនបានបំពេញលក្ខខណ្ឌក្នុងការស្នើសុំបន្ធូរបន្ថយទោស ឬលើកលែងទោស ប៉ុន្តែ មិនត្រូវបានប្រធានពន្ធនាគារធ្វើការស្នើសុំឱ្យខ្លួន សាមីខ្លួន ឬអ្នកតំណាងស្របច្បាប់មានសិទ្ធិប្ដឹងតវ៉ាទៅគណៈកម្មការថ្នាក់ជាតិ ដោយមានការគាំទ្រពីក្រុមការងារប្រឡងប្រណាំងនៃពន្ធនាគារ។ ពាក្យបណ្ដឹងតវ៉ានេះ ត្រូវដាក់នៅគណៈកម្មការថ្នាក់ជាតិ ដោយផ្ទាល់ ឬតាមរយៈប្រធានពន្ធនាគារ។ បន្ទាប់ពីបានទទួលពាក្យបណ្ដឹងតវ៉ានេះ ប្រធានពន្ធនាគារត្រូវបញ្ជូនពាក្យប្ដឹងនេះ មកគណៈកម្មការថ្នាក់ជាតិ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ពាក់ព័ន្ធនឹងការអនុវត្តទោសរបស់ទណ្ឌិតនោះ។

មាត្រា១៣.-

គណៈកម្មការថ្នាក់ជាតិ ត្រូវប្រជុំពិនិត្យ និងវាយតម្លៃលើបញ្ជីឈ្មោះទណ្ឌិតដែលត្រូវស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស និងរៀបចំបែបបទជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ដើម្បីដាក់សំណើថ្វាយព្រះមហាក្សត្រសុំបន្ធូរបន្ថយទោស និងលើកលែងទោសឱ្យទណ្ឌិត យ៉ាងយឺតបំផុត ១០ (ដប់)ថ្ងៃមុនថ្ងៃកំណត់ដូចមានចែងក្នុងមាត្រា៣ នៃព្រះរាជក្រឹត្យនេះ។

## ជំពូកទី៥
## ការអនុវត្តព្រះរាជក្រឹត្យបន្ធូរបន្ថយទោស និងលើកលែងទោស

មាត្រា១៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ត្រូវរៀបចំសំណៅចែកផ្សាយជូនក្រសួងយុត្តិធម៌ ដើម្បីចាត់ចែងអនុវត្ត ក្រោយពីបានទទួលព្រះរាជក្រឹត្យបន្ធូរបន្ថយទោស និងលើកលែងទោស។

មាត្រា១៥.-

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចាត់បញ្ជូនព្រះរាជក្រឹត្យបន្ធូរបន្ថយទោស និងលើកលែងទោស ទៅព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី ខេត្តដែលមានសមត្ថកិច្ច ដើម្បីអនុវត្ត។

មាត្រា១៦.-

ចំពោះទណ្ឌិតដែលត្រូវបានលើកលែងទោសដោយព្រះរាជក្រឹត្យ នឹងត្រូវដោះលែងឱ្យមានសេរីភាព ដោយប្រធានពន្ធនាគារ បន្ទាប់ពីទទួលបានដីកាបង្គាប់ឱ្យដោះលែងទណ្ឌិតរបស់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី ខេត្តដែលមានសមត្ថកិច្ច។

ទណ្ឌិតដែលត្រូវបានបន្ធូរបន្ថយទោសដោយព្រះរាជក្រឹត្យ លើកលែងឱ្យទណ្ឌិតនោះរួចផុតពីការអនុវត្តទោសសម្រាប់រយៈពេលដែលត្រូវបានបន្ធូរបន្ថយ។ ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង

រាជធានី ខេត្តដែលមានសមត្ថកិច្ច និងប្រធានពន្ធនាគារ ត្រូវធ្វើការប្រកាសផ្សព្វផ្សាយព្រះរាជក្រឹត្យបន្ធូរបន្ថយទោស ដល់ទណ្ឌិតដែលត្រូវបានបន្ធូរបន្ថយទោស។

**មាត្រា១៧.-**

ការបន្ធូរបន្ថយទោស និងការលើកលែងទោស មិនមែនជាឧបសគ្គដល់សិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលសំណងជួសជុលការខូចខាតទេ លើកលែងតែមានបទប្បញ្ញត្តិផ្ទុយនឹងព្រះរាជក្រឹត្យដែលពាក់ព័ន្ធនឹងការបន្ធូរបន្ថយទោស និងលើកលែងទោសនោះ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៨.-**

ក្រឹត្យលេខ២៨ក្រ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៨៨ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៩.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃ អង្គារ ១៤រោច ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១២ ខែ មករា ឆ្នាំ២០២១

**នរោត្តម សីហមុនី**

ពរក.០១២១.០៣២

**បានប្រមាប់ព្រះរាជលញ្ឆករហើយ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**